សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ មិថុនា ឆ្នាំ 2014

# លីអាហូណា



**ចម្លើយចំពោះសំណួរទាំងបួន ស្ដីពីបព្វជិតភាព ទំព័រ 18**

ការជ្រើសរើសការកម្សាន្តដែលសក្តិសមនឹងពេលវេលារបស់អ្នក ទំព័រ 14

ការស្ថាបនាទីក្រុងស៊ីយ៉ូននៅកន្លែងដែលអ្នករស់នៅ ទំព័រ 30



*« ឪពុកមានសិទ្ធិអំណាច និង ទំនួលខុសត្រូវដើម្បីបង្រៀនកូនចៅខ្លួន និង ប្រសិទ្ធពរ ហើយផ្ដល់ឲ្យពួកគេនូវពិធីបរិសុទ្ធនៃដំណឹងល្អ និង រាល់ការការពារនៃបព្វជិតភាពដ៏ចាំបាច់ផ្សេងទៀត ។ គាត់ត្រូវបង្ហាញសេចក្ដីស្រឡាញ់ និង ភក្ដីភាព ព្រមទាំងគោរពដល់ម្ដាយ ដើម្បីឲ្យកូនចៅខ្លួនអាចមើលឃើញពីសេចក្ដីស្រឡាញ់នោះ » ។*

ប្រធាន បិយដ៍ យេ ផាកកឺ ប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « These Things I Know » Liahona, ខែឧសភា ឆ្នាំ 2013 ទំព័រ 7 ។

# លីអាហូណា ខែ មិថុនា ឆ្នាំ 2014



## សារលិខិត


4 **សារលិខិតគណៈប្រធានទីមួយ ៖ ការពន្លឿនកិច្ចការ**
ដោយ ប្រធាន ថូម៉ាស អេស ម៉នសុន

7 **សារលិខិតសួរសុខទុក្ខ ៖ បេសកកម្មដ៏ទេវភាពនៃព្រះយេស៊ូវគ្រីស្ទ ៖ ការបម្រើ**


## អត្ថបទពិសេស។


14 **ប្រព័ន្ធផ្សព្វផ្សាយដែលមានគុណធម៌**
ដោយ ខាធើរីន ណេលសិន
*ទំនាក់ទំនងរបស់យើងជាមួយនឹងការកម្សាន្ត អាចជាការជ្រើសរើសដ៏មានប្រយោជន៍ ហើយពិសិដ្ឋ ។*

17 **ការធ្វើជាឪពុកម្ដាយ បិទគ្រឿងអេឡិចត្រូនិច**
ដោយ ជេន ភិនប្ប៉ូ
*នៅពេលយើងធ្វើតាមព្រះអង្គសង្គ្រោះ ហើយមើលថែកូនចៅរបស់យើង នោះយើងនឹងបំបិទខ្លួន ដកខ្លួន ហើយផ្ដាច់ខ្លួនចេញពីការរំខានទាំងឡាយ ។*

18 **អំណាចបព្វជិតភាព—មានសម្រាប់មនុស្សគ្រប់គ្នា**
ដោយ លីនដា ខេ បើតុន
*បព្វជិតភាពគឺជាការទុកចិត្តដ៏ពិសិដ្ឋមួយដែលត្រូវបានប្រទានឲ្យដើម្បីប្រទានពរដល់បុរស ស្ត្រី និងកុមារទាំងឡាយ ដើម្បីយើងអាចរស់នៅជាក្រុមគ្រួសារដ៏នៅអស់កល្បជានិច្ចជាមួយនឹងព្រះ ។*

24 **អ្នកត្រួសត្រាយផ្លូវនៅគ្រប់ដែនដី: ពួកបរិសុទ្ធថ្ងៃចុងក្រោយនៅប្រទេសអ៊ីតាលី ៖ មរតកនៃសេចក្ដីជំនឿ**
ដោយ លៀ ម៉ាកក្លេណាហាន
*ការសង់ព្រះវិហារបរិសុទ្ធមួយនៅប្រទេសអ៊ីតាលីគឺជាលទ្ធផលនៃប្រវត្តិសាស្ត្រមួយដ៏យូរអង្វែងនៃពួកបរិសុទ្ធដ៏ស្មោះត្រង់ ។*

30 **ការអំពាវនាវឲ្យប្រែក្លាយដូចជាព្រះគ្រីស្ទ**
ដោយ អែលឌើរ ជេហ្វ្រី អ័រ ហូឡិន
*ឥឡូវនេះជាពេលសម្រាប់យើងដើម្បីស្ថាបនាទីក្រុងស៊ីយ៉ូននៅទីកន្លែងដែលយើងរស់នៅ—ថ្វីបើយើងរស់នៅក្នុងទីក្រុងបាប៊ីឡូនក្ដី ។*


## ផ្នែកទាំងឡាយ


8 **យើងនិយាយអំពីព្រះគ្រីស្ទ: ឆ្ងល់យ៉ាងអស្ចារ្យនូវក្ដីស្នេហ៍ព្រះគ្រីស្ទឲ្យខ្ញុំ**
ដោយ សេសា លីម៉ា អេស្តាឡេនតេ

10 **គេហដ្ឋាន និង ក្រុមគ្រួសាររបស់យើង: ឧបសគ្គទាំងឡាយគឺជាពរជ័យ**
ដោយ រ៉ាជែល ហារីសិន

12 **ពួកព្យាការីគម្ពីរសញ្ញាចាស់: សាំយ៉ូអែល**

13 **ការបង្រៀន *ដើម្បីកម្លាំងនៃយុវជន:* ដង្វាយមួយភាគក្នុងដប់ និង ដង្វាយផ្សេង។**

38 **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

80 **លុះត្រាយើងជួបទៀត: អំណាចនៃពាក្យនៅពេលដែល**
ដោយ ខេលី លូីស អ៊ុយរ៉ារី
*ក្នុងរយៈពេលតែ 24 ម៉ោង ស្វាមីរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺជាទម្ងន់ ។ មានពាក្យមួយម៉ាត់ដែលបានជួយយើងឲ្យស៊ូទ្រាំ ។*


**នៅលើគម្រប**
ខាងមុខ ៖ រចនារូបថតដោយ ជេរី ហ្គាមស៍ ។ ខាងក្នុងគម្របខាងមុខ ៖ រចនារូបថតដោយ ប្រ៊ែដលី ស្លាដ ។

## យុវមជ្ឈិមវ័យ





42 **ដើរតាមផ្លូវនៃសុភមង្គល**
ដោយ ប៊ីស្សព ហ្គេរ៉ាល ក្ញសសៃ
*គោលការណ៍ទាំងបីនេះអាចជួយអ្នកឲ្យប្រែក្លាយជាអ្នករៀបចំ សម្រាប់សុភមង្គលរបស់អ្នក ។*

47 **ការចែកចាយដំណឹងល្អលើបណ្ដាញ**
ដោយ ម៉ារីយ៉ា ម៉ាហ្សុនរី អ៊ីព្រ្ហាហ្សិល អាឌួ អង់ដាកា
*ខ្ញុំតែងតែមានការអៀនខ្មាស់ពីជំនឿរបស់ខ្ញុំ ប៉ុន្តែវិធីសាស្ត្រថ្មីមួយបានជួយខ្ញុំឲ្យចេះចែកចាយ ។*




*ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ តើអ្វីនៅក្នុងសំណាញ់ ?*

## យុវវ័យ


48 **សិទ្ធិជ្រើសរើស និង ចម្លើយ ៖ ការស្គាល់វិវរណៈ**
ដោយ អែលឌើរ រីឆាដ ជី ស្កត
*ដើម្បីមានការរីកចម្រើន យើងត្រូវរៀនទុកចិត្តលើសមត្ថភាពរបស់យើងក្នុងការធ្វើការជ្រើសរើសដ៏ត្រឹមត្រូវ ។*

52 **ចុះបើខ្ញុំគ្មានអារម្មណ៍ខ្ជួលខ្វាញ់នៅក្នុងទ្រូងវិញ ?**
ដោយ រ៉ាជែល នៀលសិន
*ខ្ញុំពុំធ្លាប់មានអារម្មណ៍ខ្ជួលខ្វាញ់នៅក្នុងទ្រូងឡើយ ។ តើនោះមានន័យថា ព្រះវិញ្ញាណបរិសុទ្ធមិនបានមានបន្ទូលមកកាន់ខ្ញុំទេឬអី ?*

56 **សូមធ្វើតាមការបំផុសគំនិតតូចៗ**
*អ្នកអាចនឹងមិនដឹងថា ការបំផុសគំនិតតូចៗនឹងមានឥទ្ធិពលធំបែបណានោះទេ ។*

57 **ការប្រសិទ្ធពរមួយសម្រាប់ប្អូនប្រុសរបស់ខ្ញុំ**
ដោយ ជេស ចូនស៍
*ប្អូនប្រុសរបស់ខ្ញុំបានដួលម៉ូតូ ហើយត្រូវសម្រាកនៅមន្ទីរពេទ្យ ។ ខ្ញុំមានការព្រួយបារម្ភជាខ្លាំង ។*

58 **សំណួរ និង ចម្លើយទាំងឡាយ**
*តើខ្ញុំគួរតែគិតអំពីអ្វីខ្លះ អំឡុងពេលសាក្រាម៉ង់ ?*

60 **ដើម្បីកម្លាំងនៃយុវជន: ដង្វាយមួយភាគក្នុងដប់ផ្ដល់កម្លាំងនៅក្នុងចិត្ត**
ដោយ អែលឌើរ អាន់ចូនី ឌី ភើគីន
*ការបង់ដង្វាយមួយភាគក្នុងដប់របស់អ្នកនឹងជួយអ្នកឲ្យដឹងថា ព្រះអម្ចាស់រក្សារាល់សេចក្ដីសន្យារបស់ទ្រង់ ។*

62 **ការស្វែងរកផ្លូវរបស់ខ្ញុំត្រឡប់ទៅសាសនាចក្រវិញ**
ដោយ ឌូក ប៊ីយ៉ាក
*ខ្ញុំបានគិតថា ខ្ញុំមិនត្រូវការសាសនាចក្រទេ រហូតដល់មានការធ្វើដំណើរ និង ដង្វាយមួយភាគក្នុងដប់បានបង្រៀនខ្ញុំឲ្យគិតផ្សេងពីនេះវិញ ។*

63 **ប័ណ្ណប្រកាស ៖ ភាពរឹងមាំ**





## កុមារ





64 **ការប្រសិទ្ធពរមួយសម្រាប់អ្នកម្ដាយ**
ដោយ ស៊ូសាន បារ៉េត
*ខ្នងរបស់ម៉ាក់រូប៊ិនឈឺយ៉ាងខ្លាំង ។ តើរូប៊ិនអាចជួយគាត់បែបណាទៅ ?*

66 **សាក្សីពិសេស ៖ តើខ្ញុំអាចក្លាយដូចជាអ្នកផ្សព្វផ្សាយសាសនាម្នាក់នៅពេលនេះបានដោយរបៀបណា ?**
ដោយ អែលឌើរ នែល អិល អាន់ឌើរសិន

67 **កូនចៀមដែលគួរឲ្យគោរព**
ដោយ អែលឌើរ ស្កត់ ឌី វីតធីង
*ខ្ញុំចង់មានគារវភាព ដើម្បីខ្ញុំអាចទទួលបានស្លាកមួយ ប៉ុន្តែមានអ្វីមួយដែលប្រសើរជាងនេះបានកើតឡើង ។*

68 **ការបង្កើតមិត្តភាពនៅជុំវិញពិភពលោក: ខ្ញុំឈ្មោះ ឡូរេដាណា មកពីប្រទេសអ៊ីតាលី**
ដោយ អេមី ជេន ឡឺវិត

70 **សកម្មភាពរូបភាពពន្យល់ ៖ ម៉ាស៊ីម៉ូ មកពីប្រទេស អ៊ីតាលី**

71 **ការធ្វើតាមព្រះយេស៊ូវ ៖ ការចេះជួយគ្នា**

72 **ការប្រគុំតន្ត្រីនៅប្រទេស អ៊ូហ្គង់ដា**
ដោយ ដេវីឌ ឌីកសុន
*ការដឹកនាំតន្ត្រីនៅចំពោះមុខមនុស្សគ្រប់គ្នាអាចជារឿងមួយគួរឲ្យភ័យខ្លាច ប៉ុន្តែសម្រាប់ចច វិញគឺមិនដូច្នោះឡើយ !*

74 **ការនាំថ្នាក់កុមារមកក្នុងលំនៅដ្ឋាន: ពិធីបរិសុទ្ធនៃបព្វជិតភាព និង កិច្ចការព្រះវិហារបរិសុទ្ធប្រសិទ្ធិពរជ័យដល់គ្រួសារខ្ញុំ**
ដោយ ជែននីហ្វើ ម៉ាឌី

76 **ទំព័ររបស់យើង**

78 **សម្រាប់កុមារតូចៗ**

81 **រូបគំនូរព្យាការី: ហ្គរដុន ប៊ី ហ៊ិងគ្លី**

**ច្បាប់សម្រាប់ខែ មិថុនា ឆ្នាំ 2014 វ៉ុល 13 លេខ 3**
**លីអាហូណា 10986 258**
ទស្សនាវដ្ដីអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ
**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេហ្វ. អុជដូហ្វ
**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** បយដ៍ ខេ. ផាកកឺ, អិល. ថម ភែរី, រ័សុល អិម. ណិលសុន, ដាល្លិន អេក. អូក, អិម. រ័សុល បាឡឺដ, រីឆាដ ជី. ស្កត, រ៉ូប៊ឺត ឌី. ហែល, ជែហ្វ្រី អ័រ. ហូឡិន, ដេវីឌ អេ. បែដណា, ឃ្វីនថិន អិល. ឃុក, ឌី ថត. គ្រីស្តូហ្វឺសិន, នែល អិល. អាន់ឌើរសិន
**អ្នកកែសម្រួល ៖** ក្រេក អេ. ខារដុន
**អ្នកប្រឹក្សា ៖** សមើរីន ប៊ី អាល់ណុល, រូនេ អិម. បូរិន, ប្រ៊ែដលី ឌី. ហ្វូស្ទើរ, ចស អិល អាឡុនសូ, គ្រីស្តូហ្វែល ហ្គូលឌិន ជុញ្ញ័រ
**នាយកគ្រប់គ្រង ៖** ដេវីឌ ធី. វ៉ នើរ
**នាយកគាំទ្រគ្រួសារ និង សមាជិក ៖** វីនសេនត៍ អេ. វ៉ាញ
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ. ឡយបិច
**អ្នកគ្រប់គ្រងពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណុន
**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រ. វ៉ាល ចនសុន
**ជំនួយការអ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** ប៉អិន ខារ
**និពន្ធ និងកែសម្រួល ៖** ប្រ៊ីតថានី ប៊ីតធី, ដេវីដ ឌិកសុន, ដេវីដ អេ. អេដវ៉ដ, ម៉ាថាយ ឌី. ហ្វលិតតុន, មិនឌី ប៉ ហ្វ្រៀដមែន, ហែរី អេច. ហ្គាហ្វ, ឡារិននេ ផតធើរ ហ្គូន, ជេនីហ្វើរ ម្រ៉ុស ជូនស៍, ម៉ៃឃើល អ័រ. ម៉ូរីស, សាលី ចនសុន អូឌេឃឹក, ឃ្វីស្វេ ជេ ភីធី, ជេន ភីនបូរ៉ាហ្វ, រីឆាដ អិម. រ៉មនី, ប៉ុល វ៉ែនដិនបើជ, ម៉ារីស្សា វីឌីសុន
**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ. ស្កត នូដសិន
**នាយកផ្នែកសិល្បៈ ៖** ចាត អ័រ. ភីធើរសុន
**រចនាម៉ូត ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី. អាន់ត្រូស, មែនឌី អឺម. បែនលី, ស៊ី. ឃីមបឺល បុត, ថូម៉ាស ឆាល, ណាត ហ៊្គីនេស, ខូលីន ហ៊ីងគ្លី, អេរិក ភី. ចនសិន, ស៊ូសាន ឡហ្វ្រីន, ស្កត អិម. ម៉ូយ, ម៉ាក ដបុលយូ. រ៉ូប៊ីសុន, ប្រាត ធៀរ, ឃេ. នីកូល វ៉កឃិនហ្វូស
**អ្នកសម្របសម្រួលកម្មសិទ្ធបញ្ញា ៖** ខូលែត នែបេឃើ អាន
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ខេវិន ស៊ី. បើងស៍, ខននី ប៊ូស្រូប ប្រ៊ីជ, ជូលី ប៊ើដេត, ប្រាយអេន ដបុលយូ. ជីគី, ដេនីស គើបៃ, ជិន្នីស ខឹប៊ី, ជីន្នី ហ៊្គីននី ជេ. នីលសុន, ហ្គែលី ថេត រ៉ាហ្វៃធី
**អ្នកពិនិត្យមុនការបោះពុម្ព ៖** ជេហ្វ អិល. ម៉ាទីន
**នាយកផ្នែកបោះពុម្ព ៖** ក្រេហ្គ ខេ. សែតវីត
**នាយកផ្នែកចែកចាយ ៖** ស្ទេហ្វិន អ័រ គ្រីស្ទិនសិន
ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬ សាខារបស់អ្នក ។
**សូមផ្ញើអត្ថបទ និងសំណួរទាំងឡាយ** តាមអ៊ិនធើរណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ *Liahona,* Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។
*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន ( ងាយស្រួល ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូអានី, ហ៊្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងហ្គារី, អាយឡេនឌិក, ឥណ្ឌូនេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី,នរវេ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញញឹកញាប់ប៉ុនណា គឺប្រែប្រួលទៅតាមភាសា ) ។
© 2014 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។
អត្ថបទ និង សម្ភារដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចថតចម្លងយកទៅប្រើប្រាស់ជាបន្ទាប់បន្សំ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មតាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារដែលមើលឃើញ មិនអាចថតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។
**For Readers in the United States and Canada:**
June 2014 Vol. 13 No. 3. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)
POSTMASTER: Send all UAA to CFS (see DMM 707.4.12.5). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

# គំនិតទាំងឡាយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពនានាដែលអាចយកទៅប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។ នៅខាងក្រោមនេះ មាននូវគំនិតចំនួនពីរ ។*



**« អំណាចបព្វជិតភាព—មានសម្រាប់មនុស្សគ្រប់គ្នា »** ទំព័រ 18 ៖ ពីមុនរាត្រីជួបជុំក្រុមគ្រួសារ សូមអានសំណួរទាំងបួនដែលស៊ិស្ទើរ ប៊ើតុន បានលើកឡើងនៅក្នុងអត្ថបទនេះ ។ សូមយកចង្កៀងអគ្គីសនីតូចមួយសម្រាប់ការធ្វើរាត្រីជួបជុំក្រុមគ្រួសារ (សូមដកខ្សែភ្លើងចេញ) ។ សូមឲ្យសមាជិកគ្រួសារផ្សេងទៀតសាកល្បងបើកវា ។ សូមប្រដូចថាមពលអគ្គីសនីដែលត្រូវការដើម្បីធ្វើចង្កៀងនោះឲ្យភ្លឺទៅនឹងអំណាចបព្វជិតភាព ។ សូមដោតខ្សែភ្លើងចូល ហើយបើកចង្កៀងនោះ រួចពិភាក្សាពីរបៀបដែលយើងទាំងអស់គ្នាអាចទទួលបានអត្ថប្រយោជន៍ពីពន្លឺនៃចង្កៀងនោះ ឬ អំណាចនៃបព្វជិតភាព ។ សូមឲ្យសមាជិកគ្រួសារពិចារណាពីវិធីនានាដែលពួកគេ ធ្លាប់ទទួលបានពរជ័យតាមរយៈបព្វជិតភាព ។ អ្នកអាចចាប់ផ្ដើមដោយការទន្ទេញនូវបទគម្ពីរនៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា 84 ដែលស៊ិស្ទើរ ប៊ើតុន សុំឲ្យយើងទន្ទេញ ។

**« គំនិតដ៏ប្រពៃរបស់រីល »** ទំព័រ 78 ៖ អ្នកអាចចាប់ផ្ដើមដោយការច្រៀងបទ « I Love to See the Temple » (Children's Songbook ទំព័រ 95) ឬ ចម្រៀងផ្សេង ទៀតស្ដីពីព្រះវិហារបរិសុទ្ធ ។ សូមអានអត្ថបទនេះជាគ្រួសារ ហើយពិភាក្សាស្ដីពីសារៈសំខាន់នៃព្រះវិហារបរិសុទ្ធ ។ សូមឲ្យសមាជិកគ្រួសារម្នាក់ៗគូររូបព្រះវិហារបរិសុទ្ធ ប្រហែលជាព្រះវិហារបរិសុទ្ធមួយដែលនៅជិតជាងគេបំផុតនឹងទីកន្លែងដែលអ្នករស់នៅ ។ សូមគិតគូរអំពីការដាក់ព្យួររូបគំនូរនោះ និងរូបភាពនៅទំព័រ 79 ក្នុងគេហដ្ឋានរបស់អ្នកត្រង់កន្លែងដែលអាចមើលឃើញរាល់ថ្ងៃ ។ សូមនិយាយពីការមើលឃើញរូបភាពនៃព្រះវិហារបរិសុទ្ធអាចជួយរំឭកយើងឲ្យធ្វើការសម្រេចចិត្ត ដែលនឹងរក្សាខ្លួនយើងឲ្យមានភាពសក្តិសមដើម្បីចូលទៅក្នុងព្រះវិហារបរិសុទ្ធ ។

## ជាភាសារបស់អ្នក

*លីអាហូណា* និងឯកសារផ្សេងទៀតរបស់សាសនាចក្រមានជាច្រើនភាសានៅ **languages.lds.org** ។

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**
*លេខទាំងឡាយ គឺតំណាងឲ្យទំព័រទីមួយនៃអត្ថបទ។*

*ការគោរពប្រតិបត្តិ* 18, 56
*ការតែងតាំង* 14
*ការថយ់បារម្ភ* 39
*ការបម្រើ* 71, 72
*ការផ្លាស់ប្រែចិត្តជឿ* 24, 62
*ការហៅ* 72
*ការអធិស្ឋាន* 48
*កិច្ចការផ្សព្វផ្សាយសាសនា* 24, 30, 47, 66
*គារវភាព* 67
*គ្រួសារ* 10, 17
*ដង្វាយតមអាហារ* 13, 60
*ដង្វាយធួន* 8, 58
*ដង្វាយមួយភាគក្នុងដប់* 13, 60, 62
*តន្ត្រី* 72
*តម្លៃរបស់បុគ្គលម្នាក់ៗ* 42
*ទីក្រុងស៊ីយ៉ូន* 30
*បទបញ្ញត្តិទាំងឡាយ* 30
*បព្វជិតភាព* 18, 64, 74
*ប្រព័ន្ធផ្សព្វផ្សាយ* 14, 17, 47
*ពង្សប្រវត្តិ* 4, 6, 38
*ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ* 40
*ព្យាការីទាំងឡាយ* 12, 41, 81
*ព្រះគម្ពីរសញ្ញាចាស់* 12
*ព្រះយេស៊ូវគ្រីស្ទ* 7, 8
*ព្រះវិញ្ញាណបរិសុទ្ធ* 48, 52, 56, 67
*ព្រះវិហារបរិសុទ្ធ* 10, 24, 74, 78
*វិវរណៈ* 18, 41, 48, 52, 56
*សាក្រាម៉ង់* 8, 58
*សិទ្ធិជ្រើសរើស* 14, 48
*សុភមង្គល* 42
*សេចក្ដីជំនឿ* 80
*សេចក្ដីសង្ឃឹម* 80
*ហ៊ិងគ្លី, ហ្គរដុន ប៊ី.* 81
*អាពាហ៍ពិពាហ៍* 10
*អ្នកត្រួសត្រាយ* 24



ដោយ ប្រធាន
ថូម៉ាស អេស. ម៉នសុន

# ការពន្លឿនកិច្ចការ

តើអ្នកដឹងទេថា សាសនាចក្រដែលបានស្ដារឡើងវិញនេះមានអាយុកាល 98 ឆ្នាំ ពីមុនវាមានស្តេកចំនួន 100 នោះ ? ប៉ុន្តែតិចជាង 30 ឆ្នាំក្រោយមក សាសនាចក្រនេះត្រូវបានរៀបចំស្តេកចំនួន 100 របស់ខ្លួនជាលើកទីពីរ ។ ហើយក្នុងរយៈពេលតែប្រាំបីឆ្នាំក្រោយមកទៀត សាសនាចក្រនេះមានស្តេកច្រើនជាង 300 កន្លែង ។ សព្វថ្ងៃនេះ យើងមានស្តេកដ៏រឹងមាំចំនួន 3,000 ស្តេក ។

ហេតុអ្វីបានជាការរីកចម្រើននេះកើតឡើងយ៉ាងឆាប់រហ័ស ? តើវាដោយសារយើងត្រូវបានគេស្គាល់ច្រើនមែនទេ ? តើវាដោយសារយើងមានសាលាប្រជុំដ៏ស្រស់ស្អាតមែនទេ ?

រឿងទាំងនេះជាកត្តាដ៏សំខាន់ ប៉ុន្តែហេតុផលដែលសាសនាចក្រនេះកំពុងរីកចម្រើននាសព្វថ្ងៃនេះ គឺដោយសារព្រះអម្ចាស់បានកំណត់វា ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ទ្រង់បានមានបន្ទូលថា « មើលចុះ យើងនឹងពន្លឿនកិច្ចការរបស់យើងឲ្យឆាប់នៅពេលកំណត់ » ។[1]

ក្នុងនាមជាកូនចៅខាងវិញ្ញាណរបស់ព្រះវរបិតាសួគ៌យើង យើងត្រូវបានបញ្ជូនមកកាន់ផែនដីនៅពេលនេះ ដើម្បីឲ្យយើងអាចចូលរួមនៅក្នុងការពន្លឿនកិច្ចការដ៏អស្ចារ្យនេះ ។

បើតាមខ្ញុំដឹង គឺថាព្រះអម្ចាស់ពុំធ្លាប់បង្ហាញថា កិច្ចការរបស់ទ្រង់ត្រូវបានបង្ខាំងចំពោះជីវិតរមែងស្លាប់ឡើយ ។ ផ្ទុយទៅវិញ កិច្ចការរបស់ទ្រង់មានដល់ភាពអស់កល្បជានិច្ច ។ ខ្ញុំជឿថា ទ្រង់កំពុងពន្លឿនកិច្ចការរបស់ទ្រង់នៅក្នុងពិភពវិញ្ញាណ ។ ខ្ញុំក៏ជឿផងដែរថា ព្រះអម្ចាស់កំពុងរៀបចំវិញ្ញាណជាច្រើនឲ្យទទួលយកដំណឹងល្អតាមរយៈពួកអ្នកបម្រើរបស់ទ្រង់នៅទីនោះ ។ កិច្ចការរបស់យើងគឺត្រូវស្វែងរកដូនតារបស់យើងដែលបានចែកឋានទៅ រួចហើយទៅព្រះវិហារបរិសុទ្ធ ហើយធ្វើពិធីការពិសិដ្ឋដែលនាំឲ្យអ្នកដែលនៅភពម្ខាងទៀតមានឱកាសដូចជាយើងដែរ ។

ប្រធាន ព្រិកហាំ យ៉ង់ ( ឆ្នាំ 1801–77 ) បានថ្លែងថា ពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏ល្អគ្រប់រូបនៅក្នុងពិភពវិញ្ញាណគឺមានភាពមមាញឹក ។ « តើពួកគាត់កំពុងធ្វើអ្វីនៅទីនោះ ? ពួកគាត់កំពុងប្រកាស គឺប្រកាសគ្រប់ពេលវេលា ហើយកំពុងរៀបចំផ្លូវសម្រាប់យើងឲ្យពន្លឿនកិច្ចការរបស់យើង នៅក្នុងការសង់ព្រះវិហារបរិសុទ្ធនៅទីនេះ និង នៅទីកន្លែងផ្សេងទៀត » ។[2]

ឥឡូវនេះ កិច្ចការពង្សប្រវត្តិមិនងាយស្រួលនោះទេ ។ ចំពោះអ្នកដែលមកពីស្កានឌីណាវៀ ខ្ញុំសូមចែកចាយពីការលំបាករបស់អ្នក ។ ឧទាហរណ៍ តាមខ្សែស្រឡាយស៊ុយអែដរបស់ខ្ញុំ ជីតារបស់ខ្ញុំមានឈ្មោះ នេលស៍ ម៉នសុន ឈ្មោះរបស់ឪពុកខ្ញុំពុំមែនជា ម៉នសុននោះទេ ប៉ុន្តែជា ម៉នស៍ អូកេសុន ។ ឈ្មោះឪពុករបស់ម៉នស៍គឺអូកេ ផេឌឺសិន ហើយឈ្មោះឪពុករបស់គាត់គឺភីធើរ ម៉នសុន—ត្រឡប់ទៅ ម៉នសុនវិញ ។

ព្រះអម្ចាស់រំពឹងទុកឲ្យអ្នក ហើយនិងខ្ញុំធ្វើកិច្ចការពង្សប្រវត្តិរបស់យើងឲ្យបានល្អ ។ ខ្ញុំគិតថា កិច្ចការទីមួយដែលយើងត្រូវធ្វើ ប្រសិនបើយើងចង់ធ្វើកិច្ចការរបស់យើងឲ្យបានល្អ គឺត្រូវមានព្រះវិញ្ញាណរបស់ព្រះវរបិតាសួគ៌របស់យើងគង់នៅជាមួយនឹងយើង ។ នៅពេលយើងខំប្រឹងប្រែងរស់នៅយ៉ាងសុចរិតបំផុតនោះទ្រង់នឹងបើកផ្លូវសម្រាប់ការបំពេញពរជ័យដែលយើងស្វែងរកដោយស្មោះត្រង់ហើយដោយខិតខំយ៉ាងខ្លាំង ។

យើងនឹងធ្វើកំហុស ប៉ុន្តែគ្មានយើងណាម្នាក់អាចក្លាយជាអ្នកជំនាញនៅក្នុងកិច្ចការពង្សប្រវត្តិដោយគ្មានការក្លាយជាអ្នកថ្មីថ្មោងនោះទេ ។ ហេតុដូច្នេះហើយ យើងត្រូវប្រទ្បូកក្នុងកិច្ចការនេះ ហើយយើងត្រូវរៀបចំខ្លួនសម្រាប់ឧបសគ្គមួយចំនួន ។ វាពុំមែនជាកិច្ចការងាយស្រួលនោះទេ ប៉ុន្តែព្រះអម្ចាស់បានដាក់វាមកលើអ្នក ហើយទ្រង់បានដាក់វាមកលើខ្ញុំ ។

នៅពេលយើងព្យាយាមធ្វើកិច្ចការពង្សប្រវត្តិ អ្នកនឹងរកឃើញដោយខ្លួនឯងថា អ្នកកំពុងដើរនៅលើផ្លូវទាល់ ហើយអ្នកនឹងនិយាយប្រាប់ខ្លួនឯងថា « ខ្ញុំមិនអាច



ធ្វើអ្វីផ្សេងទៀតបានទេ » ។ នៅពេលអ្នកមកដល់ចំណុចនោះ សូមលុតជង្គង់ចុះ ហើយទូលសុំដល់ព្រះអម្ចាស់ឲ្យបើកផ្លូវនោះ ហើយទ្រង់នឹងបើកផ្លូវនោះឲ្យអ្នក ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា រឿងនេះជាការពិត ។

ព្រះវរបិតាសួគ៌ស្រឡាញ់កូនចៅរបស់ទ្រង់នៅក្នុងពិភពវិញ្ញាណ ដូចជាទ្រង់ស្រឡាញ់អ្នក ហើយនិងខ្ញុំដែរ ។ ព្យាការី យ៉ូសែបស្ម៊ីធ បានមានប្រសាសន៍ស្ដីពីកិច្ចការសង្គ្រោះដល់ដូនតារបស់យើងដែលបានចែកឋានទៅ ថា « ហើយឥឡូវនេះ ដោយសារព្រះរាជបំណាងដ៏អស្ចារ្យនៃព្រះកំពុងពន្លឿនទៅរកភាពជោគជ័យរបស់ខ្លួន ហើយរឿងទាំងឡាយដែលបានលើកឡើងដោយព្យាការីកំពុងត្រូវបានបំពេញ ដូចជានគរព្រះត្រូវបានស្ថាបនានៅលើផែនដី ហើយរឿងពីបុរាណត្រូវបានស្ដារឡើងវិញ នោះព្រះអម្ចាស់បានបើកសម្ដែងមកកាន់យើងពីកាតព្វកិច្ច និង ឯកសិទ្ធិនេះ » ។[3]

ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ ( ឆ្នាំ 1838–1918 ) បានប្រកាសស្ដីពីដូនតារបស់យើងដែលបានចែកឋានទៅដោយមិនបានស្គាល់ដំណឹងល្អថា « តាមរយៈកិច្ចខិតខំរបស់យើងដើម្បីប្រយោជន៍របស់ពួកគេ នោះច្រវ៉ាក់ដែលចងភ្ជាប់ពួកគេនឹងត្រូវបានរលោះ ហើយសេចក្ដីងងឹតដែលព័ទ្ធជុំវិញពួកគេនឹងរសាយបាត់ ពន្លឺនោះអាចនឹងជះរស្មីមកលើពួកគេ ហើយពួកគេនឹងស្ដាប់ឮនៅពិភពវិញ្ញាណស្ដីពីកិច្ចការដែលបានធ្វើសម្រាប់ពួកគេតាមរយៈកូនចៅរបស់ពួកគេនៅទីនេះ ហើយពួកគេនឹងរីករាយជាមួយអ្នកនៅក្នុងការអនុវត្តរបស់អ្នកចំពោះកាតព្វកិច្ចទាំងនេះ ។[4]

មានកូនចៅវិញ្ញាណរបស់ព្រះវរបិតាសួគ៌របស់យើងរាប់រយរាប់លាននាក់ដែលពុំធ្លាប់ឮព្រះនាមរបស់ព្រះគ្រីស្ទពីមុនចែកឋាន ហើយនឹងនៅក្នុងពិភពវិញ្ញាណ ។ ប៉ុន្តែឥឡូវនេះពួកគេបានបង្រៀនពីដំណឹងល្អ ហើយកំពុងរង់ចាំថ្ងៃដែលអ្នក ហើយនិងខ្ញុំនឹងធ្វើការស្រាវជ្រាវដែលចាំបាច់ដើម្បីបើកផ្លូវនោះ ដើម្បីយើងអាចចូលទៅដំណាក់ព្រះអម្ចាស់ ហើយធ្វើកិច្ចការដែលពួកគេពុំអាចធ្វើបានដោយខ្លួនឯង ។

បងប្អូនប្រុសស្រីរបស់ខ្ញុំអើយ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់នឹងប្រទានពរដល់យើង ពេលយើងទទួលយក ហើយឆ្លើយតបចំពោះសំណូមពរនេះ ។ ■

### ការបង្រៀនចេញពីសារលិខិតនេះ

សូមគិតពីដំណើររឿងមួយដែលអ្នកចូលចិត្តនៅក្នុងពង្សប្រវត្តិរបស់អ្នក ហើយចែកចាយដំណើររឿងនោះជាមួយនឹងមនុស្សដែលអ្នកទៅសួរសុខទុក្ខ ។ អ្នកអាចប្រើសំណួរនៅក្នុងផ្នែកនៃសារលិខិតគណៈប្រធានទីមួយរបស់កុមារ ( ទំព័រ 6 ) ដើម្បីលើកទឹកចិត្តសមាជិកដែលអ្នកសួរសុខទុក្ខឲ្យចែកចាយដំណើររឿងរបស់ពួកគេ ។ សូមពិចារណាអានគោលលទ្ធិ និង សេចក្ដីសញ្ញា 128:15ហើយពិភាក្សាពីសារៈសំខាន់នៃការធ្វើពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធសម្រាប់ដូនតារបស់យើង ។

**កំណត់ចំណាំ**

1. គោលលទ្ធិ និង សេចក្ដីសញ្ញា 88:73។
2. Teachings of Presidents of the Church: Brigham Young ( ឆ្នាំ 1997 ) ទំព័រ 280 ។
3. Teachings of Presidents of the Church: Joseph Smith ( ឆ្នាំ 2007 ) ទំព័រ 409 ។
4. Teachings of Presidents of the Church: Joseph F. Smith ( ឆ្នាំ 1998 ) ទំព័រ 247 ។

## តើខ្ញុំអាចរីករាយនឹងការធ្វើលិបិក្រមដែរឬទេ ?

ដោយអិមម៉ា អាប្រ៊ីល គូឡេឌូ ស៊ីស្នេរុស

ខ្ញុំបានចូលរួមនៅក្នុងគោលដៅរបស់ស្តេកយើង ដើម្បីធ្វើលិបិក្រមឈ្មោះចំនួន 50,000នាក់ ។ ពីដំបូង វាលំបាកណាស់ ។ ពីរបីដង បាច់ដែលបានខ្ញុំបានទាញយក មានអក្សរសរសេរដៃពិបាកអានណាស់ ហើយពេលខ្លះខ្ញុំចង់ផ្ញើវាទៅវិញ ហើយទាញយកបាច់មួយផ្សេងទៀត ។ ប៉ុន្តែពេលនោះខ្ញុំបានដឹងថា ប្រសិនបើមនុស្សគ្រប់គ្នាគិតដូច្នេះ នោះបាច់ទាំងនោះនឹងត្រូវបានទុកចោលជារៀងរហូត ។ ខ្ញុំអាចស្រមើស្រមៃឃើញមនុស្សជាច្រើនដែលកំពុងរង់ចាំនៅពិភពវិញ្ញាណ ហើយខ្ញុំបានសម្រេចចិត្តបន្តព្យាយាមអានឈ្មោះទាំងនោះ ហើយកត់ត្រាវាដោយផ្ចិតផ្ចង់ ។

ខ្ញុំបានរៀនមានសេចក្ដីស្រឡាញ់ចំពោះមនុស្សទាំងនោះ ។ ខ្ញុំយល់ថា ពួកគេពិតជាត្រូវការជំនួយ ហើយយើងក៏ត្រូវការជំនួយពីពួកគេផងដែរ ។ ខ្ញុំបានយល់កាន់តែច្បាស់ថា ផែនការដ៏ល្អឥតខ្ចោះរបស់ព្រះវរបិតាសួគ៌ឲ្យមនុស្សគ្រប់គ្នាគិតវិនិច្ឆ័យ ។ នៅពេលយើងធ្វើតាមការបំផុសគំនិត និងការណែនាំរបស់ពួកអ្នកដឹកនាំរបស់ទ្រង់ដែលបានជ្រើសរើស នោះយើងនឹងមើលឃើញសេចក្ដីមេត្តាករុណា និង សេចក្ដីស្រឡាញ់ដ៏គ្មានទីបញ្ចប់របស់ទ្រង់ ។

ការធ្វើលិបិក្រមបានក្លាយជាបទពិសោធន៍មួយដ៏ល្អសម្រាប់ខ្ញុំ ។ ខ្ញុំរៀនផ្ដល់តម្លៃ ហើយស្រឡាញ់រឿងជាច្រើនទាក់ទងនឹងពង្សប្រវត្តិ ។ ខ្ញុំក៏ទទួលបានអំណោយនៃតម្លៃដ៏ធំអស្ចារ្យពីព្រះអម្ចាស់របស់យើងតាមរយៈការគោរពនូវអ្វីមួយយ៉ាងសាមញ្ញដោយចូលរួមនៅក្នុងការធ្វើលិបិក្រម ។

*អ្នកនិពន្ធរស់នៅក្នុងប្រទេស វេរ៉ាក្រាស់ ប្រទេស ម៉ិកស៊ិកូ ។*



## ស្គាល់ពីដំណើររឿងរបស់អ្នក

ឪពុកម្ដាយ និង ជីដូនតារបស់យើងមាននូវដំណើរផ្សងព្រេងជាច្រើន—មានរឿងខ្លះអ្នកមិនបានដឹងនោះទេ ! ដំណើររឿងពួកគាត់ខ្លះនឹងធ្វើឲ្យអ្នកសើច ហើយដំណើររឿងទាំងនោះអាចជួយឲ្យអ្នកមានសេចក្ដីជំនឿលើព្រះវរបិតាសួគ៌ ។ ប៉ុន្តែពេលខ្លះ សូម្បីតែមនុស្សពេញវ័យមានអារម្មណ៍ខ្មាស់អៀនផងដែរ ។ សូមប្រើសំណួរទាំងនេះដើម្បីពួកគេឲ្យចងចាំពីដំណើររឿងមួយចំនួនដែលពួកគេចូលចិត្ត ហើយសរសេរ ឬគូររូបស្ដីពីចម្លើយរបស់ពួកគេ ។




គំនូរដោយ ស៊ីម៉ុន ស៊ីន

*សូមសិក្សាឯកសារនេះដោយការអធិស្ឋាន ហើយព្យាយាមយល់ដឹងនូវអ្វីដែលត្រូវចែកចាយ ។ តើការយល់ដឹងពីឆាកជីវិត និងបេសកកម្មរបស់ព្រះអង្គសង្គ្រោះ នឹងពង្រឹងសេចក្តីជំនឿរបស់អ្នកលើទ្រង់ ហើយប្រទានពរដល់អ្នកទាំងឡាយដែលមើលថែទាំតាមរយៈការបង្រៀនតាមផ្ទះដោយរបៀបណា ? ចំពោះព័ត៌មានបន្ថែម សូមចូលទៅ reliefsociety.lds.org ។*

# បេសកកម្មដ៏ទេវភាពនៃព្រះយេស៊ូវគ្រីស្ទ ៖ ការបម្រើ

*នេះជាផ្នែកនៃគំរូមួយអំពីសារលិខិតបង្រៀនតាមផ្ទះ ដែលឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃបេសកកម្មរបស់ព្រះអង្គសង្គ្រោះ ។*

នៅពេលអ្នកបម្រើដល់មនុស្សដទៃ យើងប្រែក្លាយជាអ្នកដើរតាមដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានធ្វើជាគំរូដល់យើង ។ ប្រធាន ថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា ៖ « យើងត្រូវបានហ៊ុមព័ទ្ធដោយជនដែលមានសេចក្តីត្រូវការ ។ . . . យើងគឺជាព្រះហស្តរបស់ព្រះអម្ចាស់នៅលើផែនដីនេះ ដោយមានបញ្ញត្តិឲ្យបម្រើ ហើយជួយដល់កូនចៅទ្រង់ ។[1]

លីនដា ខេ បើតុន ជាប្រធានសមាគមសង្គ្រោះទូទៅបានបង្រៀនថា ៖ « ដោយការអនុវត្ត យើងម្នាក់ៗអាចក្លាយកាន់តែដូចព្រះអង្គសង្គ្រោះ នៅពេលយើងបម្រើដល់កូនចៅរបស់ព្រះ ។ ដើម្បីជួយយើងឲ្យ [ បម្រើ ] គ្នាទៅវិញទៅមកឲ្យកាន់តែប្រសើរ ខ្ញុំចង់ឲ្យអ្នកចាំនូវឃ្លានេះ ៖ ‹ ដំបូង ធ្វើការសង្កេត បន្ទាប់មក បម្រើ › ។ . . .នៅពេលយើងធ្វើដូច្នោះ យើងកំពុងរក្សាសេចក្តីសញ្ញា ហើយការបម្រើរបស់យើង ក៏ដូចជាការបម្រើរបស់ប្រធានម៉នសុនដែរ ដែលនឹងក្លាយជាភស្តុតាងនៃភាពជាសិស្សរបស់យើង » ។[2]

យើងអាចអធិស្ឋានរៀងរាល់ព្រឹក ដើម្បីឲ្យស្គាល់ពីឱកាសដើម្បីបម្រើដល់មនុស្សដទៃ ។ ដេវីឌ អិល បេក ជាប្រធានយុវជនទូទៅបានមានប្រសាសន៍ថា « ព្រះវរបិតាសួគ៌នឹងដឹកនាំអ្នក ហើយពួកទេវតានឹងជួយដល់អ្នក » ។ « អ្នកនឹងប្រទានឲ្យនូវអំណាចដើម្បីប្រទានពរដល់ជីវិត ហើយជួយសង្គ្រោះដល់ព្រលឹង » ។[3]



### ចេញពីព្រះគម្ពីរ

ម៉ាថាយ 20:25–28, នីហ្វៃទី 1 11:27–28, នីហ្វៃទី 3 28:18

**កំណត់ចំណាំ**

1. ថូម៉ាស អេស ម៉នសុន « តើនៅថ្ងៃនេះខ្ញុំបានធ្វើអ្វីខ្លះចំពោះមនុស្សម្នាក់ ? » Liahona, ខែ វិច្ឆិកា ឆ្នាំ 2009 ទំព័រ 86 ។
2. លីនដា ខេ បើតុន « First Observe, Then Serve » Liahona, ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 78, 80 ។
3. ដេវីឌ អិល បេក « Your Sacred Duty to Minister » Liahona, ខែ ឧសភា ឆ្នាំ 2013 ទំព័រ 56 ។
4. លូស៊ី មេស៊ើរ ស្ម៊ីធ ក្នុង *Daughters in My Kingdom: The History and Work of Relief Society* ( ឆ្នាំ 2011 ) ទំព័រ 36–37 ។
5. ចច អ័លប៊ើត ស្ម៊ីធ ក្នុង *Daughters in My Kingdom*, ទំព័រ 77 ។

### សូមពិចារណាពីចំណុចនេះ

1. តើការអធិស្ឋានអាចដឹកនាំយើងឲ្យក្លាយជាឧបករណ៍ នៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់បានដោយរបៀបណា ?
2. តើការបម្រើដល់អ្នកដទៃអាចជួយយើងឲ្យរក្សាសេចក្តីសញ្ញារបស់យើងបានដោយរបៀបណា ?

## សេចក្តីជំនឿ គ្រួសារ ការសង្គ្រោះ

### ចេញពីប្រវត្តិសាស្ត្ររបស់យើង

នៅសន្និសីទទូទៅខែ តុលា ឆ្នាំ 1856 ប្រធានព្រិកហាំ យ៉ង់ ( ឆ្នាំ 1801–77 ) បានប្រកាសថា ពួកអ្នកត្រួសត្រាយនឹងបន្តដើរឆ្លងកាត់ទីវាលទំនាប ហើយចាមនុស្សគ្រប់គ្នាត្រូវជួយប្រមូលអាហារសម្រាប់ពួកគេយ៉ាងឆាប់រហ័ស ។ លូស៊ី មេស៊ើរ ស្ម៊ីធ បានសរសេរថា ពួកស្ត្រី « បានដោះរ៉ូបរបស់ខ្លួន [ រ៉ូបធំ ] ស្រោមជើងវែង និងអ្វីគ្រប់យ៉ាងដែលពួកគេមាន នៅក្នុងរោងឧបោសថ ហើយដាក់[ វា ]ចូលទៅក្នុងរទេះ » ។

នៅពេលពួកអ្នកត្រួសត្រាយដែលត្រូវបានគេជួយសង្គ្រោះបានមកដល់ទីក្រុងសលត៍ លេក លូស៊ី បានសរសេរថា « ខ្ញុំពុំធ្លាប់រីករាយ. . .យ៉ាងខ្លាំងនៅក្នុងកិច្ចការទាំងឡាយដែលខ្ញុំធ្លាប់ធ្វើនៅក្នុងជីវិតរបស់យើងឡើយ ដោយសារកិច្ចការនេះមាននូវអារម្មណ៍នៃសាមគ្គីភាព នៅក្នុងចំណោមសមាជិកទូទៅ ។ ខ្ញុំគ្រាន់តែដើរចូលទៅក្នុងហាងមួយ ហើយពន្យល់ប្រាប់ពីសម្ភារដែលខ្ញុំចង់បាន ប្រសិនបើវាជាសំលៀកបំពាក់ នោះវានឹងត្រូវបានគេរាស់វែង ហើយកាត់ដោយឥតគិតថ្លៃឡើយ » ។[4]

ប្រធាន ចច អ័លប៊ើត ស្ម៊ីធ ( ឆ្នាំ 1870–1951 ) បានមានប្រសាសន៍ពីការបម្រើដល់អ្នកដទៃថា ៖ « សុភមង្គលដ៏អស់កល្បរបស់យើងនឹងក្លាយជាផ្នែកមួយនៅក្នុងរបៀបដែលយើងលះបង់ខ្លួនឯងជួយដល់អ្នកដទៃ » ។[5]

សេចក្តីលម្អិតផ្ទាំងគំនូរ ☒☒☒ ☒☒☒☒☒☒ ☒☒? ដោយ ជេ អិល ខប

# ឆ្ងល់យ៉ាងអស្ចារ្យនូវក្ដីស្នេហ៍ព្រះគ្រីស្ទឲ្យខ្ញុំ

ដោយ សេសា លីម៉ា អេស្កាឡេនតេ

នៅថ្ងៃអាទិត្យមួយពីមុនការប្រជុំសាក្រាម៉ង់ ប៊ីស្សពបានដើរមករកខ្ញុំ ហើយសួរថា « តើអ្នកអាចជួយប្រសិទ្ធពរសាក្រាម៉ង់បានទេ ? » ខ្ញុំបាននិយាយថា ពិតជាបាន ។

ខ្ញុំដើរទៅរកសៀវភៅទំនុកតម្កើងរបស់ខ្ញុំ រួចហើយបានលាងដៃរបស់ខ្ញុំពីមុនចូលទៅអង្គុយនៅឯតុសាក្រាម៉ង់ ។ ខ្ញុំបានបើកសៀវភៅទំនុកតម្កើងរបស់ខ្ញុំ ហើយទំនុកតម្កើងដំបូងដែលខ្ញុំបើកចំគឺបទ « ខ្ញុំឆ្ងល់យ៉ាងអស្ចារ្យ » (ទំនុកដំកើងព្រះ និង ចម្រៀងកុមារាកុមារី ទំព័រ 22). ការប្រជុំពុំទាន់ចាប់ផ្ដើមនៅឡើយ ដូច្នេះខ្ញុំក៏ចាប់ផ្ដើមអានឃ្លាទីមួយ ៖ « ខ្ញុំឆ្ងល់យ៉ាងអស្ចារ្យនូវក្ដីស្នេហ៍ព្រះគ្រីស្ទឲ្យខ្ញុំ » ។ រំពេចនោះ អារម្មណ៍នៃសេចក្ដីស្រឡាញ់មួយដ៏ជ្រាលជ្រៅបានដក់នៅក្នុងចិត្តខ្ញុំ ។

កាលពីយប់ម្សិលខ្ញុំបានអានព្រះគម្ពីរប៊ីបស្ដីពីគ្រាចុងក្រោយនៃឆាកជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ—ជាផ្នែកដែលទាក់ទងនឹងអាហារថ្ងៃចុងក្រោយ សួនគែតសេម៉ានី និង ការសុគត និង ការរស់ឡើងវិញរបស់ទ្រង់ ។ ខ្ញុំនឹកស្រមៃពីព្រះយេស៊ូវត្រូវបានគេធ្វើទារុណកម្ម វាយដំ ហើយប្រមាថចំអកពីសំណាក់អស់អ្នក ដែលបានធ្វើឃាតទ្រង់ ។ ខ្ញុំក៏បាននឹកស្រមៃផងដែរពេលព្រះយេស៊ូវធ្វើពលិកម្មធ្វើឲ្យធួនរបស់ទ្រង់នៅក្នុងសួនគែតសេម៉ានី ខណៈដែលពួកសិស្សរបស់ទ្រង់បានដេកលក់ ។

ខ្ញុំបានដឹងថា ខ្ញុំនឹងប្រសិទ្ធពរដល់នំប៉័ង និង ទឹកដែលជាតំណាងឲ្យព្រះកាយ និង ព្រះលោហិតរបស់ទ្រង់ ។ សាក្រាម៉ង់អនុញ្ញាតឲ្យយើងរំឭកពីសេចក្ដីសញ្ញាដែលយើងបានធ្វើពេលយើងជ្រមុជទឹក គឺថាត្រូវចងចាំទ្រង់ជានិច្ច គោរពព្រះបញ្ញត្តិរបស់ទ្រង់ ហើយលើកដាក់មកលើខ្លួនយើងនូវព្រះនាមរបស់ទ្រង់ ។

នៅពេលការប្រជុំសាក្រាម៉ង់បានចាប់ផ្ដើម គំនិតទាំងនេះបានដក់ជាប់ក្នុងគំនិតរបស់ខ្ញុំ ។ ខ្ញុំមានអារម្មណ៍យ៉ាងអស្ចារ្យថា ព្រះយេស៊ូវបានរងទុក្ខតាមរបៀបមួយដ៏ឈឺចាប់ ហើយហួសនិស្ស័យ ដែលធ្វើឲ្យយើងមិនអាចយល់បាន ។ រួចគំនិតនោះបានកើតមានចំពោះខ្ញុំថា ទ្រង់បានស៊ូទ្រាំការរងទុក្ខនោះ ដោយសារសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះយើង—ចំពោះខ្ញុំ ។

ខ្ញុំបានទទួលអារម្មណ៍នូវសេចក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅរបស់ព្រះអម្ចាស់ រហូតធ្វើឲ្យខ្ញុំទប់ទឹកភ្នែកមិនបាន ។ ខ្ញុំមានអារម្មណ៍ដូចជាខ្ញុំខ្វះភាពសក្ដិសមចំពោះអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើសម្រាប់ខ្ញុំ ។ ប៉ុន្ដែខ្ញុំក៏មានអារម្មណ៍ថា សេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះខ្ញុំគឺល្អឥតខ្ចោះ ។ មិត្តម្នាក់សុខចិត្តលះបង់ជីវិតរបស់ខ្លួនសម្រាប់មិត្តរបស់គាត់ ( សូមមើល យ៉ូហាន 15:13) ។ នៅពេលទំនុកតម្កើងសាក្រាម៉ង់បានចាប់ផ្ដើម ខ្ញុំបានក្រោកឈរជាមួយនឹងបងប្រុសម្នាក់ទៀតដើម្បីចាប់ផ្ដើមធ្វើពិធីការនោះ ។

យើងបានទាញបើកកម្រាលពណ៌-សដ៏ស្រស់



**បទពិសោធន៍នៃការលាងសម្អាតជីវិតខាងវិញ្ញាណ**

« ដើម្បីឲ្យសាក្រាម៉ង់ក្លាយជាបទពិសោធន៍នៃការលាងសម្អាតមួយខាងវិញ្ញាណជារៀងរាល់សប្ដាហ៍ យើងត្រូវរៀបចំខ្លួនយើង *ពីមុនពេល*យើងមកកាន់ការប្រជុំសាក្រាម៉ង់ ។ យើងធ្វើការណ៍នេះដោយការទុកចោលនូវកិច្ចការ និង ការកម្សាន្តប្រចាំថ្ងៃរបស់យើង ហើយទម្លាក់ចោលនូវគំនិត និង ការខ្វល់ខ្វាយខាងលោកិយ ។ ពេលយើងធ្វើដូច្នោះ យើងទុកកន្លែងក្នុងគំនិត និង ដួងចិត្តរបស់យើងសម្រាប់ព្រះវិញ្ញាណបរិសុទ្ធ ។ . . .

« ពេលយើងច្រៀងបទទំនុកតម្កើងក្នុងពិធីសាក្រាម៉ង់ ចូលរួមក្នុងការអធិស្ឋានសម្រាប់សាក្រាម៉ង់ ហើយទទួលទានតំណាងនៃព្រះកាយ និង ព្រះលោហិតទ្រង់ នោះយើងអធិស្ឋានស្វែងរកការអត់ទោសចំពោះអំពើបាប និង ភាពទន់ខ្សោយរបស់យើង ។ យើងគិតអំពីការសន្យាដែលយើងបានធ្វើ និង រក្សាអំឡុងសប្ដាហ៍មុន ហើយធ្វើការតាំងចិត្តជាក់លាក់ផ្ទាល់ខ្លួនដើម្បីធ្វើតាមព្រះអង្គសង្គ្រោះក្នុងសប្ដាហ៍បន្ទាប់នោះ ។

**អែលឌើរ រ៉ូប៊ឺត ឌី ហែល ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់** « Coming to Ourselves: The Sacrament, the Temple, and Sacrifice in Service » Liahona, **ខែ ឧសភា ឆ្នាំ 2012 ទំព័រ 34 ។**



CHRIST MOCKED BY A SOLDIER ដោយ ខាល ហេនរិច ប្លុក © HOPE GALLERY

ស្អាតដែលបានគ្របនំប៉័ងឡើង ។ នៅពេលខ្ញុំកាន់នំប៉័ងនោះ ខ្ញុំបានដឹងថា ខ្ញុំមានទំនួលខុសត្រូវដើម្បីហែកនំប៉័ងនោះជាផ្នែកមួយនៃពិធីការនេះ ប៉ុន្តែខ្ញុំបានមានការស្ទាក់ស្ទើរ ។ នំប៉័ងនោះតំណាងឲ្យព្រះកាយនៃព្រះគ្រីស្ទ ។ ខ្ញុំបានគិតពីពួកកងទ័ពដែលធ្វើបាបដល់ព្រះអម្ចាស់ ហើយខ្ញុំមិនចង់ហែកនំប៉័ងនោះឡើយ ។ នៅពេលហែកបំណែកដំបូង ខ្ញុំបានគិតពីការឈឺចាប់ និង ភាពអាម៉ាស់ដែលព្រះយេស៊ូវបានទទួលពីមុនការសុគតរបស់ទ្រង់—មកុដបន្លា ការវាយនឹងរំពាត់ ការរងទុក្ខ ។ ទឹកភ្នែករបស់ខ្ញុំបានហូរស្រក់មកលើថ្ពាល់របស់ខ្ញុំ ពេលខ្ញុំបានរៀបចំនំប៉័ង ។

រួចហើយមានគំនិតមួយ បានកើតឡើងចំពោះខ្ញុំថា ព្រឹត្តិការណ៍ដ៏ឈឺចាប់ ហើយ អាម៉ាស់នេះគឺជារឿងដ៏ចាំបាច់ ។ វាគឺជាផ្នែកមួយនៃពលិកម្មធួនរបស់ព្រះយេស៊ូវគ្រីស្ទ ហើយទ្រង់បានធ្វើពលិកម្ម ដោយសារតែសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះខ្ញុំ និង យើងម្នាក់ៗ ។

ខ្ញុំបានចាប់ផ្ដើមមានអារម្មណ៍នូវសេចក្ដីសុខសាន្ត និងសេចក្ដីអំណរយ៉ាងខ្លាំង ។ ខ្ញុំបានហែកនំប៉័ងជាចំណែកៗ ហើយធ្វើវាមួយៗដោយប្រុងប្រយ័ត្ន ដោយដឹងថា អ្វីដែលខ្ញុំបានកាន់នៅក្នុងដៃនឹងត្រូវបានប្រសិទ្ធពរ ហើយធ្វើឲ្យបរិសុទ្ធសម្រាប់គោលបំណងពិសេសមួយ ហើយជាតំណាងនូវអ្វីមួយដែលមានតម្លៃអស្ចារ្យបំផុត ។ ខ្ញុំមានអារម្មណ៍នូវទំនួលខុសត្រូវដ៏ធំនៅក្នុងការធ្វើពិធីការនេះ ដើម្បីឲ្យសមាជិកនៅក្នុងការប្រជុំនេះអាចរំឭកចាំពីសេចក្ដីសញ្ញាជាមួយនឹងព្រះអម្ចាស់ ហើយទទួលពរជ័យនៃដង្វាយធួន ។

នៅពេលយើងបានបញ្ចប់ ខ្ញុំបានឃើញថាសទាំងនោះមានពេញទៅដោយបំណែកនំប៉័ង ។ ទិដ្ឋភាពនោះមានភាពអស្ចារ្យ ហើយ បរិសុទ្ធ ។ ដៃគូរបស់ខ្ញុំពោលពាក្យអធិស្ឋាន ។ ខ្ញុំពុំធ្លាប់មានការយល់ដឹងយ៉ាងច្បាស់នូវឃ្លា « ប្រយោជន៍ឲ្យពួកគេអាចទទួលទានដោយនូវការចងចាំដល់ព្រះកាយនៃព្រះរាជបុត្រារបស់ព្រះអង្គ » (គ. និង ស. 20:77) ។

នៅពេលខ្ញុំទទួលទាននំប៉័ង ខ្ញុំទទួលអារម្មណ៍នូវសេចក្ដីស្រឡាញ់របស់ព្រះអម្ចាស់ជាថ្មីម្ដងទៀត ។ ខ្ញុំមានអារម្មណ៍ដឹងនូវការការពារ ចិត្តរាបសា និងការតាំងចិត្តដើម្បីធ្វើនូវអ្វីដែលត្រឹមត្រូវ ។ ខ្ញុំចង់ត្រួតពិនិត្យពីជីវិតរបស់ខ្ញុំ ហើយប្រែចិត្តនូវរាល់អ្វីដែលខ្ញុំបានធ្វើខុស ។

ខ្ញុំមានអំណរគុណចំពោះព្រះយេស៊ូវគ្រីស្ទចំពោះសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះខ្ញុំ។ ខ្ញុំមានអំណរគុណថា យើងអាចទទួលពរជ័យនៃដង្វាយធួនរបស់ទ្រង់ ៖ ដោយទទួលបានការអត់ទោសពីអំពើបាបរបស់យើង ហើយមានឱកាសត្រឡប់ទៅរកព្រះវរបិតាសួគ៌របស់យើងវិញ ។ ■

*អ្នកនិពន្ធរស់នៅក្នុងទីក្រុង ម៉ិកស៊ីកូ ប្រទេសម៉ិកស៊ីកូ*

**សំណួរដើម្បីពិចារណា ៖**

តើខ្ញុំអាចធ្វើអ្វីខ្លះនៅក្នុងសប្ដាហ៍នេះដើម្បីរៀបចំខ្លួនឲ្យបានប្រសើរដើម្បីទទួលទានសាក្រាម៉ង់ ? តើខ្ញុំគិតពីអ្វីខ្លះនៅក្នុងពេលសាក្រាម៉ង់ ? តើខ្ញុំទទួលអារម្មណ៍ពីការអត់ទោស ហើយទទួលបានការបំផុសគំនិត ពេលខ្ញុំទទួលទានសាក្រាម៉ង់ដែរឬទេ ?

# ឧបសគ្គទាំងឡាយគឺជាពរជ័យ

ដោយ រ៉ាជែល ហារ៉ិសិន

*អ្វីដែលខ្ញុំបានគិតថាជាឧបសគ្គចំពោះអាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ ផ្ទុយទៅវិញ បានក្លាយទៅជាពរជ័យដ៏អស្ចារ្យ ។*

ខ្ញុំបាននិយាយនឹងមិត្តម្នាក់ស្ដីពីពរជ័យនៃការរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ ។ ខ្ញុំបាននិយាយលេងថា ខ្ញុំអាចគិតឃើញតែពរជ័យបន្តិចបន្តួចខ្លះប៉ុណ្ណោះ ប៉ុន្តែខ្ញុំអាចគិតឃើញនូវឧបសគ្គជាច្រើន ។ គាត់បានពោលថា « មែនហើយ ប្រហែលជារឿងទាំងនោះជាពរជ័យ ! »

ខ្ញុំបានដឹងថា គាត់និយាយត្រូវ ។

ការផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធបានប្រទានពរដល់ខ្ញុំជាមួយនឹងទស្សនវិស័យអស់កល្បជានិច្ចស្ដីអំពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។ សេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធរបស់ខ្ញុំបានក្លាយជា « កញ្ចក់ឆ្លុះបញ្ចាំង » ដែលស្វាមីរបស់ខ្ញុំ និង ខ្ញុំតែងប្រើដើម្បីមើលពីជម្រើសនានានៅចំពោះមុខយើង ទោះជាយើងជាគូស្វាមីភរិយាវ័យក្មេងទើបរៀបការថ្មោងថ្មីក៏ដោយ ។

អាពាហ៍ពិពាហ៍នាំមកនូវទំនួលខុសត្រូវដ៏សំខាន់បំផុត—និងគ្រាដ៏រីករាយបំផុតមួយចំនួនសម្រាប់ជីវិត ។ យើងចង់ឮពីគ្រាដ៏រីករាយដែលអ្នកមាននៅក្នុងអាពាហ៍ពិពាហ៍របស់អ្នក ។ សូមចែកចាយដំណើររឿងរបស់អ្នកនៅ liahona.lds.org ( សូមចុច «Submit Your Work») ឬតាមរយៈអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ។

### ទស្សនវិស័យអស់កល្បជានិច្ច

យើងបានចាប់ផ្ដើមអាពាហ៍ពិពាហ៍របស់យើងជាមួយនឹងទស្សនវិស័យអស់កល្បជានិច្ចមួយ ហើយយើងមានអារម្មណ៍ថា វាមានន័យថា យើងមិនគួរពន្យារពេល ឬកំណត់ចំនួនកូនចៅដែលកំពុងរង់ចាំមកកើតនៅក្នុងគ្រួសាររបស់យើងឡើយ ។ ស្វាមីរបស់ខ្ញុំបានបន្តការសិក្សារបស់គាត់ ( ថ្នាក់បរិញ្ញាបត្រ ) ខណៈដែលគ្រួសាររបស់យើងបានរីកចម្រើន ។ លុះដល់ពេលគាត់ចូលធ្វើការពេញម៉ោង នោះយើងមានកូនប្រាំនាក់ ។ ខ្ញុំបានបន្តការសិក្សាក្រៅម៉ោងរបស់ខ្ញុំ ដើម្បីខ្ញុំអាចមើលថែកូនៗរបស់ខ្ញុំនៅផ្ទះ ។ ខ្ញុំបានក្រឡេកមើលទៅប៉ុន្មានឆ្នាំមុននោះដោយរីករាយសោមនស្ស ។ វាជាពេលដ៏អស្ចារ្យ ! យើងបានរស់នៅក្នុងផ្ទះតូចមួយដោយមានកូនពីរនាក់មានអាយុក្រោម 15 ខែ យើងរស់នៅដោយប្រាក់ឧបត្ថម្ភសម្រាប់និស្សិតបន្តិចបន្តួចរបស់យើង ហើយហូបអាហារសាច់គោចិញ្ច្រាំជាច្រើន ( ហែមប៊ើហ្គឺ ) ។

ខ្ញុំគិតពីឆ្នាំទាំងនោះថាជាឆ្នាំនៃការត្រួសត្រាយរបស់យើង—យើងបានឆ្លងកាត់ « ទីវាល » នៃការសិក្សា ការចាប់ផ្ដើមគ្រួសារ និង ការរស់នៅដោយមានធនធានហិរញ្ញវត្ថុមានកំណត់ ។ ខ្ញុំមានអារម្មណ៍ដូចគ្នា—ប៉ុន្តែវាតិចតួចប៉ុណ្ណោះ —ទៅនឹងអ្វីដែលអ្នករស់រានមានជីវិតតែម្នាក់ នៅក្នុងក្រុមរទេះរុញម៉ាទីនបានថ្លែងពីដំណើររបស់ពួកគេថា ៖ « យើងគ្រប់គ្នាបានឆ្លងកាត់ជាមួយនឹងចំណេះដឹងដ៏ពិតថាព្រះមានព្រះជន្មរស់ ត្បិតយើងបានស្គាល់ទ្រង់នៅក្នុងគ្រាដ៏លំបាករបស់យើង » ។[1]

នៅក្នុងទស្សនៈនៃលោកិយនេះ អ្វីដែលយើងបានជ្រើសរើសដើម្បីធ្វើនៅក្នុងបណ្ដាឆ្នាំដំបូងទាំងប៉ុន្មាន នៃអាពាហ៍ពិពាហ៍គឺជារឿងដ៏ចម្លែក ។ ការពន្យារពេលការបញ្ចប់ការសិក្សារបស់ខ្ញុំដើម្បីមានកូន ដោយរស់នៅលើប្រាក់ចំណូលតែម្នាក់ និង ការលះបង់នូវគ្រឿងប្រណិតៗមួយចំនួន ទំនងមើលទៅជារឿងមួយដ៏ឆ្កួតលីលា ។ ប៉ុន្តែព្រះអម្ចាស់បានមានបន្ទូលប្រាប់ទៅអេសាយថា ៖

« ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា គំនិតយើងមិនមែនដូចជាគំនិតរបស់អ្នករាល់គ្នាទេ ឯផ្លូវរបស់អ្នករាល់គ្នាក៏មិនមែនជាផ្លូវរបស់យើងដែរ ។

« ត្បិតដែលផ្ទៃមេឃខ្ពស់ជាងផែនដីយ៉ាងណា នោះអស់ទាំងផ្លូវរបស់យើង ខ្ពស់ជាងផ្លូវរបស់អ្នក ហើយគំនិតរបស់យើង ក៏ខ្ពស់ជាងគំនិតរបស់អ្នករាល់គ្នាយ៉ាងនោះដែរ » (អេសាយ 55:8–9 ) ។

ការលះបង់គោលដៅខាងលោកិយ ដើម្បីធ្វើតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌សម្រាប់គ្រួសាររបស់យើងបានក្លាយទៅជាពរជ័យមួយដ៏រាបសានៅក្នុងជីវិតរបស់យើង ។

### ការប្រឈមមុខនឹងឧបសគ្គរួមគ្នា

យើងអាននៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញាថា អស់អ្នកដែល « យល់ព្រមគោរពតាមសេចក្ដីសញ្ញារបស់ខ្លួនដោយការបូជា. . .ត្រូវបានទទួលដោយ [ ព្រះអម្ចាស់ ] ហើយ ។

« ត្បិតយើងជាព្រះអម្ចាស់នឹងបណ្ដាលឲ្យពួកគេបង្កើតឡើងនូវគ្រប់ដើមឈើដែលមានផ្លែណាដែលបានដាំនៅលើដីល្អ គឺនៅក្បែរស្ទឹងសុទ្ធសាធ ដើម្បីឲ្យបង្កើតបានផ្លែវិសេសជាច្រើន » (គ. និង ស. 97:8–9) ។ កូនទាំងប្រាំរបស់យើងគឺជាផលផ្លែដ៏វិសេសរបស់យើង ។ ពួកគេពិតជាពរជ័យដ៏ធំធេងបំផុតរបស់យើង ។

លុះពេលវេលាជាច្រើនឆ្នាំបានកន្លងផុតទៅ



រូបថតបានទទួលសិទ្ធិអនុញ្ញាតពី វ៉ែលេ ហារ៉េន

ស្វាមីខ្ញុំ និង ខ្ញុំបានប្រឈមមុខនឹងឧបសគ្គជាច្រើននៅក្នុងជីវិតអាពាហ៍ពិពាហ៍របស់យើង ហើយដោយគិតពី អតីតកាល ខ្ញុំអាចនិយាយដោយស្មោះថា ខ្ញុំមានអំណរគុណចំពោះបញ្ហាទាំងនោះ ។ ព្រះអម្ចាស់ប្រទានពរយើងជាមួយនឹងការសាកល្បងដើម្បីធ្វើឲ្យយើងបានប្រសើរឡើងក្នុងនាមជាបុគ្គលម្នាក់ៗ និង ដើម្បីជួយយើងឲ្យងាកទៅរកទ្រង់ និង ដៃគូរបស់យើង ។

អាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធគឺជាសេចក្ដីសញ្ញានៃភាពតម្កើងឡើងដ៏អស្ចារ្យ ។ នៅពេលសេចក្ដីសញ្ញានេះត្រូវបានគោរក្សា វាដឹកនាំទៅរកកម្រិតដ៏ខ្ពស់បំផុតនៅក្នុងនគរសេឡេស្ទាល ឬជីវិតដ៏នៅអស់កល្បជានិច្ច មានន័យថាជាការរីកច្រើនអស់កល្បជានិច្ច ( សូមមើល គ. និង ស. 131:1–4) ។ ដោយសាររង្វាន់ដ៏អស្ចារ្យនេះ យើងគួររំពឹងទុកឲ្យអាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធពង្រឹងយើង ហើយផ្លាស់ប្ដូរនិស្ស័យរបស់យើង ។

អែលឌើរ ប្រ៊ូស សុី ហាហ្វេន សមាជិកចូលនិវត្តន៍នៃពួកចិតសិបនាក់ បានថ្លែងថា ៖ « យើងប្រហែលជាចាប់ផ្ដើមរៀបការដើម្បីមាន ភាពកក់ក្ដៅ ។ ប៉ុន្តែក្រោយមកបញ្ហាបានកើតមានឡើង ។ ប្រសិនបើយើងខិតខំព្យាយាមដោះស្រាយវា យើងនឹងមិនសុខស្រួលជានិច្ចនោះទេ ប៉ុន្តែយើងនឹងរីកចម្រើន ។ នៅទីបំផុតយើងនឹងពុំមែនគ្រាន់តែរៀបការសម្រាប់ភាពកក់ក្ដៅនោះទេ ប៉ុន្តែសម្រាប់សេចក្ដីអំណរ » ។[2]ការដោះស្រាយបញ្ហារបស់យើងរួមគ្នាពុំមែនជាភាពសុខស្រួលជានិច្ចនោះទេ ប៉ុន្តែវាពិតជានាំមកឲ្យយើងមាននូវសេចក្ដីអំណរ ។

## ការខិតខំ និង សេចក្ដីអំណរ

ការធ្វើជាម្ដាយម្នាក់គឺជាកិច្ចការដ៏លំបាកបំផុតដែលខ្ញុំពុំធ្លាប់ទ្រទ្រង់ពីមុនមក ។ ពីមុនពេលមានកូន ខ្ញុំបានគិតថា ភាពជាម្ដាយភាគច្រើន តែពុំមែនជានិច្ចកាលនោះទេ ជាកិច្ចការដែលពោរពេញដោយសេចក្ដីអំណរ—ដែលមានការលំបាកតែបន្តិចបន្តួចប៉ុណ្ណោះ ។ ប៉ុន្តែខ្ញុំបានដឹងថា វាគឺជារឿងផ្ទុយស្រឡះ ។ ដោយសារភាពជាដៃគូអស់កល្បជានិច្ចជាមួយនឹងស្វាមីរបស់ខ្ញុំ ភាពជាម្ដាយ និង អាពាហ៍ពិពាហ៍បានក្លាយជាកន្លែងដកពិសោធន៍មួយសម្រាប់ការប្រែក្លាយដូចជាព្រះវរបិតាសួគ៌ ។ ទំនួលខុសត្រូវនៃភាពជាឪពុកម្ដាយនៅក្នុងជីវិតនេះស្រដៀងគ្នាទៅនឹងកិច្ចការ និង ព្រះរាជបំណងរបស់ព្រះវរបិតាសួគ៌យើង « ដើម្បីនាំឲ្យមានអតមភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » ដែរ (ម៉ូសេ 1:39) ។ ការធ្វើជាភរិយា និង ជាម្ដាយម្នាក់តម្រូវឲ្យមានភាពអត់ធ្មត់ ភាពរឹងមាំ និង សេចក្ដីស្រឡាញ់ពីសួគ៌ា ។ ការធ្វើជាម្ដាយម្នាក់កំពុងជួយខ្ញុំឲ្យប្រែក្លាយកាន់តែដូចជាព្រះទាំងនិស្ស័យ បំណងប្រាថ្នា និង លទ្ធភាព ។

ការផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធបានប្រទានពរដល់ខ្ញុំ តាមរបៀបដែលខ្ញុំពុំធ្លាប់រំពឹងទុក ។ វាជាប្រភពនៃភាពរឹងមាំចំពោះខ្ញុំ និង ជាស្ថិរភាពដល់កូនចៅរបស់ខ្ញុំ ។ វាគឺជាតំណចងភ្ជាប់មួយទៅនឹងដូនតារបស់ខ្ញុំ ហើយប្រទានពរដល់ពួកគាត់ ពេលខ្ញុំធ្វើកិច្ចការព្រះវិហារបរិសុទ្ធសម្រាប់ពួកគាត់ ។ អាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធរបស់ខ្ញុំ គឺមានតម្លៃសមនឹងការលះបង់គ្រប់យ៉ាង ហើយខ្ញុំដឹងថា វានាំមកនូវពរជ័យដ៏ធំធេង ។ ■

*អ្នកនិពន្ធរស់នៅប្រទេស នូវ៉ែលសេឡង់ ។*

**កំណត់ចំណាំ**

1. ហ្វ្រេនសុីស វេបស្ទើរ ក្នុងអត្ថបទវិល្លាម អ័រ ផមម៉ើរ «Pioneers of Southern Utah» The Instructor, ខែ ឧសភា ឆ្នាំ 1944 ទំព័រ 217–18 ។
2. ប្រ៊ូស សុី ហាហ្វេន [illegible] [illegible]: [illegible] [illegible] [illegible] [illegible] [illegible] [illegible] [illegible] ( ឆ្នាំ 2005 ) ទំព័រ 13 ។

# សាំយ៉ូអែល

*« បទពិសោធន៍របស់ក្មេងប្រុសសាំយ៉ូអែល ពេលគាត់បានឆ្លើយតបនឹងការហៅរបស់ព្រះអម្ចាស់ គឺជារឿងបំផុសគំនិតដល់ខ្ញុំយ៉ាងខ្លាំង » ។ —ប្រធាន ថូម៉ាស អេស ម៉នសុន*[1]

ម្ដាយរបស់ខ្ញុំ ហាន់ណា ដោយគ្មានកូនក៏បានទៅព្រះវិហារបរិសុទ្ធ អធិស្ឋានសុំកូនប្រុសមួយដោយសច្ចាថានឹងថ្វាយគាត់ដល់ព្រះអម្ចាស់ ។ ព្រះបានឆ្លើយដល់ការអធិស្ឋានរបស់គាត់ ហើយគាត់ក៏កើតបានរូបខ្ញុំមក ។ កាលខ្ញុំនៅក្មេង គាត់បាននាំខ្ញុំទៅព្រះវិហារបរិសុទ្ធដើម្បីបម្រើទ្រង់ ។ នៅទីនោះមានអាចារ្យឈ្មោះ អេលី បានមើលថែ ហើយបង្រៀនដល់ខ្ញុំ ។[2]

កាលពីក្មេង មានយប់មួយ ខ្ញុំបានឮសំឡេងស្រែកហៅឈ្មោះខ្ញុំ ។ លើកទីបីខ្ញុំក៏បានទៅរកអេលី ប៉ុន្តែគាត់មិនបានហៅខ្ញុំទេ ។ គាត់បានថ្លែងថា ព្រះអម្ចាស់កំពុងហៅខ្ញុំ ។ ខ្ញុំបានធ្វើតាមការទូន្មានរបស់អេលី ពេលខ្ញុំឮឈ្មោះខ្ញុំជាលើកទីបួន ហើយក៏ឆ្លើយតបថា « សូមទ្រង់មានបន្ទូលមកចុះ ត្បិតទូលបង្គំជាអ្នកបម្រើទ្រង់ប្រុងស្ដាប់ហើយ » ។[3] ព្រះអម្ចាស់បានមានបន្ទូលមកកាន់ខ្ញុំ ហើយពេលខ្ញុំធំដឹងក្ដីឡើង នោះទ្រង់គង់នៅនឹងខ្ញុំ ។ ទ្រង់បានហៅខ្ញុំធ្វើជាព្យាការីរបស់ទ្រង់ ។

ពេលខ្ញុំមានវ័យចំណាស់ ខ្ញុំបានតែងតាំងពួកប្រុសរបស់ខ្ញុំឲ្យធ្វើជាចៅក្រមលើសាសន៍អ៊ីស្រាអែល ។ ពួកកូនប្រុសរបស់ខ្ញុំមានចិត្តទុច្ចរិត ដូច្នេះពួកចាស់ព្រឹទ្ធាចារ្យនៃអ៊ីស្រាអែលក៏ស្នើសុំឲ្យមានស្ដេចមួយអង្គ ។ ខ្ញុំបានព្រមានដល់ប្រជាជនពីគ្រោះថ្នាក់នៃការមានស្ដេច ប៉ុន្តែពួកគេនៅតែមានចិត្តមានះ ។ ព្រះអម្ចាស់បានបញ្ជាថា ខ្ញុំគួរ « ស្ដាប់តាមពាក្យគេ » ។[4]

ព្រះអម្ចាស់បានបញ្ជូនសូលមកឲ្យខ្ញុំ— « ដែលមានរូបឆោមល្អណាស់ »[5]—ហើយខ្ញុំបានចាក់ប្រេងតាំងគាត់ជា «អ្នកគ្រប់គ្រងលើពួកអ៊ីស្រាអែល » ។[6] គាត់បានក្លាយទៅជាស្ដេចរបស់ពួកគេ ។ ប៉ុន្តែ នៅពេលព្រះអម្ចាស់បញ្ជាសូលឲ្យបំផ្លាញពួកសាសន៍អាម៉ាលេក និង អ្វីទាំងអស់ដែលពួកគេមាន នោះគាត់មិនបានគោរពតាមទេ ។ គាត់បានទុកសត្វរបស់ពួកអាម៉ាលេក ហើយថ្វាយវាជាការបូជា ។ ខ្ញុំបានបង្រៀនសូលថា « ស្ដាប់បង្គាប់នោះវិសេសលើសជាងយញ្ញបូជា ហើយដែលផ្ទៀងត្រចៀក នោះក៏វិសេសជាខ្លាញ់នៃចៀមឈ្មោលទៅទៀត » ។[7]

ដោយសារការមិនគោរពតាមរបស់សូល ព្រះអម្ចាស់បានបញ្ជាខ្ញុំឲ្យចាក់ប្រេងតាំងស្ដេចថ្មីនៅក្នុងចំណោមពួកកូនប្រុសរបស់អ៊ីសាយ ។ អ៊ីសាយបានឲ្យកូនច្បងបង្អស់ទាំងពីរនាក់របស់គាត់ដើរនៅមុខខ្ញុំ ប៉ុន្តែព្រះអម្ចាស់មិនបានជ្រើសរើសពួកគេទេ ។[8] ព្រះអម្ចាស់បានបើកបង្ហាញដល់ខ្ញុំថា កូនប្រុសពៅឈ្មោះ ដាវីឌ គួរធ្វើជាស្ដេច ។ តាមមុខមាត់ ឬរូបរាង ពួកបងប្រុសរបស់ដាវីឌទំនងសមធ្វើជាស្ដេចជាង ប៉ុន្តែព្រះអម្ចាស់បានជ្រើសរើសក្មេងឃ្វាលចៀមម្នាក់នេះឲ្យដឹកនាំរាស្ត្រទ្រង់ ។ ខ្ញុំបានរៀនពីបទពិសោធន៍នេះថា « ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា កុំឲ្យមើលតែឫកពាខាងក្រៅ ឬកម្ពស់ខ្លួននោះឡើយ ត្បិតយើងមិនទទួលអ្នកនោះទេ ពីព្រោះព្រះទ្រង់មិនទតចំពោះសេចក្ដីដែលមនុស្សលោកពិចារណាមើលទេ » ។[9] ■

**កំណត់ចំណាំ**

1. ថូម៉ាស អេស ម៉នសុន « *The Priesthood in Action* » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1992 ទំព័រ 47 ។
2. សូមមើលសាំយ៉ូអែលទី 1 1–2 ។
3. សាំយ៉ូអែលទី 1 3:10 ។
4. សាំយ៉ូអែលទី 1 8:22 ។
5. សាំយ៉ូអែលទី 1 9:2 ។
6. សាំយ៉ូអែលទី 1 9:16 ។
7. សាំយ៉ូអែលទី 1 15:22 ។
8. សូមមើលសាំយ៉ូអែលទី 1 16:10 ។
9. សាំយ៉ូអែលទី 1 16:7 ។







*GOD APPEARS IN A NIGHT VISION TO THE BOY PROPHET SAMUEL* ដោយ ហារី អេនឌើរសិន *ISRAELITES DESIRE A KING* ដោយ ផល ម៉ាន សេចក្ដីលម្អិតដកស្រង់ចេញពី *SAMUEL INSTRUCTING SAUL* ដោយ ធេដ ហេននីងជើ រូបថតនៃរមូរក្រដាស ដោយ *FORPLAYDAY/ISTOCKPHOTO/ THINKSTOCK*

# ដង្វាយមួយភាគក្នុងដប់ និង ដង្វាយផ្សេងៗ



តាមរយៈការបង់ដង្វាយមួយភាគក្នុងដប់ និង ដង្វាយផ្សេងៗ កុមារអាចរៀនថា ព្រះអម្ចាស់រក្សាសេចក្ដីសន្យារបស់ទ្រង់ ។

ក្នុងអត្ថបទនៅទំព័រ 60–61 នៃលេខនេះ អែលឌើរ អាន់ថូនី ឌី ភើគីន នៃពួកចិតសិបនាក់ បានថ្លែងពីរបៀប ដែលការបង់ដង្វាយមួយភាគក្នុងដប់ពីមុនចំណាយប្រាក់កម្រៃរបស់លោកកាលពីនៅជាយុវវ័យ បានបង្រៀនលោកឲ្យបែងចែករវាងការចង់បាន និង សេចក្ដីត្រូវការ ។

អែលឌើរ ភើគីន ថ្លែងថា នៅពេលលោកគោរពតាមបទបញ្ញត្តិនេះ « សេចក្ដីជំនឿរបស់ខ្ញុំកាន់តែរឹងមាំ រួមទាំងបំណងប្រាថ្នារបស់ខ្ញុំ ដើម្បីគោរពតាមបទបញ្ញត្តិផ្សេងទៀតរបស់ [ ព្រះអម្ចាស់ ] ផងដែរ » ។ លោកបានអនុវត្តតាមគោលការណ៍មួយដែលបានបង្រៀននៅក្នុង*ដើម្បីកម្លាំងនៃយុវជន*៖ « ឥរិយាបថរបស់អ្នកគឺជារឿងដ៏សំខាន់នៅក្នុងការបង់ដង្វាយមួយភាគក្នុងដប់ ។ . . .ចូរបង់វាដោយស្មោះស្ម័គ្រជាមួយនឹងដួងចិត្តដែលពោរពេញដោយអំណរគុណ » ([ ឆ្នាំ 2011 ] ទំព័រ 38) ។

### យោបល់ទាំងឡាយសម្រាប់បង្រៀនយុវវ័យ

- ជារឿយៗ យុវវ័យអាចរៀនពីគំរូរបស់មនុស្សដទៃទៀត ។ សូមមើល « The Blessings of Tithing » (*Liahona,* ខែ មិនា ឆ្នាំ 2013 ទំព័រ 26 ) ដើម្បីអានពីមនុស្សប្រាំនាក់ដែលបានទទួលពរជ័យ ដោយសារពួកគេបានបង់ដង្វាយមួយភាគក្នុងដប់ ។ សូមពិភាក្សាពីរបៀបដែលដង្វាយមួយភាគក្នុងដប់បានប្រទានពរដល់គ្រួសាររបស់អ្នក ។ អ្នកក៏អាចនិយាយពីរបៀបដែលដែលដង្វាយមួយភាគក្នុងដប់ និង ដង្វាយផ្សេងៗបានប្រទានពរដល់សមាជិកសាសនាចក្រគ្រប់រូបផងដែរ ។
- សូមពិចារណាអានរួមគ្នានូវផ្នែកស្ដីពីដង្វាយមួយភាគក្នុងដប់ និង ដង្វាយផ្សេងៗ នៅក្នុង*ដើម្បីកម្លាំងនៃយុវជន* ( ទំព័រ 38–39 ) ។ អ្នកអាចពិភាក្សាពីរបៀបដែលការតមអាហារ និង ដង្វាយតមអាហារមានទំនាក់ទំនងនឹងគ្នា និងពីរបៀបដែលគ្រួសាររបស់អ្នកបង់ដង្វាយតមអាហារ ។

### យោបល់ទាំងឡាយដើម្បីបង្រៀនកូនចៅ

- សូមពិចារណាប្រើនូវបទបង្ហាញដូចខាងក្រោមនេះ ៖ ដាក់កាក់ 10 នៅលើតុ ។ សួរសមាជិកគ្រួសារថាតើពួកគេមានអារម្មណ៍បែបណា ប្រសិនបើអ្នកនិយាយថា អ្នកនឹងឲ្យកាក់ប្រាំបួនដល់ពួកគេ ហើយអ្នកទុកកាក់តែមួយដើម្បីជួយស្ថាបនានគររបស់ព្រះអម្ចាស់ ។ តើពួកគេសុខចិត្តទទួលយកការផ្ដល់ឲ្យនោះដែរឬទេ ? បន្ទាប់មក អ្នកអាចពន្យល់ពីរឿងប្រៀបធៀបពីស្ថានភាពនេះ និង ច្បាប់ដង្វាយមួយភាគក្នុងដប់ ។
- អ្នកអាចប្រើផ្នែក « សម្រាប់កុមារតូចៗ » នៅក្នុង *Liahona,* ខែ សីហា ឆ្នាំ 2011 ( ទំព័រ 70–72 ) ដែលរួមមាននូវបទពិសោធន៍នៃជីវិតពិតមួយដែលក្មេងប្រុសម្នាក់រៀនថាការបង់ដង្វាយមួយភាគក្នុងដប់គឺជាការជ្រើសរើសមួយដ៏ល្អ—ទោះបីជាគាត់បានបរិច្ចាគតែប្រាក់មួយកាក់ក្ដី ។ អ្នកក៏បំពេញសកម្មភាពដែលពាក់ព័ន្ធជាមួយនឹងកូនៗរបស់អ្នកផងដែរ ។ ■

**បទគម្ពីរស្ដីពីប្រធានបទនេះ**

លេវីវិន័យ 27:30, 32
ចោទិយកថា 26:12
នេហេមា 10:38
ម៉ាឡាគី 3:8, 10សូមមើលផង
ដែរនីហ្វៃទី 3 24:8, 10
លូកា 18:12
អាលម៉ា 13:15
គោលលទ្ធិ និង សេចក្ដីសញ្ញា 64:23, 97:10–12, 119:3

*កំណែពីមុននៃ* Liahona *អាចរកបាននៅលើបណ្ដាញក្នុង* liahona.lds.org ។



*រាល់ប្រព័ន្ធផ្សព្វផ្សាយដែល ប្រើមានឥទ្ធិពលមួយមកលើ អ្នក ។ តើប្រព័ន្ធផ្សព្វផ្សាយដ៏ ជម្រើសរបស់អ្នកបានផ្ដល់ជា អត្ថប្រយោជន៍ ការតាំងចិត្ត និង ការបំផុសគំនិតដែរឬទេ ?*

# ប្រព័ន្ធផ្សព្វផ្សាយ រួមជាមួយនឹង គុណធម៌

**ដោយ ខាធើរីន ណេលសិន**

នៅពេល ដានីយ៉ែល, សាដ្រាក់, មែសាក់ និង អ័បេឌ-នេកោ ត្រូវបាននាំទៅគាល់ស្ដេចប៊ីក្មេសា នោះពួកគេត្រូវបរិភោគអាហារ ហើយផឹកស្រារបស់ស្ដេច ។ ប៉ុន្តែពួកគេបានសម្រេចចិត្តបរិភោគបន្លែ ( ម្ហូបធ្វើពីគ្រាប់ធញ្ញជាតិ ) ហើយផឹកទឹកជំនួសវិញ ។ លុះ 10 ថ្ងៃក្រោយមក « មុខគេបានស្រស់ជាង ហើយគេមានសាច់ល្អជាងពួកកម្លោះៗដែលបរិភោគអាហាររបស់ស្ដេចទៅទៀត ។ . . .[ ហើយ ] ព្រះទ្រង់ប្រទានឲ្យគេមានតំរិះ ហើយឲ្យបានឆ្លៀវឆ្លាតក្នុងគ្រប់ទាំងចំណេះ និង ប្រាជ្ញា ៖ ឯដានីយ៉ែល លោកក៏មានយោបល់ក្នុងអស់ទាំងការជាក់ស្តែង និង ការយល់សប្តិផង » (ដានីយ៉ែល 1:15, 17) ។

ទោះជាយើងប្រើដំណើររឿងនេះដើម្បីចង្អុលបង្ហាញពីគោលការណ៍សំខាន់ស្ដីពីពាក្យសម្ដីនៃប្រាជ្ញាវាងវៃ និង អាហារដែលយើងបរិភោគ*ពិត* ជាញឹកញាប់ក្ដី ប៉ុន្តែវាក៏បង្រៀនយើងពីគោលការណ៍ផ្សេងទៀតស្ដីពីអ្វីដែលយើងប្រើប្រាស់*ដោយការប្រៀបធៀប*ផងដែរ ។ នេះរួមបញ្ចូលទាំងប្រព័ន្ធផ្សព្វផ្សាយដែលយើងប្រើសម្រាប់ការកម្សាន្ត—ជាអ្វីៗទាំងអស់រាប់តាំងពីសិល្បៈ សៀវភៅ របាំ និង តន្ត្រី រហូតដល់ប្រព័ន្ធផ្សព្វផ្សាយខាងឌីជីថល និង ខាងសង្គម ។ ដូចជាដានីយ៉ែល និង មិត្តរបស់គាត់បានធ្វើការសម្រេចចិត្តមួយដោយចេតនាដើម្បីជៀសវាងពីអាហារដែលឥតប្រយោជន៍ ដែលមិនបានផ្ដល់ឲ្យពួកគេនូវការចិញ្ចឹមបីបាច់ដែលពួកគេត្រូវការ—ហើយអាចនឹងធ្វើឲ្យពួកគេបែកអារម្មណ៍ពីការបំពាក់បំប៉ន នៅក្នុងដំណាក់របស់ស្ដេច—ដូច្នេះយើងត្រូវចេះវិនិច្ឆ័យល្អនៅក្នុងជ្រើសរើសការកម្សាន្តដែលល្អ ( សូមមើល គ. និង ស. 25:10 ) ។

យោបល់ដូចតទៅនេះអាចជួយយើងឲ្យជ្រើសរើសការកម្សាន្តដែលមានតម្លៃសក្តិសមនឹងពេលវេលារបស់យើងនៅក្នុងជីវិតសាកល្បងនេះ ។



**ជៀសវាងគំនិតផ្ដេសផ្ដាស**

យើងងាកទៅរកការកម្សាន្តដើម្បីរំសាយចិត្តពីកង្វល់ប្រចាំថ្ងៃ ។ វាអាចជាពេលវេលាមួយដើម្បីសម្រាក ហើយចែកចាយសំណើច និង ការពិភាក្សាល្អជាមួយនឹងគ្រួសារ និង មិត្តភក្តិ ។[1] ការធ្វើឲ្យចិត្តស្រស់បស់ដែលយើងបានទទួលពីសកម្មភាពទាំងនេះ កើតចេញមកពីព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធដែលផលផ្លែរបស់ទ្រង់គឺជា « សេចក្ដីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត [ ហើយ ] ដឹងខ្នាត » (កាឡាទី 5:22–23) ។ ដើម្បីមានអារម្មណ៍ស្រស់បស់ជាថ្មីបន្ទាប់ពីការកម្សាន្តរបស់យើង យើងត្រូវជ្រើសការកម្សាន្តដែលរក្សាយើងឲ្យងាកទៅរកការបំផុសគំនិត និង ព្រះចេស្ដានៃការព្យាបាលពីព្រះវិញ្ញាណបរិសុទ្ធ ។

ដើម្បីជៀសវាងពីការបាត់បង់នូវភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ និង ការបំផ្លាញដល់វិញ្ញាណរបស់យើង នោះយើងត្រូវបានទូន្មានមិនឲ្យ « ចូលរួមមើល ឬប្រឡូកនៅក្នុងអ្វីដែលអាក្រក់ អសីលធម៌ ហិង្សា ឬអាសគ្រាម ទោះតាមវិធីណាមួយក៏ដោយ » ។[2]ប៉ុន្តែពេលខ្លះប្រព័ន្ធផ្សព្វផ្សាយដែល ជាគ្មានរឿងអសីលធម៌ ក៏អាចមានរឿងដ៏គ្រោះថ្នាក់ផងដែរ ដោយអូសទាញយើងចេញពីគោលបំណងរបស់យើងនៅក្នុងជីវិត ។

ខណៈដែលការកម្សាន្តល្អអាចជួយយើងឲ្យមានអារម្មណ៍រីករាយ នោះការកម្សាន្តតាមទម្រង់ផ្សេងទៀតអាចនាំយើងឲ្យមានគំនិតផ្ដេសផ្ដាស ។ ក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ព្រះអម្ចាស់បានបញ្ជាយើងថា ៖ « ចូរឈប់ពីសម្ដីអសារឥតការទាំងអស់របស់អ្នក ពីសំណើចទាំងអស់ ពីសេចក្ដីប៉ងប្រាថ្នាដ៏ស្រើបស្រាលទាំងអស់របស់អ្នក [ និង ] ពីសេចក្ដីឆ្មើងឆ្មៃ និង គំនិតផ្ដេសផ្ដាសទាំងអស់របស់អ្នក » ( 88:121 ) ។ ការកម្សាន្តខ្លះអូសទាញយើងចេញពីគោលបំណងនៃផែនការសង្គ្រោះ ដោយបំពេញគំនិតរបស់យើងនូវអ្វីដែលអែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានរៀបរាប់ថាជាគំនិតខ្ជិលច្រអូស និង ជារឿងឥតប្រយោជន៍ ។[3]ការកម្សាន្តផ្ដេសផ្ដាសបែបនេះអាចធ្វើឲ្យយើងជាប់អន្ទាក់មួយយ៉ាងឆាប់រហ័ស ហើយក្លាយជា « ការខ្វះគារវភាពដោយចេតនាដែលធ្វើឲ្យរឿងពិសិដ្ឋបាត់បង់តម្លៃ ហើយអាក្រក់ជាងនេះទៀត វាបានក្លាយជាការប្រមាថដល់រឿងពិសិដ្ឋ និង ពាក្យត្មះតិះដៀល » ។[4]



**ធ្វើជាភ្នាក់ងារម្នាក់ដ៏សកម្ម**

ទោះបីវាជាការងាយស្រួលដែលអនុញ្ញាតឲ្យការកម្សាន្តដែលយើងស្ដាប់ មើល និង អានចូលទៅក្នុងដួងចិត្ត និង គំនិតរបស់យើងដោយមិនបានត្រួតពិនិត្យមើលក្ដី វាជាផ្នែកមួយដ៏សំខាន់នៃជីវិតដើម្បីរៀនធ្វើជាភ្នាក់ងារ—ដើម្បីរៀន « ដើម្បីធ្វើសកម្មភាពដោយ [ ខ្លួនឯង ] ហើយពុំមែនទទួលសកម្មភាពទេ » (នីហ្វៃទី 2 2:26) ។ ផ្នែកនៃការក្លាយជាភ្នាក់ងារដ៏ពិតម្នាក់គឺការមានភាពឈ្លាសវៃចំពោះការកម្សាន្តដែលយើងប្រើប្រាស់ ។

ផ្ទុយពីការប្រើប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការកម្សាន្តដោយខ្វះការគិតពិចារណា នោះយើងត្រូវដឹងជាមុនពីរយៈពេលដែលយើងត្រូវចំណាយជាមួយវា និង សារលិខិតអ្វីខ្លះ—ទោះជារឿងជាក់ច្បាស់ ឬបំលែង—វានឹងផ្ញើចេញទៅ ។ រ៉ាយអិន ហូមស៍ នាយកនៃក្រុមប្រព័ន្ធផ្សព្វផ្សាយផ្នែកឌីជីថល នៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ ពន្យល់ថា យើងត្រូវធ្វើ « ការប្រើបច្ចេកវិទ្យាដោយគិតទុកជាមុន » ហើយធ្វើការពិចារណាដោយប្រុងប្រយ័ត្នពី « រាល់លទ្ធផលរបស់

រូបថតដោយ CIENPIES DESIGN/SHUTTERSTOCK

វា » ។[5]អេមី ភីធើរសិន ជេនសិន ប្រធាននាយកដ្ឋានមហោស្រពសិល្បៈ និងប្រព័ន្ធផ្សព្វផ្សាយ នៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់ បានថ្លែងថា វាជាការចាំបាច់ដើម្បី « ជ្រើសរើសចូលរួមចំណែកនៅក្នុងការសន្ទនាក្នុងប្រព័ន្ធផ្សព្វផ្សាយដែលសកម្ម ហើយ ជៀសវាងការប្រើប្រព័ន្ធផ្សព្វផ្សាយដែលអកម្ម » ។[6]

### ចំណាយពេលវេលាដោយឈ្លាសវៃ

ផ្នែកនៃការធ្វើជាភ្នាក់ងារម្នាក់កាន់តែសកម្ម គឺជាការចេះគិតទុកជាមុនចំពោះពេលវេលាដែលយើងចំណាយលើការកម្សាន្ត ។ ដោយព្រោះតែមានជម្រើសជាច្រើនមុខ នោះវាងាយដើម្បីទម្រេតខ្លួនទៅលើ « អ្វីៗដែលអ្នកបានឃើញដូចជាតាមសារ អ៊ីម៉ែល ទិន្នន័យព័ត៌មានថ្មី វីដេអូលើបណ្ដាញ និង ការជូនដំណឹងនានា » ។[7] ប៉ុន្តែពេលយើងធ្វើដូច្នេះ យើងខាតបង់ « ពេលវេលានៃការសាកល្បង [ របស់យើង ] » (នីហ្វៃទី 2 9:27) ជាមួយនឹងសកម្មភាពដែលឥតប្រយោជន៍ដែលមិនបានជួយឲ្យក្លាយជាអ្នកតំណាងរបស់ព្រះយេស៊ូវគ្រីស្ទដ៏រឹងមាំ ឈ្លាសវៃ ហើយមានចិត្តសប្បុរសឡើយ ។

ជំនួសឲ្យការខាតពេលពេញមួយល្ងាចមើលវីដេអូ កម្មវិធីថ្មី ឬ ស្ថានភាពថ្មី យើងអាចចំណាយពេលដើម្បីរីករាយនឹងការកម្សាន្ត ដែលមានអត្ថន័យដែលធ្វើឲ្យយើងមានអារម្មណ៍ស្រស់បស់ជាថ្មី ។ បងប្រុស ហូមស៍ បានថ្លែងថា « សូមធ្វើការជ្រើសរើសដោយគិតពិចារណា ។ អ្នកសម្រេចចិត្តពីអ្វី ពេលណា និងរបៀបដែលអ្នកនឹងប្រើគ្រឿងឌីជីថល » ។[8]

### ជ្រើសរើសប្រព័ន្ធផ្សព្វផ្សាយដែលលើកតម្កើង

ផ្នែកសំខាន់មួយទៀតនៃការជ្រើសរើសដ៏ប្រុងប្រយ័ត្នចំពោះការកម្សាន្តរបស់យើង គឺការប្រុងប្រយ័ត្នចំពោះសារដែលប្រព័ន្ធផ្សព្វផ្សាយនឹងផ្ញើមក ។

រាល់ទម្រង់នៃការកម្សាន្តមានជាក់ទាក់ទងនឹងអ្វីមួយ មិនថាសាររបស់វាធ្វើឡើងដោយចេតនា ឬក៏អត់នោះទេ ។ ឧទាហរណ៍ ខណៈដែលកំពុងរីករាយនឹងខ្សែភាពយន្ត ឬ សៀវភៅមួយ សូមសួរខ្លួនឯងថា តើសារអ្វីខ្លះដែលវាបានផ្ដល់ឲ្យអ្នកតាមរយៈនិមិត្តរូប តួអង្គ អត្ថបទចម្រៀង និងរូបភាពរបស់វា ។ តើវាមានតម្លៃអ្វីខ្លះ ? តើវាគាំទ្រនូវឥរិយាបថអ្វីខ្លះ ? សំខាន់ជាងគេ តើវាជួយអ្នកឲ្យគិត ហើយ មានគារវភាពដល់ព្រះយេស៊ូវគ្រីស្ទដែរឬទេ ? តើវាជួយអ្នកឲ្យយល់ពីទេវភាពរបស់ទ្រង់ដែរឬទេ ? តើវាបង្រៀនអ្នកនូវអ្វីមួយស្ដីពីការលះបង់ដែរទេ? ពីសេចក្ដីស្រឡាញ់ឬ ? ពីភាពមិនអត្មានិយមឬទេ? តើវាបានថ្លែងនូវអ្វីមួយស្ដីពីសារៈសំខាន់នៃក្រុមគ្រួសារ ឬ ពីបរិសុទ្ធភាពនៃអាពាហ៍ពិពាហ៍ដែរទេ ? ប្រសិនបើអ្នកអាចប្រមែប្រមូលនូវសេចក្ដីពិតមួយចំនួន ទាក់ទងទៅនឹងដំណឹងល្អនៅក្នុងសារកម្សាន្តរបស់អ្នកទេ នោះវាគ្មានតម្លៃ ហើយមិនសក្ដិសមនឹងពេលវេលារបស់អ្នកឡើយ ។

មនុស្សមួយចំនួនអាចត្រូវបានល្បួងឲ្យនិយាយថា « វាគ្រាន់តែជាការកម្សាន្ត—ពុំមែនជាសាលា ឬជាព្រះវិហារនោះទេ ។ ខ្ញុំពុំចាំបាច់ត្រូវរៀនអ្វីមួយពីវាឡើយ » ។ ប៉ុន្តែមិនថាអ្នកបានគិតពីវាទុកជាមុន ឬក៏អត់នោះទេ « អ្វីក៏ដោយដែលអ្នកអាន ស្ដាប់ ឬសម្លឹងមើលមានឥទ្ធិពលមួយមកលើអ្នក » ។[9]

ពេលយើងធ្វើឲ្យគំនិត និង ចិត្តរបស់យើងប្រឡូកនៅក្នុងការវាយតម្លៃចំពោះប្រព័ន្ធផ្សព្វផ្សាយដែលយើងប្រើ នោះយើងមានពេលដើម្បីសញ្ជឹងគិត ។ សាស្ត្រាចារ្យ ជេនសិន បានហៅគ្រាទាំងនេះថា « ការសន្ទនា » ៖ « ជាការផ្លាស់ប្ដូរមួយ—ជាការប្រាស្រ័យទាក់ទងនឹងអ្វីដែលយើងស្ដាប់ ហើយអនុវត្តតប ។ ជារឿយៗ ការសន្ទនាដ៏ល្អបំផុតដែលយើងមានបានក្លាយជាគ្រានៃការប្រែចិត្តដ៏ស្ងៀមស្ងាត់ ដោយសារស្ថិត នៅក្នុងការសន្ទនាទាំងនោះហើយដែលយើងផ្លាស់ប្ដូរគំនិត រកឃើញផ្លូវថ្មីមួយ ឬសម្រេចចិត្តធ្វើរឿងដែលប្រសើរជាង ។ ជាទូទៅ ការផ្លាស់ប្ដូរដែលយើងធ្វើចំពោះព្រលឹងរបស់យើងនៅក្នុងគ្រាទាំងនេះ វាមានលក្ខណៈតូច សាមញ្ញ ល្ងង់លោម ហើយមានប្រយោជន៍ »[10]

យើងស្វែងរក « អ្វីណាមួយដែលប្រកបដោយគុណធម៌ គួរស្រឡាញ់ ឬ ឈ្មោះល្អ ឬក៏គួរឲ្យសរសើរ »—សូម្បីតែនៅក្នុងពេលទំនេររបស់យើងក៏ដោយ (មាត្រានៃសេចក្ដីជំនឿ) ។ ក្នុងនាមជាអ្នកតំណាងឲ្យព្រះយេស៊ូវគ្រីស្ទយើងត្រូវប្រកាសថា « អ្វីគ្រប់យ៉ាងដែល [ យើង ]អាន ឬ [ មើល ] . . .បង្រៀនពីអ្វីមួយល្អ ឬស្ថាបនាអ្វីមួយល្អនៅក្នុង [ ខ្លួនយើង ] ឬ [ ក្រុមគ្រួសាររបស់យើង ] » ។ សកម្មភាពរបស់យើងជាមួយការកម្សាន្តគប្បីជា « សកម្មភាពដែលមានគោលបំណងច្បាស់លាស់ ហើយបរិសុទ្ធ. . .ដែល [ ជួយយើង ]ឲ្យទទួលបាន ហើយចែកចាយនូវទស្សនវិស័យរបស់ព្រះវរបិតាសួគ៌យើង » ។[11]

យើងដឹងថា ការកម្សាន្តដែលប្រកបដោយគុណធម៌ គួរឲ្យស្រឡាញ់ ហើយគួរឲ្យសរសើរបែបនេះ—ប្រព័ន្ធផ្សព្វផ្សាយដែលមានគុណធម៌—លើកតម្កើងយើង រៀបចំយើងសម្រាប់ឧបសគ្គក្នុងជីវិត ហើយពង្រឹងភាពជាសិស្សរបស់យើង ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា.* ។

**កំណត់ចំណាំ**

1. សូមមើល « The Family: A Proclamation to the World » Liahona, ខែវិច្ឆិកា ឆ្នាំ 2010 ទំព័រ 129 ដែលរៀបរាប់ពី « សកម្មភាពកម្សាន្តល្អៗ » ជាគោលការណ៍មួយដែលស្ថាបនាគ្រួសារមួយដ៏រីករាយ ។
2. *ដើម្បីកម្លាំងនៃយុវជន* ( ឆ្នាំ 2011 ) ទំព័រ 11។
3. សូមមើល ដាល្លិន អេក អូក « Powerful Ideas » Ensign, ខែ វិច្ឆិកា ឆ្នាំ 1995 ទំព័រ 27 ។
4. ប្រាដ វិលខុក « If We Can Laugh at It, We Can Live with It » Ensign, ខែ មិនា ឆ្នាំ 2000 ទំព័រ 29 ។
5. រ៉ាយអិន ហូមស៍ « The Truth of All Things » ( Brigham Young University devotional ថ្ងៃទី 7 ខែ ឧសភា ឆ្នាំ 2013 ) speeches.byu.edu ។
6. អេមី ភីធើរសិន ជេនសិន « Some Hopeful Words on Media and Agency » ( Brigham Young University devotional ថ្ងៃទី 20 ខែ មិនា ឆ្នាំ 2012 ) speeches.byu.edu ។
7. ហូមស៍ « The Truth of All Things » speeches.byu.edu ។
8. ហូមស៍ « The Truth of All Things » speeches.byu.edu ។
9. *ដើម្បីកម្លាំងនៃយុវជន* ទំព័រ 11 ។
10. ជេនសិន « Media and Agency » speeches.byu.edu ។
11. ជេនសិន « Media and Agency » speeches.byu.edu ។

# ការធ្វើជាឪពុកម្ដាយ បិទគ្រឿងអេឡិចត្រូនិច

ដោយ ជេន ភិនឃ្យូ
ទស្សនាវដ្ដីសាសនាចក្រ



ព្រះអង្គសង្គ្រោះបានមានបន្ទូលនូវពាក្យដ៏សាមញ្ញបួនម៉ាត់ថា ៖ « មើលកូនតូចរបស់អ្នករាល់គ្នា » ។ សាសន៍នីហ្វៃបានងាកមុខទៅរកកូនរបស់ខ្លួន ។ និងអ្វីដែលបានកើតឡើងតាមក្រោយ នៅក្នុងចំណោមព្រឹត្តិការណ៍ដ៏ពិសិដ្ឋបំផុតនៅក្នុងព្រះគម្ពីរ ។ ( សូមមើលនីហ្វៃទី 3 17:23–24 ) ។

ដំបូងឡើយ ខ្ញុំបានជួបនឹង « ការមើលឃើញ » ពេលកូនស្រីដំបូងរបស់ខ្ញុំបានកើតមក ។ គាត់បានយំ ជាការទួញយំដែលធ្វើឲ្យខ្ញុំភ្ញាក់ឡើងប្រហែលពាក់កណ្ដាលអាធ្រាត្រ ហើយវាបានកើតឡើងនៅពេលខ្ញុំរៀបនឹងបំបៅគាត់ នៅពេលដែលរឿងមួយ បានកើតឡើង ។ គាត់បានបើកភ្នែកធំៗ ហើយបានសម្លឹងមើលមុខចំនឹងភ្នែកខ្ញុំយ៉ាងយូរ ។ ពេលគាត់ និងខ្ញុំ « បានឃើញ » គ្នាទៅវិញទៅមកជាលើកដំបូង ខ្ញុំមានអារម្មណ៍ពីអ្វីមួយស្ដីពីចំណងអស់កល្បជានិច្ចដែលយើងមាន ។

ការសិក្សាខាងប្រសាទជីវវិទ្យាបានបញ្ជាក់ពីសារៈសំខាន់នៃ « ការមើលឃើញ» រវាងកុមារ និង ឪពុកម្ដាយ ។ យោងតាមវេជ្ជបណ្ឌិត អាឡាន់ អិន ស្គ័រ អ្នកឯកទេសខាងប្រសាទជីវវិទ្យា ទំនាក់ទំនង ដោយមិនប្រើពាក្យសម្ដីនៃ « ការសម្លឹងគ្នាទៅវិញទៅមក » គឺជាកត្តាដ៏ចាំបាច់ចំពោះការអភិវឌ្ឍដ៏ត្រឹមត្រូវដល់ខួរក្បាលទារក ។[1] លុះច្រើនឆ្នាំក្រោយមកទៀត ការតភ្ជាប់នេះនៅតែមានសារៈសំខាន់ចំពោះការអភិវឌ្ឍចិត្ត គំនិត និង វិញ្ញាណរបស់កូនចៅយើងដែលកំពុងចម្រើនវ័យ ។

« ការមើល » គឺពុំមែនការចោលកន្ទុយភ្នែកធម្មតានោះទេ ។ វាគឺជាទង្វើនៃការការយកចិត្តទុកដាក់ទាំងចិត្តនឹងគំនិតជាមួយមនុស្សម្នាក់ទៀត ។ វាជាការផ្ដល់នូវការយកចិត្តទុកដាក់ដែលប្រាប់ថា « ខ្ញុំមើលអ្នកឃើញ ។ អ្នកជាមនុស្សសំខាន់ចំពោះខ្ញុំ » ។

ចំពោះឪពុកម្ដាយសព្វថ្ងៃនេះ ជារឿយៗការមើលបែបនេះតម្រូវឲ្យមានការតាំងចិត្តដើម្បីដកចេញ ជាជម្រើសខាងសតិសម្បជញ្ញៈមួយដើម្បីបែរភ្នែកចេញពីកញ្ចក់អេក្រង់របស់យើង ហើយបិទឧបករណ៍ឌីជីថលរបស់យើង ។ វាអាចមានន័យថា ការតតាំងនឹងការល្បួងឲ្យមើលសាររបស់យើង ឬរំកិលមើលការដាក់ព័ត៌មាននៅក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម ។ វាប្រហែលជាទាក់ទងនឹងការបង្កើតវិន័យផ្ទាល់ខ្លួន និង ជាគ្រួសារស្ដីពីប្រព័ន្ធផ្សព្វផ្សាយដោយស្ថាបនាកំហិតដែលនឹងការពារព្រំដែនដែលនឹងការពារពេលវេលាដ៏ពិសិដ្ឋដែលយើងផ្ដល់ឲ្យគ្នាទៅវិញទៅមកជាប្រចាំនៅក្នុងក្រុមគ្រួសាររបស់យើង ។

ដោយការព្យាយាមមើលកូនតូចរបស់យើងឲ្យបានពេញលេញ ហើយញឹកញាប់ នោះយើងនឹងចិញ្ចឹមនូវអារម្មណ៍នៃតម្លៃរបស់កូនយើង កែលម្អទំនាក់ទំនងរបស់យើងជាមួយនឹងគ្នា ហើយរីករាយនឹងពេលដ៏ពិសិដ្ឋទាំងនោះកាន់តែច្រើន ពេលយើងមើលទៅក្នុងដួងចិត្តរបស់កូនយើង ។ ■



រូបថតដោយ ដារ៉េន ស្លូវ

**កំណត់ចំណាំ**

1. សូមមើល « Relational trauma and the developing right brain: The neurobiology of broken attachment bonds » នៅក្នុងកំណែរបស់ តេស្សា បារ៉ាឌុន Relational Trauma in Infancy ( ឆ្នាំ 2010 ) ទំព័រ 19–47 ។

## ការផ្ដាច់ចេញ ហើយស្ដាប់ដោយសេចក្ដីស្រឡាញ់

« ចម្លើយចំពោះការអធិស្ឋានរបស់យើងស្ដីពីរបៀបដើម្បីបំពេញសេចក្ដីត្រូវការរបស់កូនចៅយើង ប្រហែលជាត្រូវផ្ដាច់ចេញខាងផ្នែកបច្ចេកវិទ្យាឲ្យបានញឹកញាប់ ។ ឱកាសដ៏មានតម្លៃដើម្បីកម្សាន្ត ហើយប្រាស្រ័យទាក់ទងជាមួយនឹងកូនចៅយើងនឹងរលាយបាត់ ពេលយើងផ្ដេកផ្ដួលខ្លួនចំពោះការរំខានទាំងឡាយ ។ ហេតុអ្វីបានជាមិនជ្រើសយកពេលមួយជារៀងរាល់ថ្ងៃដើម្បីផ្ដាច់ចេញពីបច្ចេកវិទ្យា ហើយតភ្ជាប់ឡើងវិញជាមួយនឹងគ្នា ? គ្រាន់តែបិទអ្វីៗទាំងអស់ចោល ។ ពេលអ្នកធ្វើបែបនេះ ផ្ទះរបស់យើងអាចទំនងជាមានភាពស្ងប់ស្ងាត់ពីដំបូង អ្នកប្រហែលជាមានអារម្មណ៍ថាគ្មានអ្វីធ្វើ ឬគ្មានអ្វីនិយាយថែមទៀតផង ។ បន្ទាប់មក ពេលអ្នកផ្ដល់ការយកចិត្តទុកដាក់ពេញលេញដល់កូនរបស់យើង នោះការសន្ទនាមួយនឹងចាប់ផ្ដើមមាន ហើយអ្នកនឹងអាចរីករាយស្ដាប់គ្នាទៅវិញទៅមក » ។

**រ៉ូសម៉ារី អិម វិកសូម ប្រធានអង្គការបឋមសិក្សាទូទៅ « The Words We Speak » Liahona, ខែ ឧសភា ឆ្នាំ 2013 ទំព័រ 82 ។**



**ដោយ លីនដា ខេ បើតុន**
ប្រធានសមាគមសង្គ្រោះទូទៅ

# អំណាចបព្វជិតភាព





## មានសម្រាប់មនុស្សគ្រប់គ្នា

*អ្នកដឹកនាំបព្វជិតភាពត្រូវបានផ្ដល់ឲ្យដោយការតែងតាំង ប៉ុន្តែអំណាចបព្វជិតភាពគឺមានសម្រាប់មនុស្សគ្រប់គ្នា ។ សេចក្ដីសុចរិតគឺជាគុណសម្បត្តិសម្រាប់យើងម្នាក់ៗ ដើម្បីអញ្ជើញអំណាចបព្វជិតភាពចូលមកក្នុងជីវិតរបស់យើង ។*

យើងមានអភ័យឯកសិទ្ធិដើម្បីរស់នៅក្នុងគ្រានេះនៃប្រវត្តិសាស្ត្រសាសនាចក្រ ពេលដែលសំណួរទាំងឡាយត្រូវចោទសួរអំពីបព្វជិតភាព ។ មាននូវចំណាប់អារម្មណ៍ និង បំណងប្រាថ្នាដ៏អស្ចារ្យដើម្បីស្គាល់ ហើយយល់បន្ថែមទៀតស្ដីពីសិទ្ធិអំណាច អំណាច និង ពរជ័យដែលមានជាមួយនឹងបព្វជិតភាពនៃព្រះ ។ វាជាសេចក្ដីសង្ឃឹមរបស់ខ្ញុំថា គោលលទ្ធិនៃបព្វជិតភាពនេះនឹង « *ចុះ*មកលើ [ ព្រលឹងរបស់យើង ] ដូចជាទឹកសន្សើមចុះពីលើមេឃ » (គ. និង ស. 121:45 ការគូសបញ្ជាក់ត្រូវបានបន្ថែម) ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់កំពុងពន្លឿនកិច្ចការរបស់ទ្រង់ ហើយវាជាការសំខាន់ចំពោះយើងដើម្បីយល់ដឹងពីរបៀបដែលព្រះអម្ចាស់សម្រេចកិច្ចការរបស់ទ្រង់ ដើម្បីយើងអាចទទួលអំណាចដែលកើតចេញការអនុវត្តស្របតាមផែនការ និង ព្រះរាជបំណងរបស់ទ្រង់ ។

ព្រះអម្ចាស់តែងសម្រេចកិច្ចការរបស់ទ្រង់ ដែលជាការ « នាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » (ម៉ូសេ 1:39) តាមរយៈអំណាចនៃបព្វជិតភាពរបស់ទ្រង់ ។ តាមរយៈ

រចនារូបថតដោយ ជេ ហ្គាមស៍ លើកលែងតែបានកត់សម្គាល់។ ខាងស្ដាំ ៖ រចនារូបថត ដោយ ខូឌី បែល



អំណាចនេះស្ថានសួគ៌ និង ផែនដីត្រូវបានបង្កើតឡើង ។ តាមរយៈពិធីបរិសុទ្ធនៃបព្វជិតភាព ឥទ្ធិពលនៃការធ្លាក់ត្រូវបានយកឈ្នះ ដោយសារដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ដោយសារសិទ្ធិអំណាចនៃបព្វជិតភាពត្រូវបានប្រគល់ដល់មនុស្សដើម្បីប្រទានពរដល់កូនចៅរបស់ព្រះវរបិតាសួគ៌ នោះទ្រង់ចង់ឲ្យយើងអញ្ជើញអំណាចនៃបព្វជិតភាពនេះចូលទៅក្នុងផ្ទះរបស់យើង ដើម្បីប្រទានពរ ហើយពង្រឹងដល់ក្រុមគ្រួសាររបស់យើង និងជីវិតរបស់យើងម្នាក់ៗ ។

ក្នុងការបំពាក់បំប៉នថ្នាក់ដឹកនាំទូទាំងពិភពលោក ឆ្នាំ 2013 អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានថ្លែងយ៉ាងម៉ឺងម៉ាត់ថា ៖ « ពួកបុរសពុំមែនជាបព្វជិតភាពទេ ! »[1] ចំពោះខ្ញុំ ពាក្យនោះគឺជាការដាស់តឿនអារម្មណ៍ក៏ដូចជាការអញ្ជើញមួយដល់យើងទាំងអស់គ្នាឲ្យសិក្សា សញ្ជឹងគិត ហើយឲ្យមានការយល់ដឹងកាន់តែច្បាស់ថែមទៀតស្ដីពីបព្វជិតភាព ។ ប្រសិនបើមាននរណាម្នាក់ ប្រហែលជាកុមារម្នាក់ ឬមិត្តម្នាក់ដែលជាសមាជិកនៃសាសនាផ្សេង សួរអ្នកនូវសំណួរដូចតទៅនេះ តើអ្នកអាចឆ្លើយបានទេ ?

- តើបព្វជិតភាពគឺជាអ្វី ?
- ហេតុអ្វីបានជាបព្វជិតភាពសំខាន់ម្ល៉េះ ?
- តើកូនសោនៃបព្វជិតភាពគឺជាអ្វីទៅ ?
- តើនរណាកាន់កូនសោបព្វជិតភាព ?

**តើបព្វជិតភាពគឺជាអ្វី ?**

បព្វជិតភាពគឺជាអំណាច និង សិទ្ធិអំណាចអស់កល្បជានិច្ចរបស់ព្រះដែលទ្រង់បានប្រទានពរ ប្រោសលោះ ហើយលើកតម្កើងដល់កូនចៅទ្រង់ ។ អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ពីបព្វជិតភាពតាមរបៀបនេះថា ៖ « បព្វជិតភាពគឺជាមធ្យោបាយដែលព្រះអម្ចាស់ធ្វើកិច្ចការតាមរយៈមនុស្សដើម្បីសង្គ្រោះព្រលឹង ។ . . .អ្នកកាន់បព្វជិតភាពម្នាក់ត្រូវបានរំពឹងទុកឲ្យអនុវត្តសិទ្ធិអំណាចដ៏ពិសិដ្ឋនេះស្របតាមព្រះតំរិះ ព្រះហឫទ័យ និង ព្រះរាជបំណងដ៏បរិសុទ្ធរបស់ព្រះ ។ *បព្វជិតភាពគឺមិនគិតតែពីខ្លួនឯងនោះទេ ។ បព្វជិតភាពតែងតែត្រូវបានប្រើដើម្បីបម្រើ ប្រទានពរ ហើយពង្រឹងមនុស្សផ្សេងទៀត ។*»[2]

« គ្មានកិច្ចការណាមួយនៅក្នុងបព្វជិតភាពដែលផ្ដោតសំខាន់តែចំពោះខ្លួនឯងឡើយ ។ បព្វជិតភាពតែងត្រូវបានប្រើដើម្បីបម្រើ ប្រទានពរ ហើយពង្រឹងមនុស្សដទៃទៀត » ។

**អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់**



ពេលខ្ញុំបានសិក្សា សញ្ជឹងគិត ហើយស្វែងយល់ពីបព្វជិតភាព វាមានប្រយោជន៍ដើម្បីពិចារណាថា តើពិភពលោកនេះនឹងក្លាយទៅជាយ៉ាង *បើគ្មាន* បព្វជិតភាពនោះ ។ អែលឌើរ រ៉ូបឺត ឌី ហែល ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពន្យល់បន្ថែមទៀតពីគំនិតនេះ នៅពេលលោកបានថ្លែងថា ៖ « តើអ្នកស្រមៃឃើញថាជីវិតរមែងស្លាប់នេះនឹងមានភាពខ្មោងងឹង ហើយឥតន័យយ៉ាងណានោះទេ ប្រសិនបើគ្មានបព្វជិតភាពនោះ ? ប្រសិនបើគ្មានអំណាចបព្វជិតភាពនៅលើផែនដី នោះមារសត្រូវនឹងមានសេរីភាពដើម្បីរាតត្បាត ហើយគ្រងរាជ្យដោយគ្មានការរឹតបណ្ដឹង ។ វានឹងគ្មានអំណោយទានព្រះវិញ្ញាណបរិសុទ្ធដើម្បីដឹកនាំ ហើយបំភ្លឺយើងនោះទេ ។ គ្មានពួកព្យាការីដើម្បីថ្លែងនៅក្នុងព្រះនាមនៃព្រះអម្ចាស់ទេ ។ គ្មានព្រះវិហារបរិសុទ្ធដែលយើងអាចធ្វើសេចក្ដីសញ្ញាអស់កល្បជានិច្ចដ៏ពិសិដ្ឋឡើយ ។ គ្មានសិទ្ធិអំណាចដើម្បីប្រសិទ្ធពរ ឬជ្រមុជទឹក ព្យាបាល ឬ លួងលោមឡើយ ។ . . .វានឹងគ្មានពន្លឺ គ្មានសេចក្ដីសង្ឃឹម—គឺមានតែសេចក្ដីងងឹតប៉ុណ្ណោះ » ។[3]

គំនិតនៃការគ្មានអំណាចបព្វជិភាពគឺជារឿងសោកសៅ ។ ហេតុផលមួយដែលខ្ញុំក្រោកឈរឡើង ហើយរីករាយដោយសារអំណាចដ៏ពិសិដ្ឋនេះត្រូវបានស្ដារឡើងវិញនៅលើផែនដីនេះ តាមរយៈព្យាការីនៃព្រះនៅសម័យកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ចុងក្រោយដ៏រុងរឿងនេះ !

ប៉ុន្តែ អែលឌើរ អូក បានហាមយើងនៅក្នុងសេចក្ដីយោងរបស់យើងចំពោះបព្វជិតភាព ៖ « ពេលខ្លះខណៈដែលយើងគិតថាពួកអ្នកកាន់បព្វជិតភាពគឺជា ‹ បព្វជិតភាព › នោះមិនត្រូវភ្លេចថា បព្វជិតភាពពុំត្រូវបានកាន់កាប់ ឬ តំណាងឲ្យអ្នកដែលកាន់អំណាចនេះនោះទេ ។ អំណាចនេះត្រូវបានកាន់នៅក្នុង*ការទុកចិត្តដ៏ពិសិដ្ឋមួយដើម្បីប្រើសម្រាប់ជាប្រយោជន៍ដល់បុរស ស្ត្រី និង កុមារដូចគ្នា ។*»[4]

ខាងស្ដាំ ៖ រូបថតដោយ ដាន ខាធើរ

## ហេតុអ្វីបានជាបព្វជិតភាពសំខាន់ម្ល៉េះ ?

យើងដឹងថា « ផែនការនៃសុភមង្គលដ៏ទេវភាពនេះអាចធ្វើឲ្យទំនាក់ទំនងក្រុមគ្រួសារចេះតែបន្តមានរហូតហួសពីសេចក្តីស្លាប់ ។ ពីធីបរិសុទ្ធ និង សេចក្តីសញ្ញាពិសិដ្ឋនានា ដែលមាននៅក្នុងព្រះវិហារបរិសុទ្ធអាចធ្វើឱ្យបុគ្គលម្នាក់ៗ ត្រឡប់ទៅកាន់វត្តមាននៃព្រះវិញ ហើយធ្វើឲ្យក្រុមគ្រួសារអាចត្រូវបានរួមរស់នឹងគ្នាដ៏អស់កល្បជានិច្ច » ។[5] ដូចជា អែលឌើរ រ័សុល អិម ណិលសុន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា « សិទ្ធិអំណាចបព្វជិតភាពត្រូវបានស្តារឡើងវិញ ដើម្បីឲ្យក្រុមគ្រួសារអាចត្រូវបានផ្សារភ្ជាប់ដ៏នៅអស់កល្បជានិច្ច » ។[6]

« សិទ្ធិអំណាចបព្វជិតភាពត្រូវបានតម្រូវឲ្យធ្វើពិធីបរិសុទ្ធនៃដំណឹងល្អ ។ . . .ពិធីបរិសុទ្ធនីមួយៗបើកទ្វារសម្រាប់ពរខាងវិញ្ញាណដ៏ច្រើន » ។[7]ព្រះយេស៊ូវបានប្រគល់កូនសោដ៏ពិសិដ្ឋនៃព្រះនគរឲ្យពេត្រុស រួមជាមួយនឹងទំនួលខុសត្រូវថា « បើអ្នកនឹងចងទុកអ្វីៗនៅផែនដី នោះនឹងត្រូវចងទុកនៅលើស្ថានសួគ៌ដែរ ហើយបើអ្នកនឹងស្រាយអ្វីៗនៅផែនដី នោះនឹងត្រូវស្រាយនៅស្ថានសួគ៌ដែរ » (ម៉ាថាយ 16:19) ។

## តើកូនសោនៃបព្វជិតភាពគឺជាអ្វីទៅ ?

ការពន្យល់ដ៏សាមញ្ញមួយស្តីពីកូនសោនៃបព្វជិតភាពគឺមាននៅក្នុង ⌧⌧⌧ ⌧⌧⌧ ខែ ឧសភា ឆ្នាំ 2012 ៖

« ដោយមានកូនសោមួយសំណុំ នោះអ្នកអាចធ្វើកិច្ចការជាច្រើនដែលអ្នកមិនអាចធ្វើ—ដូចជា ការចូលទៅក្នុងអគារ បើកឡាន និងហឹបឡានខាងក្រោយក្នុងចំណោមកិច្ចការផ្សេងទៀតជាច្រើន ។ កូនសោមានន័យថា សិទ្ធិអំណាច និង សិទ្ធិចូលដំណើរការ ។

« រីឯកូនសោនៃបព្វជិតភាពក៏មានន័យដូចគ្នានេះដែរ ។ វាត្រួតពិនិត្យសិទ្ធិដើម្បីទទួលបានពរជ័យ និង ពិធីបរិសុទ្ធនៃបព្វជិតភាព ។ . . .កូនសោនៃបព្វជិតភាពគឺជាសិទ្ធិដើម្បីធ្វើជាអធិបតី ហើយដឹកនាំសាសនាចក្រ ។ . . .ជាទូទៅ កូនសោអនុវត្តចំពោះតំបន់ភូមិសាស្ត្រមួយ ដូចជាវួដ ស្តេក ឬបេសកកម្ម ។ ជាទូទៅ វាក៏រួមបញ្ចូលនូវសិទ្ធិអំណាចដើម្បីគ្រប់គ្រងលើពិធីបរិសុទ្ធ និង សកម្មភាពជាក់លាក់ផងដែរ ( ឧទាហរណ៍ ដូចជា បុណ្យជ្រមុជទឹក សាក្រាម៉ង់ កិច្ចការផ្សព្វផ្សាយសាសនា និង កិច្ចការព្រះវិហារបរិសុទ្ធ ) » ។[8]

## តើនរណាកាន់កូនសោបព្វជិតភាព ?

« ព្រះយេស៊ូវគ្រីស្ទបានកាន់កូនសោបព្វជិតភាពទាំងអស់សម្រាប់សាសនាចក្ររបស់ទ្រង់ ។ ទ្រង់បានប្រគល់ឲ្យពួកសាវករបស់ទ្រង់ម្នាក់ៗនូវរាល់កូនសោ ដែលមានសម្រាប់នគរព្រះនៅលើផែនដី ។ សាវកច្បងដែលនៅរស់ ជាប្រធានសាសនាចក្រ គឺជាបុគ្គលតែម្នាក់គត់នៅលើផែនដីដែលត្រូវបានផ្តល់សិទ្ធិអំណាចឲ្យដើម្បីអនុវត្តរាល់កូនសោបព្វជិតភាព ( សូមមើល គ. និង ស. 107:91–92 ) ។ . . .[ បន្ទាប់មក លោក ] បែងចែកកូនសោនៃបព្វជិតភាពទៅអ្នកដឹកនាំបព្វជិតភាពផ្សេងទៀត ដើម្បីពួកគាត់អាចធ្វើជាអធិបតីនៅក្នុងផ្នែកនៃទំនួលខុសត្រូវរបស់ខ្លួន ។ . . .ប្រធានអង្គការជំនួយ និង ទីប្រឹក្សាពួកគាត់ពុំមានកូនសោទេ ។ ពួកគាត់ទទួលបានការចែករំលែកសិទ្ធិអំណាចដើម្បីធ្វើការហៅរបស់ខ្លួន » ។[9]

ប៉ុន្តែមានភាពខុសគ្នាមួយរវាងសិទ្ធិអំណាចបព្វជិតភាព និង អំណាចបព្វជិតភាព ។ សិទ្ធិអំណាចបព្វជិតភាពត្រូវបានផ្តល់ឲ្យដោយការតែងតាំង ប៉ុន្តែអំណាចបព្វជិតភាពគឺមានសម្រាប់មនុស្សគ្រប់គ្នា ។ ដោយសារអំណាចបព្វជិតភាពគឺជាអ្វីមួយដែលយើងចង់បាននៅក្នុងក្រុមគ្រួសារ និង ផ្ទះរបស់យើង តើ*យើង*ត្រូវធ្វើអ្វីខ្លះដើម្បីនាំអំណាចនោះចូលមកក្នុងជីវិតរបស់យើងបាន ? សេចក្តីសុចរិតផ្ទាល់ខ្លួនគឺជាកត្តាដ៏សំខាន់ដើម្បីមានអំណាចបព្វជិតភាព ។

## ការយល់ដឹងពីគោលលទ្ធិនៃបព្វជិតភាព

ទីមួយ សូមព្យាយាមធ្វើឲ្យខ្លួនសក្តិសមនឹងអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ។ ដោយសារគោលលទ្ធិនៃបព្វជិតភាពត្រូវបានយល់ដឹងកាន់តែច្បាស់តាមរយៈវិវរណៈ នោះវាជាការចាំបាច់ដើម្បីមានជំនួយពីព្រះវិញ្ញាណបរិសុទ្ធដើម្បីបើកសម្តែង ហើយធ្វើឲ្យគោលលទ្ធិនេះបានបរិសុទ្ធសម្រាប់ព្រលឹងរបស់យើង ។

ទីពីរ ចូលរួមនៅក្នុងព្រះវិហារបរិសុទ្ធ ។ យើងដឹងថា ព្រះវិហារបរិសុទ្ធ « ជាទីកន្លែងដ៏បរិសុទ្ធបំផុតក្នុង



ចំណោមកន្លែងថ្វាយបង្គំទាំងអស់ » [10] ហើយវាផ្តល់បរិយាកាសដ៏ល្អ ដើម្បីរៀនពីបព្វជិតភាពតាមរយៈវិញ្ញាណនៃវិវរណៈ ។

ទីបី អានព្រះគម្ពីរ ។ ការស្រាវជ្រាវ ការសញ្ជឹងគិត និង ការសិក្សាព្រះគម្ពីរគឺជាការអញ្ជើញឲ្យព្រះវិហារបរិសុទ្ធបើកសម្តែងមកកាន់យើងនូវសេចក្តីពិតដ៏សំខាន់ស្តីពីបព្វជិតភាព ។ ខ្ញុំផ្តល់អនុសាសន៍នូវបទគម្ពីរដូចតទៅនេះដល់អ្នក ជាប្រយោជន៍ដល់ការពិចារណាដោយយកចិត្តទុកដាក់ និងពោរពេញដោយការអធិស្ឋាន ៖ គោលលទ្ធិ និង សេចក្តីសញ្ញា កណ្ឌ 13, 20, 84, 107 និង 121 និង អាលម៉ា 13 ។ បន្ទាប់មក ខ្ញុំសូមអញ្ជើញអ្នកឲ្យទន្ទេញនូវសម្បថ និង សេចក្តីសញ្ញានៃបព្វជិតភាព ដែលមាននៅក្នុងគោលលទ្ធិ និង សេចក្តីសញ្ញា 84:33–44 ។ តាមរយៈការធ្វើដូច្នេះ ខ្ញុំសូមសន្យានឹងអ្នកថា ព្រះវិញ្ញាណបរិសុទ្ធនឹងពង្រីកការយល់ដឹងរបស់អ្នក

ស្ដីពីបព្វជិតភាព ព្រមទាំងបំផុស ហើយលើកតម្កើងអ្នកតាមរបៀបដ៏អស្ចារ្យទាំងឡាយ ។

ខ្ញុំក៏សូមអញ្ជើញអ្នកឲ្យពិចារណានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា 121:34–46រួចសួរខ្លួនឯងនូវសំណួរទាំងនេះ ៖



- តើដួងចិត្តរបស់ខ្ញុំត្រូវបានដាក់ទៅលើរឿងនៃលោកិយនេះមែនទេ ?
- តើខ្ញុំបានបំផុសគំនិតឲ្យគោរពដល់បុរស ឬស្ត្រីដែរទេ ?
- តើខ្ញុំបានព្យាយាមបិទបាំងអំពើបាបរបស់ខ្ញុំដែរទេ ?
- តើខ្ញុំជាមនុស្សមានអំនួតដែរទេ ?
- តើខ្ញុំបានអនុវត្តការត្រួតត្រា ឬការគ្រប់គ្រង ឬការបង្ខំទៅលើកូន ភរិយា ឬអ្នកដទៃទៀតដែរទេ ?
- តើខ្ញុំកំពុងព្យាយាមអនុវត្តដោយស្មោះដើម្បីនឹងអនុវត្តគោលការណ៍សុចរិតដូចជាការល្អងលោម ភាពស្លូតបូត ការអត់ធ្មត់ ចិត្តល្អ ភាពទន់ភ្លន់ សេចក្ដីស្រឡាញ់ស្មោះត្រង់ ( មានន័យថាសេចក្ដីស្រឡាញ់ស្មោះពិត ឬចេញពីចិត្ត ) ដែរឬទេ ?
- តើគុណធម៌គ្រប់គ្រងគំនិតខ្ញុំឥតឈប់ឈរដែរឬទេ ?
- តើខ្ញុំចង់បានព្រះវិញ្ញាណបរិសុទ្ធធ្វើជាដៃគូដ៏ខ្ជាប់ខ្ជួនរបស់ខ្ញុំដែរទេ ?

ពាក្យថា *ការល្អងលោម ភាពស្លូតបូត ការអត់ធ្មត់ ចិត្តល្អ ភាពទន់ភ្លន់*និង *សេចក្ដីស្រឡាញ់ស្មោះត្រង់*បានបង្កើតអត្ថន័យផ្ទាល់ខ្លួនថ្មីមួយសម្រាប់ខ្ញុំ ពេលខ្ញុំរំឭកចាំពីការប្រសិទ្ធពរមួយដែលខ្ញុំសុំដល់ឪពុកខ្ញុំយូរឆ្នាំមកហើយ ។

កាលខ្ញុំនៅលីវ ខ្ញុំមានភាពស្មុគស្មាញយ៉ាងខ្លាំងក្នុងការសម្រេចចិត្តមួយ ។ ដូចដែលខ្ញុំធ្លាប់បានធ្វើជាច្រើនដង ខ្ញុំបានដើរសំដៅទៅរកឪពុកខ្ញុំ ហើយសុំការប្រសិទ្ធពររបស់ឪពុក ។ ដោយរំពឹងទុកថាគាត់នឹងធ្វើតាមសំណើរបស់ខ្ញុំភ្លាមៗ ខ្ញុំមានការភ្ញាក់ផ្អើលនៅពេលគាត់តបមកវិញថា « ប៉ាត្រូវការពេលខ្លះដើម្បីរៀបចំខ្លួនធ្វើការប្រសិទ្ធពរនេះដល់កូន ។ តើកូនអាចរង់ចាំពីរបីថ្ងៃទៀតបានទេ ? »

វាគួរឲ្យចាប់អារម្មណ៍ណាស់ 40 ឆ្នាំក្រោយមក ខ្ញុំបានភ្លេចពីអ្វីដែលគាត់បានថ្លែងនៅក្នុងការប្រសិទ្ធពររបស់ឪពុក ប៉ុន្តែខ្ញុំពុំដែលភ្លេចពីគារវភាពដ៏ប្រពៃដែលឪពុកខ្ញុំមានចំពោះបព្វជិតភាពបរិសុទ្ធ ពេលគាត់បានរៀបចំខ្លួនខាងវិញ្ញាណដើម្បីប្រកាសការប្រសិទ្ធពររបស់ឪពុកមកកាន់រូបខ្ញុំ ។ គាត់បានយល់ពីគោលការណ៍ដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា 121 ហើយគាត់បានតាំងចិត្តដើម្បីរស់នៅតាមគោលការណ៍ទាំងនោះ ដើម្បីមានគុណសម្បត្តិគ្រប់គ្រាន់នឹងទទួលបានអំណាចបព្វជិតភាពដើម្បីប្រទានពរដល់គ្រួសារគាត់ ។

## ប្រសាសន៍របស់ពួកព្យាការីនៅរស់

វាជាឯកសិទ្ធិរបស់ខ្ញុំដោយបានធ្វើការជាមួយពួកព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈដ៏បំផុសគំនិតស្ទើរតែរាល់ថ្ងៃ ។ ប្រសិនបើយើងពិតជាចង់ដឹងពីគោលលទ្ធិនៃបព្វជិតភាព យើងមានធនធានដ៏រឹងមាំ ហើយ រស់រវើកដែលព្រះបានប្រទានឲ្យ ៖ពួកព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ពួកលោកគឺជាពួកបុរសនៃព្រះដែលមានអំណាចបព្វជិតភាពតាមរយៈសេចក្ដីសុចរិតផ្ទាល់ខ្លួន ។

នៅក្នុងសន្និសីទទូទៅថ្មីនេះ អែលឌើរ អិម រ័សុល បាឡឺដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖ « នៅក្នុងផែនការប្រគល់បព្វជិតភាពដ៏អស្ចារ្យរបស់ព្រះវរបិតាសួគ៌យើង បុរសមានទំនួលខុសត្រូវដ៏សំខាន់ ក្នុងការគ្រប់គ្រងបព្វជិតភាព តែពួកគេពុំមែនជាបព្វជិតភាពនោះទេ ។ បុរសស្ត្រីមានតួនាទីខុសគ្នា តែមានតម្លៃស្មើគ្នា ។ ដូចជាស្ត្រីមិនអាចមានផ្ទៃពោះបានឡើយបើគ្មានបុរសនោះ ដូច្នេះបុរសក៏មិនអាចអនុវត្តអំណាចពេញលេញនៃបព្វជិតភាពដើម្បីបង្កើតគ្រួសារអស់កល្បមួយបានឡើយ បើគ្មានស្ត្រីនោះ ។ ន័យម្យ៉ាងទៀត ក្នុងទស្សនៈអស់កល្បជានិច្ចនោះ ទាំងអំណាចបង្កើតជីវិត និង អំណាចបព្វជិតភាពត្រូវបានប្រើប្រាស់ទាំងស្វាមី និង ភរិយា ។[11]

ខ្ញុំកំពុងរៀនថា ឥទ្ធិពលសីលធម៌របស់ស្ត្រីគឺជាអំណោយទានមួយដែលមានតម្លៃស្មើគ្នាទៅនឹងអំណាចបព្វជិតភាព ។ ប្រធាន ហារ៉ើដ ដបុលយូ ហ៊ីនគ្លេរី ( ឆ្នាំ 1907–95 ) បានមានប្រសាសន៍ទៅកាន់ស្ត្រីនៅក្នុងសាសនាចក្រថា « យើងសូមអង្វរអ្នកឲ្យបម្រើដោយ*ឥទ្ធិពល*ដ៏អស្ចារ្យរបស់អ្នកសម្រាប់សេចក្ដីល្អនៅក្នុងការពង្រឹងដល់ក្រុមគ្រួសាររបស់យើង សាសនាចក្ររបស់យើង និង សហគមន៍របស់យើង ។[12]នៅក្នុងសន្និសីទទូទៅថ្មីនេះ អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានលើកឡើងពីស្ត្រីថា « ថ្វីបើអ្នកនៅលីវ ឬរៀបការហើយក្ដី ជាម្ដាយ ឬពុំមែនក្ដី ជាមនុស្សចាស់ ឬក្មេង ឬពាក់កណ្ដាលវ័យក្ដី សិទ្ធិអំណាចខាងសីលធម៌អ្នកពិតជាសំខាន់ណាស់ » ។[13]

អែលឌើរ បាឡឺដបានថ្លែងស្រដៀងគ្នានេះដែរថា « នៅក្នុងពិភពលោកនេះ គ្មានអ្វីដែលជារឿងយ៉ាងជិតស្និទ្ធផ្ទាល់ ចិញ្ចឹមបីបាច់ ឬផ្លាស់ប្ដូរជីវិតដូចជា *ឥទ្ធិពល*របស់ស្ត្រីសុចរិតម្នាក់ឡើយ » ។[14]

យើងបានលើកឡើងនូវសំណួរមួយចំនួនដែលទាក់ទងនឹងបព្វជិតភាពបរិសុទ្ធនៃព្រះ ប៉ុន្តែនៅមានសំណួរសំខាន់ផ្សេងទៀត ។

**ដំបូង គោរពប្រតិបត្តិ រួចហើយយល់ដឹង**

ខ្ញុំសូមបញ្ចប់ជាមួយនឹងបទពិសោធន៍មួយដែលបានជួយខ្ញុំឲ្យដោះស្រាយនឹងសំណួរដែលមិនបានឆ្លើយ ។ ប៉ុន្មានឆ្នាំមុន ស្វាមីខ្ញុំ និង ខ្ញុំត្រូវបានអញ្ជើញឲ្យចូលរួមក្នុងការជួបជុំមួយរបស់អ្នកដឹកនាំសាសនាចក្រ ។ មានអ្នកដឹកនាំថ្មីម្នាក់ដែលទើបតែបានហៅ ហើយនៅចុងបញ្ចប់នៃការប្រជុំនោះមានសំណួរដ៏ពិបាក និង រករឿងឈ្លោះមួយត្រូវបានចោទសួរឡើង ។ ដោយដឹងពីភាពពិបាករបស់សំណួរនេះ រំពេចនោះ ស្វាមីខ្ញុំ និង ខ្ញុំបានធ្វើការអធិស្ឋានរបស់យើងដោយស្មោះទៅកាន់ព្រះវរបិតាសួគ៌សម្រាប់អ្នកដឹកនាំថ្មីរូបនេះ ។ នៅពេលគាត់ដើរទៅកាន់វេទិកា ដើម្បីឆ្លើយសំណួរនោះ ខ្ញុំបានឃើញពីការផ្លាស់ប្ដូរមួយនៅលើទឹកមុខរបស់គាត់ ពេលគាត់បានឈរយ៉ាងអង់អាចម៉ឺងម៉ាត់ ហើយបានថ្លែងដោយព្រះចេស្ដារបស់ព្រះអម្ចាស់ ។

ចម្លើយរបស់គាត់គឺមានដូចតទៅនេះ ៖ « បងប្រុស ខ្ញុំពុំដឹងពីចម្លើយសម្រាប់សំណួររបស់អ្នកទេ ។ ប៉ុន្តែខ្ញុំសូមប្រាប់អ្នកនូវអ្វីដែលខ្ញុំដឹង ។ « ខ្ញុំដឹងថាព្រះ គឺជាព្រះវរបិតាដ៏អស់កល្បជានិច្ចរបស់យើង ។ ខ្ញុំដឹងថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះ និង ជាព្រះប្រោសលោះនៃពិភពលោក ។ ខ្ញុំដឹងថា យ៉ូសែបស្ម៊ីធ បានឃើញព្រះជាព្រះវរបិតា និង បុត្រាដ៏ជាទីស្រលាញ់របស់ទ្រង់ព្រះយេស៊ូវគ្រីស្ទ ហើយលោកជាឧបករណ៍ដែលអំណាចបព្វជិតភាពត្រូវបានស្ដារឡើងវិញនៅលើផែនដី ។ ខ្ញុំដឹងថា ព្រះគម្ពីរមរមនពិត ហើយមាននូវភាពពោរពេញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំដឹងថា យើងមានព្យាការីម្នាក់ដែលរស់នៅសព្វថ្ងៃនេះ ដែលលោកនិយាយឲ្យជំនួសព្រះអម្ចាស់ដើម្បីប្រទានពរដល់ជីវិតរបស់យើង ។ មែនហើយ ខ្ញុំមិនដឹងពីចម្លើយសម្រាប់សំណួររបស់អ្នកទេ ប៉ុន្តែខ្ញុំដឹងរឿងទាំងនេះ ។ រឿងផ្សេងទៀតខ្ញុំពឹងផ្អែកលើសេចក្ដីជំនឿ ។ ខ្ញុំព្យាយាមរស់នៅតាមពាក្យដ៏សាមញ្ញនេះស្ដីពីសេចក្ដីជំនឿដែលខ្ញុំបានរៀនជាយូរមកហើយពី ម៉ាជ័រី ហ៊ិងគ្លី ជាភរិយារបស់ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី គាត់បានពោលថា ‹ ដំបូងខ្ញុំគោរពប្រតិបត្តិ រួចហើយខ្ញុំយល់ដឹង › » ។

បព្វជិតភាពនៃព្រះគឺជាការទុកចិត្តមួយដ៏ពិសិដ្ឋដែលត្រូវបានប្រទានឲ្យ ដើម្បីប្រទានពរដល់បុរស ស្ត្រី និងកុមារទាំងឡាយ ដើម្បីយើងអាចត្រឡប់ទៅរួមរស់ជាក្រុមគ្រួសារដ៏នៅអស់កល្បជានិច្ចនៅក្នុងទីវត្តមានព្រះវិញ ។ សេចក្ដីសុចរិតគឺជាគុណសម្បត្តិសម្រាប់យើងម្នាក់ៗ ដើម្បីអញ្ជើញអំណាចបព្វជិតភាពចូលមកក្នុងជីវិតរបស់យើង ។ សូមឲ្យគោលលទ្ធិនេះធ្វើឲ្យព្រលឹងយើងបានបរិសុទ្ធ ហើយនាំយើងឲ្យខិតជិតទ្រង់ ដែលសាសនាចក្រ និង អំណាច និង សិទ្ធិអំណាចបព្វជិតភាពនេះគឺជារបស់ផងទ្រង់ ។ ■

បព្វជិតភាពនៃព្រះគឺជាការទុកចិត្តដ៏ពិសិដ្ឋមួយដែលត្រូវបានប្រទានឲ្យដើម្បីប្រទានពរដល់បុរស ស្ត្រី និង កុមារ ដើម្បីពួកគេអាចត្រឡប់ទៅរួមរស់ជាគ្រួសារដ៏អស់កល្បនៅក្នុងវត្តមានរបស់ព្រះវិញ ។



*ដកស្រង់ចេញពីសុន្ទរកថាដែលធ្វើឡើងសម្រាប់សន្និសីទស្ត្រីនៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់នៅថ្ងៃទី 2 ខែ ឧសភា ឆ្នាំ 2013 ។*

**កំណត់ចំណាំ**

1. ដាល្លិន អេក អូក « The Power of the Priesthood in the Family » (worldwide leadership training meeting) wwlt.lds.org ។
2. ដេវីឌ អេ បែដណា « The Powers of Heaven » *Liahona,* ខែ ឧសភា ឆ្នាំ 2012 ទំព័រ 48 ការគូសបញ្ជាក់បានបន្ថែម ។
3. រ៉ូបឺត ឌី ហែល « Blessings of the Priesthood » *Ensign,* ខែ វិច្ឆិកា ឆ្នាំ 1995 ទំព័រ 32 ។
4. ដាល្លិន អេក អូក «The Relief Society and the Church» *Ensign,* ខែ ឧសភា ឆ្នាំ 1992 ទំព័រ 36 ការគូសបញ្ជាក់បានបន្ថែម ។
5. « The Family: A Proclamation to the World » *Liahona*, ខែ វិច្ឆិកា ឆ្នាំ 2010 ទំព័រ 129 ។
6. រ័សុល អិម ណិលសុន « Nurturing Marriage » *Liahona,* ខែ ឧសភា ឆ្នាំ 2006 ទំព័រ 37 ។
7. *ក្បួនខ្នាតភាគ 2 ៖ ការគ្រប់គ្រងសាសនាចក្រ* ( ឆ្នាំ 2010 ) ចំណុច 2.1.2 ។
8. « Priesthood Keys » *New Era,* ខែ ឧសភា ឆ្នាំ 2012 ទំព័រ 38 ។
9. *ក្បួនខ្នាតភាគ 2*ចំណុច 2.1.1 ។
10. សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ« Temple, House of the Lord », scriptures.lds.org ។
11. អិម រ័សុល បាឡឺដ « This Is My Work and Glory » *Liahona,* ខែ ឧសភា ឆ្នាំ 2013 ទំព័រ 19 ។
12. *Daughters in My Kingdom: The History and Work of Relief Society* ( ឆ្នាំ 2011 ) ទំព័រ 157 ការគូសបញ្ជាក់បានដាក់បន្ថែម ។
13. ឌី ថត គ្រីស្តូហ្វឺសិន «The Moral Force of Women » *Liahona,* ខែ វិច្ឆិកា ឆ្នាំ 2013 ទំព័រ 30 ។
14. *Daughters in My Kingdom*, ទំព័រ 156 ការគូសបញ្ជាក់បានដាក់បន្ថែម ។








## ពួកបរិសុទ្ធថ្ងៃចុងក្រោយនៅ

# ប្រទេសអ៊ីតាលី

## មរតកនៃសេចក្ដីជំនឿ

ដោយ លៀ ម៉ាកក្លេណាហាន

ប្រវត្តិរបស់សាសនាចក្រនៅប្រទេសអ៊ីតាលី ចាប់ផ្ដើមនៅគ្រាព្រះគម្ពីរសញ្ញាថ្មី ពេលដែលរាជធានីនៃអាណាចក្ររ៉ូមបានក្លាយទៅជាទីជ្រកកោនរបស់ពួកគ្រីស្ទានដ៏ស្មោះត្រង់មួយក្រុម ។ ព្រះគម្ពីរប៊ីបពុំបានកត់ត្រាពីបុគ្គលដែលបាននាំដំណឹងល្អទៅកាន់ក្រុងរ៉ូមដំបូងគេនោះទេ ប៉ុន្តែមានសាខាមួយរបស់សាសនាចក្របាននៅទីនោះអស់រយៈពេល « ជាច្រើនឆ្នាំ » (រ៉ូម 15:23) ពេលដែលសាវកប៉ុលបានផ្ញើសំបុត្រមួយទៅកាន់ប្រជាជនរ៉ូមប្រមាណជាគ.ស. 57.

ប៉ុលបានពិពណ៌នាពីពួកគ្រីស្ទាននៅក្នុងទីក្រុងរ៉ូមថា « មានសេចក្ដីល្អពេញលេញ » ( 15:14 ) ។ លោកបានស្គាល់ពួកគេមួយចំនួន ហើយសំបុត្ររបស់លោកមាននូវបញ្ជីមួយដ៏វែងនៃពួកបរិសុទ្ធជាទីស្រឡាញ់ ជាអ្នកដែលលោកបានផ្ញើការស្វាគមន៍ទៅ ( សូមមើល 16:1–15 ) ។

ប៉ុលបានសរសើរដល់សេចក្ដីជំនឿរបស់ពួកគ្រីស្ទានទាំងនោះ ហើយបានប្រាប់ពួកគេថា លោកបានអធិស្ឋានជាញឹកញាប់សម្រាប់ពួកគេ ។ លោកប៉ងចង់ជួបនឹងពួកគេ ហើយសង្ឃឹមថា ព្រះនឹងប្រទានឱកាសឲ្យគាត់បានជួបនឹងពួកគេក្នុងពេលឆាប់ៗ ( សូមមើល 1:8–15 ) ។

នៅទីបំផុត ពេលលិកបានទៅទីក្រុងរ៉ូម គាត់បានក្លាយជាអ្នកទោស ប៉ុន្តែសេចក្ដីសង្ឃឹមរង់ចាំរបស់សមាជិកសាសនាចក្រចំពោះការមកដល់របស់គាត់នៅតែមាន រហូតដល់មានបងប្អូនប្រុសមួយចំនួនបានធ្វើដំណើរ 69 គ.ម. ដើម្បីមកជួបនឹងគាត់នៅឯផ្សារអាប់ភាស ។ ដោយបានជួបនឹងពួកគេ នោះលោក « ក៏អរព្រះគុណដល់ព្រះ ហើយមានចិត្តសង្ឃឹមឡើង » (កិច្ចការ 28:15) ។

ក្រោយមកទៀត ប៉ុលត្រូវបានគេសម្លាប់នៅទីក្រុងរ៉ូម ជាកន្លែងដែលពួកគ្រីស្ទានមានការបៀតបៀនយ៉ាងខ្លាំងពីសំណាក់ណេរ៉ូ និង ព្រះចៅអធិរាជផ្សេងទៀត ។ នៅទីបំផុត សាសនាចក្របានធ្លាក់ចូលទៅក្នុងការក្បត់សាសនា ប៉ុន្តែពួកបរិសុទ្ធនៅទីក្រុងរ៉ូមកាលពីមុនបានទុកនូវមរតកនៃសេចក្ដីជំនឿ នៅឯចំណុចកណ្ដាលនៃអាណាចក្រនេះ ដោយ កំណត់ដំណាក់កាលសម្រាប់គ្រីស្ទសាសនាដើម្បីប្រកាសទូទាំងពិភពលោក ។

រូបថតដោយ ម៉ាសីម៉ូ គ្រីសសីយ៉ូន លើកលែងដូចបានកត់សម្គាល់ ។ រូបថតនៃ គីងហ្គេ តេប៉ ដោយ ដានីយ៉ែល ចន អែនឌើរសិន ។ រូបថតនៃភ្នំ © CORBIS



*យុវវ័យនៅស្តេកអ៊ីតាលីរ៉ូមខាងកើតបានជួយសម្អាត និងធ្វើទីជម្រកដល់អ្នកដែលខ្វះទីជម្រក ។*

**កាលប្បវត្តិ**

**ឆ្នាំ 63មុន គ.ស.៖ មេទ័ព រ៉ូម ប៉ុមពៃ បានគ្រប់គ្រង យេរូសាឡិម ដែលក្លាយជាផ្នែកមួយនៃអាណាចក្ររ៉ូម*

*គ.ស. 45 ៖ សាវក ប៉ុល ជាពលរដ្ឋរ៉ូមម្នាក់ បានចាប់ផ្ដើមដំណើរផ្សព្វផ្សាយសាសនាដំបូង នៅក្នុងអាណាចក្ររ៉ូម*

*64 ៖ ពួកគ្រីស្ទានត្រូវបានគេស្ដីបន្ទោសដោយសារសង្គ្រាមនៅទីក្រុងរ៉ូម ហើយចាប់ផ្ដើមបៀតបៀនពីសំណាក់រដ្ឋាភិបាលរ៉ូម*



*◄ 313 ៖ ខនស្ទែនធីនបានក្លាយជាព្រះចៅអធិរាជរ៉ូមដំបូងជាគ្រីស្ទាន ហើយបានអនុម័តច្បាប់ឲ្យការថ្វាយបង្គំគ្រីស្ទសាសនា*

*380 ៖ ព្រះចៅអធិរាជ ធេដូស៊ីស ទី 1 បានធ្វើឲ្យគ្រីស្ទសាសនាជាសាសនារដ្ឋជាផ្លូវការរបស់អាណាចក្ររ៉ូម ហើយបានត្រួសត្រាយសម្រាប់គ្រីស្ទសាសនាឲ្យរីកសាយពេញពិភពលោក ។*

**មនុស្សមួយក្រុមដែលត្រូវបានលាក់បំបាំងដោយព្រះអម្ចាស់**

ក្នុងឆ្នាំ 1849 អែលឌើរ ឡូរ៉ែនសូ ស្នូ ( ឆ្នាំ 1814–1901 ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ត្រូវបានហៅឲ្យបង្កើតបេសកកម្មមួយនៅប្រទេសអ៊ីតាលី ។ នៅពេលលោកសញ្ជឹងគិតពីទីកន្លែងចាប់ផ្ដើម លោកបានរៀនពីក្រុមវ៉លឌេនសៀន ជាក្រុមសាសនាមួយនៅលើភ្នំផេម៉ុននៅភាគពាយព្យប្រទេសអ៊ីតាលី ។

ពួកវ៉លឌេនសៀន បានស៊ូទ្រាំនឹងការបៀតបៀនយ៉ាងខ្លាំង ជាងប្រាំពីរទសវត្សរ៍ ដោយសារតែជំនឿរបស់ពួកគេ ។ ដោយមានកំណើតមុនពួកប្រូតេស្តង់ដល់ទៅពីរបីរយឆ្នាំ ពួកគេបានប្រកាសថា សាសនាចក្រពីមុនរបស់ព្រះគ្រីស្ទបានធ្លាក់ចូលទៅក្នុងការក្បត់សាសនា ។ ពួកគេបានផ្ដាច់ខ្លួនចេញពីព្រះវិហាររ៉ូម៉ាំងកាតូលិក ហើយត្រូវបានគេប្រកាសថាជា ហោរាក្លែងក្លាយ ហើយត្រូវបានបណ្ដេញចេញពីទីក្រុង ធ្វើទារុណកម្ម ព្រមទាំងត្រូវបានគេសម្លាប់ទៀតផង ។ ជាជាងបដិសេធនូវសេចក្ដីជំនឿរបស់ខ្លួន ពួកគេបានភៀសខ្លួនទៅរស់នៅលើកំពូលភ្នំ ។[1]

អែលឌើរ ស្នូ បានកត់ត្រាថា « មានពន្លឺមួយបានដក់ជាប់នៅក្នុងគំនិតខ្ញុំ ពេលខ្ញុំបានគិតពី [ ពួកវ៉លឌេនសៀន ] » ។ នៅក្នុងសំបុត្រមួយផ្ញើមកគ្រួសាររបស់លោក លោកបានសរសេរថា « ខ្ញុំជឿថា ព្រះអម្ចាស់បានគង់នៅទីនោះ ដើម្បីលាក់បំបាំងមនុស្សមួយក្រុមនៅក្នុងចំណោមជ្រលងភ្នំដ៏ខ្ពស់ » ។[2]

នៅក្នុងសាសនាផ្សេងទៀតរបស់ប្រទេសអ៊ីតាលី ច្បាប់ទាំងឡាយពុំអនុញ្ញាតឲ្យមានសកម្មភាពផ្សាយសាសនាឡើយ ។ ប៉ុន្តែពីមុនការមកដល់របស់អែលឌើរ ស្នូ ពីរឆ្នាំ ពួកវ៉លឌេនសៀននៅតំបន់ផេម៉ុន បានទទួលសិទ្ធិសេរីភាពខាងសាសនាបន្ទាប់ពីបានទទួលរងការបៀតបៀនជាច្រើនសតវត្សរ៍ ។[3]មិនត្រឹមតែប៉ុណ្ណោះទេ មានមនុស្សមួយចំនួនក្នុងចំណោមពួកគេបានមានសុបិន និង ការនិមិត្តដ៏អស្ចារ្យដែលរៀបចំពួកគេដើម្បីទទួលសារលិខិតរបស់ពួកអ្នកផ្សព្វផ្សាយសាសនា ។[4]

អែលឌើរ ស្នូ អមដំណើរដោយអ្នកផ្សាយសាសនាពីររូប បានឧទ្ទិសប្រទេសអ៊ីតាលីសម្រាប់ការប្រកាសដំណឹងល្អនៅថ្ងៃទី 19 ខែ កញ្ញា ឆ្នាំ 1850 ។ អែលឌើរ ស្នូ បានកត់ត្រាថា « ចាប់ពីថ្ងៃនោះមក ឱកាសនានាបានចាប់ផ្ដើមកើតមានសម្រាប់ការប្រកាសសារលិខិតរបស់យើង » ។[5]

ជាងបួនឆ្នាំក្រោយមក កិច្ចខិតខំរបស់ពួកអ្នកផ្សព្វផ្សាយសាសនាបានជួបទាំងភាពជោគជ័យ និង ការប្រឆាំង ។ ពួកគេបានបង្កើតតំបន់ផ្សព្វផ្សាយសាសនាចំនួនពីរ និងការបកប្រែព្រះគម្ពីរមរមនជាភាសាអ៊ីតាលី ។ ពួកគេបានជ្រមុជទឹកដល់ពួកអ្នកប្រែចិត្តជឿជាច្រើន ។ ប៉ុន្តែលុះដល់ឆ្នាំ 1854 កិច្ចការនេះបានធ្លាក់ចុះ—ពួកអ្នកផ្សព្វផ្សាយសាសនាត្រូវបានហៅឲ្យទៅតំបន់ផ្សេង ពួកអ្នកប្រែចិត្តជឿដ៏ស្មោះត្រង់បំផុតបានធ្វើអន្តោប្រវេសន៍ទៅរដ្ឋយូថាហ៍ ហើយ

**រាល់កាលបរិច្ឆេទកាលពីដើមគឺជាការស្មាន ។*

រូបថតរូបចម្លាក់ ខនស្ទែនធីន ដោយ TETRA IMAGES/THINKSTOCK

ការបៀតបៀនកាន់តែរីកធំឡើង ។ ក្នុងឆ្នាំ 1862 រាល់ការផ្សព្វផ្សាយសាសនាទាំងអស់ត្រូវបានផ្អាក ហើយបេសកកម្មត្រូវបានបិទនៅឆ្នាំ 1867 ។

បេសកកម្មអ៊ីតាលីមានដំណើរការតែ 12 ឆ្នាំប៉ុណ្ណោះ ប៉ុន្តែនៅអំឡុងពេលនោះ មាន 12 គ្រួសារ និង មនុស្សប្រាំពីរនាក់ផ្សេងទៀតត្រូវបានប្រែចិត្តជឿ ហើយបានធ្វើអន្តោប្រវេសន៍ទៅរដ្ឋយូថាហ៍ ។ ពួកវ៉ាលឌេនសៀនដែលបានក្រសោបយកដំណឹងល្អ បាននាំមកនូវកម្លាំងដ៏អស្ចារ្យសម្រាប់សាសនាចក្រនៅរដ្ឋ យូថាហ៍ ហើយសព្វថ្ងៃនេះមានសមាជិករាប់ម៉ឺននាក់បានជាប់សាច់ញាតិនឹងពួកវ៉ាលឌេនសៀនដ៏ស្មោះត្រង់ចំនួន 72 នាក់ ដែលបានចាកចេញពីដែនដីកំណើតរបស់ខ្លួនមកចូលរួមនឹងពួកបរិសុទ្ធថ្ងៃចុងក្រោយនៅភ្នំរ៉ាកគី ។[6]

## ការពន្លឿនកិច្ចការ

បន្ទាប់ពី បេសកកម្មនៅអ៊ីតាលីបានបិទ គ្មានកិច្ចការផ្សព្វផ្សាយសាសនាជាផ្លូវការណាមួយត្រូវបានធ្វើឡើងនៅប្រទេសអ៊ីតាលីឡើយ អស់រយៈពេលជិតមួយរយឆ្នាំ ។ នៅពេលពន្លឺនៃដំណឹងល្អបានចាប់ផ្តើមភ្លឺម្តងទៀតនៅប្រទេសអ៊ីតាលី វាបានកើតឡើងនៅក្នុងសង្គ្រាមលោកលើកទី 2 ពេលបុគ្គលិកយោធារបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយមកពីសហរដ្ឋអាមេរិកបានបោះទីតាំងនៅគ្រប់ទីក្រុងក្នុងប្រទេសអ៊ីតាលី ។ សមាជិកទាំងនេះបានបង្កើតជាក្រុមដើម្បីជួបប្រជុំគ្នានៅថ្ងៃអាទិត្យ ហើយក្រុមនេះបានបន្តទៅមុខ បន្ទាប់ពីសង្គ្រាម ដោយមានសមាជិកត្រូវបានចាត់ឲ្យទៅមូលដ្ឋានយោធានៅប្រទេសអ៊ីតាលី ។

លុះ 20 ឆ្នាំ ក្រោយមក ព្រះអម្ចាស់បានពន្លឿនកិច្ចការរបស់ទ្រង់ ។ អ្នកដែលមានដើមកំណើតជាជនជាតិអ៊ីតាលីបានចាប់ផ្តើមចូលរួមនឹងសាសនាចក្របន្ទាប់ពីបានជួបនឹងពួកអ្នកផ្សព្វផ្សាយសាសនានៅបណ្តាប្រទេសក្បែរនោះ ។ ក្រុមរបស់សមាជិកជាយោធានៅទីក្រុងណាប៉ូលី និង វ៉េរ៉ូណា ត្រូវបានរៀបចំទៅជាសាខានៅក្រោមការដឹកនាំរបស់បេសកកម្មស្វីស ។ បេសកកម្មបានបកប្រែព្រះគម្ពីរមរមនជាភាសាអ៊ីតាលីសារជាថ្មី ហើយបានបោះពុម្ពវា ។ ពេលវេលាដើម្បីបញ្ជូនពួកអ្នកផ្សព្វផ្សាយសាសនាបានខិតចូលមកដល់ ។

ក្នុងឆ្នាំ 1964 ប្រទេសអ៊ីតាលីត្រូវបានរៀបចំជាមណ្ឌលនៃបេសកកម្មស្វីស ហើយមិនយូរប៉ុន្មានពួកអ្នកផ្សព្វផ្សាយសាសនាជាភាសាអ៊ីតាលីត្រូវបានបញ្ជូនទៅទីក្រុងមួយចំនួន ។ ក្នុងឆ្នាំ 1966 បេសកកម្មអ៊ីតាលីត្រូវបានរៀបចំឡើងគឺ 99 ឆ្នាំ បន្ទាប់ពីបេសកកម្មអ៊ីតាលីពីមុនត្រូវបានបិទ ។ អែលឌើរ អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន ( ឆ្នាំ 1899–1994 ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានធ្វើការឧទ្ទិសប្រទេសអ៊ីតាលីឡើងវិញសម្រាប់ការផ្សាយដំណឹងល្អ ។

រយៈពេលដប់ឆ្នាំបន្ទាប់បេសកកម្មបានបើក ចំនួនសមាជិកនៅប្រទេសអ៊ីតាលីមានការកើនឡើងពីប្រមាណជា 300 នាក់ ទៅ 5,000 នាក់ ។ ចំនួននោះត្រូវបានកើនឡើងទ្វេដងគិតត្រឹមឆ្នាំ 1982 ។ នៅប៉ុន្មានឆ្នាំថ្មីៗនេះ មានការរីកចម្រើនយ៉ាងខ្លាំង ។ ពីឆ្នាំ 2005 ដល់ 2010 មានស្តេកថ្មីចំនួនបួនត្រូវបានបង្កើតឡើង ដោយសរុបស្តេកទាំងអស់មានដល់ទៅប្រាំពីរ ។ សព្វថ្ងៃនេះមានពួកបរិសុទ្ធថ្ងៃចុងក្រោយនៅប្រទេសអ៊ីតាលីជិត 25,000 នាក់ ។

## ការស្ថាបនាសាសនាចក្រ

អែលឌើរ ក្រេក អេ ខាតុន នៃពួកចិតសិបនាក់គឺជាមនុស្សម្នាក់ក្នុងចំណោមពួកបរិសុទ្ធថ្ងៃចុងក្រោយរាប់ពាន់នាក់ដែលមានជាប់ខ្សែស្រឡាយនឹង ភីលីព ខាតុន ជាអ្នកប្រែចិត្តជឿវ៉ាលឌេនសៀនម្នាក់ដែលបានធ្វើអន្តោប្រវេសន៍មករដ្ឋ

*► 1173 ៖ វ៉ាលដូ នៅទីក្រុងលីយ៉ុង ប្រទេសបារាំង បានចាប់ផ្តើមចលនាមួយដើម្បីត្រឡប់ទៅរកដំណឹងល្អពីមុនដែលបានបង្រៀនដោយព្រះគ្រីស្ទ និង ពួកសាវករបស់ទ្រង់*



*1215 ៖ វ៉ាលដូ និង ពួកអ្នកដើរតាមលោក ជាពួកវ៉ាលឌេនសៀន—ខ្លះរស់នៅអ៊ីតាលី—ត្រូវបានប្រកាសថាជាហោរាក្លែងក្លាយ ហើយត្រូវបានគេបៀតបៀន ។*

*1843 ៖ ហ្គីសេពេ ( យ៉ូសែប ) តូរ៉ង់តូ បានជ្រមុជទឹកនៅម៉ាស្សាឈូសេត ស.រ.អា.—ជាជនជាតិអ៊ីតាលីដំបូងដែលបានចូលក្នុងសាសនាចក្រ*

*1848 ៖ ស្តេច ខាលូ អាល់ប៊ើតូ នៃផេម៉ុន-សាឌីញ៉ាបានប្រទានសិទ្ធិសេរីភាពខាងសាសនាដល់ពួកវ៉ាលឌេនសៀន*



*◄ 1850 ៖ អែលឌើរ ឡរ៉ែនសូ ស្នូ ជាមួយនឹងអែលឌើរ យ៉ូសែប តូរ៉ន់តូ និង ប៊ី អេជ ស្តេនហោស ចាប់ផ្តើមកិច្ចការផ្សព្វផ្សាយសាសនានៅអ៊ីតាលី*

*1852 ៖ ការបកប្រែព្រះគម្ពីរមរមនជាភាសាអ៊ីតាលីត្រូវបានបោះពុម្ព*

*អែលឌើរ អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន ( កណ្តាល ) ជួបនឹងពួកអ្នកផ្សព្វផ្សាយសាសនាក្នុងបេសកកម្មអ៊ីតាលីដែលទើបរៀបចំថ្មីៗ ។*









យូថាហ៍ក្នុងឆ្នាំ 1854 ។ អែលឌើរ ខាតុន បានឃើញកិច្ចការរបស់ព្រះអម្ចាស់បានរីកចម្រើននៅលើដែនដីរបស់ដូនតាលោក ដំបូងក្នុងនាមអ្នកផ្សព្វផ្សាយសាសនាម្នាក់ក្នុងបេសកកម្មអ៊ីតាលីដែលទើបបើកថ្មីក្នុងឆ្នាំ 1960 រួចមកក្នុងនាមជាប្រធានបេសកកម្មរ៉ូមអ៊ីតាលីក្នុងឆ្នាំ 1980 ។

នៅពេលអែលឌើរ ខាតុន ត្រូវបានហៅឲ្យធ្វើជាប្រធានបេសកកម្មក្នុងឆ្នាំ 1983 នៅក្នុងចំណោមសាលាប្រជុំទាំងអស់នៅទីក្រុងរ៉ូមមានសាលាប្រជុំមួយដែលជាអគារជួល ។ នៅគ្រានោះអគារថ្មីៗរបស់សាសនាចក្រ ត្រូវបានបង់ថ្លៃមួយចំណែក ចេញពីប្រាក់បរិច្ចាគរបស់សមាជិកនៅតំបន់នោះ ។ ដោយសារតម្រូវការនូវមូលនិធិដើម្បីសង់អគារពីបីកន្លែង វាមើលទៅមិនអាចកើតឡើងបានឡើយ ដើម្បីឲ្យសមាជិកធ្វើការបរិច្ចាគយ៉ាងច្រើនបែបនេះនោះ ។ បន្ទាប់ពីធ្វើការពិចារណាប្រកបដោយការអធិស្ឋានមក សមាជិកនៅអ៊ីតាលីត្រូវបានអញ្ជើញឲ្យយកប្រាក់ដែលពួកគេនឹងចំណាយសម្រាប់បុណ្យគ្រីស្ទម៉ាសនៅឆ្នាំនោះទៅបរិច្ចាគសម្រាប់មូលនិធិសាងសង់អគារ ។ ក្រុមគ្រួសារទាំងឡាយបានដាក់ដុំថ្មនៅក្រោមដើមឈើគ្រីស្ទម៉ាស់របស់ខ្លួនជាតំណាងឲ្យការលះបង់របស់ពួកគេ ជាជាងអំណោយវិញ ។

1854 ៖ កិច្ចការផ្សព្វផ្សាយសាសនាធ្លាក់ចុះដោយសារការបៀតបៀនបានកើនឡើង ហើយពួកអ្នកផ្សព្វផ្សាយសាសនាបានផ្តោតយកចិត្តទុកដាក់ទៅលើប្រទេសស្វ៊ីសវិញ ។ ពួកអ្នកប្រែចិត្តជឿវ៉ែលឌេនសៀនបានចាប់ផ្តើមធ្វើអន្តោប្រវេសន៍ទៅទីក្រុងសលត៍ លេក រដ្ឋ យូថាហ៍

1862 ៖ រាល់ការផ្សព្វផ្សាយនៅប្រទេសអ៊ីតាលីបានបញ្ចប់

1944 ៖ ក្រុមសមាជិកយោធាអិល.ឌី.អេស. ត្រូវបានបង្កើតឡើងនៅអ៊ីតាលី




◄ 1964 ៖ សាសនាចក្របានបោះពុម្ពការបកប្រែព្រះគម្ពីរមរមនជាភាសាអ៊ីតាលីថ្មី ។ បេសកកម្មស្វ៊ីសបានរៀបចំមណ្ឌលអ៊ីតាលីមួយ

► 1966 ៖ បេសកកម្មអ៊ីតាលីត្រូវបានរៀបចំឡើង ។ អែលឌើរ អ៊ែសរ៉ា ថាហ្វ បែ៊នសឹន បានឧទ្ទិសប្រទេសអ៊ីតាលីឡើងវិញសម្រាប់ការផ្សាយដំណឹងល្អ







អែលឌើរ ខាតុន បានថ្លែងថា « អ្វីដែលបានកើតឡើងនៅពេលនោះគឺជារឿងអស្ចារ្យណាស់ » ។ « ការបរិច្ចាគគឺទទួលបានលើសពីសេចក្តីត្រូវការ ។ ដោយសារតែការបរិច្ចាគនេះ និង ការបន្តបង់ដង្វាយមួយភាគក្នុងដប់ដ៏ស្មោះត្រង់របស់ពួកបរិសុទ្ធ ព្រះអម្ចាស់បានចាក់ពរជ័យខាងវិញ្ញាណដ៏ច្រើនមកលើបេសកកម្ម និង មកលើពួកបរិសុទ្ធនៅក្នុងតំបន់នេះ នៅពេលពួកគេមានឆន្ទៈធ្វើឲ្យអស់ពីលទ្ធភាពរបស់ខ្លួនដើម្បីស្ថាបនាសាសនាចក្រ ។ ខ្ញុំជឿជាក់ថា ការតាំងចិត្តរបស់ពួកគេគឺជាផ្នែកមួយដ៏សំខាន់ចំពោះអ្វីដែលបានអនុញ្ញាតឲ្យសាសនាចក្របន្តរីកចម្រើនទៅដល់ចំណុចមួយ ដែលស្តេកត្រូវបានរៀបចំឡើង ហើយឥឡូវនេះព្រះវិហារបរិសុទ្ធមួយត្រូវបានសង់នៅទីក្រុង រ៉ូម » ។[7]

ពីមុនត្រូវបានហៅជាពួកអ្នកមានសិទ្ធិអំណាចទូទៅម្នាក់ អែលឌើរ ខាតុន បានត្រឡប់ទៅប្រទេសអ៊ីតាលីនៅឆ្នាំ 2005 ដើម្បីចូលរួមនៅក្នុងការបង្កើតស្តេកអ៊ីតាលី រ៉ូម ។ វាជាបទពិសោធន៍មួយដ៏ផ្អែមល្ហែម ។ លោកបានថ្លែងថា « នេះជាកម្លាំងនៃបព្វជិតភាព កូនសោបព្វជិតភាព និយមន័យក្នុងព្រះគម្ពីរស្តីពីកន្លែងមួយសម្រាប់ជ្រកកោន—ជាស្តេក—ឥឡូវនេះ ត្រូវបានបង្កើតនៅទីក្រុងរ៉ូម » ។

## ព្រះវិហារបរិសុទ្ធនៅទីក្រុង រ៉ូម

នៅសន្និសីទទូទៅខែ តុលា ឆ្នាំ 2008 នៅពេលដែលប្រធាន ថូម៉ាស អេស ម៉នសុន បានប្រកាសថា មានព្រះវិហារ



សាលាប្រជុំនៃវួដកាតានៀនៅលើឆ្នេរ ស៊ីស៊ីលី ។ សាខាកាតានៀបានបង្កើតឡើងនៅឆ្នាំ 1967 មួយឆ្នាំក្រោយបេសកកម្មអ៊ីតាលីត្រូវបានរៀបចំ ។

បរិសុទ្ធមួយនឹងត្រូវបានសង់នៅទីក្រុងរ៉ូម នោះមានការសម្រក់ទឹកភ្នែកដោយក្ដីរំភើបពេញទាំងមជ្ឈមណ្ឌលសន្និសីទ ។ ពួកបរិសុទ្ធអ៊ីតាលីដែលបានមើលតាមផ្កាយរណបបានស្រែកឡើងដោយសេចក្ដីអំណរ ។ មានបងស្រីម្នាក់បាននៅចាំថា « យើងបានត្រឡប់ទៅផ្ទះយើងវិញដោយអារម្មណ៍ហោះហើរជាមួយនឹងសេចក្ដីអំណរនៅក្នុងដួងចិត្តរបស់យើង » ។

ហេតុអ្វីបានជាការមានព្រះវិហារបរិសុទ្ធនៅទីក្រុង រ៉ូមមានអត្ថន័យដល់ម្ល៉េះ ? ក្រៅពីការដឹងពីសារៈសំខាន់ខាងវិញ្ញាណដ៏អស្ចារ្យរបស់ព្រះវិហារបរិសុទ្ធ សមាជិកមានអារម្មណ៍ពីសារៈសំខាន់នៃប្រវត្តិសាស្ត្ររបស់ទីក្រុងនេះ អែលឌើរ ខាតុន បានថ្លែងថា ៖ « អភិបាលកិច្ច និង អំណាចនៅក្នុងគ្រាដ៏ជាក់លាក់របស់វា អ្នករុករក វិចិត្រករ អ្នកវិទ្យាសាស្ត្រ និង អ្នករចនាដែលបានបរិច្ចាគយ៉ាងច្រើនចំពោះពិភពលោកនេះ និង ពរជ័យដែលអំណាចសាសនាចក្ររបស់រ៉ូមបានជួយដល់ការណែនាំគ្រីស្ទសាសនានៅក្នុងពិភពលោក គឺជាផ្នែកមួយនៃប្រវត្តិសាស្ត្ររបស់រ៉ូម ឥឡូវនេះបានលម្អរដោយព្រះវិហារបរិសុទ្ធនៃព្រះអម្ចាស់ » ។ នៅកម្មវិធីបញ្ចុះបឋមសិលាក្នុងឆ្នាំ 2010 ប្រធាន ម៉នសុន បានថ្លែងថា « ទាក់ទងនឹងព្រះវិហារបរិសុទ្ធដែលនឹងសាងសង់នៅតំបន់នេះ វាមានអត្ថន័យខ្លាំងណាស់ចំពោះពួកបរិសុទ្ធថ្ងៃចុងក្រោយ » ។[8]

អស់រយៈពេលជាង 40 ឆ្នាំ ដែលសមាជិកអ៊ីតាលីត្រូវធ្វើដំណើរទៅព្រះវិហារបរិសុទ្ធ ប៊ើនស្វ៊ីស ការធ្វើដំណើរខ្លះត្រូវចំណាយពេលពីរថ្ងៃដើម្បីទៅដល់ទីនោះ ។ ម៉ាស៊ីម៉ូ ឌី ហ្វីអូ អតីតប្រធានស្តេករ៉ូម ហើយឥឡូវនេះជាពួកចិតសិបនាក់ប្រចាំតំបន់ជឿថា ព្រះវិហារបរិសុទ្ធរ៉ូមគឺជាសញ្ញាមួយដែលព្រះអម្ចាស់បានទតឃើញពីការបម្រើ និង ការលះបង់អស់រយៈពេលជាច្រើនឆ្នាំរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយ ហើយទទួលស្គាល់ពីបំណងប្រាថ្នាដ៏ធំធេងរបស់ពួកគេសម្រាប់ព្រះវិហារបរិសុទ្ធ ។

នៅពេលការប្រកាសពីព្រះវិហារបរិសុទ្ធនេះត្រូវបានធ្វើឡើង អែលឌើរ ឌី ហ្វីអូ បានថ្លែងថា ក្ដីរំភើបនោះគឺប្រៀបបាននឹងអារម្មណ៍នៅក្នុងកីឡាដ្ឋានមួយ នៅពេលដែលក្រុមមួយឈ្នះនៅនាទីចុងក្រោយ ។ សេចក្ដីអំណរនោះគឺស្រដៀងគ្នាទៅនឹងអ្វីដែលគាត់បាននឹកឃើញ ជាអារម្មណ៍ដែលយើងមាននៅជីវិតមុនឆាកជីវិតនេះ ពេលផែនការសង្គ្រោះត្រូវបានប្រកាសឡើង ។ ពួកបរិសុទ្ធបានឱបគ្នាទាំងស្នាមញញឹមលាយលំនឹងទឹកភ្នែក ។ វាជាសុភមង្គលដ៏ពិត ។

អែលឌើរ ឌី ហ្វីអូ បានថ្លែងថា « វាជាការអស្ចារ្យណាស់ដើម្បីបម្រើព្រះអម្ចាស់នៅសព្វថ្ងៃនេះ។ វាសំខាន់ណាស់សម្រាប់ប្រទេស អ៊ីតាលី សម្រាប់ទីក្រុងរ៉ូម » ។ គាត់បានថ្លែងទីបន្ទាល់ថា « ខ្ញុំដឹងថា ព្រះអម្ចាស់កំពុងប្រទានពរយ៉ាងច្រើនសម្រាប់ផ្នែកនេះនៃនគររបស់ទ្រង់ » ។[9] ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*

## សមាជិកនៅអ៊ីតាលី




**សាសនាចក្រនៅប្រទេសអ៊ីតាលីសព្វថ្ងៃ ***

**សមាជិក** ៖ 25,453 នាក់

បេសកកម្ម ៖ 2

ស្តេក ៖ 7

វួដ ៖ 46

សាខា ៖ 52

មណ្ឌល ៖ 5

ព្រះវិហារបរិសុទ្ធ ៖ 1 ( កំពុងសាងសង់ )

មជ្ឈមណ្ឌលពង្សប្រវត្តិ ៖ 49

** គិតត្រឹមខែ ធ្នូ ឆ្នាំ 2013*



*1972 ៖ ប្រធាន ហារ៉ូល ប៊ី លី បានទៅជួបនឹងសមាជិកនៅអ៊ីតាលី ជាប្រធានសាសនាចក្រទីមួយដែលបានទៅ នៅសម័យនោះ*

*1981 ៖ ស្តេកអ៊ីតាលី មីឡាន ត្រូវបានរៀបចំឡើង ជាស្តេកដំបូងនៅអ៊ីតាលី*

*1993 ៖ សាសនាចក្របានផ្ដល់ការទទួលស្គាល់តាមច្បាប់នៃអចលនទ្រព្យផ្ទាល់ខ្លួន ហើយធ្វើការរៀបអាពាហ៍ពិពាហ៍ដែលទទួលស្គាល់ដោយរដ្ឋាភិបាល*



*2008 ៖ ព្រះវិហារបរិសុទ្ធរ៉ូមអ៊ីតាលីបានប្រកាសដោយប្រធាន ថូម៉ាស អេសម៉នសុន*

*2012 ៖ សាសនាចក្រត្រូវបានផ្ដល់ឲ្យនូវស្ថានភាពផ្នែកច្បាប់ខ្ពស់បំផុត ដែលបានផ្ដល់សាសនានានានៅអ៊ីតាលី*

**កំណត់ចំណាំ**
1. សូមមើល រ៉ូណល អេ ម៉ាឡាន « Waldensian History: A Brief Sketch » Waldensian Families Research, www.waldensian.info/History.htm ។
2. ឡូរែនសូ ស្នូ The Italian Mission, ( ឆ្នាំ 1851 ) ទំព័រ 10–11 ។
3. ឡូរែនសូ ស្នូ The Italian Mission, ទំព័រ 10–11 ។
4. ដាយអេន ស្ដូកូ « The Mormon Waldensians » ( master's thesis, Brigham Young University ឆ្នាំ 1985 ) ទំព័រ 26–27 ។ ជាឧទាហរណ៍នៃសុបិនមួយបែបនេះ សូមមើល អេលីហ្សាប៊ែត ម៉ាគី «‹Suddenly the Thought Came to Me›:Child's Vision Prepares Her Family for the Gospel» ថ្ងៃទី 3 ខែ មិថុនា ឆ្នាំ 2013 history.lds.org/article/marie-cardon-italy-conversion ។
5. ឡូរែនសូ ស្នូ The Italian Mission, ទំព័រ 15, 17 ។
6. ស្ដូកូ «The Mormon Waldensians » ទំព័រ 1–5, 71–84 ។
7. ក្រេក អេ ខាតុន ដកស្រង់ចេញពីបទសម្ភាសន៍មួយជាមួយនឹងអ្នកនិពន្ធនៅខែ មិថុនា ឆ្នាំ 2013 ។
8. ម៉នសុន, ថូម៉ាស អេស. ម៉នសុន នៅក្នុង ជេសិន ស្វេនសុន « Rome Italy Temple Groundbreaking » Church News ថ្ងៃទី 23 ខែ តុលា ឆ្នាំ 2010, ldschurchnews.com ។
9. « Interview with President Massimo De Feo—Italy—Episode 1 » Into All the World (archived radio program) mormonchannel.org ។

HAMA/ISTOCKPHOTO/THINKSTOCK



**ដោយ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# ការអំពាវនាវឲ្យ ប្រែក្លាយដូចជាព្រះគ្រីស្ទ

នៅក្នុងប្រវត្តិសាស្ត្ររបស់អ៊ីស្រាអែលជាច្រើនជំនាន់ នៅពេលរឿងទាំងឡាយពោរពេញដោយអំពើបាបជាខ្លាំង ឬ សង្គមទោរទន់ទៅរកខាងលោកិយពេក ឬជីវិតជាមួយសាសន៍ដទៃបានចាប់ផ្ដើមបដិសេធនូវក្រមសីលធម៌ និង បទបញ្ញត្តិដែលព្រះបានប្រទានឲ្យ នោះកូនចៅនៃសេចក្ដីសញ្ញានឹងត្រូវបញ្ជូនឲ្យចូលទៅក្នុងទីរហោស្ថានដើម្បីចាប់ផ្ដើមសារជាថ្មី ហើយស្ថាបនាក្រុងស៊ីយ៉ូនឡើងវិញ ។

នៅក្នុងគ្រានៃព្រះគម្ពីរសញ្ញាចាស់ អ័ប្រាហាំ ជាឪពុកនៃសេចក្ដីសញ្ញាត្រូវរត់ភៀសខ្លួន ដើម្បីបានរួចជីវិតពីពួកខាល់ដេ—ជាពួកបាប៊ីឡូន—ទៅស្រុកកាណា ដែលឥឡូវនេះយើងហៅថា ដែនដីបរិសុទ្ធ ( សូមមើល អ័ប្រាហាំ 2:3–4) ។ ប៉ុន្តែមិនច្រើនតំណរមុន ពូជពង្សរបស់អ័ប្រាហាំបានបាត់បង់ក្រុងស៊ីយ៉ូនរបស់ខ្លួន ហើយត្រូវបានក្លាយជាទាសករនៅស្រុកអេស៊ីព្ទ ( សូមមើល និក្ខមនំ 1:7–14) ។ ដូច្នេះម៉ូសេត្រូវបានចិញ្ចឹមបីបាច់ឲ្យធំដឹងក្ដី ឡើងដើម្បីដឹកនាំកូនចៅនៃសេចក្ដីសន្យាចូលទៅក្នុងទីរហោស្ថានម្ដងទៀត ។

ប៉ុន្មានសតវត្សរ៍ក្រោយមក ដំណើររឿងមួយដែលធ្វើឲ្យយើងមានចំណាប់អារម្មណ៍បានបើកសម្ដែងឡើង នៅពេលក្រុមគ្រួសារសាសន៍អ៊ីស្រាអែលមួយដឹកនាំដោយព្យាការីម្នាក់ឈ្មោះលីហៃ ត្រូវបានបញ្ជាឲ្យចាកចេញពីក្រុងយេរូសាឡិម ដោយសារក្រុងបាប៊ីឡូននឹងគ្រប់គ្រងវាជាថ្មីម្ដងទៀត ! ( សូមមើល នីហ្វៃទី 1 2:2) ។ ពួកគេបានដឹងស្ដួចស្ដើងណាស់ថា ពួកគេនឹងទៅដែនដីថ្មីមួយ ដើម្បីស្ថាបនាក្រុងស៊ីយ៉ូនថ្មី ( សូមមើល នីហ្វៃទី 1 18:22–24) ។ ហើយពួកគេមិនបានដឹងច្រើនថា ការធ្វើដំណើរនេះបានកើតឡើងរួចហើយជាមួយនឹងដូនតាពួកគេមួយក្រុម ដែលហៅថាសាសន៍យ៉ារេឌ ( សូមមើល អេធើរ 6:5–13) ។

វាជារឿងមួយដែលគួរឲ្យចាប់អារម្មណ៍ចំពោះអស់អ្នកដែលអបអរដល់ការស្ដារឡើងវិញនៃដំណឹងល្អថា អាណានិគមរបស់អាមេរិកត្រូវបានកើតឡើងពីមនុស្សមួយក្រុមដែលភៀសខ្លួនចេញពីដែនដីកំណើតរបស់ខ្លួនដើម្បីថ្វាយបង្គំតាមអ្វីដែលគេចង់បាន ។ មានអ្នកប្រាជ្ញដ៏ល្បីឈ្មោះម្នាក់ ក្នុងចំណោមពួកពួរីតង់ដែលមកតាំងលំនៅនៅអាមេរិកបានរៀបរាប់ពីបទ ពិសោធន៍នេះថាជា « បេសកកម្មចូលទៅក្នុងទីរហោស្ថាន » របស់គ្រីស្ទសាសនា—ជាកិច្ចខិតខំនៃពួកអ៊ីស្រាអែលសម័យទំនើប ដើម្បីធ្វើឲ្យពួកគេរួចផុតពីការមិនគោរពដល់ព្រះនៅក្នុងសម័យព្រះគម្ពីរសញ្ញាចាស់ ហើយស្វែងរកផ្លូវទៅកាន់ស្ថានសួគ៌ជាថ្មីម្ដងទៀតនៅលើដែនដីថ្មី ។[1]

***ព្រះកំពុងហៅអ៊ីស្រាអែលនៅថ្ងៃចុងក្រោយនេះឲ្យប្រែក្លាយដូចព្រះគ្រីស្ទ ហើយបរិសុទ្ធជាងអ្វីដែលយើងមាននៅពេលនេះ នៅក្នុងការតាំងចិត្តរបស់យើងដើម្បីរស់នៅតាមដំណឹងល្អ និង ស្ថាបនាក្រុងស៊ីយ៉ូនឡើង ។***



ខ្ញុំសូមរំឭកពីការភៀសខ្លួនចុងក្រោយមួយ ។ វាស្ដីពីសាសនាចក្ររបស់យើងផ្ទាល់ ដែលបានដឹកនាំដោយពួកព្យាការីរបស់យើង ដើម្បីដឹកនាំសាសនារបស់យើង ។ ដោយយ៉ូសែបស្ម៊ីធត្រូវបានគេបៀតបៀននៅក្នុងរដ្ឋ នូវយ៉ោក រដ្ឋផែនស៊ីលវេញ៉ា រដ្ឋ អូហៃអូ និង មិសសួរី ហើយនៅទីបំផុតត្រូវបានគេសម្លាប់នៅរដ្ឋ អិលលីណោយ យើងបានឃើញនូវការបង្កើតឡើងវិញនៅថ្ងៃចុងក្រោយរបស់កូនចៅអ៊ីស្រាអែលជាថ្មីម្ដងទៀត ដោយសារស្វែងរកទីកន្លែងស្ងប់ស្ងាត់មួយ ។ ប្រធាន ព្រិកហាំ យ៉ង់ ( ឆ្នាំ 1801–77 ) ជាលោកម៉ូសេជនជាតិអាមេរិក បានដឹកនាំពួកបរិសុទ្ធទៅកាន់ជ្រលងភ្នំ នៅពេលដែលពួកបរិសុទ្ធដែលមានការព្រួយបារម្ភទាំងនោះបានច្រៀងថា ៖

*យើងនឹងរកឃើញកន្លែងដែលព្រះរៀបទុក*
*នៅទិសខាងលិចដ៏ឆ្ងាយ*
*គឺជាកន្លែងដែលគ្មានអ្នកណាកំហែង*
*ពួកបរិសុទ្ធបានពរ ។*[2]

ក្រុងស៊ីយ៉ូន ។ ដែនដីសន្យា ។ ក្រុងយេរូសាឡិមថ្មី ។ ភៀសខ្លួន ហើយស្វែងរក ។ រត់ ហើយបោះទីជម្រក ។ គេចចេញពីបាប៊ីឡូន ។ សង់ជញ្ជាំងការពាររបស់ក្រុងស៊ីយ៉ូន ។

រហូតដល់សម័យយើង ។

## សង់ក្រុងស៊ីយ៉ូននៅទីកន្លែងដែលអ្នករស់នៅ

ឥរិយាបថមួយដ៏វិសេសវិសាលនៃគ្រាកាន់កាប់ត្រួតត្រារបស់យើងគឺការផ្លាស់ប្ដូរលក្ខណៈសម្បត្តិ ពីរបៀបដែលយើងស្ថាបនានគរព្រះនៅលើផែនដី ។ គ្រាកាន់កាប់ត្រួតត្រានេះគឺជាពេលនៃការផ្លាស់ប្ដូរមួយយ៉ាងលឿនបំផុត ។ ហើយរឿងមួយដែលបានផ្លាស់ប្ដូរគឺថា សាសនាចក្រនៃព្រះនឹងពុំភៀសខ្លួនម្ដងទៀតឡើយ ។ សាសនាចក្រនេះនឹងពុំចាកចេញពីក្រុងអ៊ើរ ដើម្បីទៅក្រុងខារ៉ានទៀត ឡើយ ដើម្បីចេញពីខារ៉ានទៅក្រុង កាណាន់ ចេញពីកាណាន់ទៅក្រុងយេរូសាឡិម ចេញពីយេរូសាឡិមទៅប្រទេស អង់គ្លេស ចេញពីអង់គ្លេសទៅក្រុងណៅវូ ចេញពីណៅវូទៅកន្លែងផ្សេងទៀតដែលពុំស្គាល់ទៀតឡើយ ។

មែនហើយ ដូចដែលព្រិកហាំ យ៉ង់បានថ្លែងប្រាប់យើងទាំងអស់គ្នាថា « យើងត្រូវបានគេបណ្ដេញចេញពីស្ថានភាពមួយដ៏គ្រោះថ្នាក់ឲ្យចូលទៅក្នុងស្ថានភាពដ៏កាន់តែគ្រោះថ្នាក់មួយទៀតជាបន្តបន្ទាប់ ហើយយើងបានមកដល់ទីនេះ ហើយយើងនឹងរស់នៅទីនេះ » ។[3]

ពិតណាស់ សេចក្ដីថ្លែងការណ៍នោះបានក្លាយជាសេចក្ដីថ្លែងការណ៍មួយសម្រាប់សមាជិកសាសនាចក្រនៅជុំវិញពិភពលោក ។ នៅថ្ងៃចុងក្រោយនេះ ក្នុងគ្រាកាន់កាប់ត្រួតត្រារបស់យើង យើងមានសមត្ថភាពគ្រប់គ្រាន់ដើម្បីឈប់រត់គេចទៀតហើយ ។ យើងមានសមត្ថភាពគ្រប់គ្រាន់ដើម្បីតាំងជំហររបស់យើង ក្រុមគ្រួសារយើង និងគ្រឹះរបស់យើងនៅគ្រប់ប្រជាជាតិ គ្រប់សាសន៍ គ្រប់ភាសា និងដល់មនុស្សទូទៅ*ជារៀងរហូត* ។ក្រុងស៊ីយ៉ូនមាននៅគ្រប់ទីកន្លែង—គឺនៅគ្រប់ទីកន្លែងដែលមានសាសនាចក្រ ។ ហើយជាមួយនឹងការផ្លាស់ប្ដូរនោះ យើងលែងគិតថាក្រុងស៊ីយ៉ូនជា*កន្លែង*ដែលយើងនឹងរស់នៅទៀតហើយ យើងគិតថាវាជា*របៀប*ដែលយើងនឹងរស់នៅវិញ ។

ដើម្បីពន្យល់ពីកិច្ចការថ្មីនេះ ខ្ញុំសូមលើកឡើងពីព្រឹត្តិការណ៍បី ។

## ព្រឹត្តិការណ៍បី និង មេរៀនបី

**1.** ប៉ុន្មានឆ្នាំមុន មានមិត្តវ័យក្មេងរបស់ខ្ញុំម្នាក់—ជាអ្នកដែលត្រឡប់មកពីបេសកកម្មវិញ—ជាកីឡាករម្នាក់ក្នុងក្រុមកីឡាបាល់បោះសម្រាប់មហាវិទ្យាល័យមួយនៅរដ្ឋយូថាហ៍ ។ គាត់គឺជាយុវជនដ៏អស្ចារ្យម្នាក់ ហើយពូកែលេងបាល់បោះ ប៉ុន្តែគាត់មិនបានលេងច្រើនដូចជាអ្វីដែលគាត់បានរំពឹងទុកឡើយ ។ ទេពកោសល្យ និង ជំនាញដ៏ជាក់លាក់របស់គាត់ពុំមែនជាអ្វីដែលក្រុមរបស់គាត់ត្រូវមាននៅក្នុងជំហាននៃការអភិវឌ្ឍរបស់វា ឬគាត់នោះទេ ។ រឿងនោះកើតឡើងនៅក្នុងអាជីពកីឡា ។ ដូច្នេះ ដោយមានការគាំទ្រយ៉ាងពេញទំហឹងពីពួកគ្រូបង្វឹក និង មិត្តរួមក្រុមរបស់គាត់ មិត្តវ័យក្មេងរបស់ខ្ញុំបានប្ដូរទៅសាលាមួយទៀត ជាទីកន្លែងដែលគាត់រំពឹងថា គាត់អាចចូលរួមចំណែកបានច្រើនជាងមុន ។

រឿងទាំងឡាយបានដំណើរការទៅយ៉ាងល្អនៅឯសាលាថ្មី ហើយមិនយូរប៉ុន្មាន មិត្តរបស់ខ្ញុំបានក្លាយជាកីឡាករជម្រើស ។ តើអ្នកដឹងថាមានអ្វីកើតឡើងទេ—កាលវិភាគរបស់ក្រុមបានធ្វើឲ្យយុវជនត្រឡប់ទៅប្រកួតនឹងក្រុមមុនរបស់គាត់នៅទីក្រុងសលត៍ លេក ។

ភាពជូរចត់ដែលពួកអ្នកទស្សនាបានស្រែកថាឲ្យយុវជននេះនាយប់នោះ—ជាស្វាមីថ្មោងថ្មីដែលបានបង់ដង្វាយមួយភាគក្នុងដប់ បានបម្រើនៅក្នុងក្វ៉ូមអែលឌើរ បានផ្ដល់ការបម្រើដ៏សប្បុរសដល់យុវវ័យនៅក្នុងសហគមន៍ ហើយបានរង់ចាំដោយចិត្តរំភើបសម្រាប់កូនដែលនឹងកើតមក—ជាបទពិសោធន៍មួយដែលពុំធ្លាប់ជួបប្រទះដោយមនុស្សណាម្នាក់ មិនថានៅក្នុងកីឡា ឬ សាកលវិទ្យាល័យរបស់គាត់ ឬមិនថាការសម្រេចចិត្តផ្ទាល់ខ្លួនឡើយ ។

***មិនថាមានស្ថានភាព ឬការរករឿង ឬបញ្ហាអ្វីនោះទេ គ្មានសិស្សនៃព្រះគ្រីស្ទដ៏ពិតណាម្នាក់អាចដឹងពីសាសនារបស់ខ្លួនបានភ្លាមៗឡើយ ។***

គ្រូបង្វឹករបស់ក្រុមភ្ញៀវដែលមានកេរ្តិ៍ឈ្មោះនៅក្នុងអាជីពនេះ បានងាកមករកគាត់បន្ទាប់ពីការប្រកួតមួយដ៏អស្ចារ្យ ហើយបានពោលថា ៖ « ម៉េចបានអញ្ចឹង ? ឯងជាកីឡាករដែលលេងបានយ៉ាងល្អ ។ ទាំងនេះជាប្រជាជនរបស់អ្នក ។ ទាំងនេះជាមិត្តរបស់អ្នក » ។ ប៉ុន្តែលើសពីនេះទៀត រួចហើយបានពោលទាំងងឿងឆ្ងល់ថា « តើមនុស្សទាំងនេះភាគច្រើនពុំមែនជាសមាជិកព្រះវិហាររបស់ឯងទេឬអី ? »



**2.** ខ្ញុំត្រូវបានអញ្ជើញឲ្យនិយាយនៅឯការប្រជុំធម្មនិដ្ឋានស្តេកមួយសម្រាប់មជ្ឈិមវ័យនៅលីវ ។ ពេលខ្ញុំចូលតាមទ្វារក្រោយរបស់មជ្ឈមណ្ឌលស្តេក នោះមានស្ត្រីវ័យក្មេងម្នាក់អាយុប្រហែលជា 30 ឆ្នាំ បានដើរចូលមកក្នុងអគារប្រហែលជាពេលដំណាលគ្នាដែរ ។ ទោះបីជានៅក្នុងហ្វូងមនុស្សកកកុញកំពុងដើរចូលក្នុងសាលាជំនុំក្តី ក៏វាមិនពិបាកនឹងកត់សម្គាល់នាងដែរ ។ នាងមានសាក់ពីរកន្លែង មានក្រវិលច្រើននៅត្រចៀក និង ច្រមុះ មានសក់ជ្រោងស្រួចៗដែលមានចំរុះពណ៌ មានសំពត់ដែលខ្លីពេក និង អាវដែលខើចពេក ។

មានសំណួរមួយចំនួនបានផុសឡើងនៅក្នុងគំនិតរបស់ខ្ញុំ ៖ តើស្ត្រីម្នាក់នេះជាសមាជិកព្រះវិហារផ្សេងដែលមានបញ្ហា ដែលត្រូវបាននាំមក—ឬប្រសើរជាងនេះទៀត ត្រូវបាននាំមកដោយនរណាម្នាក់មក—កាន់ការប្រជុំធម្មនិដ្ឋាននេះក្រោមការដឹកនាំរបស់ព្រះអម្ចាស់ ដើម្បីជួយគាត់ឲ្យស្វែងរកសេចក្តីសុខសាន្ត និង ការដឹកនាំពីដំណឹងល្អដែលគាត់ត្រូវការនៅក្នុងជីវិតមែនទេ ? ឬ តើនាងជាសមាជិកម្នាក់ដែលបានវង្វេងចេញពីសេចក្តីសង្ឃឹម និង បទដ្ឋានមួយចំនួនដែលសាសនាចក្រលើកទឹកចិត្តសមាជិករបស់ខ្លួនឲ្យធ្វើតាម ប៉ុន្តែ ដោយអំណរគុណ ជាម្នាក់ដែលមិនទាន់អសកម្មទាំងស្រុង ហើយបានជ្រើសរើសចូលរួមក្នុងសកម្មភាពសាសនាចក្រនាយប់នោះ ?

**3.** កាលចូលរួមនៅក្នុងការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធកានសាស ស៊ីធី មីសស្សួរី ស៊ិស្ទើរ ហូឡិន និង ខ្ញុំបានស្នាក់នៅផ្ទះរបស់បងប្រុស អ៊ីសាក ហ្វ្រីស្តូន ជាមន្ត្រីតម្រួតម្នាក់ និង ជាសង្ឃជាន់ខ្ពស់នៅក្នុងស្តេកមិសស្សួរី លីប៊ើធី ។ នៅក្នុងការសន្ទនារបស់យើង គាត់បានប្រាប់យើងថា មានយប់មួយ គាត់បានទទួលទូរស័ព្ទមួយឲ្យទៅស៊ើបអង្កេតពីការប្តឹងមួយនៅតំបន់ដ៏គ្រោះថ្នាក់មួយក្នុងទីក្រុង ។ នៅក្នុងចំណោមភ្លេងដ៏ឮ ខ្លាំងៗ និង ក្លិនកញ្ឆា គាត់បានឃើញស្ត្រីម្នាក់ និងពួកបុរសពីរបីនាក់កំពុងផឹកស្រា ហើយប្រើពាក្យអសុរស ពួកគេទំនងជាមិនបានឃើញក្មេងតូចៗប្រាំនាក់ទេ---អាយុប្រមាណជាពីរទៅប្រាំឆ្នាំ---ប្រឹងឱបគ្នានៅក្នុងបន្ទប់មួយ ដោយព្យាយាមដេកនៅលើឥដ្ឋដ៏កខ្វក់ គ្មានគ្រែ គ្មានពូក គ្មានខ្នើយ គ្មានអ្វីៗទាំងអស់ ។

បងប្រុស ហ្វ្រីស្តូនបានមើលក្នុងទូរផ្ទះបាយ និង ទូរទឹកកកថាតើមានអាហារនៅក្នុងនោះដែរឬអត់— ប៉ុន្តែគាត់មិនឃើញអ្វីទាំងអស់ ។ គាត់បាននិយាយថា សត្វឆ្កែដែលព្រុសនៅខាងក្រោយផ្ទះមានអាហារច្រើនជាងក្មេងទាំងនោះទៀត ។

នៅក្នុងបន្ទប់ដេករបស់ម្តាយ គាត់បានរកឃើញពូកទទេរមួយ គឺពូកតែមួយនៅក្នុងផ្ទះ ។ គាត់បានខំរករហូតបានឃើញកម្រាលមួយចំនួន ដាក់វានៅលើពូកនោះ ហើយដាក់ក្មេងទាំងប្រាំនាក់នោះឲ្យដេកនៅលើគ្រែបណ្តោះអាសន្ននេះ ។ បន្ទាប់មក គាត់បានលុតជង្គង់ចុះអធិស្ឋានទាំងទឹកភ្នែកទៅកាន់ព្រះវរបិតាទូលសុំការការពារដល់ពួកគេ ហើយបានពោលពាក្យរាត្រីសួស្តី ។

នៅពេលគាត់ បានក្រោកឡើង ហើយដើរទៅកាន់មាត់ទ្វារ មានក្មេងម្នាក់បានក្រោកចេញពីគ្រែ រត់មករកគាត់ កាន់ដៃគាត់ជាប់ ហើយបានអង្វរថា « *សូមពូយកខ្ញុំទៅចិញ្ចឹមបានទេ ?* » បងប្រុស ហ្វ្រីស្តូនបានដាក់ក្មេងនោះឲ្យទៅដេកវិញទាំងទឹកភ្នែក ហើយគាត់បានទៅរកម្តាយដែលញៀនថ្នាំ ( បុរសទាំងនោះបានរត់គេចអស់ហើយ ) ហើយបាននិយាយទៅកាន់នាងថា ៖ « ថ្ងៃស្អែកខ្ញុំនឹងមកម្តងទៀត ហើយផ្ទះនេះត្រូវតែមានការផ្លាស់ប្តូរមួយចំនួននៅពេលខ្ញុំដើរមកដល់ទ្វារនេះ ។ ហើយនឹងត្រូវមានការផ្លាស់ប្តូរថែមទៀតក្រោយពីនោះ ។ ត្រូវចាំពាក្យរបស់ខ្ញុំ » ។[4]

តើព្រឹត្តិការណ៍ទាំងបីនេះមានអ្វីដូចគ្នា ? វាផ្តល់នូវបទពិសោធន៍ពីជីវិតពិតខុសៗពីគ្នានៅក្នុងបាប៊ីឡូន—រឿងមួយបង្ហាញពីឥរិយាបថដ៏អាក្រក់នៅការប្រកួតបាល់បោះ រឿងមួយទៀតនិយាយពីឧបសគ្គខាងវប្បធម៌របស់មនុស្ស



ម្នាក់ៗជាមួយនឹងអ្នកដែលរស់នៅខុសប្លែកពីយើង ហើយមួយទៀតបង្ហាញពីបញ្ហាមួយដ៏ធ្ងន់ធ្ងរ ។

***មេរៀនទី 1 ៖ កុំភ្លេចពីបទដ្ឋានសាសនារបស់អ្នក***

ដំបូង ចូរយើងបញ្ចប់ព្រឹត្តិការណ៍បាល់បោះ ។ ថ្ងៃក្រោយពីការប្រកួតនោះ ពេលដែលមានគំនិតគិតគូរពីសាធារណៈមួយចំនួន និងការអំពាវនាវឲ្យប្រែចិត្តចំពោះព្រឹត្តិការណ៍នោះ យុវជនម្នាក់បាននិយាយថា ៖ « សូមស្ដាប់ ។ យើងកំពុងនិយាយពីកីឡាបាល់បោះនៅទីនេះ ពុំមែនសាលាថ្ងៃអាទិត្យទេ ។ ប្រសិនអ្នកមិនអាចទ្រាំទ្រនឹងការស្រែកនេះបាន អញ្ចឹងកុំលេងកីឡា ។ យើងចំណាយប្រាក់ជាច្រើនមកមើលការប្រកួតទាំងនេះ ។ យើងអាចប្រព្រឹត្តតាមដែលយើងចង់ធ្វើ។ យើងភ្លេចបទដ្ឋានសាសនារបស់យើង » ។

« យើងភ្លេចបទដ្ឋានសាសនារបស់យើង » ? មេរៀនទីមួយសម្រាប់ការស្ថាបនាក្រុងស៊ីយ៉ូននៅក្នុងសតវត្សរ៍ទី 21 ៖ អ្នក*មិនត្រូវ*ភ្លេចពីបទដ្ឋានសាសនារបស់អ្នកនោះទេ ។

ភាពជាសិស្សបែបនេះមិនអាចកើតមានបានឡើយ—វាពុំមែនភាពជាសិស្សនោះទេ ។ ពេលព្យាការីអាលម៉ាបានបង្រៀនថា យើងត្រូវ « ឈរជាសាក្សីដល់ព្រះនៅគ្រប់ពេល និងគ្រប់សេចក្ដី និងគ្រប់ទីកន្លែងដែល[ យើង ]បាននៅ » (ម៉ូសាយ 18:9)—*ពុំមែន* គ្រាន់តែពេលខ្លះ កន្លែងមួយចំនួន ឬពេលដែលក្រុមយើងនាំមុខច្រើននោះទេ ។

ទោះក្នុងស្ថានភាព ឬការញុះញង់ ឬបញ្ហាណាក៏ដោយ គ្មានសិស្សពិតណាម្នាក់របស់ព្រះគ្រីស្ទអាចបំភ្លេចនូវបទដ្ឋានសាសនារបស់ខ្លួនបានឡើយ ។

***មេរៀនទី 2 ៖ មានចិត្តមេត្តា ប៉ុន្តែត្រូវស្មោះត្រង់ចំពោះព្រះបញ្ញត្តិ***

ការនោះបានដឹកនាំខ្ញុំទៅរកយុវនារីនៅឯការប្រជុំធម្មនិដ្ឋាននោះ ។ ប៉ុន្តែមនុស្សម្នាក់នឹងឆ្លើយតបចំពោះនាងនូវច្បាប់ជារៀងរហូតនោះគឺថា ឥរិយាបថរបស់យើងឆ្លុះបញ្ចាំងពីជំនឿសាសនាចក្រ និង ការតាំងចិត្តរបស់យើងចំពោះដំណឹងល្អ ។ ហេតុដូច្នោះហើយ របៀបដែលយើងឆ្លើយតបចំពោះស្ថានភាពណាក៏ដោយ ត្រូវតែធ្វើឲ្យអ្វីៗប្រសើរឡើង មិនមែនកាន់តែអាក្រក់ទៅៗនោះទេ ។ ក្នុងករណីនេះ យើងមិនអាចប្រព្រឹត្ត ឬ មានប្រតិកម្ម ក្នុងរបៀបមួយដែលថា យើងមានកំហុសព្រោះយើងជាអ្នកធ្វើឲ្យមានការអាក់អន់ចិត្ត ជាងដែលនាងធ្វើឲ្យមានការអាក់អន់ចិត្តនោះទេ ។

នោះមិនមែនមានន័យថា យើងពុំមានមតិយោបល់ ថាយើងពុំមានបទដ្ឋានថាដោយរបៀបណាមួយនោះ យើងមិនគោរពសោះចំពោះអ្វីដែលបានបញ្ជាដោយទេវភាពថា « ត្រូវឲ្យឯង » និង « ហាមមិនឲ្យឯង » នៅក្នុងជីវិតនោះទេ ។ ប៉ុន្តែ វាពិតជាមានន័យថា យើងត្រូវតែរស់នៅតាមបទដ្ឋានទាំងនោះ ហើយគាំទ្របញ្ញត្តិទាំងនោះ នៅក្នុងរបៀបដ៏សុចរិតមួយ ឲ្យអស់ពីសមត្ថភាពរបស់យើងជារបៀបមួយដែលព្រះអង្គសង្គ្រោះបានរស់នៅ និង បានការពារបទដ្ឋានទាំងនោះ ។ ហើយទ្រង់តែងតែបានធ្វើនូវអ្វីដែលគួរត្រូវធ្វើ ដើម្បីធ្វើឲ្យស្ថានភាពប្រសើរឡើង—រាប់ចាប់ពីការបង្រៀនសេចក្ដីពិត ទៅដល់ការអត់ទោសដល់ពួកអ្នកមានបាប សម្អាតព្រះវិហារបរិសុទ្ធ ។

ដូច្នេះជាមួយនឹងមិត្តថ្មីរបស់យើង យើងចាប់ផ្ដើមនូវចំណុចខាងលើ ដោយចង់ចាំថា នាងគឺជាបុត្រីម្នាក់របស់ព្រះ ហើយមានតម្លៃអស់កល្បជានិច្ច ។ យើងចាប់ផ្ដើមដោយចងចាំថា នាងគឺជាកូនស្រីរបស់មនុស្សម្នាក់ ។ យើងចាប់ផ្ដើម

ដោយការមានអំណរគុណថា នាងមកកាន់សកម្មភាពសាសនាចក្រ មិនបានគេចវេស ។ និយាយឲ្យខ្លីទៅ យើងព្យាយាមឲ្យអស់ពីសមត្ថភាពរបស់យើងនៅក្នុងស្ថានភាពនេះ គឺនៅក្នុងបំណងប្រាថ្នាដើម្បីជួយនាងឲ្យធ្វើអស់ពីសមត្ថភាពរបស់នាង ។

យើងបន្តការអធិស្ឋានដោយស្ងាត់ស្ងៀម ៖ តើអ្វីទៅជាការណ៍ល្អដើម្បីធ្វើនៅទីនេះ ? តើអ្វីទៅជាការណ៍ល្អដើម្បីនិយាយ ? តើ*នៅទីបំផុត*អ្វីទៅនឹងធ្វើឲ្យស្ថានភាពនេះ និង រូបនាងបានប្រសើរឡើង ? ការសួរសំណួរទាំងនេះ និង ការព្យាយាមយ៉ាងពិតប្រាកដដើម្បីធ្វើអ្វីដែលព្រះអង្គសង្គ្រោះធ្វើ គឺជាអ្វីដែលខ្ញុំគិតថា ទ្រង់មានន័យដូចម្ដេច ពេលទ្រង់បានមានបន្ទូលថា « កុំឲ្យជំនុំជម្រះតាមភាពដែលមើលឃើញតែខាងក្រៅឡើយ ត្រូវជំនុំជម្រះតាមសេចក្ដីសុចរិតវិញ » (យ៉ូហាន 7:24) ។

សាសនាចក្រពុំដែលបន្ទាបគោលលទ្ធិរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងសុឆន្ទៈរបស់សង្គម ឬ ការចាំបាច់ខាងនយោបាយ ឬដោយប្រការណាមួយឡើយ ។ មានតែការស្ថិតនៅទីសុវត្ថិភាពនៃសេចក្ដីពិតដែលបានបើកសម្ដែងប៉ុណ្ណោះទេ ដែលអាចជួយយើងឲ្យជួយលើកអ្នកផ្សេងទៀតដែលអាចមានបញ្ហា ឬ មានអារម្មណ៍ថាត្រូវបោះបង់ ។ សេចក្ដីអាណិតអាសូររបស់យើង និង សេចក្ដីស្រឡាញ់របស់យើង—ដែលជាចរិតលក្ខណៈ និង ជាតម្រូវការគ្រឹះនៃភាពជាពួកគ្រីស្ទានរបស់យើង—ត្រូវតែ*មិន*ត្រូវបានបកស្រាយថា ជាការបន្ទាបសម្រួលបទបញ្ញត្តិទាំងឡាយសោះឡើយ ។

នៅពេលជួបនឹងស្ថានភាពបែបនេះ វាអាចក្លាយជារឿងដ៏លំបាក ហើយច្របូកច្របល់ ។ យុវវ័យអាចសួរថា « មែនហើយ យើងមិនជឿថា យើងគួររស់នៅ ឬ ប្រព្រឹត្តតាមរបៀបនេះទេ ចុះតើហេតុអ្វីបានជាយើងត្រូវធ្វើឲ្យមនុស្សដទៃទៀតធ្វើដូចគ្នានេះដែរ ? តើពួកគេពុំមានសិទ្ធិជ្រើសរើសរបស់ពួកគេទេឬ ? តើយើងមិនកំពុងតែគិតពីភាពសុចរិតផ្ទាល់ខ្លួន និង វិនិច្ឆ័យទេឬ ដែលបង្ខំអ្នកដទៃឲ្យធ្វើតាមជំនឿយើង ដែលទាមទារ*ពួកគេ*ក៏ដូចជាខ្លួនយើងដែរ ឲ្យប្រព្រឹត្តតាមរបៀបជាក់លាក់មួយនោះ ? »

ក្នុងស្ថានភាពទាំងនោះ អ្នកនឹងត្រូវតែពន្យល់ដោយប្រុងប្រយ័ត្នពីអារម្មណ៍គេពីមូលហេតុដែលគោលការណ៍*មួយចំនួន*ត្រូវបានការពារ និង អំពីបាបមួយចំនួនត្រូវបានជំទាស់*ពេលដែលត្រូវបានរកឃើញ*ពីព្រោះបញ្ហា និង ច្បាប់ទាំងឡាយដែលជាប់ទាក់ទង គឺ*មិន*គ្រាន់តែជាខាងសង្គម ឬ នយោបាយនោះទេ ប៉ុន្តែវាមានលទ្ធផលដ៏អស់កល្បជានិច្ច ។ ហើយខណៈដែលគ្មានបំណងខ្វែងគំនិតទាស់នឹងពួកអ្នកដែលជឿខុសពីយើង អាក់អន់ចិត្ត នោះយើងរឹតតែមិនចង់ធ្វើឲ្យព្រះអន់ព្រះទ័យទៅទៀត ។

វាស្រដៀងបន្តិចដែរទៅនឹងយុវវ័យម្នាក់ដែលនិយាយថា « ឥឡូវនេះ ដោយខ្ញុំអាចបើកឡានបានហើយ នោះខ្ញុំដឹងថា ខ្ញុំត្រូវឈប់នៅភ្លើងក្រហម ប៉ុន្តែតើយើងពិតជាត្រូវតែវិនិច្ឆ័យ ហើយព្យាយាមឲ្យមនុស្សគ្រប់គ្នាផ្សេងទៀតឈប់នៅភ្លើងក្រហមដែរឬ ? » តើ*មនុស្សគ្រប់គ្នា*ត្រូវតែធ្វើដូចយើងមែនទេ ? « តើអ្នកដទៃទៀតពុំមានសិទ្ធិជ្រើសរើសរបស់ពួកគេទេឬ ? » តើពួកគេត្រូវប្រព្រឹត្តដូចយើងដែរឬ ? » បន្ទាប់មក អ្នកត្រូវពន្យល់ថា មែនហើយ យើងពិតជាសង្ឃឹមថា*មនុស្សទាំងអស់គ្នា*នឹងឈប់នៅភ្លើងក្រហម ។ ហើយអ្នកត្រូវធ្វើដូចនេះ *ដោយមិន*បន្ទាបបន្ថោកដល់ពួកអ្នកបំពានរំលង ឬ អ្នកដែលជឿខុសពីយើងនោះទេ ពីព្រោះ មែនហើយ ពួកគេពិតជាមានសិទ្ធិជ្រើសរើសខាងសីលធម៌របស់ពួកគេ ។

មិត្តវ័យក្មេងរបស់ខ្ញុំអើយ ក្នុងពិភពលោកនេះ មានភាពខុសប្លែកគ្នាខាងការជឿទាំងឡាយ យ៉ាងធំសម្បើមហើយមាននូវសិទ្ធិសេរីភាពខាងសីលធម៌សម្រាប់មនុស្សទាំងអស់គ្នា ប៉ុន្តែគ្មាននរណាម្នាក់ត្រូវបានផ្ដល់សិទ្ធិឲ្យប្រព្រឹត្តដូចជា ព្រះទ្រង់នៅស្ងៀមស្ងាត់ ពុំមានបន្ទូលអ្វីសោះចំពោះរឿងទាំងនេះ ឬ ដូចជាបទបញ្ញត្តិគ្រាន់តែសំខាន់ ប្រសិនបើមានការយល់ស្របពីសាធារណៈនោះ ។ នៅសតវត្សរ៍ទី 21 យើងមិនអាចភៀសខ្លួនចេញទៀតឡើយ ។ យើងនឹងតតាំងគាំទ្រច្បាប់ កាលៈទេសៈ និង មជ្ឈដ្ឋាននានាដែលអនុញ្ញាតឲ្យមានការអនុវត្ត ដោយសេរីខាងសាសនា ហើយមានសាសនារបស់យើងនៅក្នុងនោះដែរ ។ នោះជាវិធីមួយដែលយើងត្រូវអត់ធ្មត់នៅក្នុងបាប៊ីឡូន ប៉ុន្តែពុំមែនដោយសារវាឡើយ ។

***តវិយាបថរបស់យើងត្រូវឆ្លុះបញ្ចាំងពីជំនឿសាសនាចក្ររបស់យើង និង ពីការតាំងចិត្តរបស់យើងចំពោះដំណឹងល្អ ។ ហេតុដូច្នោះហើយ របៀបដែលយើងឆ្លើយតបចំពោះស្ថានភាពណាក៏ដោយ ត្រូវតែធ្វើឲ្យអ្វីៗប្រសើរឡើង មិនមែនកាន់តែអាក្រក់ទៅៗនោះទេ ។***

ខ្ញុំពុំបានស្គាល់ពីសមត្ថភាពណាដែលសំខាន់ជាងនេះ និង សច្ចធម៌ណាដែលអស្ចារ្យជាងនេះ សម្រាប់យើងនឹងបង្ហាញក្នុងលោកីយ ជាងការដើរតាមផ្លូវដ៏ប្រុងប្រយ័ត្ននោះទេ—តាំងជំហរសីលធម៌ ទៅតាមអ្វីដែលព្រះបានប្រកាស និង ទៅតាមក្រិត្យវិន័យដែលទ្រង់បានប្រទាន ដោយអនុវត្តតាមដោយសេចក្ដីអាណិតស្រឡាញ់ ដោយការយល់ចិត្ត និង ដោយសេចក្ដីសប្បុរសដ៏អស្ចារ្យ ។

#### *មេរៀនទី 3 ៖ ប្រើគុណតម្លៃដំណឹងល្អដើម្បីផលប្រយោជន៍សហគមន៍ និង ប្រទេសជាតិ*

ពុំមែនយើងភាគច្រើននឹងក្លាយជាមន្ត្រីប៉ូលីស ឬ ភ្នាក់ងារសេវាសង្គម ឬ ចៅក្រមដែលបម្រើនៅក្នុងប្រព័ន្ធច្បាប់នោះទេ ប៉ុន្តែយើងទាំងអស់គ្នា គួរតែខ្វល់ខ្វាយអំពីសុខុមាលភាពរបស់អ្នកដទៃ និង សុវត្ថិភាពខាងសីលធម៌ក្នុងសមាគមន៍ដ៏ទូលំទូលាយរបស់យើង ។ អែលឌើរ ឃ្វីនថិន អិល ឃុក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានជូនសុន្ទរកថាសន្និសីទទូទៅទាំងស្រុង អំពីប្រធានបទនេះ កាលពីពីរឆ្នាំកន្លងទៅ ។ នៅក្នុងការនិយាយអំពីសេចក្ដីត្រូវការរបស់យើង ដើម្បីមានឥទ្ធិពលក្នុងសង្គម ក្រៅពីគេហដ្ឋានរបស់យើង លោកបានមានប្រសាសន៍ថា ៖

« ដើម្បីបន្ថែមការការពារក្រុមគ្រួសាររបស់យើង នោះយើងគួរតែធ្វើជាប្រភពនៃពន្លឺ ដើម្បីការពារសហគមន៍របស់យើង ។ ចូរចាំថា ៖ ‹ ឲ្យពន្លឺរបស់អ្នករាល់គ្នា



បានភ្លឺទៅមុខមនុស្សលោកយ៉ាងនោះដែរ ដើម្បីឲ្យគេឃើញការល្អដែលអ្នករាល់គ្នា ប្រព្រឹត្តរួចសរសើរតម្កើងដល់ព្រះវរបិតានៃអ្នករាល់គ្នាដែលគង់នៅស្ថានសួគ៌ › ( ម៉ាថាយ 5:16 ) ។ . . .

« នៅក្នុងពិភពលោកដែលភាពទុច្ចរិតកំពុងតែកើនឡើង នោះវាសំខាន់ដែលគុណតម្លៃផ្តោតទៅលើជំនឿសាសនាក្លាយជា [ ភស្តុតាងនៅក្នុង ] ត្រចៀក និង ភ្នែកនៃសាធារណៈ ។ . . .

« ជំនឿសាសនា គឺជាប្រភពពន្លឺ ចំណេះដឹង និង ប្រាជ្ញា ហើយមានប្រយោជន៍ដល់សង្គមយ៉ាងខ្លាំង » ។[5]

ប្រសិនបើយើងពុំយកពរជ័យនៃដំណឹងល្អទៅកាន់ពហុសហគមន៍ និង ប្រទេសរបស់យើងទេ នោះធាតុពិតដ៏សាមញ្ញនៃបញ្ហានេះនឹងកើតមាន គឺថាយើងនឹងពុំអាចមានប៉ូលីសគ្រប់គ្រាន់—ក៏នឹងពុំមានអ៊ីសាក ញ្ញ៉ូស្តូន គ្រប់គ្រាន់—ដើម្បីជួយអនុវត្តឲ្យមានឥរិយាបទមានសីលធម៌ ទោះបីជាដោយការបង្ខំក្តី ។ ហើយវាគ្មានទេ ។ កូនចៅទាំងឡាយដែលនៅក្នុងផ្ទះគ្មានអាហារបរិភោគ ឬ សម្លៀកបំពាក់ស្លៀកពាក់ គឺជាបុត្រា និង បុត្រីរបស់ព្រះ ។ ម្តាយរូបនោះ ដែលគួរមានការទទួលខុសត្រូវច្រើន ដោយសារតែនាងមានវ័យចាស់ជាង ឬ គួរតែមានការទទួលខុសត្រូវច្រើន រីឯបុត្រីម្នាក់របស់ព្រះដែរក៏ដូច្នោះដែរ ។ ស្ថានភាពដូច្នោះ អាចនឹងតម្រូវឲ្យមានក្តីស្រឡាញ់ជាផ្លូវការច្រើន ក៏ដូចជាផ្លូវច្បាប់ដែរ ប៉ុន្តែយើងត្រូវតែព្យាយាមជួយក្នុងពេលវេលា និង ទីកន្លែងណា ដែលយើងអាចធ្វើបាន ដោយសារយើងពុំភ្លេចពីបទដ្ឋានសាសនាក៏ដូចជាពេលយើងមានអារម្មណ៍ថាអ្នកដទៃ កំពុងតែធ្វើទង្វើរគួរឲ្យអាណិត ឬពុំទទួលខុសត្រូវដែរ ។

មែនហើយ យើងមិនអាចធ្វើអ្វីគ្រប់យ៉ាងបានទេ ប៉ុន្តែយើងអាចធ្វើនូវរឿងមួយបាន ។ ហើយនៅក្នុងចម្លើយចំពោះការហៅរបស់ព្រះ « កូនចៅអ៊ីស្រាអែល » គឺជាអ្នកដែលត្រូវធ្វើវា—ពុំមែនត្រូវភៀសខ្លួនពីបាប៊ីឡូននៅពេលនេះទេ ប៉ុន្តែត្រូវប្រយុទ្ធនឹងវា ។ ដោយពុំឆោតល្ងង់ចំពោះបញ្ហានេះ យើងអាចរស់នៅតាមសាសនារបស់យើងដោយមោះមុត និង មិនប្រែប្រួល ដើម្បីយើងរកឃើញគ្រប់ឱកាសដើម្បីជួយគ្នា ជួយដល់ក្រុមគ្រួសារ ប្រទានពរដល់អ្នកជិតខាង និង ការពារដល់អ្នកដទៃ រួមទាំងជំនាន់កំពុងពេញវ័យ ។



*ពួកបរិសុទ្ធថ្ងៃចុងក្រោយ ត្រូវបានហៅឲ្យធ្វើ ជាមេដំបែរ នៅក្នុងដុំម្សៅ ធ្វើជាអំបិលដែលពុំបាត់បង់ជាតិប្រៃរបស់វា ធ្វើជាពន្លឺដែលនៅលើភ្នំ មិនលាក់ពន្លឺនៅក្នុងថាំងឡើយ ។*

**បង្ហាញសេចក្ដីស្រឡាញ់របស់អ្នកចំពោះព្រះយេស៊ូវគ្រីស្ទ**

ពួកបរិសុទ្ធថ្ងៃចុងក្រោយ ត្រូវបានហៅឲ្យធ្វើ ជាមេដំបែរ នៅក្នុងដុំម្សៅ ធ្វើជាអំបិលដែលពុំបាត់បង់ជាតិប្រៃរបស់វា ធ្វើជាពន្លឺដែលនៅលើភ្នំ មិនលាក់ពន្លឺនៅក្នុងថាំងឡើយ ។ ដូច្នេះសូមចាប់ផ្ដើមចែកចាយ !

ប្រសិនបើយើងធ្វើត្រូវ ហើយនិយាយត្រូវ និង ឈោងទៅរកគេដោយសប្បុរសទាំងតាមពាក្យសម្ដី និង ទង្វើរបស់យើង ពេលព្រះអង្គសង្គ្រោះកាត់កិច្ចការដោយសេចក្ដីសុចរិតរបស់ទ្រង់ឲ្យខ្លី នោះនឹងពាក្យបន្លឺឡើងថា គ្រាកាន់កាប់ត្រួតត្រាចុងក្រោយនេះដល់ទីបញ្ចប់ហើយ គ្រាកាន់កាប់ត្រួតត្រាដ៏ធំ រួចចូលមកក្នុងសិរីល្អរបស់ទ្រង់ នោះទ្រង់នឹងរកឃើញថាយើង— អ្នក និង ខ្ញុំ ហើយយើងទាំងអស់គ្នា— បានខំអស់ពីលទ្ធភាពរបស់យើង ព្យាយាមរស់នៅតាមដំណឹងល្អ ព្យាយាមកែលំអរជីវិតរបស់យើង សាសនាចក្រ និង សង្គមរបស់យើង យ៉ាងល្អបំផុតតាមដែលយើងអាចធ្វើបាន ។

នៅពេលទ្រង់យាងមក ខ្ញុំចង់ឲ្យទ្រង់ឃើញថា ខ្ញុំកំពុងរស់នៅក្នុងដំណឹងល្អ *ខ្លាំងណាស់* ។ ខ្ញុំចង់មានការភ្ញាក់ផ្អើលនោះចំពេលកំពុងតែចែកចាយសេចក្ដីជំនឿ និងធ្វើអ្វីដែលល្អបើខ្ញុំអាច ។ ខ្ញុំចង់ឮព្រះអង្គសង្គ្រោះមានបន្ទូលមកខ្ញុំថា ៖ « ដេហ្វ៊ី យើងស្គាល់អ្នកពុំមែនដោយសារតែការហៅរបស់អ្នកទេ ប៉ុន្តែស្គាល់អ្នកដោយសារជីវិតអ្នក របៀបដែលអ្នកកំពុងព្យាយាមរស់នៅតាម និង បទដ្ឋានដែលអ្នកកំពុងតែព្យាយាមការពារ ។ យើងមើលឃើញសេចក្ដីសុចរិតក្នុងចិត្តអ្នក ។ យើងដឹងថាអ្នកបានព្យាយាមធ្វើឲ្យអ្វីៗបានល្អប្រសើរជាមុនសិន បន្ទាប់មកព្យាយាមធ្វើឲ្យខ្លួនអ្នកបានល្អប្រសើរ រួចហើយតាមរយៈការប្រកាសបន្ទូលរបស់យើង និង ការការពារដំណឹងល្អរបស់យើង ដើម្បីអ្នកដទៃ តាមរបៀបដ៏មេត្តាបំផុតតាមដែលអ្នកអាចធ្វើបាន » ។

ទ្រង់នឹងបន្តមានបន្ទូលថា ៖ « យើងដឹងថា អ្នកពុំមានជោគជ័យជានិច្ចកាលនោះទេ ជាមួយនឹងអំពើបាបផ្ទាល់ខ្លួនរបស់អ្នក ឬ ស្ថានភាពនានារបស់អ្នកដទៃ ប៉ុន្តែយើងជឿថាអ្នកបានព្យាយាមយ៉ាងស្មោះត្រង់ ។ យើងជឿទៅលើដួងចិត្តរបស់អ្នក ថាអ្នកពិតជាស្រឡាញ់យើង » ។

ខ្ញុំចង់មានរឿងដូច្នោះនៅថ្ងៃណាមួយ ជាងអ្វីទាំងអស់ក្នុងជីវិតរមែងស្លាប់នេះ ។ ហើយខ្ញុំចង់បានសម្រាប់អ្នក ។ ខ្ញុំចង់បានសម្រាប់យើងទាំងអស់គ្នា ។ « អ៊ីស្រាអែល អ៊ីស្រាអែល ព្រះកំពុងហៅ »[6]—កំពុងហៅយើងឲ្យរស់នៅដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទផ្ទាល់ខ្លួន តាមរបៀបតូចៗ ក៏ដូចជារបៀបធំៗផងដែរ រួចហើយឈោងទៅរកអ្នកទាំងឡាយដែលមើលទៅពុំដូចរូបអ្នក ឬ មានឥរិយាបថពុំដូចយើង បន្ទាប់មក ( បើអ្នកអាច ) សូមទៅឲ្យហួសពីនោះ ដើម្បីបម្រើនៅក្នុងសមាគមដ៏ធំបំផុត ដែលអ្នកអាចមានឥទ្ធិពល ។

ខ្ញុំស្រឡាញ់ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ដែលខ្ញុំព្យាយាមធ្វើជាអ្នកបម្រើទ្រង់ ។ ហើយខ្ញុំស្រឡាញ់ព្រះវរបិតាសួគ៌របស់យើង ដែលយកព្រះទ័យទុកដាក់ចំពោះយើងគ្រប់គ្រាន់ ដែលបានប្រទានអង្គទ្រង់ដល់យើង ។ ទាក់ទងនឹងអំណោយទាននោះ ខ្ញុំដឹងថា ព្រះកំពុងហៅអ៊ីស្រាអែលនៅថ្ងៃចុងក្រោយនេះឲ្យប្រែក្លាយដូចព្រះគ្រីស្ទ ហើយបរិសុទ្ធជាងអ្វីដែលយើងមាននៅពេលនេះនៅក្នុងការតាំងចិត្តរបស់យើង ដើម្បីរស់នៅតាមដំណឹងល្អ និង ស្ថាបនាក្រុងស៊ីយ៉ូន ។ ខ្ញុំក៏ដឹងផងដែរថា ទ្រង់នឹងប្រទានដល់យើងទាំងកម្លាំង និង ភាពបរិសុទ្ធ ដើម្បីក្លាយជាសិស្សពិត បើយើងអង្វរចង់បាន ។ ■

*ដកស្រង់ចេញពីសុន្ទរកថាក្នុងការប្រជុំធម្មនិដ្ឋានស៊ី.អ៊ី.អេស « Israel, Israel, God Is Calling » ធ្វើឡើងនៅសាកលវិទ្យាល័យរដ្ឋឌីកស៊ី នៅសេន ចច រដ្ឋ យូថាហ៍ នៅថ្ងៃទី 9 ខែ កញ្ញា ឆ្នាំ 2012 ។ សម្រាប់សុន្ទរកថាទាំងស្រុង សូមចូលទៅ lds.org/broadcasts។*

**កំណត់ចំណាំ**


1. សូមមើល ភែរី មីលើ Errand into the Wilderness ( ឆ្នាំ 1956 ) ទំព័រ 2–3 ។
2. « មកមកពួកបរិសុទ្ធ » *ទំនុកតម្កើង* ទំព័រ 2 ។
3. ព្រិកហាំ យ៉ង់ ក្នុង ជេមស៍ អេស ប្រោន Life of a Pioneer: Being the Autobiography of James S. Brown ( ឆ្នាំ 1900 ) ទំព័រ 121 ។
4. អ៊ីសាក ហ្វ្រីស្តូន បទពិសោធន៍ដែលចែកចាយនឹងអ្នកនិពន្ធនៅថ្ងៃទី 5 ខែ ឧសភា ឆ្នាំ 2012 ។
5. ឃ្វីនថិន អិល ឃុក « Let There Be Light ! » Liahona, ខែ វិច្ឆិកា ឆ្នាំ 2010 ទំព័រ 28, 29 ។
6. «Israel, Israel, God Is Calling» Hymns, លេ.រ. 7 ។


រូបថតនៃទីក្រុងដោយ TLA144/ISTOCKPHOTO/THINKSTOCK រូបថតទៀនដោយ ENSKANTO/ISTOCKPHOTO/THINKSTOCK

# ការកត់ចំណាំខ្ញុំលើថ្មមុខផ្នូរ

នៅរដូវក្ដៅឆ្នាំ 2003 ខ្ញុំបាននៅរដ្ឋ មីឈីហ្គេន ស.រ.អា. ធ្វើការស្រាវជ្រាវឡើងវិញពីពូទួតរបស់ខ្ញុំឈ្មោះ រ៉ូប៊ឺត ហល ។ នៅចុងបញ្ចប់នៃដំណើររបស់ខ្ញុំ ខ្ញុំបានទៅកន្លែងបញ្ចុះសពមួយម្ដងទៀត ដែលខ្ញុំធ្លាប់ទៅកាលពី 20 ឆ្នាំមុន ។

កាលខ្ញុំបានទៅទីបញ្ចុះសពនោះកាលពីមុន ខ្ញុំបានឃើញមានផ្កានៅលើថ្មដាក់នៅមុខផ្នូរមួយដែលមានត្រកូលថា ហល ។ ពេលនេះខ្ញុំបានសរសេរកំណត់ចំណាំមួយ ដាក់កាលបរិច្ឆេទ ហើយអ៊ុតប្លាស្ទីកវាដើម្បីការពារនឹងអាកាសធាតុ ។ បន្ទាប់មក ខ្ញុំបានទុកកំណត់ចំណាំនោះលើថ្មនោះប្រកបដោយការអធិស្ឋាន ដោយសង្ឃឹមថានឹងមានមនុស្សម្នាក់នឹងមើលឃើញវា ហើយគាត់អាចជួយខ្ញុំឲ្យរៀនបន្ថែមទៀតពីរ៉ូប៊ឺត ហល ។ ខ្ញុំបានត្រឡប់មកផ្ទះនៅកាលីហ្វ័រញ៉ាវិញដោយក្ដីសង្ឃឹម ប៉ុន្តែសង្ស័យថាតើនឹងមានកើតឡើងចំពោះកំណត់ចំណាំនេះដែរទេ ។

មួយសប្ដាហ៍ក្រោយមក ខ្ញុំបានទទួលសំបុត្រមួយពីបងប្អូនជីដូនមួយដែលរស់នៅឆ្ងាយឈ្មោះ ខេក បេនលី ។

គាត់បានសរសេរថា « ម្សិលមិញ ខ្ញុំមានបទពិសោធន៍មួយចម្លែក » ។ « នៅម៉ោង 3:00 រសៀល ខ្ញុំបានចេញទៅទិញផ្លែស្ត្របឺរី ខណៈនោះខ្ញុំបានសម្រេចចិត្តឈប់នៅលើផ្លូវនៃទីបញ្ចុះសព ដើម្បីមើលផ្នូររបស់ដូនតាខ្ញុំ ។ ខ្ញុំមិនបានទៅទីនោះពីរបីឆ្នាំហើយ ។ នៅក្បែរផ្នូរនោះខ្ញុំបានឃើញកាតរបស់ឯង » ។




គំនូរដោយ ប្រាយអិន ប៊ីច

> **ខ្ញុំបានទុកកំណត់ចំណាំនោះលើថ្មនោះប្រកបដោយការអធិស្ឋាន ដោយសង្ឃឹមថានឹងមានមនុស្សម្នាក់នឹងមើលឃើញវា ហើយគាត់អាចជួយខ្ញុំឲ្យរៀនបន្ថែមទៀតពីរ៉ូប៊ឺត ហល ។**

ខេក បានទៅទីបញ្ចុះសពនោះថ្ងៃតែមួយដែលខ្ញុំបានទុកកាតនោះ ។ ខ្ញុំក៏បានទូរស័ព្ទទៅគាត់ភ្លាម ។ នៅក្នុងការពិភាក្សារបស់យើងខ្ញុំបានរកឃើញថាគាត់រស់នៅហ៊ីលស្ដេល មានចម្ងាយលើសពី 80 គ.ម. ពីទីបញ្ចុះសពនោះ ។

ពីរបីខែក្រោយមក ខ្ញុំត្រឡប់ទៅមីឈីហ្គេនវិញដើម្បីទៅលេងនឹងខេកដោយក្ដីរំភើប ។ គាត់បានប្រាប់ខ្ញុំថា គាត់មានសាច់ញាតិដែលបញ្ចុះនៅទីបញ្ចុះសពទល់មុខនឹងផ្ទះរបស់គាត់ ហើយគាត់បានសួរខ្ញុំថាតើខ្ញុំចង់ទៅទីនោះដែរឬទេ ។ គាត់បានប្រាប់ខ្ញុំថា ទីបញ្ចុះសពនោះមានថ្មដាក់មុខផ្នូរបួនរបស់គ្រួសារ ហល ពីរដែលគាត់មិនស្គាល់ ។

នៅឯទីបញ្ចុះសពនោះ ខេកបានបង្ហាញខ្ញុំពីថ្មទាំងនោះ ។ ថ្មពីរដែលគាត់មិនស្គាល់ជារបស់ ម៉ាទីន និង អាន់ណា ហល ។ ខ្ញុំមិនបានយកកំណត់ត្រារបស់ខ្ញុំមកជាមួយទេ ប៉ុន្តែខ្ញុំនៅចាំថា ខ្ញុំបានស្រាវជ្រាវឡើងវិញពី ម៉ាទីន ហល ។

យើងបានប្រញាប់ប្រញាល់ទៅតុលាការស្រុកមួយម៉ោងមុនវាបិទ ដោយសង្ឃឹមថា កំណត់ត្រារបស់មនុស្សស្លាប់នឹងបញ្ជាក់ពីឪពុកម្ដាយរបស់ ម៉ាទី ។ វាបានបញ្ជាក់មែន ! ឪពុករបស់ម៉ាទីនគឺ រ៉ូប៊ឺត ហល ! ព្រះវិញ្ញាណបរិសុទ្ធបានបញ្ជាក់ចំពោះខ្ញុំថា ការស្រាវជ្រាវរបស់ខ្ញុំជាយូរមកហើយត្រូវបានបញ្ចប់ ។

ខេកដែលពុំមែនជាសមាជិកនៃសាសនាចក្របានថ្លែងថា ការស្វែងរករ៉ូប៊ឺត ហល ហាក់ដូចជា « រឿងខាងវិញ្ញាណ » ។ ខ្ញុំបានញញឹម ដោយដឹងថា ព្រះវិញ្ញាណបានដឹកនាំខ្ញុំ ។

ខេក បានថ្លែងថា « ឯងប្រហែលជាធ្លាប់ខកបំណងដោយសារអ្នកពុំបានទុកកំណត់ចំណាំកាលពី 20 ឆ្នាំ មុន ប៉ុន្តែតាមពិតទៅ ខ្ញុំទើបផ្លាស់មកនៅហ៊ីលស្ដេលបីឆ្នាំមុនប៉ុណ្ណោះ ! »

បទពិសោធន៍នេះជាមេរៀនមួយសម្រាប់ខ្ញុំថា ពង្សប្រវត្តិពិតជាផ្នែកមួយនៃកិច្ចការរបស់ព្រះមែន ហើយថាទ្រង់ដឹកនាំយើងនៅក្នុងកិច្ចការដ៏សុចរិត ។ ■

ម៉ារៀន ឆាព្លីន ស្លូវ៉ល កាលីហ្វ័រញ៉ា ស.រ.អា.

# តើព្រះអម្ចាស់នឹងប្រោសឲ្យកូនប្រុសរបស់យើងបានជាសះស្បើយដែរឬទេ ?

**នៅ**ពេលកូនប្រុសរបស់យើងមានអាយុបួនឆ្នាំ ជាញឹកញាប់គាត់បានសុំឲ្យខ្ញុំច្រៀងបទ « Master, the Tempest Is Raging ( ព្រះអម្ចាស់អើយ ខ្យល់ព្យុះកំពុងបក់បោកយ៉ាងខ្លាំង ) » (*Hymns* លេ.រ. 105) ។ ភ្នែកដ៏តូចៗរបស់គាត់បានមានពន្លឺនៅត្រង់វគ្គបន្ទរ ជាពេលដែលព្រះអម្ចាស់បញ្ជាឲ្យខ្យល់ និង ទឹករលកស្ងប់ ។ គាត់បានសួរខ្ញុំពីព្រះចេស្ដារបស់ព្រះយេស៊ូវ ។ ខ្ញុំបានឆ្លើយថា ព្រះយេស៊ូវអាចធ្វើកិច្ចការសុចរិតបានគ្រប់យ៉ាង ដោយសារទ្រង់មានព្រះចេស្ដាទាំងអស់ ។ ព្រះអង្គសង្គ្រោះគឺជាវីរៈបុរសរបស់កូនប្រុសយើង ។

ប៉ុន្តែនៅពេលកូនរបស់យើងមានអាយុ 13 ឆ្នាំ គាត់ធ្លាក់ចូលទៅក្នុងភាពអស់សង្ឃឹមយ៉ាងខ្លាំង ។ គាត់មិនចង់និយាយ ហើយថែមទាំងមិនចង់ទទួលទានអ្វីទាំងអស់ ។ គាត់មិនចង់ធ្វើអ្វីដែលគាត់បានធ្វើពីមុន ហើយជាពិសេសគាត់មិនចង់ចូលរួមនៅក្នុងការអធិស្ឋាន ឬ រាត្រីជួបជុំគ្រួសារឡើយ ។ គាត់ហាក់ដូចជាលែងមានចំណាប់អារម្មណ៍ចំពោះព្រះវិហារ ឬដំណឹងល្អទៀតហើយ ។

ជារឿយៗ សមាជិកផ្សេងទៀតក្នុងគ្រួសារយើងបានអធិស្ឋាន ហើយបានតមអាហារឲ្យគាត់ ហើយមានបងប្អូនប្រុសស្រីនៅក្នុងវួដ និង ស្តេកព្រមទាំងមិត្ត និង សាច់ញាតិជាច្រើនក៏បានធ្វើដូចគ្នាផងដែរ ។ កិច្ចខិតខំរបស់យើងប្រៀបដូចជាបទពិសោធន៍នៃអធិស្ឋានរបស់អាលម៉ាជាឪពុកសម្រាប់កូនប្រុសគាត់ ( សូមមើល ម៉ូសាយ 27:14, 22–23) ។

យើងមិនចង់បង្ខំកូនប្រុសរបស់យើងឲ្យទទួលដំណឹងល្អ ដូច្នេះយើងបានប្រាប់គាត់ថា គាត់ពុំចាំបាច់ចូលរួមនៅក្នុងការអធិស្ឋាន ឬរាត្រីជួបជុំក្រុមគ្រួសាររបស់យើងទេ ប៉ុន្តែថាយើងចង់ឲ្យគាត់នៅទីនោះជាមួយនឹងយើង ។ នៅពេលយើងធ្វើតាមបន្ទូលរបស់ព្រះអង្គសង្គ្រោះឲ្យ « អធិស្ឋាននៅក្នុងក្រុមគ្រួសារអ្នកដល់ព្រះវរបិតាដើម្បីឲ្យ.កូនចៅរបស់អ្នកអាចបានពរ » ( នីហ្វៃទី 3 18:21) ទាំងការអធិស្ឋានជាគ្រួសារ និង រាត្រីជួបជុំក្រុមគ្រួសាររបស់យើងកាន់តែមានភាពរឹងមាំ ។ យើងទទួលអារម្មណ៍ពីព្រះវិញ្ញាណនៅក្នុងផ្ទះរបស់យើង ។ ហើយទោះបីជាកូនប្រុសយើងមិននិយាយស្តីក្តី ក៏គាត់បាននៅទីនោះដែរ ។

បន្តិចម្តងៗរយៈពេលជាងពីរឆ្នាំ យើងបានឃើញថា ការអធិស្ឋាន និង រាត្រីជួបជុំក្រុមគ្រួសាររបស់យើងបានជះឥទ្ធិពលទៅលើកូនប្រុសរបស់យើង ។ នៅក្នុងរាត្រីជួបជុំគ្រួសារនាល្ងាចមួយ គាត់បានថ្លែងទីបន្ទាល់ពីព្រះអង្គសង្គ្រោះ រួចហើយបានសួរថា តើគាត់អាចរៀបចំរាត្រីជួបជុំក្រុមគ្រួសារបានទេ ។ គាត់បានចាប់ផ្តើមចូលរួមនៅក្នុងការអធិស្ឋានជាគ្រួសារ ហើយទៅព្រះវិហារដោយក្តីរីករាយ ។ គាត់បានទទួលនូវការផ្លាស់ប្តូរដួងចិត្តដ៏អស្ចារ្យមួយដែលបានកើតឡើង ពេលគាត់បានទទួលនូវសេចក្តីស្រឡាញ់ដ៏ប្រោសលោះរបស់ព្រះអង្គសង្គ្រោះ ( សូមមើល អាលម៉ា 5:26) ។ ព្រះអម្ចាស់ពិតជាបានសង្គ្រោះដល់កូនប្រុសរបស់យើងដោយព្រះចេស្តានៃការប្រោសព្យាបាលរបស់ទ្រង់មែន ។

គាត់បានចាប់ផ្តើមរីករាយ ហើយមានជីវិតស្រស់បស់សារជាថ្មី ដោយមានឆន្ទៈជួយដល់អ្នកដទៃ ហើយបង្ហាញសេចក្តីស្រឡាញ់ ។ គាត់បានប្រាប់ថា គាត់បានដឹងថា ព្រះអង្គសង្គ្រោះបានព្យាបាលគាត់ ។ ការសាកល្បងរបស់កូនប្រុសយើងបានជួយគាត់ មានទីបន្ទាល់មួយដ៏រឹងមាំ ហើយបង្កើនសេចក្តីស្រឡាញ់ និង ការទុកចិត្តទៅលើព្រះអង្គសង្គ្រោះ ។ គាត់បានបម្រើព្រះអម្ចាស់ជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ នៅបេសកកម្ម ប៊ួណូស អ៊ែរ៉េស អាហ្សង់ទីន ខាងត្បូង ។ បន្ទាប់ពីគាត់ត្រឡប់មកវិញគាត់បានរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ ហើយគាត់ និង ភរិយាមានកូនស្រីម្នាក់ដ៏ស្រស់ស្អាត ។

ខ្ញុំដឹងថា ព្រះអង្គសង្គ្រោះមានព្រះចេស្តាដើម្បីព្យាបាល ធ្វើអព្ភូតហេតុ ហើយធ្វើឲ្យយើងរីករាយនៅក្នុងជីវិតនេះ និងនៅជីវិតខាងមុខ ។ ■

អាណា ក្រម៉ាសឈី ហ្សាណាទូ សាន់ត្យាហ្គោ ប្រទេស ឈីលី

**នៅ**ពេលកូនរបស់យើងមានអាយុ 13 ឆ្នាំ គាត់ធ្លាក់ចូលទៅក្នុងភាពអស់សង្ឃឹមយ៉ាងខ្លាំង ហើយគាត់មិនចង់ចូលរួមនៅក្នុងការអធិស្ឋាន ឬ រាត្រីជួបជុំគ្រួសារឡើយ ។



# តើអ្នកជាពួកមរមនឬ ?

ខ្ញុំបានឃ្លាតចេញឆ្ងាយពីផ្ទះទៅចូលរួមសន្និសីទអន្តរជាតិមួយសម្រាប់ការងាររបស់ខ្ញុំ ។ មានមនុស្សរាប់រយនាក់បានចូលរួម ប៉ុន្តែខ្ញុំជាមនុស្សតែម្នាក់គត់ដែលមកពីរដ្ឋ និងតំបន់របស់ខ្ញុំ ។

មានល្ងាចមួយ អាហារពេលល្ងាចត្រូវបានគេរៀបចំឡើងសម្រាប់ពួកអ្នកចូលរួម ។ នៅពេលចូលទៅដល់បន្ទប់អាហារ យើងម្នាក់ៗបានទទួលសំបុត្រចំនួនបួនសន្លឹក ដើម្បីប្រើទទួលទានគ្រឿងស្រវឹងដោយឥតគិតថ្លៃ ។ ខ្ញុំបានគិតថា វាងាយណាស់ចំពោះមនុស្សម្នាក់ដែលចេញឆ្ងាយពីផ្ទះ ដើម្បីទទួលការល្បួងនៅក្នុងឱកាសបែបនេះ ដោយគិតថាគ្មាននរណាម្នាក់ដឹងនោះទេ ។ វាជាគំនិតខ្លីមួយ ហើយខ្ញុំបានហុចសំបុត្រនោះ ឲ្យទៅអ្នកដែលឈរចែកនៅមាត់ទ្វារវិញ ។

នៅក្នុងអាហារពេលល្ងាចនោះខ្ញុំបានអង្គុយជាមួយនឹងមនុស្ស ដែលខ្ញុំមិនស្គាល់ចំនួនប្រាំពីរនាក់ ។ ខ្ញុំបានផឹកទឹក ខណៈដែលយើងបានហូបអាហារ និយាយ សើច ហើយចែករំលែកព័ត៌មានជាមួយគ្នាដែលវានឹងជួយយើងនៅក្នុងការងាររបស់យើង ។

លុះព្រឹកស្អែកនៅពេលអាហារពេលព្រឹក ខ្ញុំបានរាក់ទាក់នឹងសុភាពបុរសម្នាក់ដែលបានអង្គុយនៅតុជាមួយខ្ញុំ ។ ខ្ញុំរីករាយដោយដឹងថាគាត់មកពីស្រុកកំណើតខ្ញុំ ដោយឃើញឈ្មោះនៅលើស្លាករបស់គាត់—ជាក្រុងមួយដែលឃ្លាតឆ្ងាយអស់រយៈពេល 35 ឆ្នាំ ហើយ ។ បន្ទាប់ពីបញ្ចប់ថ្នាក់វិទ្យាល័យខ្ញុំបានចេញពីផ្ទះបន្តការសិក្សានៅមហាវិទ្យាល័យ បានរៀបការ ហើយបានផ្លាស់ទៅនៅឆ្ងាយ ។

នៅពេលយើងបានពិភាក្សាពីទីកន្លែង និងព្រឹត្តិការណ៍ក្នុងសហគមន៍ជាច្រើនដែលយើងទាំងពីរបានស្គាល់ គាត់បានសួរខ្ញុំថា តើគ្រួសាររស់នៅខ្ញុំទីនោះដែរទេ ។ ខ្ញុំបានតបថា ខ្ញុំគ្មានទេ ប៉ុន្តែមានមិត្តសម្លាញ់រស់នៅទីនោះ ហើយយើងនៅតែទាក់ទងគ្នាជានិច្ច ។ គាត់បានសួរថាតើពួកគេជានរណា ហើយខ្ញុំបានចាប់ផ្ដើមប្រាប់ឈ្មោះពួកគេមួយចំនួន ។

បន្ទាប់ពីប្រាប់បានពីរបីឈ្មោះដំបូង គាត់បានបញ្ឈប់ខ្ញុំ ហើយពោលថា « ឈប់សិន តើអ្នកជាពួកមរមនមែនទេ ? មនុស្សទាំងអស់ដែលអ្នកបានប្រាប់ឈ្មោះគឺជាពួកមរមន » ។

ពេលខ្ញុំប្រាប់ថា ខ្ញុំជាពួកបរិសុទ្ធថ្ងៃចុងក្រោយ គាត់បានប្រាប់ខ្ញុំថា មិត្តរបស់ខ្ញុំទាំងអស់នោះជាពលរដ្ឋដ៏ល្អ ហើយ ថាពួកគេបានបម្រើនៅក្នុងសហគមន៍ ហើយបានធ្វើជាគំរូល្អដល់មនុស្សគ្រប់គ្នា ។ គាត់បានចែកចាយពីការកោតសរសើររបស់គាត់ចំពោះសាសនាចក្រ និងមិត្តរបស់ខ្ញុំអស់ប៉ុន្មាននាទី ដោយប្រាប់ខ្ញុំពីរបៀបដែលពួកគេបានក្លាយជាអ្នកគាំទ្រសម្រាប់សេចក្ដីល្អ នៅក្នុងសហគមន៍ ។

នៅពេលយើងលាគ្នាចេញទៅ ខ្ញុំបានគិតយ៉ាងច្រើនពីអ្វីដែលអាចនឹងកើតឡើង ប្រសិនបើខ្ញុំបានជ្រើសប្រើសំបុត្រទាំងនោះ ។ ខ្ញុំត្រូវបានបង្រៀនឲ្យជ្រើសរើសផ្លូវត្រូវដោយមនុស្សគ្រប់គ្នាដែលខ្ញុំបាននិយាយជាមួយ ។ ខ្ញុំប្រហែលជាមិនស្រណុកនៅក្នុងចិត្ត ហើយខ្មាស់អៀនដើម្បីប្រាប់ថា ខ្ញុំជាសមាជិកនៃសាសនាចក្រ ប្រសិនបើខ្ញុំប្រើសំបុត្រនោះ ។

ខ្ញុំមានអំណរគុណខ្លាំងណាស់សម្រាប់គំរូរបស់មិត្តទាំងនោះដែលសក្តិសម សកម្ម ហើយមានការបម្រើ—ជារយៈពេល 35 ឆ្នាំក្រោយមក និងមានចម្ងាយផ្លូវ 3,220 គ.ម. ពីផ្ទះកាលដែលខ្ញុំនៅជាយុវវ័យ ។ ■

ខារ៉ូល អេ ប៊ូរស៍ ខ្សូរ៉ៃឡូណា ខាងជើង ស.រ.អា.



នៅពេលចូលទៅដល់បន្ទប់អាហារ យើងម្នាក់ៗបានទទួលសំបុត្រចំនួនបួនសន្លឹក ដើម្បីប្រើទទួលទានគ្រឿងស្រវឹងដោយឥតគិតថ្លៃ ។

# ព្យាការីបានឆ្លើយតបនឹងការអធិស្ឋានរបស់ខ្ញុំ

នៅចុងបញ្ចប់នៃឆ្នាំទីពីររបស់ខ្ញុំ ខ្ញុំបានដាក់ពាក្យទៅក្នុងកម្មវិធីផ្នែកការរចនាក្រាហ្វិករបស់សាកលវិទ្យាខ្ញុំ ។ ខ្ញុំមិនត្រូវបានគេទទួលយកទេ ប៉ុន្តែខ្ញុំមានសិទ្ធិធ្វើការដាក់ពាក្យម្តងទៀតនៅឆ្នាំក្រោយ ។ ខ្ញុំគ្មានចិត្តរំភើបពីការរង់ចាំមួយឆ្នាំទៀតដើម្បីទទួលសញ្ញាបត្រឡើយ ។

ជំនាញដែលខ្ញុំជ្រើសរើសគឺផ្នែកថតរូប ។ ដូច្នេះខ្ញុំបានអធិស្ឋានពីការផ្លាស់ប្តូរជំនាញរបស់ខ្ញុំ ហើយមានអារម្មណ៍ល្អពីវា ។ ខ្ញុំគ្រាន់តែចង់បានសញ្ញាបត្ររបស់ខ្ញុំប៉ុណ្ណោះ !

នៅដើមឆមាសសម្រាប់រដូវស្លឹកឈើជ្រុះ ខ្ញុំមានមុខវិជ្ជាដែលទាក់ទងនឹងខ្សែភាពយន្ត និង ពីប្រវត្តិនៃការថតរូបផ្នែកសង្គម ។ ខ្ញុំមានចិត្តរីករាយនឹងមុខវិជ្ជាទាំងពីរនេះ ។ ប៉ុន្តែពេលខ្ញុំមើលកាលវិភាគនៃមុខវិជ្ជាខ្សែភាពយន្តរបស់ខ្ញុំ ខ្ញុំឃើញថា និស្សិតទាំងឡាយត្រូវតម្រូវឲ្យមើលប្រភេទខ្សែភាពយន្ត R-Rated. ក្នុងមុខវិជ្ជាថតរូបរបស់ខ្ញុំ គ្រូបង្រៀនបានថ្លែងថា រូបភាពដែលយើងនឹងសិក្សាមាននូវការរំលោភបំពាន ការរំខាន និង វិបត្តិខាងផ្លូវភេទ ។ គាត់បានថ្លែងថា រូបថតនោះភាគច្រើនស្តីពីជំនាន់នេះ ។

ចិត្តខ្ញុំមានការព្រួយបារម្ភ ពេលខ្ញុំគិតពីអ្វីដែលត្រូវធ្វើ ។ ខ្ញុំបានដឹងថា ដំណឹងល្អបានបង្រៀនប្រឆាំងនឹងរឿងទាំងនេះ ប៉ុន្តែមុខវិជ្ជានេះគឺត្រូវឲ្យធ្វើដូច្នេះ ។ ខ្ញុំបានគិតនូវបទគម្ពីរស្តីពីការរស់នៅក្នុងលោកិយ ប៉ុន្តែពុំមែនជារបស់ផងលោកិយ ( សូមមើល យ៉ូហាន 15:19) ។ តើខ្ញុំអាចរៀនមុខវិជ្ជានោះដោយមិនពាក់ព័ន្ធនឹងរឿងទាំងនោះបានដែរទេ ?

ខ្ញុំបានអធិស្ឋានដើម្បីដឹងពីអ្វីដែលត្រូវធ្វើ និង ដើម្បីមានសេចក្តីជំនឿធ្វើអ្វីដែលត្រឹមត្រូវ ។ ខ្ញុំក៏បានពិភាក្សានឹងភរិយា ឪពុក និងបងប្រុសរបស់ខ្ញុំផងដែរ ។ នៅពេលខ្ញុំនិយាយនឹងបងប្រុសខ្ញុំ គាត់បានរំឭកខ្ញុំពីបទគម្ពីរដូចតទៅនេះ ៖ « ត្បិតបើមនុស្សណានឹងបានលោកិយទាំងមូល តែបាត់ព្រលឹងទៅ នោះតើមានប្រយោជន៍អ្វីដល់អ្នកនោះ ឬតើមនុស្សនឹងយកអ្វីទៅដូរឲ្យបានព្រលឹងខ្លួនវិញ ? ឬ តើមនុស្សនឹងយកអ្វីទៅដូរឲ្យបានព្រលឹងខ្លួនវិញ ? » (ម៉ាថាយ 16:26) ។

ខ្ញុំបានដឹងថា ការអប់រំគឺសំខាន់ ប៉ុន្តែតើខ្ញុំបានរើសជំនាញខុសមែនទេ ? តើខ្ញុំអាចឈប់សម្រាកពីសាលាជាបណ្តោះអាសន្ន នៅពេលជិតបញ្ចប់ការសិក្សាហើយនោះបានដោយរបៀបណា ?

លុះយប់ជ្រៅនាថ្ងៃមួយ ខណៈដែលខ្ញុំនៅមើលកូនរបស់យើងដែលឈឺ នោះគំនិតមួយបានកើតឡើងចំពោះខ្ញុំឲ្យមើលទៅ ប្រធាន ថូម៉ាស អេស ម៉នសុន នៅលើអ៊ិនធើរណែត ។ រំពេចនោះខ្ញុំបានមើលសុន្ទរកថាមួយក្នុងសន្និសីទទូទៅដែលប្រធាន ម៉នសុន បានលើកឡើងនៅខែ តុលា ឆ្នាំ 2011 ។ ខ្ញុំបានខំប្រឹងស្តាប់ នៅពេលលោកបានលើកឡើងពីភាពទន់ខ្សោយនៃផ្នែកសីលធម៌របស់សង្គម ដោយថ្លែងថា ឥរិយាបថមិនសមរម្យ ហើយអសីលធម៌នោះត្រូវបានទទួលស្គាល់ដោយមនុស្សជាច្រើន ។

បន្ទាប់មក លោកបានថ្លែងចំនូវអ្វីដែលខ្ញុំចង់ឮ ៖ « យើងត្រូវតែប្រុងប្រយ័ត្ននៅក្នុងពិភពលោកមួយដែលបានរំកិលចេញយ៉ាងឆ្ងាយចេញពីរឿងខាងវិញ្ញាណ ។ វាជាការចាំបាច់ថា យើងត្រូវបដិសេធរាល់អ្វីទាំងអស់ដែលមិនសមស្របទៅនឹងបទដ្ឋានរបស់យើង ដោយបដិសេធចំពោះដំណើរការដើម្បីបោះបង់ចោលនូវអ្វីដែលយើងប្រាថ្នាចង់បានបំផុត ៖ ជាជីវិតអស់កល្បក្នុងនគរព្រះ ។[1]

ពាក្យទាំងនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ខ្ញុំ ។ កាលទឹកភ្នែករបស់ខ្ញុំបានស្រក់ចុះមក ខ្ញុំបានដឹងថា ព្យាការីដែលរស់នៅម្នាក់បានឆ្លើយតបនឹងការអធិស្ឋានរបស់ខ្ញុំ ។

ទោះបីជាខ្ញុំបានផ្អាកផែនការរបស់ខ្ញុំសម្រាប់ការបញ្ចប់ការសិក្សាក្តី តែខ្ញុំដឹងថាព្រះអម្ចាស់នឹងប្រទានពរដល់គ្រួសារខ្ញុំ និង ខ្ញុំ នៅពេលយើងធ្វើតាមព្យាការី ដោយបដិសេធចោលនូវទស្សនៈរបស់លោកិយ គោរពតាមព្រះបញ្ញត្តិ ហើយគាំទ្រដល់បទដ្ឋាននៃដំណឹងល្អ ។ ■

ឌេរីក ហ្វីលស៍ មិសសួរី ស.រ.អា.

**កំណត់ចំណាំ**

1. ថូម៉ាស អេស ម៉នសុន « Stand in Holy Places » *Liahona,* ខែ វិច្ឆិកា ឆ្នាំ 2011,ទំព័រ 83 ។

លុះយប់ជ្រៅនាថ្ងៃមួយ ខណៈដែលខ្ញុំនៅមើលកូនរបស់យើងដែលឈឺ នោះគំនិតមួយបានកើតឡើងចំពោះខ្ញុំឲ្យមើលទៅ ប្រធាន ថូម៉ាស អេស ម៉នសុន នៅលើអ៊ិនធើរណែត ។





**ដោយ ប៊ីស្សព ហ្គ៊ែរ៉ល កូសសេ**
ទីប្រឹក្សាទីមួយក្នុងគណៈ
ប៊ីស្សពជាអធិបតី

# ដើរតាមផ្លូវនៃ សុភមង្គល

ជាទូទៅ ពេលនៃភាពយុវវ័យគឺជាពេលដ៏ល្អបំផុតដើម្បីដាក់ផែនការផ្ទាល់ខ្លួន ។ ក្នុងនាមជាមជ្ឈិមវ័យវ័យក្មេង អ្នកគួរតែមានក្តីស្រមៃសម្រាប់អនាគតរបស់អ្នក ។ ប្រហែលជាក្តីស្រមៃរបស់អ្នកគឺជាការសង្ឃឹមថានឹងសម្រេចជាកីឡាករ ការបង្កើតកិច្ចការវិចិត្រសិល្បៈដ៏ប្រណិតមួយ ឬ ការទទួលបានសញ្ញាបត្រ ឬ តំណែងអាជីព ។ ប្រហែលជាអ្នក មានរូបភាពដ៏មានតម្លៃបំផុត នៅក្នុងគំនិតអ្នកអំពីអនាគតស្វាមី ឬ ភរិយារបស់អ្នក ។

តើការប៉ងប្រាថ្នារបស់អ្នកនឹងក្លាយទៅជាការពិតបានច្រើនប៉ុណ្ណាទៅ ? ជីវិតគឺពោរពេញដោយរឿងមិនជាក់លាក់ ។ វានឹងមាននូវគ្រាដ៏សំខាន់មួយសម្រាប់អ្នក ដែលវាអាចផ្លាស់ប្តូរផ្លូវនៃជីវិតរបស់អ្នកមួយរំពេច ។ គ្រាដូច្នោះ អាចមានមិនច្រើនជាងការមើល ឬ ការសន្ទនា ព្រឹត្តការណ៍ដែលគ្មានព្រៀងទុកជាដើម ។ វានឹងមាននូវឱកាសថ្មីជាច្រើន ដូចជាការប្រកាសថ្មីៗមកពីប្រធាន ថូម៉ាស អេស ម៉នសុន ស្តីពីអាយុចេញបម្រើផ្សព្វផ្សាយសាសនា ។[1]ពេលខ្លះ ការផ្លាស់ប្តូរផ្លូវនៅក្នុងជីវិតរបស់យើងកើតចេញពីឧបសគ្គ ឬ ការខកចិត្តដែលមិនបានរំពឹងទុកជាមុន។

មនុស្សជាច្រើនពុំចូលចិត្តអ្វីដែលគេមិនដឹងទេ ។ ភាពមិនច្បាស់លាស់នៃជីវិតអាចបង្កើតឲ្យមាននូវការខ្វះទំនុកចិត្ត ដែលការភ័យខ្លាចនឹងអនាគត ។ មនុស្សខ្លះ ស្ទាក់ស្ទើរនឹងការធ្វើការតាំងចិត្តចេញពីភាពភ័យខ្លាចនៃការបរាជ័យ សូម្បីតែឱកាសល្អៗបានបង្ហាញខ្លួនឡើងក្តី ។ ឧទាហរណ៍ ពួកគេអាចនឹងពន្យាពេលរៀបការ ការសិក្សា ការចាប់ផ្តើមគ្រួសារ ឬ ពន្យាពេលការចាប់ផ្តើមអាជីពនឹងនរមួយដោយចូលចិត្តដើរលេង ឬ នៅក្នុងភាពកក់ក្តៅនៃផ្ទះរបស់ឪពុកម្តាយពួកគេជាដើម ។

ទស្សនៈមួយទៀត ដែលនឹងដាក់កម្រិតដល់យើង គឺត្រូវបានបង្ហាញដោយសុភាសិតនេះថា ៖ « ចូរស៊ី ផឹក ហើយអរសប្បាយទៅចុះ ត្បិតស្អែកឡើងយើងត្រូវស្លាប់ហើយ » (នីហ្វៃទី 2 28:7) ។ ទស្សនៈនេះឲ្យយើងបណ្តោយខ្លួនតាមការសប្បាយភ្លាមៗ ដោយមិនគិតអំពីលទ្ធផលនាពេលអនាគតឡើយ ។

## ផ្លូវនៃសុភមង្គល

មានផ្លូវមួយខុសពីផ្លូវនៃភាពភ័យខ្លាច និងការសង្ស័យ ឬ ការបណ្តោយខ្លួន—ជាផ្លូវមួយដែលនាំឲ្យមានភាពសុខសាន្ត ទំនុកចិត្ត និង ភាពស្ងប់ស្ងាត់ក្នុងជីវិត ។ អ្នកមិនអាចគ្រប់គ្រងនូវរាល់ស្ថានភាពក្នុងជីវិតរបស់អ្នកបានទេ ប៉ុន្តែអ្នកអាចគ្រប់គ្រងសុភមង្គលរបស់អ្នកបាន ។ អ្នកជាអ្នកស្ថាបនាសុភមង្គលរបស់អ្នក ។

សុភមង្គលរបស់អ្នកគឺជាលទ្ធផលនៃទស្សនៈ និង គោលការណ៍ខាងវិញ្ញាណរបស់អ្នកដែលអ្នកបានផ្តោតជីវិតរបស់អ្នក លើសពីអ្វីៗផ្សេងទៀត ។ គោលការណ៍ទាំងនេះនឹងនាំសុភមង្គលឲ្យកើតមានដល់អ្នក ថ្វីបើឧបសគ្គ និង ការភ្ញាក់ផ្អើលដែលពុំរំពឹងទុកជាមុននោះជាអ្វីក៏ដោយ ។ ខ្ញុំសូមរំឭកឡើងវិញនូវគោលការណ៍ដ៏សំខាន់ទាំងនេះមួយចំនួន ។

> **សុភមង្គលរបស់អ្នក គឺអាស្រ័យទៅលើគោលការណ៍ដែលអ្នកជ្រើសរើសធ្វើតាម ជាជាងស្ថានភាពខាងក្រៅនៃជីវិតរបស់អ្នក ។**

### 1. ការទទួលស្គាល់តម្លៃផ្ទាល់ខ្លួនឯង

ថ្មីៗនេះ គ្រួសារខ្ញុំ និង ខ្ញុំ បានចំណាយពេលសម្រាកពីរបីថ្ងៃ នៅភាគខាងត្បូងនៃប្រទេសបារាំង ។ នាល្ងាចមួយ បន្ទាប់ពីព្រះអាទិត្យលិច ហើយភាពងងឹតបានគ្របដណ្តប់លើជនបទភ្លាមនោះខ្ញុំបានសម្រេចចិត្តសម្រាកនៅលើកៅអីទម្រេតមួយនៅខាងក្រៅផ្ទះ ។ ភ្នែករបស់ខ្ញុំបានចាប់ផ្តើមគយគន់មើលផ្ទៃមេឃ ។ ដំបូងឡើយ វាមានភាពខ្មៅមើលមិនធ្លុះ ។ បន្តិចម្តងៗ ស្រាប់តែមានពន្លឺមួយលេចមកលើមេឃ ដូចជាផ្កាភ្លើង បន្ទាប់មកក៏មានពីរ បន្ទាប់មកទៀតក៏មានបី ។ យូរៗទៅ ពេលភ្នែកខ្ញុំសម្របទៅនឹងភាពងងឹត ខ្ញុំឃើញថាខ្លួនខ្ញុំ




ស្មើចនឹងចំនួនផ្កាយដ៏ច្រើន ។ អ្វីដែលខ្ញុំបានគិត គឺថា មេឃពណ៌ខ្មៅ បានផ្លាស់ទៅជាកញ្ចុំផ្កាយឈ្មោះ មៀលគីវ៉េ ។

ពេលខ្ញុំបានសញ្ជឹងគិតពីភាពដ៏ធំល្វឹងល្វើយនៃ សាកលលោក និង ពីរូបកាយដ៏តូចរបស់ខ្ញុំ នោះខ្ញុំ បានសួរខ្លួនឯងថា « តើខ្ញុំជាអ្វីទៅបើប្រៀបទៅនឹង លំហដ៏ធំអស្ចារ្យនេះ ? » មានខគម្ពីរបានផុសឡើង នៅក្នុងគំនិតរបស់ខ្ញុំថា ៖

កាលណាទូលបង្គំពិចារណាមើលផ្ទៃមេឃ ជាការដែលព្រះហស្តទ្រង់បានធ្វើ គឺទាំងខែ នឹង ផ្កាយ ដែលទ្រង់បានប្រតិស្ឋានទុក

« នោះតើមនុស្សជាអ្វីដែលទ្រង់នឹករឭកដល់ គេ ហើយកូនមនុស្សផងដែលទ្រង់ប្រោសដូច្នេះ ? » (ទំនុកដំកើង 8:3–4) ។

ស្រាប់តែមានឃ្លាដ៏លួងលោមចិត្តនេះកើត ឡើង ៖

« ត្បិតទ្រង់បានធ្វើឲ្យគេទាបជាងពួកទេវតាតែ បន្តិចទេ ក៏បានបំពាក់សិរីល្អ និង កេរ្តិ៍ឈ្មោះឲ្យទុក ជាមកុដ » ( ទំនុកដំកើង8:5 ) ។

នេះគឺជាភាពប្លែក និង អព្ភូតហេតុនៃការបង្កបង្កើត ។ សាកលលោក គឺធំធេង ហើយគ្មានដែន កំណត់ ប៉ុន្តែក្នុងពេលដំណាលគ្នានោះ យើងម្នាក់ៗ មានតម្លៃរុងរឿងពិសេស និង គ្មានព្រំដែន នៅក្នុង ព្រះនេត្ររបស់អង្គបង្កបង្កើតរបស់យើង ។ វត្តមាន ខាងរូបកាយរបស់ខ្ញុំ គឺតូចក្រៃលែង ប៉ុន្តែតម្លៃ ផ្ទាល់ខ្លួនខ្ញុំ គឺសំខាន់ពុំអាចវាស់វែងបានចំពោះ ព្រះវរបិតាសួគ៌ខ្ញុំឡើយ ។



**សំបុត្រមកពីអ្នកផ្ទាល់កាលពីជីវិតមុនឆាកជីវិតនេះអាចសរសេរថា « ជូនចំពោះខ្ញុំ ខ្ញុំសង្ឃឹមថាអ្នកនឹងចងចាំថាបំណងប្រាថ្នាដ៏ធំបំផុតរបស់យើងគឺចង់ក្លាយជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ » ។**

ការដឹងថា ព្រះស្គាល់ និង ស្រឡាញ់យើងដោយផ្ទាល់ គឺដូចជាពន្លឺមួយ ដែលបំភ្លឺជីវិតយើង ហើយផ្ដល់អត្ថន័យដល់ជីវិត ។ មិនថាខ្ញុំជានរណា មិនថាខ្ញុំមានមិត្ត ឬ អត់ មិនថាខ្ញុំមានឈ្មោះល្បី ឬ ក៏អត់ ហើយសូម្បីតែខ្ញុំមានអារម្មណ៍ថា គេបដិសេធ ឬ ធ្វើទុក្ខក្ដី ខ្ញុំមានការអះអាងទាំងស្រុងមួយថា ព្រះវរបិតាសួគ៌ខ្ញុំស្រឡាញ់ខ្ញុំ ។ ទ្រង់ស្គាល់ពីសេចក្ដីការរបស់ខ្ញុំ ទ្រង់យល់ពីកង្វល់ខ្ញុំ ទ្រង់ចង់ប្រទានពរដល់ខ្ញុំ ។

សូមស្រមើស្រមៃថា តើវាមានន័យចំពោះអ្នកយ៉ាងណាទៅ ប្រសិនបើអ្នកអាចមើលឃើញខ្លួនឯងដូចជាព្រះបានទតមើលចំពោះអ្នកនោះ ។ ចុះបើអ្នកបានមើលខ្លួនអ្នកដោយក្ដីស្រឡាញ់ ចិត្តមេត្តា និង ទំនុកចិត្តដូចគ្នា ដែលព្រះមានទៅវិញនោះ ? ចូរនឹកគិតថា តើវានឹងមានឥទ្ធិពលទៅលើជីវិតរបស់អ្នកយ៉ាងណាទៅ ដើម្បីយល់ពីសក្ដានុពលដ៏អស់កល្បរបស់អ្នក ដូចជាព្រះយល់នោះ ។

ខ្ញុំធ្វើទីបន្ទាល់ថា ទ្រង់គង់នៅទីនោះ ។ សូមស្វែងរកទ្រង់ ! ស្រាវជ្រាវ ហើយ សិក្សា ។ អធិស្ឋាន ហើយទូលសុំ ។ ខ្ញុំសូមសន្យា ព្រះនឹងបញ្ជូនសញ្ញាដែលអ្នកអាចមើលឃើញពី ការមានទ្រង់ពិត និង ក្ដីស្រឡាញ់របស់ទ្រង់ចំពោះអ្នក ។

**2. ប្រែក្លាយជាខ្លួនអ្នក**[2]

ការប្រែក្លាយជាខ្លួនឯងដោយពិតប្រាកដហាក់ដូចជារឿងមួយដ៏ពិបាក ។ តើអាចក្លាយជាខ្លួនឯងដ៏ពិតប្រាកដបានដោយរបៀបណា ? ខ្ញុំនឹងបង្ហាញគោលការណ៍នេះតាមរយៈដំណើររឿងមួយ ។

ខ្សែភាពយន្តមួយដែលមាន ចំណងជើងថា ☒☒☒ ☒☒☒ ☒☒ ☒☒☒☒☒☒☒ បានប្រាប់ពីដំណើររឿងរបស់មើរហ្គើរីត ជាអ្នកវិនិយោគដ៏ស្ទុកស្ដមម្នាក់ដែលបានមានជីវិតពោរពេញដោយភាពរវល់នឹងការធ្វើដំណើរ និង សន្និសីទ ។ ថ្វីបើមានបុរសដែលល្អសក្ដិសមនឹងគាត់ក្ដី គាត់បាននិយាយថា គាត់គ្មានពេលដើម្បីនឹងរៀបការ ឬមានកូនទេ ។

លុះគាត់មានអាយុ 40 ឆ្នាំ គាត់បានទទួលសំបុត្រអាថ៌កំបាំងមួយដែលសរសេរថា ៖ « ជូនចំពោះខ្ញុំ ថ្ងៃនេះ ខ្ញុំមានអាយុ 7 ឆ្នាំហើយ ហើយខ្ញុំកំពុងសរសេរសំបុត្រនេះដល់អ្នកដើម្បីជួយឲ្យចងចាំពីការសន្យាទាំងឡាយ ដែលខ្ញុំបានធ្វើនៅពេលខ្ញុំមានអាយុប្រាំពីរឆ្នាំ ហើយក៏ដើម្បីរំឭកអ្នកផងដែរថាតើខ្ញុំចង់ក្លាយជាអ្វី » ។ ម្ចាស់សំបុត្រនោះគឺជាមើរហ្គើរីខ្លួនឯង ពេលគាត់មានអាយុប្រាំពីរឆ្នាំ ។ អ្វីដែលមានតមកទៀត គឺមានច្រើនសន្លឹក ដែលក្មេងស្រីតូចបានពិពណ៌នាលម្អិតអំពីគោលដៅជីវិតរបស់នាង ។

មើរហ្គើរីតបានដឹងថា មនុស្សដែលគាត់បានប្រែក្លាយ គឺខុសពីអ្វីដែលគាត់ចង់ប្រែក្លាយ កាលពីគាត់នៅក្មេង ។ នៅពេលគាត់សម្រេចចិត្តដើម្បីប្រែក្លាយជាមនុស្សដែលគាត់នឹកស្រមៃកាលពីកុមារនោះជីវិតរបស់គាត់បានផ្លាស់ប្ដូរទាំងស្រុង ។ គាត់បានផ្សះផ្សានឹងគ្រួសារគាត់ ហើយបានតាំងចិត្តដើម្បីលះបង់ពេលវេលាដែលនៅសល់ក្នុងជីវិតគាត់ទៅបម្រើដល់មនុស្សដែលខ្វះខាត ។[3]

ប្រសិនបើអ្នកបានទទួលសំបុត្រមួយពីជីវិតរបស់អ្នកមុនឆាកជីវិតនេះ តើវានឹងសរសេរអ្វីខ្លះ ? តើសំបុត្រមួយបែបនេះដែលបានមកពីពិភពលោកមួយដ៏ពិតតែត្រូវបានគេបំភ្លេចនឹងមានឥទ្ធិពលមកលើអ្នកយ៉ាងណាដែរ ប្រសិនបើអ្នកទទួលបានវានៅថ្ងៃនេះនោះ ?

សំបុត្រនេះប្រហែលជាសរសេរនូវអ្វីមួយដូចនេះ ៖« ជូនចំពោះខ្ញុំ ខ្ញុំសរសេរទៅកាន់អ្នក ដើម្បីអ្នកនឹងចងចាំថា តើខ្ញុំចង់ប្រែក្លាយជាមនុស្សបែបណា ។ ខ្ញុំសង្ឃឹមថា អ្នកនឹងចងចាំពីបំណងប្រាថ្នាដ៏ធំបំផុតរបស់ខ្ញុំគឺចង់ក្លាយជាសិស្សម្នាក់របស់ព្រះអង្គសង្គ្រោះយើង គឺព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំគាំទ្រដល់ផែនការទ្រង់ ហើយពេលខ្ញុំនៅលើផែនដី ខ្ញុំចង់ជួយទ្រង់នៅក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះរបស់ទ្រង់ ។ សូមចងចាំផងដែរថា ខ្ញុំចង់មានចំណែកក្នុងគ្រួសារមួយ ដែលនឹងនៅជាមួយគ្នាដ៏អស់កល្បជានិច្ច » ។

ដំណើរផ្សេងព្រេងដ៏អស្ចារ្យមួយនៃជីវិតគឺការស្វែងថា តើយើងជានរណាឲ្យពិតប្រាកដ និង ទីកន្លែងដែលយើងមក រួចហើយរស់នៅដោយក្ដីសុខសាន្តជាមួយអត្តសញ្ញាណដ៏ពិតរបស់យើងក្នុងនាមជាកូនចៅនៃព្រះ និងជាមួយគោលបំណងនៃជីវិតរបស់យើង ។

**3. ទុកចិត្តលើការសន្យារបស់ព្រះ**

ការបង្រៀនមួយមកពីព្យាការី ម៉ាឡាគី គឺជាកត្តា

មួយដ៏សំខាន់ចំពោះការស្ដារឡើងវិញនៃដំណឹងល្អ ៖ « លោកនឹងដាក់នៅក្នុងចិត្តនៃកូនចៅនូវសេចក្ដីសន្យាដែលបានធ្វើដល់ពួកឪពុក ហើយចិត្តនៃកូនចៅនឹងបានបង្វែរមករកពួកឪពុករបស់ពួកគេវិញ » (យ៉ូសែប ស៊្មីធ—ប្រវត្តិ 1:39) ។ អរគុណចំពោះការស្ដារឡើងវិញ អ្នករាល់គ្នាគឺជាកូនចៅនៃសេចក្ដីសន្យានេះ ។ អ្នកនឹងទទួលកេរមរតកនូវសេចក្ដីសន្យាដែលបានធ្វើឡើងដល់ដូនតារបស់អ្នក ។

សូមអានពររបស់លោកអយ្យកោរបស់អ្នកឡើងវិញ ។ នៅក្នុងពរជ័យនេះ ព្រះអម្ចាស់បញ្ជាក់ថា អ្នកចងភ្ជាប់ទៅនឹងពូជអំបូរមួយនៃពូជអំបូរអ៊ីស្រាអែលទាំងដប់ពីរ ហើយដោយសាររឿងនេះ និងតាមរយៈភាពស្មោះត្រង់របស់អ្នក អ្នកក្លាយជាអ្នកទទួលមរតកនូវពរជ័យដ៏ច្រើនដែលបានសន្យាដល់អ័ប្រាហាំ អ៊ីសាក និង យ៉ាកុប ។ ព្រះបានសន្យានឹងអ័ប្រាហាំថា ៖« ចំពោះមនុស្សជាច្រើនដែលទទួលដំណឹងល្អនេះ នោះនឹងត្រូវបានហៅតាមឈ្មោះអ្នក ហើយនឹងត្រូវបានរាប់ថាជាពូជអ្នក ហើយនឹងក្រោកឡើង ហើយជូនពរដល់អ្នកជាឪពុករបស់គេ » (អ័ប្រាហាំ 2:10) ។

ការសន្យាទាំងនេះគឺមានពិត ហើយប្រសិនបើយើងបំពេញតាមផ្នែករបស់យើង ព្រះនឹងធ្វើផ្នែករបស់ទ្រង់ ។ ម្យ៉ាងវិញទៀត ការសន្យាទាំងនេះមិនបានបញ្ជាក់ថា អ្វីៗគ្រប់យ៉ាងដែលកើតឡើងនៅក្នុងជីវិតរបស់យើងនឹងសមស្របតាមការរំពឹងទុក និងបំណងប្រាថ្នារបស់យើងឡើយ ។ ផ្ទុយទៅវិញ ការសន្យារបស់ព្រះបានអះអាងថា អ្វីដែលកើតឡើងចំពោះយើងគឺស្របតាមព្រះទ័យរបស់ទ្រង់ ។ រឿងដ៏ធំបំផុតដែលយើងអាចប្រាថ្នានៅក្នុងជីវិត គឺសម្របសម្រួលឆន្ទៈរបស់យើងទៅតាមព្រះទ័យរបស់ព្រះអម្ចាស់—ទទួលយករបៀបវារៈរបស់ទ្រង់សម្រាប់ជីវិតរបស់យើង ។ ទ្រង់ដឹងអ្វីៗទាំងអស់តាំងពីដើមដំបូង ទ្រង់មានទស្សនៈវិស័យដែលយើងគ្មាន ហើយទ្រង់ស្រឡាញ់យើងដោយក្ដីស្រឡាញ់គ្មានព្រំដែន ។

ខ្ញុំសូមបង្ហាញនូវគោលការណ៍នេះ តាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនមួយ ។ កាលខ្ញុំនៅក្មេង ខ្ញុំបានសម្រេចចិត្តរៀបចំខ្លួនទៅធ្វើការប្រឡងចូលសាលាពាណិជ្ជកម្មដ៏ល្អបំផុតនៅក្នុងប្រទេសបារាំង ។ ការរៀបចំខ្លួននេះ ដែលមានរយៈពេលមួយឆ្នាំ គឺជារឿងដ៏លំបាកបំផុត ។ នៅដើមឆ្នាំ ខ្ញុំបានសម្រេចចិត្តថា មិនថាមានកិច្ចការច្រើនប៉ុណ្ណាទេ ខ្ញុំនឹងមិនឲ្យការសិក្សារបស់ខ្ញុំរារាំងខ្ញុំមិនឲ្យចូលរួមក្នុងការប្រជុំថ្ងៃអាទិត្យ ឬ រារាំងខ្ញុំមិនឲ្យចូលរួមក្នុងថ្នាក់វិទ្យាស្ថានមួយសប្ដាហ៍ណាឡើយ ។ ខ្ញុំក៏បានយល់ព្រមបម្រើជាស្មៀនក្នុងវួដយុវមជ្ឈិមវ័យរបស់ខ្ញុំផងដែរ ។ ខ្ញុំមានទំនុកចិត្តថា ព្រះអម្ចាស់នឹងទទួលស្គាល់ភាពស្មោះត្រង់របស់ខ្ញុំ ហើយនឹងជួយខ្ញុំសម្រេចនូវគោលដៅរបស់ខ្ញុំ ។

នៅចុងឆ្នាំ នៅពេលដល់ពេលប្រឡង ខ្ញុំមានអារម្មណ៍ថា ខ្ញុំបានធ្វើអស់ពីសមត្ថភាពរបស់ខ្ញុំ ។ នៅពេលខ្ញុំទៅដល់ការប្រឡងក្នុងសាលាដ៏ល្បីនោះ ខ្ញុំមានទំនុកចិត្តទាំងស្រុងថា ព្រះអម្ចាស់នឹងឆ្លើយតបចំពោះបំណងប្រាថ្នារបស់ខ្ញុំ ។ ជាអកុសល ការប្រឡងផ្ទាល់មាត់នៅក្នុងប្រធានបទដែលចេះជាងគេ ត្រូវបានវិនាសដោយពុំរំពឹងទុក—ខ្ញុំបានទទួលចំណាត់ថ្នាក់ ដែលរារាំងខ្ញុំមិនឲ្យចូលរៀនក្នុងសាលា ដែលខ្ញុំចង់រៀនយ៉ាងខ្លាំងនេះ ។ ខ្ញុំពិបាកចិត្តយ៉ាងខ្លាំង ។ តើហេតុអ្វីក៏ព្រះអម្ចាស់អាចបោះបង់ខ្ញុំចោល ពេលខ្ញុំបានស៊ូទ្រាំនៅក្នុងភាពស្មោះត្រង់របស់ខ្ញុំដូច្នេះ ?

នៅពេលខ្ញុំបង្ហាញខ្លួននៅក្នុងការប្រឡងផ្ទាល់មាត់ សម្រាប់សាលាទីពីរក្នុងបញ្ជីរបស់ខ្ញុំ ខ្ញុំមានពេញដោយភាពសង្ស័យ ។ នៅក្នុងសាលានេះ ការប្រឡងដែលលំបាកបំផុតគឺការសម្ភាសន៍ជាមួយនឹងគណៈមេប្រយោគដែលត្រូវបានធ្វើជាអធិបតីដោយនាយកសាលានោះ ។ ការសម្ភាសន៍ដំបូងគឺធម្មតា—រហូតដល់ពេលដែលខ្ញុំត្រូវបានសួរនូវ



**ខ្ញុំបានទទួលចំណាត់ថ្នាក់ល្អបំផុតមួយដែលអាចធ្វើទៅបាន ដែលអនុញ្ញាតឲ្យខ្ញុំអាចចូលរៀនក្នុងសាលានេះ ជាកន្លែងនៃកិត្តិយសមួយ ។**

សំណួរដែលពុំសូវសំខាន់ថា ៖« យើងដឹងថា អ្នកបានសិក្សាច្រើនដើម្បីត្រៀមសម្រាប់ការប្រឡងនេះ ។ ប៉ុន្តែយើងនឹងចង់ដឹងអំពីសកម្មភាពផ្សេងៗដែលអ្នកធ្វើក្រៅពីការសិក្សារបស់អ្នក » ។

បេះដូងរបស់ខ្ញុំគាំងមួយសន្ទុះ ! ពេញមួយឆ្នាំ ខ្ញុំបានធ្វើតែរឿងពីរយ៉ាងប៉ុណ្ណោះគឺ ៖សិក្សា និង ទៅព្រះវិហារ ! ខ្ញុំខ្លាចថា គណៈមេប្រយោគនឹងបកស្រាយខុសចំពោះសមាជិកភាពរបស់ខ្ញុំនៅក្នុងសាសនាចក្រ ។ ប៉ុន្តែខ្ញុំបានធ្វើការសម្រេចចិត្តថាស្មោះត្រង់ជានិច្ច ចំពោះគោលការណ៍របស់ខ្ញុំក្នុងរយៈពេលមួយវិនាទីនោះ ។

ខ្ញុំបានរៀបរាប់ពីសកម្មភាពរបស់ខ្ញុំនៅក្នុងសាសនាចក្រអស់រយៈពេល 15 នាទី ៖ ការប្រជុំនៅថ្ងៃឈប់សម្រាក ថ្នាក់វិទ្យាស្ថាន និង កាតព្វកិច្ចរបស់ខ្ញុំក្នុងនាមជាស្មៀនវួដ ។ នៅពេលខ្ញុំបានបញ្ចប់ នាយកសាលាក៏បានមានប្រសាសន៍ ។

គាត់បានថ្លែងថា « អ្នកដឹងទេ កាលពីក្មេង ខ្ញុំបានសិក្សានៅក្នុងសហរដ្ឋ » ។ « ខ្ញុំមានមិត្តសម្លាញ់ម្នាក់ជាពួកមរមន ។ គាត់គឺជាយុវជនដ៏អស្ចារ្យមួយរូប ជាមនុស្សម្នាក់ដែលមានលក្ខណៈសម្បត្តិជាមនុស្សយ៉ាងអស្ចារ្យ ។ ខ្ញុំគិតថា ពួកមរមនគឺជាមនុស្សល្អណាស់ » ។

ថ្ងៃនោះ ខ្ញុំបានទទួលចំណាត់ថ្នាក់ល្អបំផុតមួយដែលអាចធ្វើទៅបាន ដែលអនុញ្ញាតឲ្យខ្ញុំអាចចូលរៀនក្នុងសាលានេះ ជាកន្លែងនៃកិត្តិយសមួយ ។

ខ្ញុំបានអរគុណព្រះអម្ចាស់ចំពោះសេចក្តីល្អរបស់ទ្រង់ ។ ប៉ុន្តែ ខ្ញុំបានចំណាយពេលជាច្រើនឆ្នាំ ដើម្បីយល់ពីពរជ័យប្រកបដោយអព្ភូតហេតុស្ដីពីការបរាជ័យរបស់ខ្ញុំក្នុងការចូលរៀននៅសាលាទីមួយ ។ នៅសាលាទីពីរ ខ្ញុំបានជួបនឹងមនុស្សសំខាន់ៗ ។ ប្រយោជន៍នៃការទំនាក់ទំនងរបស់ខ្ញុំជាមួយពួកគេបានក្លាយជាភស្តុតាងនៅពេញជីវិតអាជីពរបស់ខ្ញុំ ហើយបន្តនៅមានដល់សព្វថ្ងៃ គឺមានសារៈសំខាន់ក្នុងជីវិតរបស់ខ្ញុំ និង ជីវិតគ្រួសារខ្ញុំ ។

ប្រសិនបើរឿងពុំបានដូចដែលអ្នកសង្ឃឹម ឬ រំពឹងទុក បន្ទាប់ពីអ្នកបានធ្វើអស់ពីលទ្ធភាពរបស់អ្នកហើយ ចូរត្រៀមខ្លួនដើម្បីទទួលយកនូវឆន្ទៈរបស់ព្រះវរបិតាសួគ៌អ្នក ។ ទ្រង់នឹងមិនដាក់មកលើយើងនូវអ្វីៗដែលពុំមែនសម្រាប់សេចក្ដីល្អរបស់យើងនៅទីបំផុតនោះឡើយ ។ ចូរស្ដាប់នូវសម្លេងស្ងប់ស្ងាត់ដែលខ្សឹបក្នុងត្រចៀកយើងថា ៖« ត្បិតសាច់ឈាមទាំងអស់នៅ ក្នុងព្រះហស្តរបស់យើងហើយ ចូរបង្អង់សិន ឲ្យបានដឹងថា យើងជាព្រះ » (គ. និង ស. 101:16) ។

## អនាគតរបស់អ្នកគឺភ្លឺត្រចះត្រចង់ដូចជាសេចក្តីជំនឿរបស់អ្នកដែរ

កាលណាខ្ញុំកាន់តែសញ្ជឹងគិតអំពីទិសដៅនៃជីវិតរស់នៅរបស់ខ្ញុំ និង ភរិយារបស់ខ្ញុំ នោះខ្ញុំកាន់តែជឿថា អ្វីដែលធ្វើឲ្យមានភាពខុសប្លែក គឺស្ថិតនៅក្នុងយុវវ័យរបស់យើង ។ យើងចង់ចាប់ផ្ដើមគ្រួសារអស់កល្បជានិច្ចមួយ ។ យើងដឹងពីមូលហេតុដែលយើងនៅលើផែនដី និង អ្វីដែលជាគោលដៅដ៏អស់កល្បជានិច្ចរបស់យើង ។ យើងដឹងថា ព្រះស្រឡាញ់យើង ហើយថាយើងមានតម្លៃយ៉ាងមហិមា នៅក្នុងព្រះនេត្ររបស់ទ្រង់ ។ យើងមានទំនុកចិត្តទាំងស្រុងថា ទ្រង់នឹងឆ្លើយការអធិស្ឋានរបស់យើង តាមរបៀបរបស់ទ្រង់ និងតាមពេលដែលទ្រង់ទតឃើញថាល្អ ។

ខ្ញុំពុំដឹងថា បើសិនជាយើងត្រៀមខ្លួនជាស្រេចដើម្បីទទួលតាមឆន្ទៈរបស់ទ្រង់នៅគ្រប់រឿងនោះទេ ដោយសារតែអ្វីដែលយើងត្រូវរៀន— ហើយថាយើងនៅបន្តរៀន ។ ប៉ុន្តែយើងចង់ធ្វើឲ្យអស់ពីសមត្ថភាពរបស់យើង ដើម្បីដើរតាមទ្រង់ ហើយថ្វាយខ្លួនយើងដល់ទ្រង់ ។

ខ្ញុំថ្លែងទីបន្ទាល់ ជាមួយប្រធាន ម៉នសុន ថា « អនាគតរបស់អ្នក គឺភ្លឺត្រចះត្រចង់ដូចជាសេចក្តីជំនឿរបស់អ្នកដែរ » ។[4]សុភមង្គលរបស់អ្នក គឺអាស្រ័យទៅលើគោលការណ៍ដែលអ្នកជ្រើសរើសធ្វើតាម ជាជាងស្ថានភាពខាងក្រៅនៃជីវិតរបស់អ្នក ។ ចូរស្មោះត្រង់ចំពោះគោលការណ៍ទាំងនោះ ។ ព្រះស្គាល់អ្នក ហើយស្រឡាញ់អ្នក ។ ប្រសិនបើអ្នករស់នៅតាមផែនការដ៏អស់កល្បរបស់ទ្រង់ ហើយបើអ្នកមានជំនឿទៅលើការសន្យារបស់ទ្រង់ នោះអនាគតរបស់អ្នកនឹងភ្លឺចែងចាំង !

តើអ្នកមានក្តីស្រមៃ និង គោលដៅដែរទេ ? ល្អណាស់ ! សូមខិតខំដោយអស់ពីដួងចិត្តអ្នកដើម្បីសម្រេចវា ។ បន្ទាប់មក ទុកឲ្យព្រះអម្ចាស់ធ្វើនូវចំណែកដែលនៅសេសសល់ទាំងអស់ ។ ទ្រង់នឹងធ្វើឲ្យអ្នកក្លាយជាអ្វីដែលអ្នកពុំអាចប្រែក្លាយដោយខ្លួនឯង ។

សូមទទួលយកព្រះឆន្ទៈទ្រង់នៅគ្រប់ពេលទាំងអស់ ។ សូមត្រៀមខ្លួនជាស្រេចដើម្បីទៅកន្លែងណា ដែលទ្រង់ប្រាប់ឲ្យអ្នកទៅ និង ធ្វើនូវអ្វីដែលទ្រង់ប្រាប់ឲ្យអ្នកធ្វើ ។ ប្រែក្លាយជាបុរស និង ស្ត្រី ដែលទ្រង់ចិញ្ចឹមបីបាច់អ្នកឲ្យប្រែក្លាយ ។

សូមថ្លែងទីបន្ទាល់ថា ជីវិតនេះ គឺជាគ្រាដ៏អស្ចារ្យនៃភាពអស់កល្បជានិច្ច ។ យើងនៅទីនេះ ដោយមានគោលដៅដ៏រុងរឿងមួយ—ដែលជាការរៀបចំខ្លួនដើម្បីជួបព្រះ ។ ■

*ដកស្រង់ចេញពីសុន្ទរកថាក្នុងការប្រជុំធម្មនិដ្ឋានសុី.អ៊ី.អេស. ដែលបានធ្វើឡើងនៅរោងឧបោសថសលត៍ លេក ថ្ងៃទី 12 ខែ វិច្ឆិកា ឆ្នាំ 2012 ។ សម្រាប់អត្ថបទទាំងស្រុង សូមចូលទៅ lds.org/broadcasts។*

**កំណត់ចំណាំ**

1. សូមមើល ថូម៉ាស អេស ម៉នសុន « Welcome to Conference »Liahona, ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 4–5 ។
2. ឃ្លានេះជាការរំឭកដល់ ភីនដា ជាកវីជនជាតិក្រិកម្នាក់ល្បីឈ្មោះបំផុត ។ សូមមើល ភីនដា *Pythian* 2.72 ក្នុង *Olympian Odes, Pythian Odes* កំណែ និង បកប្រែ វិល្លៀម អេជ រេស ( ឆ្នាំ 1997 ) ទំព័រ 239 ។
3. សូមមើល *L'âge de raison* (*With Love . . . from the Age of Reason*) ដឹកនាំដោយយ៉ាន សាំយ៉ូអែល ( ឆ្នាំ 2010 ) ។
4. ថូម៉ាស អេស. ម៉នសុន « Be of Good Cheer »Liahona, ខែ ឧសភា ឆ្នាំ 2009 ទំព័រ 92 ។

# ការចែកចាយដំណឹងល្អ
# លើបណ្ដាញ

ដោយ ម៉ារីយ៉ា ម៉ាហុនរី អ៊ីហ្វ្រាហ្សិល អាឌួ អង់ដាកា



ខ្ញុំពុំដែលមានចិត្តក្លាហាន នៅក្នុងការចែកចាយដំណឹងល្អជាមួយនឹងមិត្តរបស់ខ្ញុំឡើយ ។ ពួកគេជាច្រើនបានដឹងពីសាសនារបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនបានធ្វើអ្វីថែមទៀត ដើម្បីចែកចាយទីបន្ទាល់របស់ខ្ញុំនោះទេ ។ ប៉ុន្តែ ប្រសិនបើមាននរណាម្នាក់មានការគិតខុសពីសាសនាចក្រ ខ្ញុំបានព្យាយាមអស់ពីលទ្ធភាពរបស់ខ្ញុំដើម្បីកែតម្រូវវា ។

ពេលខ្ញុំចាប់ផ្ដើមចូលរៀនមហាវិទ្យាល័យ ខ្ញុំបានចូលរួមនឹងក្រុមជជែកពិភាក្សាមួយ ។ សមាជិកផ្សេងទៀតបានដឹងថា ខ្ញុំជាពួកបរិសុទ្ធថ្ងៃចុងក្រោយពេលខ្ញុំបានកែតម្រូវពួកគេចំពោះអ្វីដែលបានលើកឡើងស្ដីពី « ពួកមរមន » ក្រោយពីការជជែកពិភាក្សាមួយ ។ ខ្ញុំពុំធ្លាប់និយាយពីសាសនារបស់ខ្ញុំពីមុនមកឡើយ ដូច្នេះនៅថ្ងៃនោះខ្ញុំត្រូវបានគេសួរនូវសំណួរជាច្រើន ។ ខ្ញុំបានមានអារម្មណ៍ភ័យខ្លាចហើយស្ទើរតែមិនចង់ឆ្លើយទៀតផង ។ ខ្ញុំបានដឹងពីអ្វីដែលខ្ញុំជឿ ប៉ុន្តែខ្ញុំពុំបានដឹងពីរបៀបដើម្បីចែកចាយវានោះទេ ។ ខ្ញុំបានអធិស្ឋាន ប៉ុន្តែហាក់ដូចជាមិនបានទទួលចម្លើយសោះ ។

ពីរបីថ្ងៃក្រោយមក ខណៈដែលខ្ញុំកំពុងលេង Facebook ខ្ញុំបានឃើញអត្ថបទមួយមកពី LDS.orgអ្នកដឹកនាំរបស់ខ្ញុំនៅព្រះវិហារបានដាក់ ។ វាបានធ្វើឲ្យខ្ញុំដឹងថា ខ្ញុំក៏អាចដាក់បង្ហាញនូវរឿងពីសាសនាចក្របានដែរ ។ ខ្ញុំបានរកមើលប្រធានបទដែលក្រុមជជែកពិភាក្សារបស់ខ្ញុំ បានសួរ ដោយបានដាក់តំណនៅលើទំព័ររបស់ខ្ញុំ ហើយបានផ្ញើទៅដល់អ្នកទាំងឡាយណាដែលជាប់ពាក់ព័ន្ធ ។ ខ្ញុំមានអារម្មណ៍ថា ពួកគេនឹងពេញចិត្តចំពោះចម្លើយទាំងនោះ ។

**ខ្ញុំបានដឹងនូវអ្វីដែលខ្ញុំជឿ ប៉ុន្តែ ខ្ញុំមានអារម្មណ៍ច្របូកច្របល់ក្នុងចិត្ត ដើម្បីព្យាយាមឆ្លើយនូវរាល់សំណួរដែលក្រុមជជែកពិភាក្សារបស់ខ្ញុំមានស្ដីពីសាសនាចក្រ ។**

ខ្ញុំពុំធ្លាប់ដាក់បង្ហាញពីជំនឿរបស់ខ្ញុំនៅតាមបណ្ដាញពីមុនមកឡើយ ដូច្នេះការណ៍នេះបាននាំឲ្យមនុស្សជាច្រើនដែលចង់ដឹងយ៉ាងខ្លាំងនោះបានសួរពីសាសនារបស់ខ្ញុំ ។ នៅពេលពួកគេសួរសំណួរ ខ្ញុំព្យាយាមផ្ដល់ជាចម្លើយយ៉ាងសាមញ្ញ រួមទាំងតំណទៅកាន់ឯកសារសាសនាចក្រផងដែរ ។ តាមរបៀបនេះមនុស្សទូទៅពុំចាំបាច់ត្រូវរង់ចាំចម្លើយពីខ្ញុំនោះទេ ប៉ុន្តែក៏អាចពឹងផ្អែកទៅលើអ្វីដែលពួកអ្នកមានសិទ្ធិអំណាចទូទៅបានថ្លែងពីសំណួររបស់ពួកគេផងដែរ ។ នៅពេលការសន្ទនាមានភាពតានតឹង ខ្ញុំបានឆ្លើយទៅកាន់បុគ្គលនោះដោយផ្ទាល់តាមរយៈការផ្ញើសារ ។

ខ្ញុំពិតជាត្រេកអរដែលសាសនាចក្របានផ្ដល់ឯកសារនៅតាមបណ្ដាញ ។ ខ្ញុំនៅតែមានអារម្មណ៍ច្របូលច្របល់ក្នុងចិត្ត នៅពេលមាននរណាម្នាក់សួរខ្ញុំពីសាសនាចក្រដោយមិនបានប្រាប់ទុកជាមុន ។ ប៉ុន្តែឥឡូវនេះ ខ្ញុំអន្ទះសាររង់ចាំសំណួរពួកគេមកដល់ ខ្ញុំបានដាក់បង្ហាញឯកសារសាសនាចក្រនៅតាមបណ្ដាញជានិច្ច ។ ខ្ញុំដឹងថា ឯកសារទាំងនេះអាចជួយទាំងមិត្តរបស់ខ្ញុំដែលជាសមាជិក និង ពុំមែនជាសមាជិក ។ ■

*អ្នកនិពន្ធរស់នៅមេត្រូ ម៉ានីឡា ប្រទេស ហ្វីលីពីន ។*

# សិទ្ធិជ្រើសរើស និង ចម្លើយ ៖ ការស្គាល់វិវរណៈ

*ពេលខ្លះអ្វីដែលហាក់ដូចជារបាំងយ៉ាងក្រាស់ នៅក្នុងទំនាក់ទំនងគឺជាជំហានដ៏ធំមួយដើម្បីដើរឆ្ពោះទៅមុខដោយមានទំនុកចិត្ត ។*



**ដោយ អែលឌើរ រីឆាដ ជី ស្កត**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

នៅទល់មុខខ្ញុំមានស្ត្រីម្នាក់បានអង្គុយយំ ។ គាត់បានប្រាប់ខ្ញុំទាំងទឹកភ្នែកថា « ខ្ញុំមិនដឹងពីអ្វីដែលខ្ញុំត្រូវជឿទៀតទេ » ។ គាត់បាននិយាយពីការជួបនឹងបញ្ហា ហើយបានអធិស្ឋានជាច្រើនថ្ងៃ ដើម្បីដឹងពីរបៀបធ្វើការសម្រេចចិត្តដ៏សំខាន់មួយ នៅក្នុងជីវិតរបស់គាត់ ប៉ុន្តែគ្មានបានជោគជ័យនោះទេ ។ គាត់បានថ្លែងទាំងបារម្ភថា « ខ្ញុំមិនដឹងថាខ្ញុំត្រូវធ្វើអ្វីនោះទេ ។ ប្រសិនបើលោកប្រាប់ខ្ញុំឲ្យធ្វើអ្វី ខ្ញុំនឹងធ្វើវា » ។ ដោយមានកាន់ព្រះគម្ពីរក្នុងដៃរបស់គាត់ គាត់បានថ្លែងថា « ព្រះមានបន្ទូលប្រាប់យើងថា ទ្រង់នឹងជួយយើង ។ ទ្រង់ឆ្លើយដល់ការអធិស្ឋានរបស់មនុស្សផ្សេងទៀតគ្រប់គ្នា ។ ហេតុអ្វីបានជាទ្រង់មិនឆ្លើយតបនឹងការអធិស្ឋានរបស់ខ្ញុំ ? »

នៅពេលមនុស្សម្នាក់ត្រូវបានបក់បោកទៅដោយខ្យល់កំនូចនៃអារម្មណ៍ចេតនា នោះវាពិបាកនឹងស្វែងរកផ្លូវចេញតែម្នាក់ឯងណាស់ ។ ការអធិស្ឋានរបស់ខ្ញុំគឺដើម្បីជួយដល់អ្នករាល់គ្នាដែលមានអារម្មណ៍ស្រដៀងនឹងខ្ញុំដែរ ។

នៅពេលចម្លើយចំពោះអធិស្ឋានដ៏សំខាន់ទំនងដូចជាមិនបានកើតឡើង វាគឺដោយសារយើងមិនបានយល់ពីសេចក្ដីពិតមួយចំនួនស្ដីពីការអធិស្ឋាន ឬដោយសារយើងមិនស្គាល់ពីចម្លើយ នៅពេលដែលវាបានមកដល់ ។

## គោលការណ៍នៃការអធិស្ឋាន

ទំនាក់ទំនងជាមួយនឹងព្រះវរបិតាសួគ៌យើងគឺជារឿងដ៏សំខាន់ ។ វាគឺជាឯកសិទ្ធិដ៏ពិសិដ្ឋមួយ ។ វាផ្អែកទៅលើគោលការណ៍ដែលពុំផ្លាស់ប្ដូរ ។ នៅពេលយើងទទួលជំនួយពីព្រះវរបិតាសួគ៌របស់យើង គឺវាកើតឡើងដោយសារសេចក្ដីជំនឿ ការគោរពប្រតិបត្តិ និង ការប្រើសិទ្ធិជ្រើសរើសបានត្រឹមត្រូវ ។

វាគឺជាកំហុសមួយដោយសន្និដ្ឋានថា រាល់ការអធិស្ឋានដែលយើងធ្វើឡើងនឹងទទួលបានចម្លើយភ្លាមនោះ ។ ការអធិស្ឋានខ្លះតម្រូវឲ្យមានការខិតខំយ៉ាងខ្លាំងពីសំណាក់យើងទាំងអស់គ្នា ។ ពិតណាស់ ពេលខ្លះការបំផុសកើតឡើងនៅពេលយើងមិនបានស្វែងរកវា ។ ជាទូទៅ វាទាក់ទងនឹងអ្វីមួយដែលយើងត្រូវដឹង ហើយបើមិនដូច្នោះទេ គឺយើងមិនអាចរកឃើញឡើយ ។

**_គាត់បានថ្លែងថា « ព្រះមានបន្ទូលប្រាប់យើងថា ទ្រង់នឹងជួយយើង ។ ទ្រង់ឆ្លើយដល់ការអធិស្ឋានរបស់មនុស្សផ្សេងទៀតគ្រប់គ្នា ។ ហេតុអ្វីបានជាទ្រង់មិនឆ្លើយតបនឹងការអធិស្ឋានរបស់ខ្ញុំ ? »_**

យើងនៅលើផែនដីនេះដើម្បីទទួលនូវបទពិសោធន៍ដែលយើងអាចទទួលបាន ដែលមិនមានផ្លូវណាផ្សេងទៀតឡើយ ។ យើងត្រូវបានផ្ដល់ឲ្យនូវឱកាសដើម្បីរីកចម្រើនអភិវឌ្ឍ ហើយមានភាពចាស់ទុំខាងវិញ្ញាណ ។ ដើម្បីធ្វើការណ៍នោះបាន យើងត្រូវរៀនអនុវត្តសេចក្ដីពិត ។ របៀបដែលយើងប្រឈមមុខនឹងឧបសគ្គ ហើយដោះស្រាយបញ្ហាលំបាកៗគឺជាកត្តាដ៏សំខាន់បំផុតចំពោះសុភមង្គលរបស់យើង ។

ដើម្បីយល់ឲ្យកាន់តែប្រសើរថែមទៀតពីការអធិស្ឋាន ខ្ញុំបានស្ដាប់តាមពាក្យទូន្មានរបស់អ្នកដទៃ សញ្ជឹងគិតពីបទគម្ពីរ ហើយសិក្សាពីជីវិតរបស់ពួកព្យាការី និងមនុស្សដទៃទៀត ។ ប៉ុន្តែអ្វីដែលទំនងជាជួយខ្ញុំច្រើនបំផុតនោះគឺការមើលឃើញនៅក្នុងគំនិតរបស់ខ្ញុំ ពីកុមារម្នាក់កំពុងដើរសំដៅទៅរកព្រះវរបិតាដែលមានសេចក្ដីស្រឡាញ់ ចិត្តល្អ ឈ្លាសវៃ ចេះយល់ចិត្ត ជាអ្នកដែលចង់ជួយយើងឲ្យមានជោគជ័យ ។

សូមកុំបារម្ភពីការសម្ដែងនូវអារម្មណ៍ដ៏ល្ងីល្ងើរបស់អ្នក ។ ចូរនិយាយទៅកាន់ព្រះវរបិតារបស់អ្នកបានហើយ ។ ទ្រង់ស្ដាប់រាល់ការអធិស្ឋាន ហើយឆ្លើយតបវាតាមរបៀបរបស់ទ្រង់ ។

« នៅពេលយើងពន្យល់ពីបញ្ហា ហើយ ដំណោះស្រាយមួយ ជួនកាលព្រះវរបិតាសួគ៌ឆ្លើយថា ត្រូវហើយ ជួនកាលទ្រង់ឆ្លើយថា ទេ ។ ជារឿយៗ ទ្រង់មិនបានឆ្លើយ ពុំមែនដោយសារទ្រង់មិនខ្វាយខ្វល់នោះទេ ប៉ុន្តែដោយព្រោះទ្រង់ស្រឡាញ់យើង—ដោយឥតខ្ចោះ ។ ទ្រង់ចង់ឲ្យយើងអនុវត្តសេចក្ដីពិតដែលទ្រង់បានប្រទានដល់យើង ។ ដើម្បីឲ្យយើងរីកចម្រើន យើងត្រូវទុកចិត្តលើសមត្ថភាពរបស់យើងនៅក្នុងការធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវ ។ យើងត្រូវតែធ្វើអ្វីដែលយើង*មានអារម្មណ៍*ថាត្រឹមត្រូវ ។ ទ្រង់នឹងឆ្លើយតាមពេលកំណត់របស់ទ្រង់ ។ ទ្រង់នឹងមិនបំភ្លេចយើងឡើយ ។

ខ្ញុំបានរៀបរាប់ពីធាតុពិតនៃទំនាក់ទំនងរបស់យើងជាមួយនឹងព្រះវរបិតាយើង ។ គ្មានអ្វីដែលទ្រង់មិនស្គាល់អំពីយើងនោះទេ ។ ទ្រង់ជ្រាបនូវរាល់សេចក្ដីត្រូវការរបស់យើង ហើយអាចប្រទាននូវរាល់ចម្លើយ ។ ប៉ុន្តែ ដោយសារព្រះរាជបំណងរបស់ទ្រង់ គឺជាសុភមង្គលអស់កល្បជានិច្ចរបស់យើង នោះទ្រង់លើកទឹកចិត្តយើងឲ្យធ្វើការជ្រើសរើសដ៏ត្រឹមត្រូវ ។

## វិធីបីយ៉ាងដើម្បីស្វែងរកចម្លើយ

### *1. ស្វែងរកភស្ដុតាងថាទ្រង់បានឆ្លើយដល់អ្នករួចហើយ*

ដូចជាយើងរាល់គ្នាជាច្រើនដែរ អូលីវើរ ខៅឌ៊ើរី ពុំបានស្គាល់ពីភស្ដុតាងនៃចម្លើយចំពោះការអធិស្ឋាន ដែលបានផ្ដល់រួចហើយពីព្រះអម្ចាស់នោះទេ ។ ដើម្បីបើកភ្នែក—របស់គាត់ និង—ភ្នែករបស់យើង វិវរណៈនេះត្រូវបានផ្ដល់ឲ្យ



តាមរយៈយ៉ូសែប ស្ម៊ីធ ៖

« អ្នកមានពរហើយចំពោះអ្វីដែលអ្នកបានធ្វើ ព្រោះអ្នកបានសូមពីយើង ហើយមើលចុះ*ដរាបណាអ្នកសូមជាញឹកញាប់ នោះអ្នកបានទទួលការបង្គាប់ពី*ព្រះវិញ្ញាណរបស់យើង ។ បើសិនជាពុំនោះសោតទេ អ្នកនឹងពុំបានមកដល់ទីដែលអ្នកនៅពេលនេះឡើយ ។

« មើលចុះ អ្នកដឹងហើយថា អ្នកបានសុំពីយើង ហើយយើងបាន*បំភ្លឺគំនិតរបស់អ្នក*ហើយឥឡូវនេះ យើងប្រាប់អ្នកនូវការណ៍ទាំងឡាយនេះ ដើម្បីឲ្យអ្នកបានដឹងថា អ្នកត្រូវបានបំភ្លឺដោយព្រះវិញ្ញាណនៃសេចក្ដីពិត » (គ. និង ស. 6:14–15 ការគូសបញ្ជាក់បានបន្ថែម) ។

ប្រសិនបើអ្នកមានអារម្មណ៍ថា ព្រះអម្ចាស់ពុំឆ្លើយតបការអធិស្ឋាន*របស់អ្នកទេ*ចូរពិចារណានូវបទគម្ពីរទាំងនេះ—រួចរកមើលភស្ដុតាងដោយយកចិត្តទុកដាក់ នៅក្នុងជីវិតអ្នកផ្ទាល់អំពីចម្លើយដែលទ្រង់បានឆ្លើយចំពោះអ្នករួចហើយនោះ ។

***2. យកចិត្តទុកដាក់ទៅលើអារម្មណ៍***

ដើម្បីជួយយើងម្នាក់ៗឲ្យស្គាល់ពីចម្លើយដែលបានផ្ដល់ឲ្យ នោះព្រះអម្ចាស់បានមានបន្ទូលថា ៖

« បើសិនជាអ្នកមានបំណងចង់បានសាក្សីថែមទៀត ចូរដាក់គំនិតទៅលើយប់ដែលអ្នកបានអំពាវនាវដល់យើងក្នុងដួងចិត្តរបស់អ្នក ដើម្បីឲ្យអ្នកអាចដឹងនូវសេចក្ដីពិតអំពីការណ៍ទាំងឡាយនេះ ។

« *តើយើងពុំបាននិយាយដោយភាពសុខសាន្តដល់គំនិតរបស់អ្នកអំពីការណ៍នេះទេឬអី ?* » ( គ. និង ស. 6:22–23 ការគូសបញ្ជាក់ត្រូវបានបន្ថែម ) ។

ព្រះអម្ចាស់ប្រទានគំនិតបន្ថែមទៀត ដោយការទូន្មានយើងឲ្យសិក្សាពីបញ្ហានៅក្នុងគំនិតរបស់យើង រួចហើយទូលសួរថា តើវាត្រឹមត្រូវដែរឬទេ ។

« បើសិនជាត្រឹមត្រូវ នោះយើងនឹងបណ្ដាលឲ្យទ្រូងរបស់អ្នកខ្ជួលខ្មាញ់ខាងក្នុង ហេតុដូច្នោះហើយ អ្នកនឹង*មានអារម្មណ៍*ថា ការណ៍នោះត្រឹមត្រូវ ។

« ប៉ុន្តែបើសិនជាការណ៍នោះមិនត្រឹមត្រូវវិញ នោះអ្នកនឹងពុំ*មានអារម្មណ៍*យ៉ាងដូច្នោះឡើយ ប៉ុន្តែអ្នកនឹងអាប់គំនិត » (គ. និង ស. 9:8–9 ការគូសបញ្ជាក់បានបន្ថែម) ។

***3. ត្រូវធ្វើសកម្មភាពនៅពេលទ្រង់ពុំឆ្លើយតប***

វាជាការសំខាន់ណាស់ដើម្បីដឹងថា ព្រះអម្ចាស់ក៏ឆ្លើយតបនូវវិធីទីបី ចំពោះការអធិស្ឋានផងដែរ ដោយ*ពុំឆ្លើយតប*ពេលការអធិស្ឋានត្រូវបានធ្វើឡើង ។ ហេតុអ្វីបានជាទ្រង់ធ្វើបែបនោះ ?

ទ្រង់គឺជាព្រះវរបិតាដ៏ល្អឥតខ្ចោះរបស់យើង ។ ទ្រង់ស្រឡាញ់យើងហួសពីយើងអាចយល់ទៅទៀត ។ ទ្រង់សព្វព្រះទ័យនូវអ្វីដែលល្អបំផុតសំរាប់យើង ។ ទ្រង់មើលឃើញទីបញ្ចប់តាំងពីដើមមក ។ ទ្រង់ចង់ឲ្យយើងធ្វើសកម្មភាពដើម្បីកើននូវបទពិសោធន៍ដែលចាំបាច់ ៖

ពេលទ្រង់ឆ្លើយថា *ត្រូវហើយ*វាជាការផ្ដល់ទំនុកចិត្តដល់យើង ។

ពេលទ្រង់ឆ្លើយថា*ទេ*វាជាការការពារនូវកំហុស ។

ពេលទ្រង់*ពុំឆ្លើយតប*វាជាការធ្វើឲ្យយើងរីកចម្រើនតាមរយៈសេចក្ដីជំនឿលើទ្រង់ ការគោរពប្រតិបត្តិចំពោះព្រះបញ្ញត្តិរបស់ទ្រង់ និង ឆន្ទៈដើម្បីធ្វើតាមសេចក្ដីពិត ។ យើងតម្រូវឲ្យធ្វើការទទួលខុសត្រូវ ដោយការអនុវត្តន៍ទៅលើការសម្រេចចិត្ត ដែលសមស្របទៅនឹងការបង្រៀនរបស់ទ្រង់ ដោយគ្មានការបញ្ជាក់ជាមុន ។ យើងមិនអង្គុយដោយអសកម្ម ឬរអ៊ូរទាំ ពីព្រោះព្រះអម្ចាស់ មិនបានមានបន្ទូលនោះឡើយ ។ យើងត្រូវធ្វើសកម្មភាព ។

ជារឿយៗ អ្វីដែលយើងជ្រើសរើសធ្វើជារឿងត្រឹមត្រូវ ។ ទ្រង់នឹងបញ្ជាក់ភាពត្រឹមត្រូវនៃការជ្រើសរើសរបស់យើងតាមរបៀបរបស់ទ្រង់ ។ ជាទូទៅ ការបញ្ជាក់នោះកើតឡើងតាមរយៈការជួយជ្រោមជ្រែងជាលំដាប់លំដោយ ។ យើងរកឃើញវាតាមរយៈការផ្ដោតយកចិត្តទុកដាក់ខាងវិញ្ញាណ ។ វាប្រៀបដូចជាសារខ្លីៗមកពីព្រះវរបិតាជាទីស្រឡាញ់ ទុកជាភស្ដុតាងពីការអនុម័តរបស់ទ្រង់ ។ ប្រសិនបើ យើងចាប់ផ្ដើមអ្វីមួយដែលមិនត្រឹមត្រូវដោយមានទំនុកចិត្ត នោះទ្រង់នឹងឲ្យយើងដឹងជាមុនថាយើងបានធ្វើខុសហើយ ។ យើងមានអារម្មណ៍ពីជំនួយនោះតាមរយៈការស្គាល់នូវអារម្មណ៍ពិបាកចិត្ត ឬសប់រសល់ចិត្ត ។

កិច្ចខិតខំរបស់នីហ្វៃដើម្បីទទួលបានផ្ទាំងស្ពាន់បង្ហាញពីរបៀបដែលគោលការណ៍នេះដំណើរការ ( សូមមើល នីហ្វៃទី 1 3:6–7) ។ បន្ទាប់ពីការព្យាយាមចំនួនពីរលើកមិនបានសម្រេចមក នីហ្វៃនៅតែមានទំនុកចិត្ត ។ គាត់



បានលបចូលទៅក្នុងក្រុង ហើយឆ្ពោះទៅកាន់ផ្ទះរបស់ឡាបាន់ដោយគ្មានចម្លើយអ្វីទាំងអស់ ។ គាត់បានសង្កេតឃើញថា « ខ្ញុំត្រូវបាននាំទៅដោយព្រះវិញ្ញាណ ដោយមិនបានដឹងជាមុនសោះឡើយថា តើខ្ញុំនឹងត្រូវធ្វើអ្វីខ្លះ » ដោយបានបញ្ជាក់បន្ថែមទៀតថា *ទោះយ៉ាងណាក៏ដោយ គង់តែខ្ញុំដើរតម្រង់ទៅមុខ* »(នីហ្វៃទី 1 4:6–7 ការគូសបញ្ជាក់បានបន្ថែម ) ។

នីហ្វៃបានមានឆន្ទៈសាកល្បងម្ដងហើយម្ដងទៀត ដោយប្រើអស់ពីសមត្ថភាពរបស់គាត់ ។ គាត់បានបង្ហាញសេចក្ដីជំនឿថា គាត់នឹងទទួលបានជំនួយ ។ គាត់បានបាក់ទឹកចិត្ត ។ ប៉ុន្តែដោយសារតែគាត់បានអនុវត្ត មានទំនុកចិត្តលើព្រះអម្ចាស់ គោរពតាម ហើយបានប្រើសិទ្ធិជ្រើសរើសរបស់គាត់បានត្រឹមត្រូវ នោះគាត់បានទទួលការដឹកនាំ ។ គាត់ត្រូវបានបំផុសគំនិតមួយជំហានម្ដងៗ ទៅរកភាពជោគជ័យ ហើយនៅក្នុងប្រសាសន៍របស់គាត់ត្រូវបាន « ប្រទាន*អំណាច*. . .[ដើម្បី ] សម្រេចនូវកិច្ចការដែលព្រះអម្ចាស់ទ្រង់បានបញ្ជា » (នីហ្វៃទី 1 5:8 ការគូសបញ្ជាក់បានបន្ថែម ) ។

នីហ្វៃបានដឹងថា គាត់ត្រូវទុកចិត្តលើព្រះ អនុវត្តសេចក្ដីជំនឿ ហើយធ្វើសកម្មភាព ដើម្បីគាត់អាចទទួលបានជំនួយ មួយជំហានម្ដងៗ ។ គាត់មិនបានត្អូញត្អែរ ឬសួររកការពន្យល់ដ៏ពេញលេញមួយនោះទេ ។ ប៉ុន្តែ ភាគច្រើន គាត់បានសង្កេត ហើយមិនបានរង់ចាំជំនួយដោយមិនបញ្ចេញសកម្មភាពសោះឡើយ ។ គាត់បានធ្វើសកម្មភាព ! ដោយធ្វើតាមក្រឹត្យវិន័យខាងវិញ្ញាណ គាត់ត្រូវបានបំផុសគំនិត ហើយផ្ដល់ឲ្យនូវអំណាចដើម្បីធ្វើសកម្មភាព ។

**ការទុកចិត្តលើព្រះទ័យ និង វិធីរបស់ព្រះ**

ពេលខ្លះ ចម្លើយចំពោះការអធិស្ឋានមិនត្រូវបានស្គាល់ ដោយសារយើងផ្ដោតចិត្តទៅលើការបញ្ជាក់ចំពោះការចង់បាន តាមបំណងប្រាថ្នារបស់យើងពេក ។ យើងបរាជ័យនឹងមើលឃើញថា ព្រះអម្ចាស់នឹងឲ្យធ្វើអ្វីមួយផ្សេងទៀត ។ ចូរយកចិត្តទុកដាក់ដើម្បីយល់ពីព្រះទ័យរបស់ទ្រង់ ។

ខ្ញុំសូមសារភាពថា ខ្ញុំមិនដឹងពីរបៀបដើម្បីធ្វើការសម្រេចចិត្តមួយត្រឹមត្រូវនោះទេ លើកលែងតែមានសេចក្ដីសុចរិត និង ការទុកចិត្តលើព្រះវរបិតាសួគ៌ ។ គោលការណ៍នឹងមិនមានប្រសិទ្ធិភាពទេ នៅពេលណាសិទ្ធិជ្រើសរើសត្រូវបានប្រើដើម្បីផ្លាស់ប្ដូរព្រះទ័យរបស់ព្រះដោយចេតនានោះ ។ ប្រសិនបើមានអំពើបាបមិនបានប្រែចិត្ត យើងត្រូវបានទុកចោលឲ្យប្រផេះប្រផាស់ ពុះពារដោះស្រាយបញ្ហាដោយខ្លួនឯង ។ យើង*អាច*ទទួលបានការសង្គ្រោះតាមរយៈការប្រែចិត្តរបស់យើងផ្ទាល់ ។

នៅពេលយើងស្វែងរកការបំផុសគំនិតដើម្បីជួយធ្វើការសម្រេចចិត្ត ព្រះអម្ចាស់ប្រទានការបំផុសគំនិតដ៏ផ្អែមល្ហែមទន់ភ្លន់ ។ ការណ៍ទាំងនេះតម្រូវឲ្យយើងគិត អនុវត្តសេចក្ដីជំនឿ បញ្ចេញសកម្មភាព ពេលខ្លះពុះពារ ហើយធ្វើសកម្មភាព ។ វាកម្រណាស់ដែលចម្លើយទាំងស្រុងចំពោះបញ្ហាដ៏សំខាន់ ឬស្មុគស្មាញបំផុតកើតមានឡើងក្នុងពេលតែមួយនោះ ។ ជានិច្ចកាល វាកើតឡើងមួយបន្តិចម្ដងៗ ដោយមានគំនិតមិនចេះចប់ឡើយ ។

ខ្ញុំបានទុកផ្នែកដ៏សំខាន់បំផុតស្ដីពីការអធិស្ឋាននៅចុងបញ្ចប់ ។ វាគឺជាការថ្លែងអំណរគុណ ! កិច្ចខិតខំដ៏ស្មោះត្រង់របស់យើងដើម្បីថ្លែងអំណរគុណដល់ព្រះវរបិតាជាទីស្រឡាញ់នៃយើងបង្កើតនូវអារម្មណ៍សុខសាន្ត ទំនុកចិត្ត និងសេចក្ដីស្រឡាញ់ដ៏អស្ចារ្យ ។

ហេតុអ្វីបានជាអ្នកដែលក្រីក្របំផុតទំនងជាដឹងពីរបៀបដ៏ល្អបំផុតដើម្បីថ្លែងអំណរគុណដល់ព្រះអម្ចាស់ ? នៅតំបន់ខ្ពង់រាបនៃប្រទេសហ្គាតេម៉ាឡា សមាជិកមានជីវិតលំបាកណាស់ ។ ការទៅព្រះវិហារបរិសុទ្ធតម្រូវឲ្យមានការលះបង់ដ៏អស្ចារ្យ ។ ដំណើរនោះត្រូវមានការរៀបចំខ្លួនរយៈពេលមួយឆ្នាំ ។ មានការងារលំបាក ការលះបង់ដើម្បីសន្សំប្រាក់ និង អាហារ ការបង្វិលហោត់ ការជ្រលក់ថ្នាំ និងការត្បាញសំលៀកបំពាក់ថ្មី ។ មានការចេញពីភ្នំដោយជើងទទេរនៅលើ

**ពេលខ្លះ ចម្លើយចំពោះការអធិស្ឋានមិនត្រូវបានស្គាល់ ដោយសារយើងផ្ដោតទៅលើការបញ្ជាក់នៃបំណងប្រាថ្នាដែលយើងចង់បានពេក ។**

ចម្ងាយផ្លូវដ៏ឆ្ងាយ ការឆ្លងកាត់បឹងអ៊ីសាប៊ែល ជិះរថយន្តក្រុងដោយមានអាហារតិចតួច ។ ពួកគេបានទៅដល់ព្រះវិហារបរិសុទ្ធទាំងអស់កម្លាំង ហើយនឿយហត់ ។ ពួកគេដុសសម្អាតខ្លួនទាល់តែស្អាត ស្លៀកសំលៀកបំពាក់ថ្មី ហើយចូលទៅដំណាក់ព្រះអម្ចាស់ ។

ដោយពាក់សំលៀកបំពាក់-សសារជាថ្មី ពួកគេត្រូវបានបង្រៀនដោយព្រះវិញ្ញាណ ទទួលពិធីបរិសុទ្ធ ហើយធ្វើសេចក្ដីសញ្ញា ។ មានស្ត្រីតំបន់ខ្ពង់រាបម្នាក់មានអារម្មណ៍រំភើបយ៉ាងខ្លាំងដោយព្រះវិញ្ញាណ និង អត្ថន័យនៃអំណោយទានពិសិដ្ឋ ។ កាលចូលទៅបន្ទប់សេឡេស្ទាល គាត់បានលុតជង្គង់នៅច្រកទ្វារចូលបន្ទប់នោះ ហើយធ្វើឲ្យអ្នកដទៃទៀតឆ្ងល់ ។ គាត់បានឱនក្បាលស្ងឹងស្ងាត ហើយបានភ្ជាប់ដួងចិត្តទៅព្រះវរបិតាសួគ៌គាត់រយៈពេលម្ភៃនាទី ។ នៅទីបំផុត ដោយមានស្នាមទឹកភ្នែកស្រក់លើសំលៀកបំពាក់គាត់ គាត់បានងើបក្បាលឡើង ។ អ្នកបម្រើស្រីនៅក្នុងព្រះវិហារបរិសុទ្ធបានសួរថា « តើខ្ញុំអាចជួយបានទេ ? » គាត់តបថា « អូ ពិតមែនឬ ? នេះជាបញ្ហាខ្ញុំ ៖ ខ្ញុំព្យាយាមប្រាប់ព្រះវរបិតាសួគ៌ពីអំណរគុណដែលខ្ញុំមានចំពោះរាល់ពរជ័យរបស់ខ្ញុំ ប៉ុន្តែខ្ញុំគ្មានអារម្មណ៍ថា ខ្ញុំមិនអាចទាក់ទងនឹងទ្រង់បានសោះ ។ តើអ្នកអាចជួយខ្ញុំជម្រាបដល់ទ្រង់ថាខ្ញុំមានអំណរគុណប៉ុណ្ណាបានទេ ? »

ការទូន្មាននេះស្ដីពីការអធិស្ឋានគឺជាការពិត ។ ខ្ញុំបានសាកល្បងវាពេញមួយជីវិតរបស់ខ្ញុំ ។ ខ្ញុំបានរកឃើញថា ពេលខ្លះអ្វីដែលទំនងជាការលំបាកនៅក្នុងទំនាក់ទំនងគឺជាជំហានដ៏ធំមួយដើម្បីដើរឆ្ពោះទៅមុខដោយទំនុកចិត្ត ។

ប្រសិនបើអ្នកស្វែងរកជំនួយរបស់ទ្រង់ សូមធ្វើឲ្យប្រាកដថាជីវិតរបស់អ្នកមានភាពស្អាតស្អំ គោលបំណងរបស់អ្នកមានភាពសក្ដិសម ហើយអ្នកនឹងមានឆន្ទៈធ្វើអ្វីដែលទ្រង់សុំឲ្យធ្វើ—ត្បិតទ្រង់នឹងឆ្លើយតបការអធិស្ឋានរបស់អ្នក ។ ទ្រង់ជាព្រះវរបិតាជាទីស្រឡាញ់របស់អ្នក ។ អ្នកគឺជាបុត្រជាទីស្រឡាញ់របស់ទ្រង់ ។ ទ្រង់ស្រឡាញ់អ្នកយ៉ាងល្អឥតខ្ចោះ ហើយចង់ជួយអ្នក ។ ■



# ចុះបើខ្ញុំគ្មានអារម្មណ៍ខ្ទួលខ្ទាញ់ នៅក្នុងទ្រូង វិញ ?

*នៅពេលអ្នកដឹងពីអ្វីដែលអ្នកស្វែងរក អ្នកកាន់តែងាយស្រួលនៅក្នុងការស្គាល់ព្រះវិញ្ញាណបរិសុទ្ធ ។*

**ដោយ រ៉ាផែល នៀលសិន**

« អញ្ជើញលោក វូដ*មកថ្នាក់សិក្ខាសាលា » ។ គំនិតនោះបានផុសនៅក្នុងគំនិតរបស់ខ្ញុំមួយរំពេចពេលខ្ញុំបានស្ដាប់ឮសេចក្ដីប្រកាស ហើយភ្លាមនោះខ្ញុំបានគិតថាវាជារឿងលីលា ។ ហេតុអ្វីបានជាខ្ញុំត្រូវអញ្ជើញគ្រូតន្ត្រីរបស់ខ្ញុំមកថ្នាក់សិក្ខាសាលានៅម៉ោង 5:30 ព្រឹកទៅវិញ ?

ប្រធានថ្នាក់សិក្ខាសាលាទើបប្រាប់ថ្នាក់សិស្សក្នុងថ្នាក់ថា យើងមានកម្មវិធីថ្ងៃថ្លែងអំណរគុណដល់គ្រូបង្រៀន ។ យើងត្រូវបានសុំឲ្យអញ្ជើញគ្រូបង្រៀនរបស់យើងមួយចំនួននៅឯសាលា មកចូលរួមជាមួយនឹងយើងសម្រាប់ថ្នាក់សិក្ខាសាលានៅពេលព្រឹក ដើម្បីយើងបានថ្លែងអំណរគុណដល់ពួកគាត់សម្រាប់ការបង្រៀនរបស់ពួកគាត់ ។ បន្ទាប់ពីបានឮការប្រកាសនោះ ខ្ញុំបានគិតពីការអញ្ជើញលោក វូដ ពេញមួយសប្ដាហ៍ ។ រាល់ពេលដែលខ្ញុំទៅថ្នាក់សិក្ខាសាលា ឬ ឃើញគាត់នៅក្នុងថ្នាក់តន្ត្រី គំនិតនោះបានផុសឡើងម្ដងទៀត ៖ « អញ្ជើញលោក វូដ មកថ្នាក់សិក្ខាសាលា » ។ បន្ទាប់ពីគំនិតនេះបានកើតឡើងជាច្រើនថ្ងៃ ខ្ញុំមិនអាចព្រងើយកន្តើយវាបានទៀតឡើយ ។

នាព្រឹកមួយ ពេលសិស្សទាំងអស់ក្នុងថ្នាក់តន្ត្រីកំពុងដកយកឧបករណ៍របស់ពួកគេចេញមក ខ្ញុំបានដាក់ត្រែរបស់ខ្ញុំទៅម្ខាង ហើយដើរទៅរកលោក វូដ ។ បេះដូងរបស់ខ្ញុំបានលោតខុសចង្វាក់ ហើយដៃរបស់ខ្ញុំញ័រ ប៉ុន្តែពេលខ្ញុំហើបមាត់ដើម្បីអញ្ជើញគាត់ នោះខ្ញុំមានអារម្មណ៍កក់ក្ដៅ ។

ខ្ញុំបានភ្ញាក់ផ្អើល ពេលលោក វូដ បាននិយាយថាគាត់នឹងទៅ ! គាត់ចង់ដឹងថាហេតុអ្វីបានជាខ្ញុំទៅថ្នាក់សិក្ខាសាលា រាល់ព្រឹកពីមុនទៅសាលា ហើយគាត់ចង់រៀនបន្ថែមទៀត ។ បន្ទាប់ពីផ្ដល់ព័ត៌មានលម្អិតដល់គាត់មក ខ្ញុំបានដើរចេញទាំងសេចក្ដីអំណរយ៉ាងខ្លាំង ។

នៅក្នុងបទពិសោធន៍នេះ ខ្ញុំមិនបានទទួលអារម្មណ៍ខ្ទួលខ្ទាញ់នៅក្នុងទ្រូងទេ (សូមមើល គ. និង ស. 9:8) ។ ប៉ុន្តែខ្ញុំពិតជាបានទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ។ គំនិតដដែលៗឲ្យអញ្ជើញលោក វូដ (សូមមើល គ. និង ស. 128:1) ជាការលួងលោមដែលខ្ញុំមាននៅពេលខ្ញុំ

*ឈ្មោះត្រូវបានផ្លាស់ប្ដូរ ។

បានអញ្ជើញគាត់ (សូមមើលយ៉ូហាន 14:26) និង សេចក្ដីអំណរដែលខ្ញុំមានបន្ទាប់ពីអញ្ជើញគាត់ (សូមមើល កាឡាទី 5:22) ទាំងអស់នេះកើតចេញពីព្រះវិញ្ញាណ ។ ប៉ុន្តែប្រសិនបើខ្ញុំរកមើលតែភាពខ្លួលខ្មាញ់នៅក្នុងទ្រូង នោះខ្ញុំប្រហែលជាមិនបានដឹងទេ នៅពេលព្រះវិញ្ញាណបរិសុទ្ធបានបំផុសគំនិតដល់ខ្ញុំ ។

ព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលតាមរបៀបជាច្រើន ហើយនៅពេលអ្នកសិក្សាពីរបៀបដែលទ្រង់ទំនាក់ទំនង នោះអ្នកដឹងពីអ្វីដែលត្រូវរកមើលពេលអ្នកព្យាយាមស្គាល់ពេល ដែលទ្រង់គង់នៅជាមួយនឹងអ្នក និង ពេលដែលទ្រង់កំពុងបង្រៀន ឬដឹកនាំអ្នក ។

## រកមើលរឿងដ៏តូច ហើយងាយ

ពីមុនមើលទៅរបៀបជាច្រើនដែលព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលមកកាន់យើង យើងត្រូវចងចាំថា ជានិច្ចកាល វិវរណៈមានភាពស្ងប់ស្ងាត់ ហើយតូច ។ ប្រសិនបើយើងកំពុងមើលទៅបទពិសោធន៍របស់អាលម៉ាជាកូនជាមួយនឹងទេវតា និង ការរញ្ជួយដី នោះយើងអាចមើលរំលងនូវការបំផុសគំនិតជាទៀងទាត់ ហើយស្ងប់ស្ងាត់ពីព្រះវិញ្ញាណបរិសុទ្ធ ។ អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានព្រមានថា ប្រសិនបើយើង « សង្កត់ធ្ងន់ទៅលើការបើកសម្ដែងខាងវិញ្ញាណដ៏អស្ចារ្យ ហើយគួរឲ្យចាប់អារម្មណ៍នោះ » យើងអាចមើលរំលងនូវ « ការបំផុសគំនិតខាងវិញ្ញាណដ៏តូច » ដែលជារឿងសាមញ្ញ ។[1]នៅពេលអ្នកព្យាយាមស្គាល់ព្រះវិញ្ញាណបរិសុទ្ធ សូមស្វែងរកការបំផុសគំនិតដ៏តូច ហើយងាយ ។

## ស្វែងរកវិធីដែលព្រះវិញ្ញាណបរិសុទ្ធទំនាក់ទំនង

ប្រសិនបើអ្នកពុំធ្លាប់មានអារម្មណ៍ខ្លួលខ្មាញ់នៅក្នុងទ្រូង សូមកុំបារម្ភ ។ មានមនុស្សជាច្រើនដែលស្គាល់ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធតាមរបៀបនេះ ប៉ុន្តែទ្រង់ក៏មានបន្ទូលតាមរបៀបផ្សេងទៀតជាច្រើនផងដែរ ហើយអ្នកពុំចាំបាច់មានអារម្មណ៍ខ្លួលខ្មាញ់នៅក្នុងទ្រូងដើម្បីទទួលអារម្មណ៍ពីវត្តមានរបស់ទ្រង់នោះទេ ។ ពិតណាស់នៅពេលអ្នករៀនពីរបៀបដែលព្រះវិញ្ញាណបរិសុទ្ធបំផុសគំនិតអ្នក ហើយស្វែងរករបៀបទាំងនោះនៅក្នុងជីវិតរបស់អ្នក អ្នកអាចរកឃើញថា ទ្រង់កំពុងទំនាក់ទំនងនឹងអ្នកលើសពីអ្នកអាចដឹងទៅទៀត ។

បញ្ជីនេះរួមមានតែរបៀបមួយចំនួនតូច ដែលព្រះវិញ្ញាណបរិសុទ្ធមានព្រះបន្ទូល ។ សូមសិក្សាព្រះគម្ពីរ និង ប្រសាសន៍របស់ពួកព្យាការីសម័យទំនើប ក៏ដូចជានៅទំព័រ 98–99 ក្នុង *ប្រកាសដំណឹងល្អរបស់យើង ៖ សៀវភៅណែនាំសម្រាប់ការបម្រើរបស់អ្នកផ្សព្វផ្សាយសាសនា* ( ឆ្នាំ 2004 ) ដើម្បីរកមើលរបៀបបន្ថែមទៀតដែលទ្រង់អាចមានបន្ទូលមកកាន់អ្នក ។

« ជាទូទៅ វិញ្ញាណនៃវិវរណៈកើតឡើងជាគំនិត និង អារម្មណ៍ដែលចូលទៅក្នុងគំនិត និង ចិត្តរបស់យើងតាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។ (សូមមើល គ. និង ស. 8:1–2, 100:5–8) » ។[2] ព្រះវិញ្ញាណបរិសុទ្ធអាចមានបន្ទូលមកកាន់អ្នកតាមរយៈ ៖

- អារម្មណ៍នៃសេចក្ដីស្រឡាញ់ សេចក្ដីអំណរ សេចក្ដីសុខសាន្ត សេចក្ដីអត់ធ្មត់ សេចក្ដីល្អ សេចក្ដីជំនឿ សេចក្ដីរាបសា (សូមមើល កាឡាទី 5:22–23) ។
- គំនិតដែលមានក្នុងគំនិត ឬ ដក់ជាប់ក្នុងអារម្មណ៍របស់អ្នក (សូមមើល គ. និង ស. 128:1) ។
- បំណងធ្វើល្អ ហើយ គោរពប្រតិបត្តិតាមព្រះបញ្ញត្តិ (សូមមើល ម៉ូសាយ 5:2) ។
- អារម្មណ៍ដែលថារឿងអ្វីមួយគឺជារឿងត្រឹមត្រូវ (សូមមើល គ. និង ស. 9:8) ។
- អារម្មណ៍នៃការលួងលោម (សូមមើល យ៉ូហាន 14:26) ។
- អារម្មណ៍ដែល « ពង្រីកព្រលឹង [ របស់អ្នក ] » (អាលម៉ា 32:28) ។
- គំនិតដែល « បំភ្លឺយោបល់ [ របស់អ្នក ] » (អាលម៉ា 32:28) ។
- ការស្រេកឃ្លាននូវសេចក្ដីពិតថែមទៀត (សូមមើល អាលម៉ា 32:28) ។
- អារម្មណ៍ដឹងដោយខ្លួនឯង ( លើកទឹកចិត្ត ) ឲ្យបញ្ចេញសកម្មភាពមួយ ឬ ឃាត់ ( ទប់ចិត្ត ) ពីការធ្វើអ្វីមួយ (សូមមើល នីហ្វៃទី 1 7:15, នីហ្វៃទី 2 32:7) ។



### តើភាពខ្លួលខ្មាញ់នៅក្នុងទ្រូងជាអ្វីទៅ ?

« តើ ‹ ភាពខ្លួលខ្មាញ់នៅក្នុងទ្រូង › » មានន័យដូចម្ដេច ? តើវាចាំបាច់ត្រូវជាអារម្មណ៍មួយនៃភាពក្ដៅ ដូចជាការបង្កើតកំដៅដោយចំហេះមែនទេ ? ប្រសិនបើវាមានន័យបែបនោះមែន ខ្ញុំពុំធ្លាប់មានភាពខ្លួលខ្មាញ់នៅក្នុងទ្រូងឡើយ ។ ប្រាកដណាស់ ពាក្យថា ‹ ភាពខ្លួលខ្មាញ់› នៅក្នុងបទគម្ពីរនេះគួសបញ្ជាក់ពីអារម្មណ៍នៃការលួងលោម និង ភាពស្ងប់ស្ងាត់ ។ នោះគឺជាសាក្សីដែលមនុស្សជាច្រើនបានទទួល ។ នោះគឺជារបៀបដែលវិវរណៈដំណើរការ » ។

**អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Teaching and Learning by the Spirit » *លេអាហូណា* ខែ ឧសភា ឆ្នាំ 1999 ទំព័រ 22 ។**



## តើខ្ញុំអាចដឹងថា គំនិតមួយជាគំនិតខ្ញុំ ឬ មកពីព្រះវិញ្ញាណបរិសុទ្ធដោយរបៀបណា ?

« យើងត្រូវធ្វើសកម្មភាព ។ បន្ទាប់មកយើងនឹងរកឃើញថា តើវាជាគំនិតរបស់យើង ឬ ជាព្រះចេស្ដានៃព្រះ ។ . . .អ្វីគ្រប់យ៉ាងដែលអញ្ជើញ ហើយទាក់ទាញយើងឲ្យធ្វើល្អ ហើយក្លាយជាមនុស្សល្អគឺមកពីព្រះ » ។

**អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Patterns of Light: Discerning Light » ( វីដេអូ ), LDS.org ។ សូមមើល វីដេអូទាំងមូលនៅ lds.org/go/patternL6 ។**

### របៀបដែលគំនិត និង អារម្មណ៍ទាំងនេះអាចកើតមាន

គំនិត និង អារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធអាចកើតមាន ៖

- « ភ្លាមៗ ហើយសឹជម្រៅ » ។
- « បន្តិចម្ដងៗ » ។
- « យ៉ាងហ្មត់ចត់រហូតធ្វើឲ្យអ្នកស្ទើរមិនអាចស្គាល់ » ។[3]

រៀនបន្ថែមទៀតពីបញ្ហានេះតាមរយៈការមើលវីដេអូមួយនៅ lds.org/go/revelationL6 ។

គំនិត និង អារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធអាចកើតមាន ៖

- ដើម្បីធ្វើឲ្យយើងចងចាំនូវរឿងទាំងឡាយ (សូមមើល យ៉ូហាន 14:26) ។
- ដើម្បីការពារយើងពីការបោកបញ្ឆោត (សូមមើល គ. និង ស. 45:57) ។
- ដើម្បីធ្វើទីបន្ទាល់ពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ (សូមមើលនីហ្វៃទី 2 31:18) ។
- ដើម្បីជួយយើងបង្រៀន (សូមមើល គ. និង ស. 84:85) ។
- ប្រទានអំណោយទានទាំងឡាយនៃព្រះវិញ្ញាណ (សូមមើល គ. និង ស. 46:11) ។
- ដើម្បីនាំមកនូវការផ្ដាច់បាប (សូមមើល នីហ្វៃទី 2 31:17) ។

### ស្វែងរកសេចក្ដីល្អ

នៅពេលអ្នកកំពុងព្យាយាមស្គាល់ព្រះវិញ្ញាណ សូមគិតពីលទ្ធផលដែលចង់បានរបស់អារម្មណ៍ ៖ តើគំនិត ឬ អារម្មណ៍នោះ ដឹកនាំអ្នកឲ្យធ្វើល្អដែរទេ ? មរ៉ូណៃ 7:16 បានចែងថា « ហេតុដូច្នោះហើយ ខ្ញុំបង្ហាញដល់អ្នកនូវវិធីវិនិច្ឆ័យ ត្បិតគ្រប់ទាំងអ្វីៗដែលអញ្ជើញឲ្យធ្វើល្អ ហើយដែលបញ្ចុះបញ្ចូលឲ្យជឿលើដល់ព្រះគ្រីស្ទ នោះគឺបានចាត់មកពីព្រះចេស្ដា និង អំណោយទាននៃព្រះគ្រីស្ទ ហេតុដូច្នោះហើយ អ្នករាល់គ្នាអាចដឹងដោយតំរិះដ៏ឥតខ្ចោះថា មកពីព្រះ » ។

ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ឆ្នាំ 1910–2008 ) បានមានប្រសាសន៍ថា « តើយើងដឹងអំពីការបំផុសគំនិតនៃព្រះវិញ្ញាណដោយរបៀបណា ? តាមពិតទៅខ្ញុំគិតថា វាពុំមែនជារឿងពិបាកនោះទេ ។ . . .តើវាបានបញ្ចុះបញ្ចូលមនុស្សម្នាក់ឲ្យធ្វើល្អ ឲ្យក្រោកឡើងឈរឲ្យខ្ពស់ ធ្វើរឿងត្រឹមត្រូវ មានចិត្តល្អ មានសេចក្ដីសប្បុរសដែរទេ ? នោះហើយជាព្រះវិញ្ញាណនៃព្រះ ។ ប្រសិនបើវាជាភាពងងឹត អំពើអាក្រក់ រឿងកខ្វក់ ទុច្ចរិត នោះអ្នកអាចដឹងថា វាមកពីមារសត្រូវ » ។[4]

ប្រសិនបើអ្នកងឿងឆ្ងល់ថា តើអ្នកកំពុងមានអារម្មណ៍ពីព្រះវិញ្ញាណដែរឬអត់ នោះសូមសួរខ្លួនឯងថា តើគំនិត ឬ អារម្មណ៍នោះកំពុងអញ្ជើញអ្នកឲ្យធ្វើល្អដែរទេ ។ ប្រសិនអញ្ចឹងមែននោះ អ្នកអាចប្រាកដថា វាគឺមកពីព្រះ ។

### ស្វែងរកឱកាសមួយដើម្បីប្រើសិទ្ធិជ្រើសរើសរបស់អ្នក

ប្រសិនបើអ្នកមានភាពសក្ដិសម ហើយអ្នកនៅតែមានការលំបាកនៅក្នុងការស្គាល់ព្រះវិញ្ញាណបរិសុទ្ធ

សូមធ្វើសកម្មភាព ។ ព្រះវរបិតាសួគ៌បានប្រទានពរឲ្យអ្នកនូវសិទ្ធិជ្រើសរើស ហើយពេលខ្លះទ្រង់នឹងតម្រូវឲ្យអ្នកធ្វើសកម្មភាពដោយគ្មានការដឹកនាំរបស់ទ្រង់ ។ ទ្រង់នឹងបង្គាប់ឲ្យអ្នកអនុវត្តសេចក្ដីជំនឿរបស់អ្នកដោយការបោះជំហានចូលទៅក្នុងភាពងងឹត ។ ប្រធាន ប៊ យដ៍ ឃេ ផាកកឺ ជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានថ្លែងថា « នៅក្នុងការស្វែងរករបស់អ្នកសម្រាប់ចំណេះដឹងខាងវិញ្ញាណ ពេលខ្លះវាត្រូវការឲ្យមាននូវ ‹ ជំហាននៃសេចក្ដីជំនឿ › ។ . . .មានគ្រាដែលអ្នកបានទៅដល់ជាយនៃពន្លឺ ហើយបានបោះជំហានចូលក្នុងភាពងងឹត ដើម្បីរកមើលថា តើផ្លូវនោះមានពន្លឺនៅខាងមុខ សម្រាប់ដើរបោះជំហាន មួយឬពីរជំហាន ដែរឬទេ ។ [5]ប្រសិនបើអ្នកធ្វើដោយស្មោះត្រង់ តាមចំណេះដឹងដែលអ្នកមានរួចហើយនោះ ទោះជាគ្មានស្គាល់នូវការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធក្ដី នោះព្រះវរបិតានឹងធ្វើឲ្យប្រាកដថា អ្នកនឹងមិនវង្វេងផ្លូវឡើយ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*

**កំណត់ចំណាំ**


1. ដេវីឌ អេ បែដណា « The Spirit of Revelation » *Liahona,* ខែ ឧសភា ឆ្នាំ 2011 ទំព័រ 88 ។
2. ដេវីឌ អេ បែដណា « The Spirit of Revelation » ទំព័រ 88 ។
3. ដេវីឌ អេ បែដណា « The Spirit of Revelation » ទំព័រ 90 ។
4. *Teachings of Gordon B. Hinckley* ( ឆ្នាំ 1997 ) ទំព័រ 260–61 ។
5. ប៊យដ៍ ឃេ ផាកកឺ «The Quest for Spiritual Knowledge» *Liahona,* ខែ មករា ឆ្នាំ 2007 ទំព័រ 18 ។




**ហេតុអ្វីបានជាការស្គាល់ព្រះវិញ្ញាណបរិសុទ្ធមានការពិបាកម្ល៉េះ ?**

« ព្រះវរបិតារបស់យើងរំពឹងឲ្យអ្នករៀន ពីរបៀបដើម្បីទទួលបានជំនួយដ៏ទេវភាពនោះតាមរយៈការអនុវត្តសេចក្ដីជំនឿជឿលើទ្រង់ និង ព្រះរាជបុត្រាដ៏បរិសុទ្ធរបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ។ ប្រសិនបើអ្នកទទួលបានការដឹកនាំដ៏បំផុសគំនិតដោយគ្រាន់តែការទូលសុំតែម៉្យាង នោះអ្នកនឹងមានភាពទន់ខ្សោយ ហើយពឹងផ្អែកលើទ្រង់កាន់តែច្រើនថែមទៀត ។ ទ្រង់ដឹងថាការរីកចម្រើនផ្ទាល់ខ្លួនដ៏ចាំបាច់នឹងកើតមាន នៅពេលណាអ្នកជួបនឹងបញ្ហាក្នុងការរៀនពីរបៀបទទួលបានការដឹកនាំពីព្រះវិញ្ញាណ » ។

**អែលឌើរ រីឆាត ជី ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « To Acquire Spiritual Guidance » *Liahona,* ខែ វិច្ឆិកា ឆ្នាំ 2009 ទំព័រ 7 ។**

## តើព្រះវិញ្ញាណធ្វើឲ្យយើងមានអារម្មណ៍បែបណា ?

« យើងគ្មានពាក្យ. . .យ៉ាងល្អឥតខ្ចោះចំពោះពិពណ៌នាពីព្រះវិញ្ញាណបានឡើយ ( ប៊យដ៍ ឃេ ផាកកឺ «The Candle of the Lord," *Tambuli,* ខែ ធ្នូ ឆ្នាំ 1988 ទំព័រ 34 ) ។ ដោយសារភាពពិបាកនៅក្នុងការរៀបរាប់នូវអារម្មណ៍ពីព្រះវិញ្ញាណ នោះមនុស្សគ្រប់គ្នាបានរៀបរាប់វាតាមរបៀបខុសៗគ្នាបន្តិចបន្តួច ។ ប៉ុន្តែដោយមិនគិតពីភាពខុសគ្នាទាំងនេះ យើងអាចរៀនបានច្រើននៅពេលមនុស្សដទៃពន្យល់ពីរបៀបដែលព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលទៅកាន់ពួកគេ ។ សូមមើលពីមនុស្សមួយចំនួនដែលបានរៀបរាប់ពីអារម្មណ៍របស់ពួកគេអំពីព្រះវិញ្ញាណបរិសុទ្ធនៅ lds.org/go/powerL6 ។

# សូម
# ធ្វើតាមការបំផុសគំនិត
# តូចៗ

*រាល់ការខ្សឹបប្រាប់ពីព្រះវិញ្ញាណ បរិសុទ្ធគឺជារឿងដែលត្រូវ ត្រងត្រាប់ស្ដាប់បំផុត ។*

ប្រសិនបើមានខ្យល់ព្យុះកំបុតត្បូងមួយបានគួចយកដើមឈើដ៏ធំបក់បោកមកលើគ្រែដេករបស់អ្នកនៅពេលយប់ អ្នកប្រហែលជាចង់ដឹងពីវាទុកជាមុន ។

វិលហ្វូឌ វូឌដ្រុព្វ ( ឆ្នាំ 1807–98 ) ដែលក្រោយមកបានក្លាយជាប្រធានទីបួននៃសាសនាចក្រ មានពេលមួយបានសម្រាកនៅខាងក្រៅក្នុងរទេះរបស់គាត់ជាមួយនឹងភរិយា និងកូនរបស់គាត់ ពេលព្រះវិញ្ញាណបានខ្សឹបប្រាប់ថា « ក្រោកឡើង ហើយរំកិលរទេះ [ របស់អ្នក ] ចេញ » ។[1]គាត់អាចគិតថា វាជាគំនិតចម្លែកមួយ ប៉ុន្តែគាត់នៅតែធ្វើតាម ។ កន្លះម៉ោងក្រោយមក មានខ្យល់ព្យុះមួយបក់គួចយកដើមឈើមួយធំទៅលើអាកាស ។ ដើមឈើនោះ បានធ្លាក់ចំកន្លែងដែលរទេះនៅ ។

មានឧទាហរណ៍ស្ដីពីអព្ភូតហេតុបែបនេះជាច្រើន ដែលបានកើតឡើងជាលទ្ធនៃការធ្វើតាមការបំផុសគំនិត ។

ចុះតើការបំផុសគំនិតមួយដែលបំផុសអ្នកឲ្យនិយាយពាក្យ ថាសួស្ដីទៅមិត្តម្នាក់តាមទូរស័ព្ទវិញ ? ឬការបំផុសមួយឲ្យដាក់ស្រោមជើងមួយគូទៀត នៅក្នុងការបូបយួររបស់អ្នក សម្រាប់ការដើរឡើងភ្នំលើកក្រោយរបស់អ្នក ? ការធ្វើតាមការបំផុសគំនិតបែបនេះទំនងជាមិនបាននាំទៅរកលទ្ធផល ដែលគួរឲ្យចាប់អារម្មណ៍នោះទេ ប៉ុន្តែវានៅតែវារឿងដ៏សំខាន់ ។

មិត្តដែលអ្នកបានទូរស័ព្ទទៅអាចមានបញ្ហាពិបាកចិត្ត ។ ការទូរស័ព្ទទៅអាចធ្វើឲ្យគាត់រីករាយក្នុងចិត្ត ។ ចំពោះការដើរឡើងភ្នំ ស្រោមជើងមួយគូទៀតអាចមានប្រយោជន៍យ៉ាងធំធេង ដំណើរមួយដ៏រីករាយ និង ពងបែកនៅនឹងជើង ប្រសិនបើជើងរបស់អ្នកសើម ។

ប្រធាន ថូម៉ាស អេស ម៉នសុន បានបង្រៀនថា ៖ « យើងមើល ។ យើងរង់ចាំ ។ យើងស្ដាប់នូវសំឡេងដ៏តូចរហៀងនោះ ។ នៅពេលទ្រង់មានព្រះបន្ទូលបុរស និងស្ត្រីដែលឆ្លាតប្រតិបត្តិតាម។ យើងពុំត្រូវពន្យារពេលក្នុងការធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាណឡើយ » ។[2]

ពេលខ្លះ ការបំផុសគំនិតខាងវិញ្ញាណគឺត្រូវការជាបន្ទាន់ ។ ប៉ុន្តែជានិច្ចកាល វាស្ងប់ស្ងាត់ ។ ព្រះវរបិតាសួគ៌បានសន្យាដឹកនាំយើង « មួយបន្ទាត់ម្ដងៗ មួយសិក្ខាបទម្ដងៗ ឯណេះបន្តិច ឯណោះបន្តិច » (នីហ្វៃទី 2 28:30) ។

អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖ « ជានិច្ចកាល វិវរណៈកើតឡើងនៅក្នុងចំនួនដ៏តូចបន្តិចម្ដងៗ ហើយត្រូវបានផ្ដល់ឲ្យស្របតាមបំណងប្រាថ្នា ភាពសក្ដិសម និងការរៀបចំខ្លួនរបស់យើង » ។[3]

ភាគច្រើន គ្មានយើងណាម្នាក់ចង់ឲ្យព្យុះកំបុតត្បូងមួយគួចយកដើមឈើមួយឲ្យធ្លាក់មកលើយើងឡើយ ។ ប៉ុន្តែយើងអាចប្រាកដថា វាតែងតែមាននូវរឿងល្អដ៏តូច ហើយសាមញ្ញមួយចំនួនដែលយើងអាចធ្វើ ពេលយើងយកចិត្តទុកដាក់ទៅលើព្រះវិញ្ញាណ ។ ■

**កំណត់ចំណាំ**

1. Teachings of Presidents of the Church: Wilford Woodruff ( ឆ្នាំ 2011 ) ទំព័រ 47 ។
2. ថូម៉ាស អេស ម៉នសុន « The Spirit Giveth Life » Ensign ខែ ឧសភា ឆ្នាំ 1985 ទំព័រ 68។
3. ដេវីឌ អេ បែដណា « The Spirit of Revelation » Liahona, ខែ ឧសភា ឆ្នាំ 2011 ទំព័រ 88 ។

# ការប្រសិទ្ធពរមួយសម្រាប់ប្អូនប្រុសរបស់ខ្ញុំ

មេរៀនទាំងឡាយនៅថ្ងៃអាទិត្យ

*ប្រធានបទសម្រាប់ខែនេះ ៖*

**បព្វជិតភាព និង កូនសោបព្វជិតភាព**

ដោយ ជេស ចូនស៍

ខ្ញុំបានរៀនពីអំណាច និង ពរជ័យទាំងឡាយនៃបព្វជិតភាពនៅគ្រាដ៏អកុសលមួយ ។ ប៉ុន្មានឆ្នាំមុន នៅពេលប្អូនប្រុសរបស់ខ្ញុំអាយុ 14 ឆ្នាំ គាត់បានដួលម៉ូតូ ហើយបានធ្វើឲ្យជើងរបស់គាត់បាក់ ។ ឪពុករបស់ខ្ញុំបានទូរស័ព្ទប្រាប់ខ្ញុំថា គេបានយកគាត់ទៅមន្ទីរពេទ្យហើយ ។ ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំង ខ្ញុំបានរួសរាន់ទៅកាន់មន្ទីរពេទ្យ ។ ពេលខ្ញុំទៅដល់ទីនោះ ខ្ញុំបានឃើញពូរបស់ខ្ញុំម្នាក់ ។ គាត់បានប្រាប់ខ្ញុំពីភាពធ្ងន់ធ្ងរនៃគ្រោះថ្នាក់នោះ ។

ដោយភ័យខ្លាចចំពោះអ្វីដែលខ្ញុំនឹងឃើញ ខ្ញុំបានបើកទ្វារដើរចូលទៅបន្ទប់ដែលប្អូនប្រុសខ្ញុំសម្រាក ។ ខ្ញុំបានដើរចូលមួយជំហានទាំងបិទភ្នែក ហើយបន្តិចម្តងៗសេចក្តីសុខសាន្តបានកើតមាន ។ ដូចដែលខ្ញុំមិនអាចភ្លេចពីការព្រួយបារម្ភរបស់ខ្ញុំដែរ ខ្ញុំមិនអាចភ្លេចពីអារម្មណ៍សុខសាន្ត និងការលួងលោមដែលកើតមានចំពោះខ្ញុំឡើយ ។ ខ្ញុំបានស្គាល់ពីអារម្មណ៍នោះ—វាជាព្រះវិញ្ញាណ ។

បន្ទាប់មកខ្ញុំបានឮឪពុកខ្ញុំនិយាយ ។ គាត់ និងពូខ្ញុំកំពុងធ្វើការប្រសិទ្ធពរបព្វជិតភាពមួយដល់ប្អូនប្រុសខ្ញុំ ។ គាត់បានប្រសិទ្ធពរដល់កូនប្រុសខ្លួនដោយចិត្តរាបទាប នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទឲ្យបានសះស្បើយ ហើយឲ្យជើងរបស់គាត់អាចដើរបានដូចប្រក្រតីវិញ ។

បន្ទាប់ពីការប្រសិទ្ធពរនោះ មនុស្សគ្រប់គ្នាមានការស្ងប់ស្ងាត់មួយរយៈ ។ នៅគ្រានោះខ្ញុំបានដឹងថា ខ្ញុំត្រូវរស់នៅឲ្យសក្តិសមដើម្បីទទួលបព្វជិតភាពមិលគីស្សាដែក ហើយអាចធ្វើការប្រសិទ្ធពរសម្រាប់កូនចៅរបស់ខ្ញុំនាពេលអនាគត ។

នៅពេលយើងបានជួបជុំគ្នានៅច្រកដើរខាងក្រៅបន្ទប់ប្អូនប្រុសខ្ញុំ ឪពុកម្តាយខ្ញុំបានចាប់ផ្តើមពិភាក្សាពីអ្វីដែលពួកគាត់ត្រូវធ្វើ ។ ពួកគាត់បានពិភាក្សាគ្នាថា តើត្រូវយកគាត់ចេញពីប្រទេសម៉ិកស៊ីកូ ទៅជួបនឹងវេជ្ជបណ្ឌិតនៅសហរដ្ឋអាមេរិក ឬធ្វើការវះកាត់នៅទីនេះ ។ គំនិតអ្វីក៏ដោយដែលគាត់ពួកគាត់គិតថាល្អបំផុតសម្រាប់ប្អូនប្រុសខ្ញុំ ខ្ញុំបានដឹងថា គាត់បានទទួលនូវការយកចិត្តទុកដាក់ដ៏ល្អបំផុតដែលគាត់គួរទទួលរួចហើយ ។ គាត់បានទទួលការប្រសិទ្ធពរដោយបុរសពីរនាក់ដែលកាន់បព្វជិតភាព ដូច្នេះមិនថា ឪពុកម្តាយខ្ញុំសម្រេចចិត្តយ៉ាងណាទេ ប្អូនប្រុសខ្ញុំនឹងពុំមានបញ្ហាឡើយ ។

ពួកគាត់បានសម្រេចចិត្តធ្វើការវះកាត់នៅប្រទេសម៉ិកស៊ីកូ ។ ពួកវេជ្ជបណ្ឌិតបានចាប់ដែក រួចដាក់វីសចំនួន 10 ចូលទៅក្នុងជើងរបស់ប្អូនប្រុសខ្ញុំ ។ វាបានជាសះស្បើយយ៉ាងល្អ ហើយពីរបីខែក្រោយមក គាត់បានចូលរួមនឹងក្រុមបាល់ទាត់មួយ ។ ការប្រសិទ្ធពរនោះត្រូវបានបំពេញដូចដែលឪពុករបស់ខ្ញុំបាននិយាយ ។

ខ្ញុំដឹងថា បព្វជិតភាពគឺជាអំណាច និង សិទ្ធិអំណាចរបស់ព្រះដែលបានប្រទានមកឲ្យបុរស ។ វាជាអំណោយទានមួយដ៏អស្ចារ្យម្ល៉េះហ្ន៎ដែលទ្រង់បានប្រទានឲ្យយើង ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ ឈីវ៉ាវ៉ា ប្រទេសម៉ិកស៊ីកូ ។*



« ពេលយើងទទួលបព្វជិតភាព យើងទទួលសិទ្ធិអំណាចធ្វើកិច្ចការក្នុងព្រះនាមព្រះ ហើយដឹកនាំក្នុងផ្លូវនៃសេចក្តីពិត និងសេចក្តីសុចរិត ។ សិទ្ធិអំណាចនេះជាប្រភពមួយដ៏សំខាន់នៃអំណាច និងឥទ្ធិពលសុចរិតជាប្រយោជន៍ដល់កូនចៅព្រះនៅលើផែនដី ហើយនឹងបន្តមានក្រោយពីសេចក្តីស្លាប់ » ។

**អែលឌើរ អិល ថម ភែរី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « The Doctrines and Principles Contained in the Articles of Faith » Liahona, ខែ វិច្ឆិកា ឆ្នាំ 2013 ទំព័រ 47 ។**



រចនារូបភាពដោយ ដាវីឌ ហាប៊ីន

# « តើខ្ញុំគួរតែគិតអំពីអ្វីខ្លះ អំឡុងពេលប្រជុំសាក្រាម៉ង់ ? »

**ទោះ** ជាយើងឈរជាសាក្សីរបស់ព្រះយេស៊ូវគ្រីស្ទនៅគ្រប់ពេល គ្រប់កិច្ចការ និងគ្រប់ទីកន្លែងក្តី (សូមមើល ម៉ូសាយ 18:9) ពេលខ្លះឥទ្ធិពលទាំងឡាយនៅក្នុងពិភពលោកដែលជុំវិញយើងក៏ប្រកួតប្រជៀតជ្រែកនឹងចំណាប់អារម្មណ៍របស់យើងដែរ ។ ពិធីសាក្រាម៉ង់ផ្តល់ឱកាសឲ្យយើងផ្តោតគំនិតរបស់យើងទៅលើព្រះអង្គសង្គ្រោះដោយគ្មានការអុកឡុករំខាន ។

នៅពេលសាក្រាម៉ង់ អ្នកអាចគិតពីអត្ថន័យ និង ភាពស្រស់ស្អាតនៃពិធីបរិសុទ្ធនេះ ។ ការទទួលទានតំណាងនៃព្រះកាយ និង ព្រះលោហិតរបស់ព្រះអង្គសង្គ្រោះអាចជួយអ្នកឲ្យគិតពីពលិកម្មធួន ហើយគ្មានទីបញ្ចប់របស់ទ្រង់ ។ នៅពេលអ្នកទទួលទានសាក្រាម៉ង់ អ្នកកំពុងរំឭកចាំពីសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់អ្នក ។ នៅពេលអ្នកធ្វើដូច្នេះ អ្នកអាចតាំងចិត្តឡើងវិញ ដើម្បីចងចាំទ្រង់ជានិច្ច ហើយគោរពតាមព្រះបញ្ញត្តិទ្រង់ ។

អ្នកអាចធ្វើឲ្យបទពិសោធន៍ក្នុងពិធីសាក្រាម៉ង់របស់អ្នកកាន់តែប្រសើរឡើង ដោយការរៀបចំចិត្តអ្នកខាងវិញ្ញាណ ។ នៅក្នុងសប្តាហ៍នោះ សូមពិចារណាសិក្សាសុន្ទរកថា ឬសារលិខិតក្នុងសន្និសីទទូទៅ ដែលជួយអ្នកឲ្យផ្តោតចិត្តលើពលិកម្មរបស់ព្រះអង្គសង្គ្រោះ និង ភាពជាសិស្សរបស់អ្នក ។ នៅពេលច្រៀងទំនុកតម្កើង និង ការអធិស្ឋានសាក្រាម៉ង់ សូមផ្តោតចិត្តលើពាក្យដែលអ្នកច្រៀង ហើយស្តាប់ឮ ហើយសញ្ជឹងគិតពីអត្ថន័យរបស់វា ។

ក្នុងពេលសាក្រាម៉ង់ សូមចំណាយពេលគិតពីការផ្លាស់ប្តូរដែលអ្នកកំពុងធ្វើនៅក្នុងជីវិតអ្នកផ្ទាល់ ដើម្បីប្រែក្លាយឲ្យកាន់តែដូចជាព្រះយេស៊ូវគ្រីស្ទ ។ បន្ទាប់ពីទទួលទានសាក្រាម៉ង់ដោយសក្តិសមមក អ្នកអាចមានអារម្មណ៍ស្អាតស្អំ ហើយបរិសុទ្ធ ដូចជាអ្នកធ្លាប់មាននៅថ្ងៃជ្រមុជទឹករបស់អ្នកដែរ ។

### បង្វែរគំនិតរបស់អ្នកទៅរកដង្វាយធួន

ក្នុងពិធីសាក្រាម៉ង់ គំនិតរបស់ខ្ញុំបានងាកទៅរកព្រះយេស៊ូវគ្រីស្ទ និង ដង្វាយធួនរបស់ទ្រង់ ។ ខ្ញុំមានការពិបាកនៅក្នុងការបង្ហាញពីអារម្មណ៍ដែលខ្ញុំមាននៅក្នុងពិធីសាក្រាម៉ង់ណាស់ ពេលខ្ញុំគិតពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំដឹងថា ព្រះយេស៊ូវគ្រីស្ទត្រូវបានជ្រើសឲ្យធ្វើជាព្រះប្រោសលោះរបស់យើង ។ ខ្ញុំដឹងថា ទ្រង់មានព្រះជន្មរស់ ។

*នីហ្វៃ ប៊ី អាយុ 20 ប្រាស្សាវៀល សាធារណរដ្ឋកុងហ្គោ*

### ចងចាំពីអាហារយប់ថ្ងៃចុងក្រោយ



យើងគួរគិតពីពលិកម្មធួននៃព្រះយេស៊ូវគ្រីស្ទ និង ពីសារៈសំខាន់នៃការទទួលទានដោយសក្តិសមនូវតំណាងនៃព្រះកាយ និង ព្រះលោហិតរបស់ទ្រង់ ។ យើងក៏អាចគិតពីពេលដែលទ្រង់បានប្រសិទ្ធពរដល់នំបុ័ង និង ស្រាជាមួយនឹងពួកសាវកទាំងដប់ពីរនាក់របស់ទ្រង់ផងដែរ ។

*ចូណាស អេ អាយុ 18 ឆ្នាំ ម៉ូរេឡូស ប្រទេស ម៉ិកស៊ិក*

### គិតពីព្រះយេស៊ូវគ្រីស្ទ



ក្នុងពេលសាក្រាម៉ង់ ខ្ញុំគិតពីអ្វីដែលព្រះអង្គសង្គ្រោះបានឆ្លងកាត់ ដើម្បីយើងអាចប្រែចិត្តពីកំហុសដែលយើងបានធ្វើ ។ ខ្ញុំក៏គិតពីរាល់ពរជ័យដែលទ្រង់បានប្រទានដល់ខ្ញុំ និង ពីអព្ភូតហេតុដ៏អស្ចារ្យដែលទ្រង់បានធ្វើ ហើយនឹងធ្វើ ។ យើងមានពរណាស់ដោយអាចទទួលទានសាក្រាម៉ង់ ដើម្បីឲ្យយើងអាចប្រែចិត្តពីអំពើបាបរបស់យើង ហើយតាំងចិត្តធ្វើឲ្យប្រសើរជាងមុន ។

*អេនឌី ប៊ី អាយុ 13 ឆ្នាំ រដ្ឋយូថាហ៍ ស.រ.អា.*

### រិះគិតពីពាក្យក្នុងទំនុកតម្កើងសាក្រាម៉ង់



ទំនុកតម្កើងសាក្រាម៉ង់បង្រៀនពីអ្វីដែលយើងគួរគិតនៅក្នុងពេលសាក្រាម៉ង់ ។ ឧទាហរណ៍ ទំនុកតម្កើងសាក្រាម៉ង់ដែលខ្ញុំចូលចិត្តគឺបទ « In Humility, Our Savior » (Hymns, លរ. 172) ដែលច្រៀងថា « ឱព្រះអម្ចាស់អើយ ចូរកុំឲ្យខ្ញុំភ្លេចថា ទ្រង់បានបង្ហូរលោហិត ហើយបានសុគតសម្រាប់ខ្ញុំ ពេលដែលព្រះហឫទ័យរបស់ទ្រង់បាក់បែកឈើចាប់នៅភ្នំខាល់វ៉ារី » ។ ដោយចងចាំនូវទំនុកចម្រៀងនៃទំនុកតម្កើងសាក្រាម៉ង់ នៅក្នុងពិធីបរិសុទ្ធដ៏ពិសិដ្ឋនេះ ជួយខ្ញុំមានអារម្មណ៍នូវសេចក្តីសុខសាន្ត ហើយ



*ចម្លើយទាំងឡាយគឺមានបំណងទុកជាជំនួយ និង ជាទស្សនវិស័យ មិនមែនជា ការប្រកាសអំពីគោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។*

បង្កើនការដឹងគុណរបស់ខ្ញុំចំពោះដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។

*អូស្ទីន ប៊ី អាយុ 15 ឆ្នាំ អាល់បើតា ប្រទេសកាណាដា*

**ចង់ចាំ ហើយស្គាល់**

គោលបំណងនៃពិធីសាក្រាម៉ង់ដើម្បីរំឭកពីសេចក្ដីសញ្ញារបស់យើងជាមួយនឹងព្រះវរបិតាសួគ៌យើង និង ដើម្បីលាងសម្អាតពីអំពើបាបដែលយើងបានប្រែចិត្ត ។ ក្នុងពិធីសាក្រាម៉ង់ យើងចងចាំពីពលិកម្មរបស់ព្រះគ្រីស្ទសម្រាប់យើង ហើយសញ្ជឹងគិតពីរបៀបដែលយើងអនុវត្តវានៅក្នុងជីវិតរបស់យើង ។ ខ្ញុំសាកល្បងគិតពីអ្វីដែលខ្ញុំបានធ្វើកាលពីសប្ដាហ៍មុន ហើយថាតើខ្ញុំបានរក្សាសេចក្ដីសញ្ញារបស់ខ្ញុំជាមួយនឹងព្រះវរបិតាខ្ញុំបានល្អដល់កម្រិតណា ។ ខ្ញុំស្គាល់ពីអំពើបាបដែលខ្ញុំបានធ្វើ ហើយផ្ដោតចិត្តលើរបៀបដែលខ្ញុំអាចប្រើដង្វាយធួនដើម្បីយកឈ្នះលើអំពើបាបនោះ ។ នៅពេលខ្ញុំធ្វើដូច្នេះ ពិធីសាក្រាម៉ង់គឺជាបទពិសោធន៍លើកស្ទួយ និង ជាការពង្រឹងខាងវិញ្ញាណ ។

*អាបាហ្គាល បេ៉ អាយុ 14 ឆ្នាំ រដ្ឋអារីហ្សូណា ស.រ.អា.*

**ថ្លែងអំណរគុណដល់ពរជ័យទាំងឡាយ**



ក្នុងពិធីសាក្រាម៉ង់យើងគួរគិតថាតើពលិកម្មដែលព្រះអង្គសង្គ្រោះបានធ្វើសម្រាប់យើងមានទំហំប៉ុណ្ណា ហើយចូរឲ្យចិត្តយើងពោរពេញដោយការដឹងគុណ ។ នៅពេលខ្ញុំទទួលទានសាក្រាម៉ង់ ខ្ញុំចូលចិត្តថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌ និង បុត្រាដ៏ជាទីស្រលាញ់របស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ សម្រាប់ពរជ័យដែលខ្ញុំបានទទួល ។

*អេឡេន អេស. អាយុ 16 ឆ្នាំ ប៉ារ៉ែបា ប្រទេស ប្រេស៊ីល*

**សញ្ជឹងគិតពីសេចក្ដីសញ្ញារបស់អ្នក**

កាលពីក្មេង រឿងមួយគត់ដែលខ្ញុំបានគិតនៅក្នុងពិធីសាក្រាម៉ង់គឺថា តើខ្ញុំអាចមានភាពស្ងៀមស្ងាត់បានដោយរបៀបណា ។ ឥឡូវនេះ ដោយសារខ្ញុំជាអ្នកកាន់បព្វជិតភាពម្នាក់ ខ្ញុំយល់ថា ដើម្បីឲ្យពិធីសាក្រាម៉ង់មានន័យ ហើយជួយខ្ញុំឲ្យរីកចម្រើនខាងវិញ្ញាណ នោះខ្ញុំត្រូវសញ្ជឹងគិតពីពិធីនេះ ។ ខ្ញុំគិតពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ និង ពីរបៀបដែលទ្រង់បានបង្ហាញសេចក្ដីស្រឡាញ់ដល់យើង ។ ខ្ញុំក៏គិតផងដែរថា តើការទទួលទានសាក្រាម៉ង់អាចពង្រឹងដល់សេចក្ដីជំនឿ និង បំណងប្រាថ្នារបស់ខ្ញុំដើម្បីបំពេញសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់ខ្ញុំយ៉ាងណាដែរ ។

*លេវី អេហ្វ អាយុ 19 ឆ្នាំ អាប៊ី ប្រទេសនីហ្សេរីយ៉ា*

**ផ្ដុំចិត្តគំនិតរបស់អ្នកពីការរសាត់រសាយ**



ខ្ញុំមានប័ណ្ណតូចមួយដាក់នៅក្នុងព្រះគម្ពីររបស់ខ្ញុំ ដែលខ្ញុំតែងដកវាមកមើលនៅក្នុងពិធីសាក្រាម៉ង់ ។ វាជាកំណត់ចំណាំនៅម៉ូសាយ 18 ជាពេលដែលអាលម៉ាបានរៀបរាប់ពីសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក ។ ប័ណ្ណនោះមានសារខ្លីៗ ដូចជា « ចូរមានអំណរគុណចំពោះដង្វាយធួន » សរសេរនៅលើនោះ ដើម្បីជួយខ្ញុំឲ្យចងចាំពីគោលបំណង និង បរិសុទ្ធភាពនៃពិធីសាក្រាម៉ង់ ។ ការមើលសារខ្លីនោះឡើងវិញបានជួយខ្ញុំឲ្យរក្សាគំនិតខ្ញុំផ្ដោតទៅលើគោលបំណង និង បរិសុទ្ធភាពនៃពិធីសាក្រាម៉ង់ ។

*អាលីស្សា អិម អាយុ 19 ឆ្នាំ រដ្ឋតិចសាស ស.រ.អា.*



**ដាក់ឲ្យពិភពលោកនៅដាច់ដោយឡែក**

« កាលពីក្មេង មានតន្ត្រីដ៏ពិរោះបានប្រគុំនៅពេលចែកសាក្រាម៉ង់ ។ រំពេចនោះ បងប្អូនប្រុសបានសុំឲ្យយើងឈប់អនុវត្តវា ដោយសារគំនិតរបស់យើងបានផ្ដោតទៅលើតន្ត្រីនោះជាជាងផ្ដោតទៅលើពលិកម្មធួនរបស់ព្រះអម្ចាស់ និង ព្រះអង្គសង្គ្រោះរបស់យើង ។ ក្នុងពេលធ្វើពិធីសាក្រាម៉ង់ យើងដាក់ពិភពលោកឲ្យនៅដាច់ដោយឡែក ។ វាជាគ្រានៃការរំឭកខាងវិញ្ញាណ ពេលយើងស្គាល់ពីសារៈសំខាន់ខាងវិញ្ញាណដ៏ជ្រាលជ្រៅស្ដីពីពិធីបរិសុទ្ធនេះ ដែលបានធ្វើសម្រាប់យើងម្នាក់ៗ ។ ប្រសិនបើយើងធ្វើដូចជាធម្មតានៅក្នុងការទទួលទានសាក្រាម៉ង់ នោះយើងនឹងបាត់បង់ឱកាសសម្រាប់ការរីកចម្រើនខាងវិញ្ញាណជាពុំខានឡើយ » ។

**អែលឌើរ អិល ថម ភែរី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « As Now We Take the Sacrament » Liahona, ខែ ឧសភា ឆ្នាំ 2006 ទំព័រ 41 ។**

## សំណួរចេញលើកក្រោយ

« មិត្តខ្ញុំម្នាក់ចង់សាកល្បងអ្វីដែលអាក្រក់ត្រឹមតែម្ដងគត់ ដើម្បីនាងអាចយល់ពីអ្វីដែលគេឯងឯទៀតបានលើករាមកនិយាយ ។ តើខ្ញុំអាចជួយនាងឲ្យយល់ ដោយរបៀបណាថាវាពុំមែនជាគំនិតល្អនោះទេ?

ប្រសិនបើអ្នកមានបំណង សូមផ្ញើចម្លើយរបស់អ្នក និង រូបថតច្បាស់មួយសន្លឹកត្រឹមថ្ងៃទី 15 ខែ កក្កដា ឆ្នាំ 2014 នៅ liahona.lds.org ដោយអ៊ីម៉ែលទៅ liahona@ldschurch.org ឬផ្ញើសំបុត្រ ( សូមមើលអាសយដ្ឋាននៅទំព័រទី 3 ) ។

ព័ត៌មាន និង ការអនុញ្ញាតខាងក្រោម ត្រូវតែបញ្ចូលនៅក្នុងអ៊ីម៉ែល ឬ សំបុត្ររបស់អ្នក ៖ (1) ឈ្មោះពេញ, (2) ថ្ងៃខែឆ្នាំកំណើត, (3) វួដ ឬ សាខា, (4) ស្តេក ឬ មណ្ឌល, (5) សំបុត្រអនុញ្ញាតដែលមានជាលាយលក្ខណ៍អក្សររបស់អ្នក ហើយបើសិនអ្នកមានអាយុក្រោម 18 ឆ្នាំ នោះត្រូវមានសំបុត្រអនុញ្ញាតពីឪពុកម្ដាយរបស់អ្នកជាលាយលក្ខណ៍អក្សរ ( អ៊ីម៉ែល អាចទទួលយកបាន ) ដើម្បីធ្វើការបោះពុម្ពចម្លើយ និង រូបថតរបស់អ្នក ។

ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ បើវាវែងពេក ឬមិនសូវច្បាស់លាស់ ។



ដោយ អែលឌើរ អាន់ថូនី ឌី ភើគីន
នៃពួកចិតសិបនាក់

# ដង្វាយមួយភាគក្នុងដប់ផ្ដល់ កម្លាំងនៅក្នុងចិត្ត

*សូមសម្រេចចិត្តនៅពេលនេះដើម្បីបង់ដង្វាយមួយភាគក្នុងដប់ដោយស្មោះត្រង់ ។ ការធ្វើដូច្នេះនឹងជួយអ្នកឲ្យដឹងថា ព្រះអម្ចាស់រក្សារាល់សេចក្ដីសន្យារបស់ទ្រង់ ។*

ប្រធាន ថូម៉ាស អេស ម៉នសុន បង្រៀនថា « ការបង់ដង្វាយមួយភាគក្នុងដប់ដោយស្មោះត្រង់ធ្វើឲ្យមនុស្សម្នាក់មានភាពរឹងមាំ និង ការតាំងចិត្តក្នុងចិត្តដើម្បីគោរពតាមបទបញ្ញត្តិផ្សេងទៀត » ។[1] ខ្ញុំមានភ័ព្វសំណាងដោយបានទទួលទីបន្ទាល់មួយ ស្ដីពីគោលការណ៍នេះកាលពីខ្ញុំនៅជាយុវវ័យ ។

ពេលខ្ញុំមានអាយុ 14 ឆ្នាំ ខ្ញុំបានចាប់ផ្ដើមការងារដំបូងរបស់ខ្ញុំ ដោយរកប្រាក់បាន 2 ដុល្លារក្នុងមួយម៉ោងជាកម្មករសំណង់ ។ ប្រាក់ខែសម្រាប់សប្ដាហ៍ទីមួយរបស់ខ្ញុំសរុបទៅមានចំនួន 80 ដុល្លារ ។ ខ្ញុំចង់ទិញកូនម៉ាញេចាក់កាសែតមួយ ដែលជាបច្ចេកវិទ្យាថ្មីបំផុតនៅពេលនោះ ។ ស៊េរីដែលខ្ញុំចង់បានមានតម្លៃ 320 ដុល្លារ ។ ខ្ញុំបានប្រាប់ឪពុកម្ដាយខ្ញុំពីគោលបំណងរបស់ខ្ញុំ ដើម្បីទិញម៉ាញេបន្ទាប់ពីបំពេញការងារបានបួនសប្ដាហ៍ដោយក្ដីរីករាយ ។

## លើសពីបួនសប្ដាហ៍

ឪពុកម្ដាយខ្ញុំបានបង្រៀនដោយភាពវៃឆ្លាតថា « វានឹងត្រូវចំណាយពេលច្រើនជាងបួនសប្ដាហ៍ដើម្បីមានប្រាក់គ្រប់គ្រាន់ទិញកូនម៉ាញេនោះ ។ កូនគួរសម្ដែងការដឹងគុណដល់ព្រះចំពោះពរជ័យជាច្រើនរបស់ទ្រង់តាមរយៈការបង់ 10 ភាគរយនៃប្រាក់ចំណូលរបស់កូនជាដង្វាយមួយភាគក្នុងដប់ ។ កូនត្រូវបង់ពន្ធ 10 ភាគរយដល់រដ្ឋាភិបាល ។ ហើយកូនគួររៀនទាន់នៅក្មេង ដើម្បីគោរពតាមការទូន្មានរបស់ពួកព្យាការីក្នុងការរៀបចំខ្លួនខាងហិរញ្ញវត្ថុសម្រាប់អនាគត រួមទាំងបេសកកម្មរបស់កូនផងដែរ យើងណែនាំឲ្យកូនដក 30 ភាគរយនៃប្រាក់ចំណូលកូនទុកវានៅក្នុងគណនីសន្សំ » ។

រំពេចនោះគំនិតដ៏វ័យក្មេងរបស់ខ្ញុំបានធ្វើការគណនាថា បើខ្ញុំធ្វើតាមអ្វីៗ ដែលឪពុកម្ដាយបង្រៀនខ្ញុំ ខ្ញុំចំណាយបានតែ 40 ដុល្លារប៉ុណ្ណោះរាល់សប្ដាហ៍ នោះមានន័យថា ខ្ញុំត្រូវធ្វើការងារយ៉ាងណាស់ពីរខែ ដើម្បីទិញបានកូនម៉ាញេដែលខ្ញុំចង់បាន ។ ខ្ញុំបានឃើញថា ខ្លួនស្ថិតនៅគ្រានៃការសម្រេចមួយដ៏សំខាន់—តើការមានសម្ភារគឺជាអាទិភាពទីមួយរបស់ខ្ញុំមែនទេ ឬ ក៏ខ្ញុំត្រូវលះបង់ដើម្បីបង់ដង្វាយមួយភាគក្នុងដប់ហើយទុកសន្សំវិញ ?



**ទ្រង់នឹងបើកផ្លូវ**

« យើងទាំងអស់គ្នាអាចមានលទ្ធភាពបង់ដង្វាយមួយភាគក្នុងដប់ ។ ធាតុពិត គឺគ្មានយើងណាម្នាក់ខ្វះលទ្ធភាព ដើម្បីបង់ដង្វាយមួយភាគក្នុងដប់ឡើយ ។ ព្រះអម្ចាស់នឹងពង្រីងដំណោះស្រាយរបស់យើង ។ ទ្រង់នឹងបើកផ្លូវមួយដើម្បីឲ្យគោរពតាម » ។

**ប្រធាន ថូម៉ាស អេស ម៉នសុន « Be Thou an Example » Liahona, ខែ មករា ឆ្នាំ 1997 ទំព័រ 42 ។**

## បង់ដង្វាយមួយភាគក្នុងដប់មុន

*ដើម្បីកម្លាំងនៃយុវជន*បានទូន្មានថា ៖ « បង់ [ ដង្វាយមួយភាគក្នុងដប់ ] មុន ទោះជាពេលអ្នកគិតថា អ្នកគ្មានប្រាក់គ្រប់គ្រាន់ ដើម្បីបំពេញសេចក្ដីត្រូវការផ្សេងទៀតរបស់អ្នកក្ដី ។ ការធ្វើដូច្នោះនឹងជួយអ្នកឲ្យអភិវឌ្ឍសេចក្ដីជំនឿកាន់តែខ្លាំងឡើង ឈ្នះលើភាពអាត្មានិយម និង ងាយស្ដាប់តាមព្រះវិញ្ញាណជាង ។[2]

ខ្ញុំបានសម្រេចចិត្តនៅអាយុ 14 ឆ្នាំ ដើម្បីបង់ដង្វាយមួយភាគក្នុងដប់ដោយស្មោះត្រង់ពេញមួយជីវិតរបស់ខ្ញុំ ។ ខ្ញុំបានតាំងចិត្តធ្វើតាមព្យាការីក្នុងការសន្សំប្រាក់សម្រាប់បេសកកម្ម និងការអប់រំនៅពេលខាងមុខរបស់ខ្ញុំ បទពិសោធន៍នេះក៏បានបង្រៀនខ្ញុំឲ្យបែងចែងរវាងការចង់បាន និង សេចក្ដី

រូបថត ដោយ ជីង ម៉ុងសុីន



ត្រូវការ ។ ខ្ញុំចង់បាននូវបច្ចេកវិទ្យាថ្មីបំផុតនោះ ប៉ុន្តែខ្ញុំមិនត្រូវការវាទេ ។ ដូច្នេះខ្ញុំបានសម្រេចចិត្តទិញស៊េរីថោកមួយដែលមានមុខងារបន្តិចបន្តួច ហើយវានៅតែដំណើរការល្អពេលខ្ញុំចេញទៅបេសកកម្មរបស់ខ្ញុំ ។

## ការសន្យាត្រូវបានរក្សា

ដូចដែលខ្ញុំបានរៀនតាមរយៈការបង់ដង្វាយមួយភាគក្នុងដប់ថា ព្រះអម្ចាស់រក្សាការសន្យារបស់ទ្រង់ នោះសេចក្តីជំនឿរបស់ខ្ញុំកាន់តែរឹងមាំ រួមទាំងបំណងប្រាថ្នារបស់ខ្ញុំដើម្បីគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ផងដែរ ។ ខ្ញុំបានរៀនថា ប្រសិនបើខ្ញុំបរិច្ចាគដង្វាយតមអាហារដោយសប្បុរស ទ្រង់នឹងឆ្លើយតបការអធិស្ឋានរបស់ខ្ញុំ ហើយដឹកនាំខ្ញុំជាបន្តបន្ទាប់ (សូមមើលអេសាយ 58:6–11) ។ ខ្ញុំបានរៀនថា ប្រសិនបើខ្ញុំអានព្រះគម្ពីរមរមន ទ្រង់នឹងបើកសម្តែងសេចក្តីពិតនៃព្រះគម្ពីរនោះមកកាន់ខ្ញុំតាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ (សូមមើល មរ៉ូណៃ 10:4–5) ។ ខ្ញុំបានរៀនថា ប្រសិនបើខ្ញុំគោរពតាមពាក្យសម្តីនៃប្រាជ្ញាវាងវៃ ទ្រង់នឹងប្រទានសុខភាព ប្រាជ្ញា និង ចំណេះដឹងដល់ខ្ញុំ ហើយថាខ្ញុំអាច « នឹងរត់ទៅឥតដែលហត់ » (សូមមើលគ. និង ស. 89:18– 21) ។ ហើយខ្ញុំបានរៀនថា ប្រសិនបើ ខ្ញុំគោរពច្បាប់ព្រហ្មចារីភាព ព្រះវិញ្ញាណបរិសុទ្ធនឹងក្លាយជាដៃគូដ៏ខ្ជាប់ខ្ជួនរបស់ខ្ញុំ ហើយព្រះអង្គសង្គ្រោះនឹងផ្តល់ទំនុកចិត្តដល់ខ្ញុំដើម្បីឈរនៅក្នុងវត្តមានរបស់ទ្រង់ ដោយគ្មានការខ្មាស់អៀននៅថ្ងៃណាមួយ (សូមមើល គ. និង ស. 121:45–46 ) ។

របៀបមួយទៀតដែលបង់ដង្វាយមួយភាគក្នុងដប់ និងដង្វាយផ្សេងទៀតបានបង្កើនកម្លាំងនៅក្នុងចិត្តរបស់ខ្ញុំគឺតាមរយៈសេចក្តីសញ្ញានៃព្រះវិហារបរិសុទ្ធ ។ *ដើម្បីកម្លាំងនៃយុវជន* បង្រៀនថា « ដើម្បីចូលទៅក្នុងព្រះវិហារបរិសុទ្ធ អ្នកត្រូវជាអ្នកថ្វាយដង្វាយមួយភាគក្នុងដប់ពេញលេញ » ។[3] នៅពេលខ្ញុំចូលទៅព្រះវិហារបរិសុទ្ធ ខ្ញុំទទួលអារម្មណ៍ពីវត្តមានរបស់ព្រះ និង សេចក្តីស្រឡាញ់របស់ទ្រង់ ។ ខ្ញុំសូមធ្វើទីបន្ទាល់ថា នៅក្នុងពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ យើងទទួល « ព្រះចេស្តាពីស្ថានលើ » (គ. និង ស. 95:8) ដើម្បីប្រឈមមុខ ហើយយកឈ្នះដោយក្តីរីករាយលើឧបសគ្គនៃជីវិតរមែងស្លាប់ ។

## ការរៀបចំពរជ័យ

ការបង់ដង្វាយមួយភាគក្នុងដប់ និង ដង្វាយផ្សេងៗបានបង្កើនសេចក្តីជំនឿរបស់ខ្ញុំថា ព្រះអម្ចាស់បំពេញការសន្យារបស់ទ្រង់ ។ តាមរយៈព្យាការីម៉ាឡាគី ទ្រង់បានប្រកាសថា « ចូរនាំយកដង្វាយមួយភាគក្នុងដប់ទាំងអស់. . .ហើយល្បងលយើងឥឡូវ បើយើងមិនបើកទ្វារស្ថានសួគ៌ដើម្បីចាក់ព្រះពរមកលើអ្នក ដែលនឹងគ្មានកន្លែងល្មមទុកបានទេ » (ម៉ាឡាគី 3:10) ។

ពេញមួយជីវិតរបស់ខ្ញុំ ទោះជានៅគ្រាដ៏លំបាកពេលខ្ញុំទើបរៀបការក្តី ព្រះទ្រង់តែងតែបើកទ្វារស្ថានសួគ៌ ដើម្បី ឲ្យគ្រួសាររបស់យើងបានទទួលនូវសម្ភារខាងសាច់ឈាមដ៏ចាំបាច់សម្រាប់ជីវិតដែរ ។ ខ្ញុំសូមធ្វើទីបន្ទាល់ថា តាមរយៈការគោរពប្រតិបត្តិតាមច្បាប់ដង្វាយមួយភាគក្នុងដប់ នោះសេចក្តីជំនឿរបស់អ្នកនឹងរីកធំឡើងទៅជាប្រភពកម្លាំងមួយដ៏អស្ចារ្យនៅក្នុងជីវិតរបស់អ្នក ។

ខ្ញុំសូមអញ្ជើញយុវវ័យគ្រប់រូប—និងសមាជិកគ្រប់រូប—ឲ្យស្តាប់ដល់ព្រះយេស៊ូវគ្រីស្ទ និង ពួកព្យាការីរបស់ទ្រង់ ដោយបង់ដង្វាយមួយភាគក្នុងដប់ពេញលេញ និង បង់ដង្វាយតមអាហារដោយសប្បុរសពេញមួយជីវិតរបស់អ្នក ។ ខ្ញុំសូមសន្យាថា ព្រះអម្ចាស់នឹងពង្រឹងអ្នក ហើយធ្វើឲ្យអ្នកជោគជ័យនៅក្នុងការសម្រេចនូវបំណងប្រាថ្នាសុចរិតរបស់អ្នកស្របតាមព្រះរាជបំណងដ៏បរិសុទ្ធរបស់ទ្រង់ ។ ■

**កំណត់ចំណាំ**

1. ថូម៉ាស់ អេស. ម៉នសុន, « Be Thou an Example » Liahona, ខែ ឧសភា ឆ្នាំ 2005 ទំព័រ 42 ។
2. *ដើម្បីកម្លាំងនៃយុវជន* ( ឆ្នាំ 2011 ) ទំព័រ 38។
3. *ដើម្បីកម្លាំងនៃយុវជន* ទំព័រ 38។

# ការស្វែងរកផ្លូវរបស់ខ្ញុំត្រឡប់ទៅសាសនាចក្រវិញ



*ខ្ញុំបានព្យាយាមរកចម្លើយនៅខាងក្រៅពីដំណឹងល្អ ប៉ុន្តែអ្វីដែលខ្ញុំបានរកឃើញគឺភាពទទេស្អាត ។*

**ដោយ ដ័ហ្គ ឞិយយ៉ាក**

ខ្ញុំត្រូវបានចិញ្ចឹមបីបាច់ឲ្យធំឡើងនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ប៉ុន្តែលុះដល់មហាវិទ្យាល័យខ្ញុំបានសម្រេចចិត្តថា ខ្ញុំមិនត្រូវការសាសនាចក្រទៀតទេ ។ ខ្ញុំបានចាប់ផ្ដើមស្វែងរក « សេចក្ដីពិត » ដ៏អាត្មានិយមមួយនៅកន្លែងផ្សេងទៀត ។ ដោយរកមិនឃើញចម្លើយដែលនាំសេចក្ដីសុខសាន្ត ឬ សេចក្ដីអំណរដល់ខ្ញុំ នោះខ្ញុំបានធ្លាក់ចូលទៅក្នុងភាពងងឹតខាងវិញ្ញាណមួយដ៏ជ្រៅ ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំនឹងមិនមានភាពរីករាយម្ដងទៀតឡើយ ។

ប៉ុន្តែ ខ្ញុំនៅតែមើលឃើញថា ខ្ញុំធ្លាប់មានភាពរីករាយពេលខ្ញុំសកម្មនៅក្នុងសាសនាចក្រ ។ ខ្ញុំបានចាប់ផ្ដើមទៅព្រះវិហារវិញ ដោយសង្ឃឹមថានឹងរកឃើញការជួយសង្គ្រោះមួយចំនួន ចេញពីភាពសោកសៅដ៏ធំដែលបានគ្រប់គ្រងជីវិតខ្ញុំ ។ ប៉ុន្តែកិច្ចខិតខំដ៏ទន់ខ្សោយរបស់ខ្ញុំមិនសម្រេចបានច្រើននោះទេ ។ ខ្ញុំបានផ្ដោតលើការសិក្សា ដោយសង្ឃឹមថា វានឹងពុំធ្វើឲ្យគិតពីអារម្មណ៍ទទេរស្អាតដែលខ្ញុំមាន ។ ការណ៍នេះបានជួយតែបណ្ដោះអាសន្នប៉ុណ្ណោះ ប៉ុន្តែវាមិនបានផ្ដល់ចម្លើយពិតឡើយ ។

បន្ទាប់ពីរកឃើញថាខ្ញុំទៅណាមិនឆ្ងាយ ខ្ញុំបានសម្រេចចិត្តផ្អាកពីការរៀនសូត្រ ហើយធ្វើដំណើរកម្សាន្ត ។ ខ្ញុំបានសន្សំប្រាក់មួយចំនួនតូច ប៉ុន្តែវាមិនគ្រប់គ្រាន់សម្រាប់រយៈពេលវែងនោះទេ ។ ពីមុនចេញទៅ ខ្ញុំបានសម្រេចចិត្តអនុវត្តសេចក្ដីជំនឿពិតមួយចំនួន ហើយបង់ដង្វាយមួយភាគក្នុងដប់ចេញពីប្រាក់សន្សំបន្តិចបន្តួចរបស់ខ្ញុំ ។ ការណ៍នេះមិនងាយស្រួលទេ ។ ខ្ញុំត្រូវឃ្លាតឆ្ងាយពីផ្ទះ ហើយមិនយូរប៉ុន្មានខ្ញុំនឹងអស់ប្រាក់ ។ ខ្ញុំនៅតែសង្ឃឹមថាមានព្រះ ហើយខ្ញុំបានដឹងថា ខ្ញុំត្រូវការជំនួយរបស់ទ្រង់ ។

ខ្ញុំបានសរសេរមូលប្បទានប័ត្រសម្រាប់ដង្វាយមួយភាគក្នុងដប់របស់ខ្ញុំ ហើយបានផ្ញើវាទៅឲ្យប៊ីស្សពរបស់ខ្ញុំ រួចដាក់ព្រះគម្ពីរមរមនរបស់ខ្ញុំ ហើយក៏ធ្វើដំណើរចេញទៅ ។ រំពេចនោះខ្ញុំមានអារម្មណ៍កក់ក្ដៅពីព្រះវិញ្ញាណ ។ ខ្ញុំមានចិត្តយ៉ាងអស្ចារ្យ ដោយមានអារម្មណ៍ថា ភាពសង្ស័យ និង ទុក្ខសោករបស់ខ្ញុំត្រូវបានជំនួសដោយការយល់ដឹង និង ទំនុកចិត្ត ។ ពីរដ្ឋ អៃដាហូទៅរដ្ឋវ៉ាស៊ីងតោន ឌី.ស៊ី. សមាជិកសាសនាចក្របានជួយដល់ខ្ញុំ ហើយសំខាន់បំផុត ពួកគេបានជួយខ្ញុំឲ្យអភិវឌ្ឍសេចក្ដីជំនឿ និង បំណងប្រាថ្នាសុចរិត ។ វាហាក់ដូចជាមានគ្រួសារនៅជុំវិញខ្ញុំ ។

បន្ទាប់ពីមួយរយៈខ្លីមក ខ្ញុំបានដឹងថា ខ្ញុំត្រូវកាត់បន្ថយពេលវេលានៃការធ្វើដំណើររបស់ខ្ញុំ—ពុំមែនដោយសារការខ្វះប្រាក់នោះទេ ប៉ុន្តែដោយសារមានដំណើរមួយដ៏ប្រសើរជាងនេះកំពុងរង់ចាំខ្ញុំ ។ ពេលត្រឡប់មកផ្ទះវិញ ខ្ញុំបានជួបនឹងប៊ីស្សព និង ប្រធានស្តេករបស់ខ្ញុំ ។ ដោយមានជំនួយពីពួកគាត់ មិនយូរប៉ុន្មានខ្ញុំបានបម្រើព្រះអម្ចាស់ជាអ្នកផ្សព្វផ្សាយសាសនា ។

ឥឡូវនេះ រាល់ពេលខ្ញុំបង់ដង្វាយមួយភាគក្នុងដប់របស់ខ្ញុំ ឬ ជួបនឹងពួកអ្នកដឹកនាំសាសនាចក្ររបស់ខ្ញុំ ខ្ញុំចងចាំពី « ការចាប់ផ្ដើម » នៃការប្រែចិត្តជឿដ៏ពិតរបស់ខ្ញុំ ។ ដោយសារពេលនោះខ្ញុំជួបភាពរីករាយ និង ភាពសោកសៅ ប៉ុន្តែខ្ញុំបានធ្វើការដើម្បីឲ្យមានភាពរឹងមាំខាងវិញ្ញាណ ។ ខ្ញុំតែងតែមានអំណរគុណចំពោះការទទួលយករបស់ព្រះវរបិតាសួគ៌ចំពោះការថ្វាយសេចក្ដីជំនឿដ៏ស្តួចស្តើងរបស់ខ្ញុំ ហើយលាតព្រះហស្តជាទីស្រឡាញ់របស់ទ្រង់មកកាន់ខ្ញុំ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ កាលីហ្វ័រញ៉ា ស.រ.អា. ។*

រចនាដោយ ដារីឌ អេវេត

# ភាពរឹងមាំ

« យើងមិនអាចបំបែកក្រិត្យវិន័យទាំងដប់ប្រការបានទេ ។ មានតែយើងធ្វើឲ្យខ្លួនឯងបំពាននឹងក្រិត្យវិន័យទាំងនេះ » ។

(សេសឹល ប៊ី ឌេមីល ជាអ្នកដឹកនាំ និង អ្នកផលិតខ្សែភាពយន្តអាមេរិក « Commencement Address » [ Brigham Young University ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៥៧ ] ទំព័រ ៥ speeches.byu.edu) ។



# ការប្រសិទ្ធពរមួយសម្រាប់ អ្នកម្ដាយ

**ដោយ ស៊ូសាន បាប៉េត**

ផ្អែកទៅលើដំណើររឿងពិតមួយ

« *បព្វជិតភាពត្រូវបានស្ដារឡើងវិញ មនុស្សបានស្គាល់សេចក្ដីពិតថា ព្រះបានមានបន្ទូលមកកាន់ផែនដី ព្រះចេស្ដារបស់ទ្រង់មាននៅទីនេះម្ដងទៀត* » (*Children's Songbook* ទំព័រ 89) ។

ថ្នាក់កុមារបានបញ្ចប់ ហើយរូប៊ិន ដែលមានអាយុ 10 ឆ្នាំ បានដើររកពួកអ្នកផ្សព្វផ្សាយសាសនា ។ ពួកគេនឹងដើរទៅផ្ទះជាមួយគាត់ ។ អែលឌើរ សាន់ឆេស និង អែលឌើរ រ៉ូចាស ធ្លាប់បង្រៀនរូប៊ិន និង បងប្រុសរបស់គាត់ ឌីអេហ្គោ នូវមេរៀនអ្នកផ្សាយសាសនា ហើយបានជ្រមុជទឹក ហើយបានបញ្ជាក់ដល់ពួកគេ ។ ឥឡូវ រូប៊ិន បានចាត់ពួកគេទុកដូចជាមិត្តល្អរបស់គាត់ ។

រូប៊ិន បានមើលតាមបង្អួចក្នុងថ្នាក់រៀនមួយដែលមានទ្វារបិទជិត ។ ពួកគេនៅទីនោះ ! តើពួកគេកំពុងធ្វើអ្វី ? ដៃពួកគេបានដាក់នៅលើក្បាលបុរសម្នាក់នៅក្នុងរង្វង់ ហើយវាមើលទៅហាក់ដូចជាពួកគេកំពុងនិយាយ ការអធិស្ឋានមួយដូចជាពួកគេធ្លាប់ធ្វើពេលរូប៊ិនទទួលការបញ្ជាក់ ។

ពេលពួកគេចេញពីបន្ទប់នោះ គាត់បានសួរពួកអ្នកផ្សព្វផ្សាយសាសនានោះថា « តើអ្នកទាំងពីរបានធ្វើអី ? »

អែលឌើរ សាន់ឆេស បាននិយាយថា « យើងបានផ្ដល់ការប្រសិទ្ធពរបព្វជិតភាពមួយដល់បងប្រុស មេនដូស្សា » ។ « វាជាការអធិស្ឋានពិសេសមួយ ហើយវាអាចផ្ដល់ការលួងលោមជួយឲ្យមនុស្សម្នាក់ដឹងពីរបៀបដោះស្រាយបញ្ហា ឬវាប្រោសមនុស្សម្នាក់ឲ្យជាសះស្បើយទៀតផង » ។





គំនូរដោយ ស្ទីវ ក្រប

លុះនៅថ្ងៃអាទិត្យក្រោយ រូប៊ិន បានដើររកពួកអ្នកផ្សព្វផ្សាយសាសនាម្តងទៀតក្រោយពីព្រះវិហារបានបញ្ចប់ ។ « តើអ្នកទាំងពីរអាចទៅផ្ទះខ្ញុំធ្វើការប្រសិទ្ធពរមួយដល់ម៉ាកខ្ញុំបានទេ ? » គាត់បានសួរ ។ « ខ្នងគាត់ឈឺខ្លាំងណាស់ » ។

ពួកគេបានប្រញាប់ប្រញាល់ទៅផ្ទះរបស់រូប៊ិន ។ អែលឌើរសាន់ឆេស និង អែលឌើររូចាស បាននិយាយទៅម៉ាក់របស់រូប៊ិន ។ គាត់ជាសមាជិកនៃសាសនាចក្រ ប៉ុន្តែគាត់មិនទៅព្រះវិហារយូរហើយ ។

អែលឌើរ រូចាស បាននិយាយថា « បងស្រី ហ្គារសៀ យើងបានដឹងថា បងស្រីមានសុខភាពមិនល្អទេ » ។

គាត់បានប្រាប់ពួកគេថា « ខ្នងខ្ញុំឈឺខ្លាំងណាស់ ពីរបីសប្តាហ៍ហើយ » ។ « ខ្ញុំបានទៅជួបនឹងវេជ្ជបណ្ឌិត ប៉ុន្តែពួកគេគ្មានលទ្ធភាពជួយខ្ញុំទេ » ។

អែលឌើរ សាន់ឆេស បាននិយាយថា « រូប៊ិនបានសុំយើងឲ្យមកដើម្បីធ្វើការប្រសិទ្ធពរបព្វជិតភាពមួយដល់បងស្រី » ។ « តើបងស្រីចង់ឲ្យយើងធ្វើកិច្ចការនោះទេ ? »

ម៉ាក់បានពោលថា « អូ ពិតជាបាន » ។

កាលពួកអ្នកផ្សព្វផ្សាយសាសនាបានដាក់ដៃរបស់ពួកគេលើក្បាលគាត់ ហើយផ្តល់ការប្រសិទ្ធពរមួយដល់គាត់ ទឹកភ្នែករបស់ម៉ាក់បានហូរស្រក់ចុះមក ។ ពេលពួកគេធ្វើចប់ រូប៊ិន បានឱបគាត់ ។ គាត់បានប្រាប់ទៅម៉ាក់គាត់ថា « កូនដឹងថាការប្រសិទ្ធពរនេះនឹងជួយដល់ម៉ាក់ » ។

បីថ្ងៃក្រោយមក ពួកអ្នកផ្សព្វផ្សាយសាសនាបានត្រឡប់មកមើលថា តើម្តាយរបស់រូប៊ិនមានអារម្មណ៍យ៉ាងណាដែរ ។ គាត់បានប្រាប់ពួកគេថា « ខ្ញុំមានចិត្តរីករាយណាស់ដោយបានឃើញអ្នកទាំងពីរ » ។ « ការឈឺចាប់នៅក្នុងខ្នងរបស់ខ្ញុំបានចាប់ផ្តើមរសាយបាត់ បន្ទាប់ពីអ្នកផ្តល់ការប្រសិទ្ធពរដល់ខ្ញុំ ហើយឥឡូវនេះ វាលែងឈឺទៀតហើយ ! »

អែលឌើរ សាន់ឆេស បាននិយាយថា « បងស្រី ហ្គារសៀ ព្រះវរបិតាសួគ៌បានប្រោសបងស្រីឲ្យជាហើយ » ។ « ហើយទ្រង់អនុញ្ញាតឲ្យយើងជួយទ្រង់ ដោយការប្រើសិទ្ធិអំណាចបព្វជិតភាពរបស់យើង ដើម្បីប្រសិទ្ធពរដល់បងស្រី » ។

លុះថ្ងៃអាទិត្យក្រោយ—និងរាល់ថ្ងៃអាទិត្យបន្ទាប់មកទៀត—ម៉ាករបស់រូប៊ិនបានទៅព្រះវិហារជាមួយរូប៊ិន និង ឪអែរហ្គោ ។ គាត់បានដឹងថាអំណាចនៃបព្វជិតភាពមានពិត ហើយរូប៊ិនក៏ដឹងដូចគ្នាដែរ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*



## តើបព្វជិតភាពគឺជាអ្វី ?

បព្វជិតភាពគឺជាសិទ្ធិអំណាចដើម្បីធ្វើកិច្ចការនៅក្នុងព្រះនាមរបស់ព្រះវរបិតាសួគ៌ ។

ក្មេងប្រុសនៅក្នុងសាសនាចក្រអាចកាន់បព្វជិតភាពអើរ៉ុន នៅពេលពួកគេមានភាពសក្តិសម ហើយមានអាយុពី 12 ឆ្នាំឡើងទៅ ។ ពួកគេអាចកាន់បព្វជិតភាពមិលគីស្សាដែកនៅពេលពួកគេមានភាពសក្តិសម ហើយមានអាយុ 18 ឆ្នាំ ។

តំណែងនៅក្នុងបព្វជិតភាពអើរ៉ុនរួមមាន ឌីកុន គ្រូ និង សង្ឃ ។ តំណែងក្នុងបព្វជិតភាពមិលគីស្សាដែករួមមាន អែលឌើរ សង្ឃជាន់ខ្ពស់ លោកអយ្យកោ ពួកចិតសិបនាក់ និង សាវក ។

**កិច្ចការមួយចំនួនដែលអ្នកបព្វជិតភាពអើរ៉ុនអាចធ្វើ ៖**

- រៀបចំពិធីសាក្រាម៉ង់ ( គ្រូ និង សង្ឃ ) ប្រសិទ្ធពរ ( សង្ឃ ) និងចែក ( ទាំងអស់គ្នា )
- ធ្វើជាគ្រូបង្រៀនតាមផ្ទះ គ្រូ និង សង្ឃ )
- ជ្រមុជទឹក ( សង្ឃ )
- ប្រមូលតង្វាយតមអាហារ ( ឌីកុន គ្រូ និង សង្ឃ )
- តែងតាំងអ្នកដទៃក្នុងបព្វជិតភាពអើរ៉ុន ( សង្ឃ )

**កិច្ចការមួយចំនួនដែលអ្នកកាន់បព្វជិតភាពមិលគីស្សាដែកអាចធ្វើ ៖**

- ធ្វើគ្រប់កិច្ចការដែលអ្នកកាន់បព្វជិតភាពអើរ៉ុនធ្វើ រួមទាំង ៖
- បញ្ជាក់សមាជិកសាសនាចក្រក្រោយពីពិធីបុណ្យជ្រមុជទឹក
- ផ្តល់ការប្រសិទ្ធពរដោយបព្វជិតភាព
- ដឹកនាំការប្រជុំសាសនាចក្រ និងផ្តល់ការហៅបម្រើ



**ដោយ អែលឌើរ នែល អិល អាន់ឌើរសិន**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់
*សមាជិកនៃកូរ៉ុមនៃពួកដប់ពីរនាក់ គឺជាសាក្សីពិសេសរបស់ព្រះយេស៊ូវគ្រីស្ទ ។*

# តើខ្ញុំអាចក្លាយដូចជាអ្នកផ្សព្វផ្សាយសាសនាចក្រម្នាក់នៅពេលនេះបានដោយរបៀបណា ?

សូមអធិស្ឋានរកវិធីដើម្បីចែកចាយដំណឹងល្អ ។

សូមអធិស្ឋានឲ្យដឹងថា នរណាដែលអ្នកអាចអញ្ជើញទៅព្រះវិហារ ។

បើអ្នកមិនមែនជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ជាមួយនឹងស្លាកឈ្មោះជាប់នឹងអាវទេនោះ ឥឡូវនេះ ជាពេលវេលាដើម្បីគូសស្លាកមួយក្នុងដួងចិត្តអ្នក ។

សូមអធិស្ឋានសម្រាប់អ្នកផ្សព្វផ្សាយសាសនាពេញម៉ោងទាំងឡាយ ។

ចូរលើកពន្លឺអ្នករាល់គ្នាឡើង ហើយធ្វើគំរូល្អតំណាងឲ្យព្រះយេស៊ូវ ។



*ដកស្រង់ចេញពី « It’s a Miracle »* Liahona, *ខែ ឧសភា ឆ្នាំ 2013, ទំព័រ 77–80 ។*



**ដោយ អែលឌើរ ស្តត់ ឌី វីតធីង**
នៃពួកចិតសិបនាក់

# កូនចៀមដែលគួរឲ្យគោរព



*« ខ្ញុំទុកសេចក្តីសុខសាន្តនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្តីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា » (យ៉ូហាន 14:27) ។*

នៅពេលខ្ញុំប្រហែលជាអាយុប្រាំពីឆ្នាំ ប្រធានថ្នាក់អង្គការបឋមសិក្សារបស់ខ្ញុំចង់ជួយកុមារ ឲ្យមានគារវភាពថែមទៀតនៅក្នុងថ្នាក់កុមាររបស់យើង ។ គាត់បានធ្វើក្តារបិទប្រកាសមួយធំរាងដូចជាកូនចៀម ។ នៅពេលណាកុមារម្នាក់មានគារវភាព គាត់បានដាក់ក្រដាសស្អិតរាងកូនចៀមនៅលើក្តារបិទប្រកាសនោះក្បែរឈ្មោះរបស់គេ ។ ខ្ញុំចង់បានកូនក្រដាសស្អិតរូបកូនចៀមនោះមួយ ។ ដូច្នេះ នៅថ្ងៃមួយក្នុងថ្នាក់កុមារ ខ្ញុំបានអង្គុយឱបដៃនៅស្ងៀម ហើយមើលមុខប្រធានថ្នាក់កុមារ ដើម្បីគាត់ឃើញខ្ញុំកំពុងមានគារវភាព ។ មានក្មេងប្រុសធំម្នាក់អង្គុយពីមុខខ្ញុំ ដូច្នេះខ្ញុំបានរំកិលកៅអីចេញបន្តិចដើម្បីគាត់អាចមើលឃើញខ្ញុំ ។



ក្រោយមក កាលខ្ញុំអង្គុយដោយគារវភាពនៅទីនោះ អ្នកលេងព្យាណូបានចាប់ផ្តើមលេងតិចៗនូវចម្រៀងថ្នាក់កុមារមួយដ៏ពិរោះ ។ នៅពេលខ្ញុំបានស្តាប់ អារម្មណ៍ពោរពេញដោយសេចក្តីសុខសាន្តមួយបានគ្របដណ្តប់មកលើខ្ញុំ ហើយទឹកភ្នែករបស់ខ្ញុំបានចាប់ផ្តើមហូរចុះមក ។ ខ្ញុំមិនបានដឹងថាហេតុអ្វីបានជាខ្ញុំមានអារម្មណ៍ពោរពេញដោយភាពរីករាយ និង សេចក្តីសុខសាន្តនៅក្នុងចិត្តនោះទេ ។

បន្ទាប់ពីថ្នាក់កុមារបានបញ្ចប់ ខ្ញុំបានប្រាប់ម្តាយខ្ញុំពីអារម្មណ៍ដែលខ្ញុំមាន ហើយគាត់បានប្រាប់ខ្ញុំថា វាជាអារម្មណ៍ពីព្រះវិញ្ញាណ ។ នៅថ្ងៃនោះ ខ្ញុំបានរៀនថា តើព្រះវិញ្ញាណធ្វើឲ្យខ្ញុំមានអារម្មណ៍បែបណា ។ នៅពេលណាខ្ញុំត្រូវការសម្រេចចិត្តដ៏សំខាន់នានា ហើយត្រូវការការដឹកនាំពីព្រះវិញ្ញាណ ខ្ញុំចងចាំពីអារម្មណ៍ពោរពេញដោយភាពសុខសាន្តដែលខ្ញុំមាននៅថ្ងៃនោះ ហើយខ្ញុំអាចស្គាល់ពីរបៀបដែលព្រះវិញ្ញាណមានបន្ទូលមកកាន់ខ្ញុំ ។ ■

# ខ្ញុំឈ្មោះ ឡូរ៉េដាណា មកពីប្រទេស អ៊ីតាលី

## Ciao, amici!*

ដកស្រង់ចេញពីបទសម្ភាសន៍មួយដោយ
អេមី ជេន លីវិត

តើទីក្រុងដែលអ្នករស់នៅមានឈ្មោះហៅក្រៅទេ ? ទីក្រុងដែល ឡូរេដាណា រស់នៅ ពេលខ្លះត្រូវគេហៅថា ទីក្រុងអស់កល្បជានិច្ច ។ ឡូរេដាណា រស់នៅក្នុងទីក្រុង រ៉ូម ប្រទេស អ៊ីតាលី ។ ទីក្រុងដ៏ស្រស់ស្អាតជាប្រវត្តិសាស្ត្រនេះមានទីកន្លែងទស្សនា ដែលគួរឲ្យចាប់អារម្មណ៍ជាច្រើន ដូចជា អាងទឹក កូឡូសៀម និង ទ្រេវី ។

រាល់ពេលទៅសាលានៅពេលព្រឹក បន្ទាប់ពីអានព្រះគម្ពីរជុំគ្នាមក ឡូរេដាណា និង គ្រួសារនាងបានហូបអាហារពេលព្រឹក ( ជាទូទៅ សេរាល និង ទឹកដោះគោ) ។ បន្ទាប់មកនាងបានទៅសាលា ។ ជាពិសេស នាងចូលចិត្តថ្នាក់សិល្បៈ និង កុំព្យូទ័រ ។ ពេលនាងមកដល់ផ្ទះ នាងចូលចិត្តលេងជាមួយនឹងប្អូនប្រុសនាង ហ្វ្រង់សេស្កូ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*

**« សួស្ដីមិត្តទាំងឡាយ ! » ជាភាសាអ៊ីតាលី ។*



*ម៉ាក់របស់ខ្ញុំបានអានព្រះគម្ពីរមរមនឲ្យខ្ញុំស្ដាប់រាល់យប់ សូម្បីតែពីមុនគាត់ចូលសាសនាចក្រក៏ដោយ ។ ពេលម៉ាក់ខ្ញុំបានសម្រេចចិត្តឲ្យពួកអ្នកផ្សព្វផ្សាយសាសនាបង្រៀនយើង ខ្ញុំបានឮពួកគាត់អានព្រះគម្ពីរមរមន ខ្ញុំបានស្គាល់ពីខ្លឹមសារក្នុងនោះ ។*



រូបថតទីក្រុងរ៉ូមដោយ SERGEY BORISOV/ISTOCKPHOTO/THINKSTOCK ;រូបថតផ្សេងទៀតបានទទួលសិទ្ធិអនុញ្ញាតជាផ្លូវការពីគ្រួសារឡូរេដាណា ។





នៅបុណ្យគ្រីស្ទម៉ាស់ និង បុណ្យអ៊ីសស្ទើរ ខ្ញុំចូលចិត្តឲ្យអំណោយដែលគ្រួសារខ្ញុំបានធ្វើទៅដល់មិត្តរបស់ខ្ញុំ ។ ខ្ញុំបានធ្វើប័ណ្ណ និង ស៊ុមរូបថតដោយខ្លួនឯងដើម្បីដាក់រូបភាពពិសេស។នៅក្នុងនោះ ។





ម៉ាក់ខ្ញុំមើលថែស្ត្រីចំណាស់ជរាម្នាក់ឈ្មោះ អាន់ជេលីណា ។ ពេលខ្លះនៅថ្ងៃសៅរ៍ ខ្ញុំប្រាប់អាន់ជេលីណាពីរឿងនានា ហើយច្រៀងចម្រៀងថ្នាក់កុមារឲ្យគាត់ស្ដាប់ ។ ខ្ញុំរីករាយជួយដល់មិត្តខ្ញុំអាន់ជេលីណា ។



ខ្ញុំចូលចិត្តមើលព្រះវិហារបរិសុទ្ធ

ម៉ាក់ និងឪពុកចុងខ្ញុំមានផែនការធ្វើការផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធរ៉ូមអ៊ីតាលី បន្ទាប់ពីព្រះវិហារបរិសុទ្ធនេះបានឧទ្ទិសឆ្លង ។ ខ្ញុំក៏មានចិត្តរីករាយសម្រាប់ថ្ងៃនោះដែរ ។ វានឹងក្លាយជាថ្ងៃដ៏ពិសេសបំផុតមួយសម្រាប់គ្រួសារយើងទាំងមូល !

គ្រួសារខ្ញុំចូលចិត្តទៅលេងមាត់សមុទ្រ ទីកន្លែងប្រវត្តិសាស្ត្រនៅទីក្រុងរ៉ូម ឬលេងនៅក្នុងទីធ្លាលេងសម្រាប់កុមារ ។

ជារឿយ។ ខ្ញុំបានជួយឪពុកចុងខ្ញុំធ្វើ ផាស្ដាអាម៉ាទ្រីស្យ៉ាណា សម្រាប់អាហារពេលល្ងាច ។

ត្រៀមខ្លួនហើយឬនៅ !

កាបូបរបស់ឡូរេដាណាត្រូវបានដាក់នូវរបស់មួយចំនួនដែលនាងចូលចិត្ត ។ តើរបស់ណាខ្លះ អ្នកចង់ដាក់ក្នុងកាបូបរបស់អ្នក ?





# ម៉ាស៊ីម៉ូ មកពីប្រទេស អ៊ីតាលី

ម៉ាស៊ីម៉ូបានពាក់ឯកសណ្ឋានកីឡាបាល់ទាត់របស់ខ្លួន ប៉ុន្តែអ្នកក៏អាចពាក់ខោអាវទៅព្រះវិហារ ឬខោអាវប្រពៃណីរបស់អ៊ីតាលីឲ្យគាត់ផងដែរ ។ សូមបិទទំព័រនេះទៅនឹងក្រដាសរឹងពីមុនអ្នកផាត់ពណ៌ ហើយកាត់យកបំណែកផ្សេងៗ ។ ■





# ការចេះជួយគ្នា





## អ្វីដែលព្រះយេស៊ូវបានបង្រៀន

មានថ្ងៃមួយកាលព្រះយេស៊ូវកំពុងបង្រៀនពីអ្វីដែលយើងគួរធ្វើ ពេលមានមនុស្សម្នាក់សុំជំនួយពីយើង ។ ទ្រង់បានមានបន្ទូលថា យើងគួរធ្វើ ឬផ្តល់លើសពីអ្វីដែលបុគ្គលម្នាក់នោះសុំពីយើងទៅទៀត ។ ចូរស្វែងរកពីហេតុផលដែលការណ៍នេះត្រូវដែលគេបានហៅថា « ចូរទៅជាមួយនឹងគេដល់ពីរយោជន៍ផង » ដោយអានបន្ទូលរបស់ព្រះយេស៊ូវនៅក្នុងម៉ាថាយ 5:40–42 ។

## ការដើរតាមព្រះយេស៊ូវនៅសព្វថ្ងៃនេះ



នាយប់មួយបងប្រុសបងស្រីខ្ញុំ ហើយនិងខ្ញុំបានចាប់ផ្តើមបោសសម្អាតផ្ទះទាំងមូល ។ រួចហើយឪពុករបស់ខ្ញុំបានចូលមក ហើយបាននិយាយថា ដល់ពេលចូលគេងហើយ ។ លុះព្រឹកឡើងខ្ញុំបានក្រោកឡើង ហើយម្តាយខ្ញុំបាននិយាយថា « អរគុណកូនដែលបានបោសសម្អាតផ្ទះ » ។

អេលីហ្សាបែ៊ត ស៊ី អាយុ 8 ឆ្នាំ អាល់ប៊ើតា ប្រទេសកាណាដា

ខ្ញុំចូលចិត្តជួយមនុស្សទូទៅ ។ ពេលម្តាយខ្ញុំចូលរួមនៅក្នុងសកម្មភាពបម្រើ ខ្ញុំចូលចិត្តទៅជាមួយគាត់ដើម្បីជួយ ។

« ដៃជំនួយ » លូីស អិន អាយុ 6 ឆ្នាំ ឈីវ៉ាវ៉ា ប្រទេសម៉ិកស៊ីកូ




ចំណងជើងគំនូរ និង ប្រាយអិន ប៊ីច

## សំណូមពរសម្រាប់ខែនេះ ៖

- [ ] សូមរកមើលវិធីនានាដើម្បីជួយដល់គ្រូក្នុងថ្នាក់កុមាររបស់អ្នកនៅពេលកំពុងរៀន ។
- [ ] សូមជួយប្អូនប្រុស ឬប្អូនស្រីជាមួយនឹងកិច្ចការសាលា ឬ កិច្ចការមួយ ។
- [ ] សូមធ្វើឲ្យឪពុក ឬម្តាយភ្ញាក់ផ្អើលដោយបោសសម្អាតបន្ទប់មួយដោយពុំចាំបាច់ស្នើសុំឲ្យធ្វើកិច្ចការនេះ ។
- [ ] ខ្ញុំតាំងចិត្តខ្លួនឯងដើម្បី. . .

______________________________

# ការប្រគុំតន្ត្រីនៅប្រទេសអ៊ូហ្គង់ដា

*តើដឹកនាំតន្ត្រីនៅមុខមនុស្សគ្រប់គ្នាមែនទេ ? ចច អាចធ្វើវាបាន ។*

**ដោយ ដេវីឌ ឌីកសុន**
ទស្សនាវដ្ដីសាសនាចក្រ

ញុំមានកុមារច្រើនដែលបម្រើនៅក្នុងការហៅក្នុងសាសនាចក្រ មុនពេលគេបញ្ចប់ថ្នាក់កុមារនោះទេ ។ ប៉ុន្តែ ចច អិន មកពីប្រទេសអ៊ូហ្គង់ដាមានអាយុតែប្រាំឆ្នាំប៉ុណ្ណោះ ពេលគាត់ត្រូវបានហៅជាការដឹកនាំភ្លេងនៅក្នុងសាខារបស់គាត់ ។

អ្នកដឹកនាំភ្លេងគឺជាមនុស្សម្នាក់ដែលឈរនៅពីមុខមនុស្សគ្រប់គ្នាក្នុងពេលការប្រជុំសាក្រាម៉ង់ដើម្បីដឹកនាំការច្រៀង ។ វាជាការងារមួយដ៏សំខាន់ !

ចច និយាយថា « ខ្ញុំធ្លាប់ភ័យកាលខ្ញុំនៅក្មេង » ។ ប៉ុន្តែទោះជានៅពេលនោះក្ដី គាត់តែងធ្វើអស់ពីលទ្ធភាពរបស់គាត់ ។ គាត់បានរីកចម្រើនរាល់សប្ដាហ៍ ។ មិនយូរប៉ុន្មានគាត់បានដឹកនាំតន្ត្រីដោយមានទំនុកចិត្ត ។

ចច រីករាយនៅក្នុងការបម្រើនៅក្នុងការហៅរបស់គាត់ ។ គាត់និយាយថា « ខ្ញុំមានអារម្មណ៍ល្អ » ។ « ខ្ញុំមានអារម្មណ៍ដូចជាព្រះវិញ្ញាណគង់នៅក្នុងបន្ទប់ » ។

តន្ត្រីគឺជាផ្នែកដ៏ធំមួយនៅក្នុងជីវិតរបស់ចច ។ គាត់ក៏ចេះលេងព្យាណូ និង ហ្គីតាផងដែរ ។ ពិតណាស់ វាបានជួយយ៉ាងច្រើនដោយសារ ចច មកពីគ្រួសារចេះលេងតន្ត្រី ។ ពួកគេទាំងអស់គ្នាចូលចិត្តច្រៀងរួមគ្នា—ចច ឪពុកម្ដាយគាត់ បងប្អូនស្រីគាត់ប្រាំមួយនាក់ និង ប្អូនប្រុសគាត់ម្នាក់ ។ រាយនាមពីអ្នកមានអាយុច្បងបំផុតរហូតដល់អ្នកមានអាយុប្អូនបំផុត គឺ រូស៊ីទ្បា មីរៀម នេនស៊ី អាឈ្លី ចច ឆៃយេន អូនីដា និង ហ្គីឌាន ។ (*Children's Songbook,* 12).

ប្អូនប្រុសរបស់គាត់ ហ្គីឌាន អាយុ 5 ឆ្នាំ បានជួយដឹកនាំភ្លេងនៅពេលខ្លះ ។ ចច បានបង្រៀន ហ្គីឌាន ពីរបៀបដឹកនាំភ្លេង ។

បងប្អូនប្រុសទាំងពីរនាក់នេះបានញញឹមដោយរីករាយនៅពេលពួកគេដឹកនាំតន្ត្រី ។ ពួកគេដឹងថា ពួកគេកំពុងជួយនាំព្រះវិញ្ញាណមកក្នុងការប្រជុំ ។ ■



ការថតរូបបានទទួលសិទ្ធិអនុញ្ញាតជាផ្លូវការពី ខាល និង រូប៊ិន ប៊េខល ។ រចនា ដោយ ហ្វីលីស លុច និង ប្រ៊ិតេលី ភ្លាក





## អំពីចច

- ក្រៅពីតន្ត្រី ចំណង់ចំណូលចិត្តមួយទៀតរបស់ចចគឺការលេងបាល់ឱប ។
- អាហារដែលគាត់ចូលចិត្តគឺបាយ ដំឡូង សណ្ដែក និង សណ្ដែកដី ។
- មុខវិជ្ជាដែលគាត់ចូលចិត្តនៅឯសាលាគឺភាសាអង់គ្លេស និង គណិតវិទ្យា ។
- ចច ចូលចិត្តលេងល្បែងលើ ផ្ទាំងក្រដាសកម្សាន្តជាមួយ គ្រួសារគាត់ ។ ល្បែងលេងផ្ទាំងក្រដាស ដែលគាត់ ចូល ចិត្តមានឈ្មោះថា Scattergories ។








## រៀបដឹកនាំតន្ត្រី

អ្នកអាចរៀនដឹកនាំតន្ត្រីបានដែរ ! នេះជារបៀបដឹកនាំបទ « Book of Mormon Stories » (*Children’s Songbook* ទំព័រ 118) ៖

1. មើលលេខពីរនៅពេលចាប់ផ្ដើមនៃចម្រៀង ។ លេខនៅខាងលើប្រាប់អ្នកពីចង្វាក់នៅក្នុងរង្វាស់នីមួយៗ ឬផ្នែកតូចនៃចម្រៀងនេះ ។ ចម្រៀងនេះមានបួនចង្វាក់នៅក្នុងរង្វាស់នីមួយៗ ។
2. លើកដៃអ្នកឡើង ហើយទប់វា កុំបាច់ប្រឹងខ្លាំងពេកដោយដាក់ម្រាមដៃអ្នកកៀកគ្នា ។
   គ្រវីដៃអ្នកចុះមកក្រោម ។
   គ្រវីដៃអ្នកមកឆ្វេង ។
   គ្រវីដៃអ្នកទៅស្ដាំ ។
   លើកដៃអ្នកឡើងលើ ។
3. សូមធ្វើតាមលំនាំនេះ ច្រំដែលសម្រាប់រង្វាស់នីមួយៗនៅក្នុងចម្រៀងនេះ ។
4. ចូរបន្តអនុវត្តវា ហើយមិនយូរប៉ុន្មានអ្នកនឹងត្រៀមខ្លួនជាស្រេច ដើម្បីដឹកនាំចម្រៀងមួយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ !



# ពិធីបរិសុទ្ធបព្វជិតភាព និង កិច្ចការព្រះវិហារបរិសុទ្ធប្រសិទ្ធិពរដល់គ្រួសារខ្ញុំ

*ដោយ ជែននីហ្វើ ម៉ាឌី*

ខាល បានរត់ចុះទៅផែកាណូតយ៉ាងរីករាយដោយបានឃើញឪពុករបស់គាត់ ។ ឪពុករបស់ខាលគឺជាអ្នកនេសាទត្រីម្នាក់ ហើយជារឿយៗ ខាល បានរត់ទៅរកកាណូតដើម្បីជួបនឹងគាត់ជារៀងរាល់ថ្ងៃ ។

« ឆាប់ឡើង ប៉ា ! » ខាល បានស្រែកហៅ ។ « កូនចង់បង្ហាញរូបភាពមួយដែលកូនគូរឲ្យប៉ានៅថ្ងៃនេះ! »

« អស្ចារ្យណាស់! » ឪពុកបានតប ។ « ប៉ុន្តែ ប៉ាត្រូវចងកាណូតទុកសិន » ។

ខល បានមើលឪពុករបស់ខ្លួនចង់កាណូតទៅនឹងផែជាមួយខ្សែពួរធំមួយដោយយកចិត្តទុកដាក់ ។ « ហេតុអ្វីបានជាប៉ាចាំបាច់ចងវាតឹងម្ល៉េះ ? » ខាល បានសួរខណៈដែលឪពុកកំពុងចងជាចំណងធំខ្សែពួរនោះ ។

ឪពុកបានចង្អុលទៅកាណូតមួយនៅលើឆ្នេរដែលមានប្រហោងធ្លុះមួយធំនៅនឹងបាតកាណូតនោះ ។ « កាណូតនោះមិនត្រូវបានគេចងឲ្យជាប់ល្អនោះទេ ។ កាលព្យុះលើកមុននោះ វាបានដាច់របូតហើយទៅបុកនឹងថ្ម » ។

ខាលបានបើកភ្នែកធំៗ ។

« តើកូនអាចគិតឃើញពីរបៀបដែលព្រះវរបិតាសួគ៌ជួយយើងឲ្យនៅជាប់នឹងទ្រង់ ដើម្បីយើងអាចមានសុវត្ថិភាពដែរទេ ? » ឪពុកបានសួរ ។

« ព្រះគម្ពីរមែនទេ ? » ខាល បានទស្សន៍ទាយ ។

ឪពុកបានតបថា « ត្រឹមត្រូវហើយ » ។ « ទ្រង់ក៏បានប្រទានឲ្យយើងនូវពិធីបរិសុទ្ធនៃបព្វជិតភាពផងដែរ ដូចជា បុណ្យជ្រមុជទឹក និង ពិធីសាក្រាម៉ង់ ។ ម៉ាក់ និង ប៉ា បានរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ ដើម្បីឲ្យគ្រួសារយើងអាចរួមរស់នៅគ្នាជារៀងរហូត » ។

ខាល បានចាប់ខ្សែពួរ ហើយជួយឪពុកចងជុំចុងក្រោយ ។ « យើងបានចងចំណងដ៏ណែនបំផុត ! » ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា.* ។

## ព្រះគម្ពីរ និង បទចម្រៀង

- ម៉ាថាយ 18:18
- « ខ្ញុំចូលចិត្តមើលព្រះវិហារបរិសុទ្ធ » *សៀវភៅចម្រៀងរបស់កុមារ*ទំព័រ 95 ។

## គំនិតយោបល់សម្រាប់ការនិយាយក្នុងគ្រួសារ

គ្រួសាររបស់អ្នកអាចអាន ម៉ាថាយ 18:18 ហើយពិភាក្សាថា តើវាមានន័យយ៉ាងណាដែរចំពោះការមានអ្វីមួយ « ចងភ្ជាប់នៅស្ថានសួគ៌ » ។ ដោយប្រើខ្សែមួយវែង អ្នកអាចប្ដូរវេណគ្នាគួចចងខ្សែនោះទៅជាចំណង ហើយប្រាប់ពីរបៀបដែលពិធីបរិសុទ្ធនៃបព្វជិតភាពបានប្រទានពរដល់ជីវិតអ្នក ។





បុណ្យជ្រមុជទឹកដោយការពន្លិច



ការប្រសិទ្ធពរអ្នកឈឺ



ការប្រសិទ្ធពរទារក



ការប្រសិទ្ធពរអ្នកឈឺ

## ការនៅជាប់នឹងព្រះវរបិតាសួគ៌

សូមដកយកទំព័រនេះចេញ ហើយបិទវានឹងក្រដាសពណ៌មួយសន្លឹក ។ សូមកាត់ប័ណ្ណនោះចេញ ហើយដាក់វាផ្កាប់លើតុ ឬឥដ្ឋ ។ សូមដាក់វេណគ្នាដើម្បីបើកផ្ងារប័ណ្ណពីរដែលដូចគ្នា ។ ពេលនរណាម្នាក់បើកផ្ងារបានប័ណ្ណដូចគ្នា សូមឲ្យគាត់ប្រាប់ពីរបៀបដែលពិធីបរិសុទ្ធដែលបង្ហាញ នៅលើប័ណ្ណនោះជួយយើងឲ្យនៅជិតនឹងព្រះវរបិតាសួគ៌ ។



ការប្រសិទ្ធពរទារក



ពិធីសាក្រាម៉ង់



បុណ្យជ្រមុជទឹកដោយការពន្លិច



ពិធីសាក្រាម៉ង់



អាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ



ពិធីបញ្ជាក់



អាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ



ពិធីបញ្ជាក់

# ទំព័ររបស់យើង



មេហ៊ារី ស៊ី អាយុ 11 ឆ្នាំ ប្រទេស អែល សាល់វ៉ាឌ័រ




*ពួកអ្នកផ្សព្វផ្សាយសាសនា* ដោយ ម៉ារី ក្លារ៉ា អេ អាយុ 9 ឆ្នាំ ប្រទេស ប្រេស៊ីល

*ផលទ្បូ និង ខាទ្បូ ឌី អាយុ 10 ឆ្នាំ មកពីប្រទេស ហ្វីលីពីន ជាបងប្អូនប្រុសភ្លោះ ។ ពួកគេចង់ធំឡើង មានអាយុគ្រប់គ្រាន់ដើម្បីទទួលបព្វជិតភាព ហើយចែកសាក្រាម៉ង់ ។ ពួកគេចូលចិត្តបង្រៀនអ្នកដទៃពីដំណឹងល្អ ហើយពួកគេត្រៀមខ្លួនជាស្រេចដើម្បីបម្រើបេសកកម្ម ។ ខាទ្បូ បានប្រាប់មនុស្សគ្រប់គ្នាថា គាត់បានដឹងពីព្យាការីនៅរស់ ហើយ ផលទ្បូ ចូលចិត្តយកព្រះគម្ពីរមរមនរបស់គាត់ទៅសាលា ហើយអានវាជាមួយនឹងមិត្តរួមថ្នាក់របស់គាត់ ។ ពួកគេដឹងថា ការអានព្រះគម្ពីររាល់ថ្ងៃ និង ការទៅព្រះវិហារនៅថ្ងៃអាទិត្យជារឿងសំខាន់ ។ ខាទ្បូ និង ផលទ្បូ ចេះនិយាយភាសាពីរយ៉ាងស្ទាត់—ភាសាតាហ្គាឡុក និង ភាសា អ៊ីឡូកាណូ— ហើយពួកគេកំពុងរៀនភាសាអង់គ្លេសនៅឯសាលា ។ ពួកគេចូលចិត្តលេងបាល់បោះជាមួយនឹងមិត្តរបស់ពួកគេ ។*





មានថ្ងៃមួយនៅឯសាលា មិត្តរបស់ខ្ញុំបានល្បួងខ្ញុំឲ្យនិយាយពាក្យមិនល្អនៅក្នុងថ្នាក់រៀនមួយដែលគ្មានមនុស្ស ។ ពេលខ្ញុំនិយាយថាទេ ពួកគេបានចំអន់ខ្ញុំ ហើយបានសើចចំអកឲ្យខ្ញុំ ។ បន្ទាប់មកខ្ញុំបាននិយាយថា យល់ព្រម ហើយខ្ញុំបាននិយាយពាក្យនោះតិច។ ហើយលឿន ។ រួចខ្ញុំមានការសោកស្ដាយចំពោះអ្វីដែលខ្ញុំបានធ្វើ ។ នៅយប់នោះ ខ្ញុំបានអធិស្ឋានអស់ពីដួងចិត្តរបស់ខ្ញុំ ហើយបានប្រែចិត្តចំពោះការនិយាយពាក្យមិនល្អ ។ ខ្ញុំដឹងថា ខ្ញុំអាចងាកទៅរកព្រះវរបិតាសួគ៌ ដើម្បីដឹងពីអ្វីដែលត្រឹមត្រូវជានិច្ច ហើយប្រសិនបើមានអ្វីមួយខុសឆ្គង ខ្ញុំនឹងនិយាយថា ទេ ទោះជាមិត្តខ្ញុំប្រាប់ខ្ញុំឲ្យធ្វើវាក្ដី ។ ខ្ញុំមានអំណរគុណចំពោះការប្រែចិត្ត !

**ផោទ្បា អិល អាយុ 10 ឆ្នាំ ប្រទេស ម៉ិកស៊ីកូ**

## ការខំក្លាយដូចជាព្រះយេស៊ូវ

នៅឯសាលារបស់ខ្ញុំ យើងបានរៀបចំតាំងពីដើមឆ្នាំសម្រាប់សកម្មភាពធំមួយហៅថា Festidanza ។ដូចរាល់ឆ្នាំដែរ វានឹងត្រូវធ្វើឡើងនៅថ្ងៃសៅរ៍ ។ លុះថ្ងៃមួយ នាយករបស់យើងបានប្រកាសថា វាត្រូវផ្លាស់ទៅថ្ងៃអាទិត្យវិញ ។ ខ្ញុំបានប្រាប់ម្ដាយខ្ញុំថា នៅថ្ងៃអាទិត្យទៅព្រះវិហារ ហើយខ្ញុំរីករាយនឹងគោរពថ្ងៃឈប់សម្រាក ។

**អ៊ីសៃយ៉ាស អ័រ អាយុ 6 ឆ្នាំ ប្រទេស ប៉េរូ**





បទពិសោធន៍ដ៏ល្អបំផុតក្នុងជីវិតខ្ញុំគឺជាថ្ងៃដែលខ្ញុំបានជ្រមុជទឹក ។ ម្ដាយខ្ញុំបានបង្រៀនខ្ញុំថា ពេលខ្ញុំបានជ្រមុជទឹក ខ្ញុំនឹងមានទំនួលខុសត្រូវនូវរាល់ទង្វើរបស់ខ្ញុំ ។ ថ្ងៃនោះបានមកដល់ ហើយឪពុកខ្ញុំ និង ខ្ញុំ បានស្លៀកសំលៀកបំពាក់ពណ៌-សទាំងពីរនាក់ ។ ខ្ញុំបានភ័យ ប៉ុន្ដែពេលខ្ញុំបានកាន់ដៃឪពុកខ្ញុំដើរចូលទៅក្នុងអាងទឹក ខ្ញុំបានដឹងថា អ្វីៗគ្រប់យ៉ាងនឹងពុំមានបញ្ហានោះទេ ។ ពេលឪពុកខ្ញុំពោលនូវការអធិស្ឋានសម្រាប់បុណ្យជ្រមុជទឹក ហើយបានពន្លិចខ្ញុំចូលទៅក្នុងទឹក ខ្ញុំមានអារម្មណ៍ល្អនៅក្នុងចិត្តខ្ញុំដែលមិនអាចពន្យល់បាន ។ បន្ទាប់មក ខ្ញុំត្រូវបានបញ្ជាក់ ហើយបានប្រគល់ឲ្យនូវអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ។ ខ្ញុំមានចិត្តរីករាយជាខ្លាំងដែលខ្ញុំបានជ្រមុជទឹក ។ ដូចជាព្រះយេស៊ូវគ្រីស្ទបានបង្ហាញគំរូដល់ខ្ញុំដែរ ខ្ញុំកំពុងតាំងជាគំរូដល់ប្អូនប្រុសរបស់ខ្ញុំ ។ ខ្ញុំដឹងថា ព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ ហើយស្រឡាញ់យើង ។

**រីឆាដ អេជ អាយុ 8 ឆ្នាំ ប្រទេស ក្វាតេម៉ាឡា**



ខ្ញុំចូលចិត្តផ្នែករបស់កុមារនៅក្នុង *លីអាហូណា* ពីព្រោះដំណើររឿងទាំងឡាយបានជួយខ្ញុំឲ្យរៀនពីព្រះវរបិតាសួគ៌ ។ ខ្ញុំតែងសុំម្ដាយរបស់ខ្ញុំឲ្យអានដំណើររឿងទាំងនោះឲ្យខ្ញុំស្ដាប់ ។ ខ្ញុំចូលចិត្តល្បែងផ្គុំរូប ល្បែងរកច្រកចេញ គូររូប និងនិទានពីដំណើររឿង ។ ខ្ញុំចូលចិត្តរៀនរឿងថ្មីៗនៅក្នុងថ្នាក់កុមារ ។ ខ្ញុំដឹងថា ព្រះវរបិតាសួគ៌ស្រឡាញ់ខ្ញុំ ហើយទ្រង់ក៏ស្រឡាញ់អ្នកផងដែរ ។ ខ្ញុំតែងតែព្យាយាមចងចាំដល់ទ្រង់ ហើយរើសផ្លូវត្រូវ ។

**ចូសលីន សី អាយុ 4 ឆ្នាំ ប្រទេស នីការ៉ាហ្គា**



*សាន់ត្យាហ្គោ និងប្អូនប្រុសរបស់គាត់ ផៀវ*

ចាប់តាំងពីខ្ញុំនៅក្មេង ខ្ញុំតែងចង់បានបព្វជិតភាពអើរ៉ុន ។ ពេលខ្ញុំមានបព្វជិតភាព ខ្ញុំនឹងអាចចែកសាក្រាម៉ង់ ហើយទ្វារនៃព្រះវិហារបរិសុទ្ធនឹងបើកសម្រាប់ខ្ញុំ ។ វាជាឯកសិទ្ធិមួយដ៏អស្ចារ្យ ដើម្បីក្លាយជាសមាជិកនៃសាសនាចក្រដែលបានស្ដារឡើងវិញនេះ ហើយខ្ញុំដឹងថា ដំណឹងល្អពិត ។ មិនយូរប៉ុន្មានខ្ញុំនឹងចេញពីថ្នាក់កុមារ ជាកន្លែងដែលខ្ញុំបានរៀនយ៉ាងច្រើន ហើយចូលរួមនឹងទ័ពកម្លោះក្នុងថ្នាក់យុវជន ។

**សាន់ត្យាហ្គោ ភី អាយុ 11 ឆ្នាំ ប្រទេស អេក្វាទ័រ**




« ហើយមានតួអង្គមួយបានលេចមកឯខ្ញុំ ពាក់រ៉ូបពណ៌-សអស្ចារ្យដែលខ្ញុំពុំធ្លាប់ឃើញពុំធ្លាប់ឃើញពីមុនមក ។ គាត់ឈ្មោះម៉ូរ៉ូណៃ » ។ ( សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:30–33 )។

**អេរិក អេជ អាយុ 9 ឆ្នាំ ប្រទេស ម៉ិកស៊ីកូ**



**អាហ្គាស្ទីណា ប៊ី អាយុ 10 ឆ្នាំ ប្រទេស អាហ្សង់ទីន**



**ម៉ារីលេណា ប៊ី អាយុ 7 ឆ្នាំ ប្រទេស អាហ្សង់ទីន**

**ចែកចាយជាមួយនឹង *លីអាហូណា***

អ្នកអាចដាក់ស្នើរូបគំនូរ រូបថត ឬបទពិសោធន៍របស់អ្នក តាមអ៊ិនធើរណែត នៅ liahona.lds.org ដោយអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ដោយដាក់ « Our Page » ក្នុងប្រអប់ប្រធានបទ ឬដោយផ្ញើសំបុត្រទៅអាសយដ្ឋាននៅទំព័រ 3 ។

ការដាក់ស្នើនីមួយត្រូវមានឈ្មោះពេញរបស់កុមារ ភេទ និង អាយុ ( 3 ឆ្នាំ ដល់ 11 ឆ្នាំ ) រួមទាំងឈ្មោះរបស់ឪពុក ឬម្ដាយ វួដ ឬសាខា ស្ដេក ឬមណ្ឌល និងសេចក្ដីអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់ឪពុក ឬម្ដាយដើម្បីប្រើរូបភាព និង ការដាក់ស្នើរបស់កុមារ ( ផ្ញើតាមអ៊ីម៉ែលអាចទទួលយកបាន ) ។ សូមកុំផ្ញើរូបគំនូររបស់ព្រះអង្គសង្គ្រោះ ។ ការដាក់ស្នើអាចនឹងត្រូវធ្វើការកែសម្រួលដើម្បីឲ្យត្រូវនឹងទំហំ ឬ ភាពច្បាស់លាស់ ។

# គំនិតអស្ចារ្យរបស់រៀល

ដោយ ឡឺន ហ្វ្រីនវេ

ផ្អែកទៅលើដំណើររឿងពិតមួយ

រៀល ចង់បានរូបភាពព្រះវិហារបរិសុទ្ធមួយ ។ គាត់ចង់ដាក់តាំងវានៅក្នុងបន្ទប់គាត់ ។ គាត់ធ្លាប់ឮព្យាការីថ្លែងថា វាជារឿងមួយល្អសម្រាប់មនុស្សគ្រប់គ្នា ដើម្បីមានរូបភាពនេះមួយ ។

« ម៉ាក់ តើម៉ាក់បានរករូបភាពព្រះវិហារបរិសុទ្ធមួយឲ្យកូនបានហើយឬនៅ ?» រៀល បានសួរ ។

ម៉ាក់បានតបថា « នៅទេ » ។ គាត់ជាប់រវល់មើលថែទាំកូនខ្ចី ។

រៀល បានតបថា « មិនអីទេ » ។

រៀល ស្រឡាញ់ព្រះវិហារបរិសុទ្ធ ។ គាត់បានដឹងថា វាជាកន្លែងពិសេសមួយដែលក្រុមគ្រួសារត្រូវបានផ្សារភ្ជាប់នឹងគ្នា ។

រៀល មានអារម្មណ៍សោកសៅបន្តិច ។ ម៉ាក់រវល់ពេក ។ តើគាត់អាចបានរូបភាពព្រះវិហារបរិសុទ្ធមួយតាមរបៀបណា ?



បន្ទាប់មក រៀល មានគំនិតអស្ចារ្យមួយ ។ គាត់មិនចាំបាច់រង់ចាំម៉ាក់ទេ !

រៀល បានរត់ទៅរកខ្មៅដៃពណ៌របស់គាត់ និង ក្រដាសមួយចំនួន ។ រួចគាត់បានអង្គុយចុះនៅនឹងតុគាត់ ហើយចាប់ផ្ដើមគូរ ។ បន្ទាប់មួយសន្ទុះធំមក រៀលបានដាក់ខ្មៅដៃពណ៌គាត់ចុះ ។ គាត់បានរត់ចូលទៅក្នុងផ្ទះបាយ ហើយកាន់រូបភាពគាត់បង្ហាញដល់ម្ដាយ ។

ម៉ាក់បានពោលថា « ព្រះវិហារបរិសុទ្ធមួយនេះស្រស់ស្អាតខ្លាំងណាស់ » ។

រៀល្លាមបានតបថា « ចូរយើងព្យួរវានៅក្នុងបន្ទប់របស់កូន » ។

« នោះជាយោបល់ល្អណាស់! » ម៉ាក់បានតប ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ អារីសូណា ស.រ.អា. ។*



# អំណាចនៃពាក្យ *នៅពេលដែល*

ដោយ ខេលី ល្វីស អ៊ុយក៉ារី

ជំងឺរបស់ស្វាមីខ្ញុំបានកើតឡើងដោយមិនបានរំពឹងទុក ។ នៅព្រឹកមួយ ពេលគាត់កំពុងកាត់ស្មៅនៅមុខផ្ទះ បន្ទាប់មកស្រាប់តែគាត់បានធ្លាក់ខ្លួនឈឺ ដោយពុំដឹងពី។ លុះថ្ងៃបន្ទាប់ទៀត គាត់ត្រូវបានគេដាក់ខ្យល់អុកស៊ីសែនឲ្យ ។ ពេលយើងផ្លាស់ពីបន្ទប់សង្គ្រោះបន្ទាន់ទៅបន្ទប់វះកាត់ មានវេជ្ជបណ្ឌិតម្នាក់បាននិយាយពាក្យថា *ប្រសិនបើ* ពួកគេនឹងមានលទ្ធភាពជួយសង្គ្រោះគាត់ ។

ដោយសារជំងឺគាត់ជាជំងឺកម្រមាន គាត់មានឱកាសតិចតួចនឹងសង្ឃឹមថាបានរស់ ។ ខ្ញុំមិនចង់ជឿថាវាក្លាយទៅជារឿងបែបនេះទេ ។ ខ្ញុំមានអារម្មណ៍ពោរពេញដោយភាពអស់សង្ឃឹម ។

ជាសំណាងល្អ ផ្លេ បានឆ្លងផុតការវះកាត់ដំបូងរបស់គាត់ដោយជោគជ័យ ហើយបានបញ្ជូនទៅបន្ទប់ថែទាំអ្នកជំងឺ ( អាយ.ស៊ី.យូ ) ។ នៅមានការសាកល្បងច្រើនទៀតនៅអនាគត ប៉ុន្តែឱកាសរបស់គាត់បានប្រសើរឡើង កាលពេលវេលាចេញតែកន្លងផុតទៅ ។ គិលានុប្បដ្ឋាយិកាដំបូងបាននិយាយប្រាប់ខ្ញុំ នៅព្រឹកបន្ទាប់ពីការវះកាត់ដំបូងនោះ ។ គាត់បាននិយាយថា *នៅពេលដែល* ភា ឆ្លងផុតជំហានបន្ទាប់នៃការព្យាបាល ។ ខ្ញុំបានឈប់ទ្រឹងមួយភ្លែតជាមួយនឹងឥទ្ធិពលនៃពាក្យនោះ ។ វាមានសេចក្ដីសង្ឃឹមយ៉ាងច្រើននៅក្នុងពាក្យថា *នៅពេលដែល* ជាងពាក្យ *ប្រសិនបើ*—វាបានមានទំនាក់ទំនងនូវទំនុកចិត្ត និងការរំពឹងទុក ។ ខ្ញុំបានអរគុណគាត់ចំពោះការជ្រើសរើសពាក្យនោះ ហើយគាត់បានញញឹមដោយទទួលយក ។

ផ្លេ បានទទួលការប្រសិទ្ធពរដោយបព្វជិតភាពជាច្រើនដែលបានផ្ដល់នូវការលើកទឹកចិត្តយ៉ាងអស្ចារ្យ ។ យើងបានដឹងដើម្បីរកមើលនូវព្រះហស្តរបស់ព្រះអម្ចាស់នៅក្នុងជីវិតយើង ដោយសារព្រះចេស្ដារបស់ទ្រង់ពុំមែនជាបញ្ហានៃពាក្យថា *ប្រសិនបើ* ប៉ុន្តែជាពាក្យថា *នៅពេលដែលវិញ* ។ គ្រប់ពេលដែលសុខភាពរបស់ ផ្លេ បានស្រុតចុះយ៉ាងខ្លាំង ខ្ញុំបានរំឭកគាត់ពីកាប្រសិទ្ធពរ ហើយថាយើងត្រូវបង្ហាញសេចក្ដីជំនឿរបស់យើងលើ



*យើងបានដឹងនិងរកមើលព្រះហស្តរបស់ព្រះអម្ចាស់ នៅក្នុងជីវិតយើង ដោយសារព្រះចេស្ដារបស់ទ្រង់ពុំមែនជាបញ្ហានៃពាក្យថា ប្រសិនបើនោះទេ ប៉ុន្តែជាពាក្យថា នៅពេលដែល វិញ ។*

ព្រះអម្ចាស់ ។ នេះជាដំណើរមួយដ៏ពិសិដ្ឋ ហើយថ្ងៃនីមួយៗគឺជាអំណោយទាន ។

សេចក្ដីសង្ឃឹមនៃពាក្យថា *នៅពេលដែល* បានធ្វើឲ្យយើងបន្តមានគំនិតវិជ្ជមាន ។ ប៉ុន្តែ រយៈពេល 18 ថ្ងៃនៅក្នុងដំណើរនោះ មានរឿងដ៏អាក្រក់បានកើតឡើង ។ នៅក្នុងការវះកាត់លើកទីប្រាំពីរ វេជ្ជបណ្ឌិតរបស់គាត់បានតាំងចិត្តថា ជំងឺនេះបានរីករាលដាលខ្លាំង ។ ក្រុមគ្រូពេទ្យបង្ហាញការសោកស្ដាយរបស់ពួកគេ នៅពេលពួកគេបានប្រាប់ ខ្ញុំថា ផ្លេ នឹងរស់មិនផុតពីយប់នេះទេ ។

ខ្ញុំអាចនៅជាមួយនឹងដៃគូអស់កល្បជានិច្ចរបស់ខ្ញុំបានខណៈដែលគាត់ចែកឋានទៅភពម្ខាងទៀត ។ យើងមានពរដោយមានកូនតែម្នាក់ពីប្រពន្ធដើមគាត់ ដែលគាត់បានទូរស័ព្ទមកដើម្បីសម្ដែងសេចក្ដីស្រឡាញ់ដែលគាត់មានចំពោះឪពុកខ្លួន ។ ផ្លេ បានចែកឋានទៅដោយសុខសាន្ត ។

ច្រើនសប្ដាហ៍ក្រោយមក នៅ ឯផ្នូររបស់គាត់ ពាក្យនៃការលួងលោមចិត្តបានកើតចេញពីម៉ូសាយ 2:41 ៖ « អ្នករាល់គ្នា [ គួរ ] គិតពិចារណាអំពីស្ថានភាពដ៏មានពរ និង រីករាយនៃអស់អ្នកណាដែលកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ។ ត្បិតមើលចុះ. . . *បើសិនជា* ពួកគេរក្សាការស្មោះត្រង់ដរាបដល់ចុងបំផុត នោះពួកគេនឹងត្រូវបានទទួលនៅស្ថានសួគ៌ ដើម្បីឲ្យពួកគេអាចរស់នៅជាមួយនឹងព្រះក្នុងស្ថានភាពសុភមង្គលដ៏មិនចេះចប់មិនចេះហើយ » ( ការគូសបញ្ជាក់បានបន្ថែម ) ។

ផ្លេ និង ខ្ញុំតែងចង់ឲ្យពាក្យ *ប្រសិនបើ* នៅក្នុងបទគម្ពីរនោះនឹងក្លាយទៅជា *នៅពេលដែល* សម្រាប់យើង ។ យើងបានដឹងថា តាមរយៈការបន្តតាំងចិត្តចំពោះសេចក្ដីសញ្ញារបស់យើង នោះយើងនឹងបានរួមរស់នឹងគ្នាវិញ—វាជាសំណួរតែមួយគត់គឺថា *នៅពេលណា* ។ យើងទុកចិត្តលើផែនការនៃក្រុមគ្រួសារអស់កល្បជានិច្ច និង ជីវិតដ៏នៅអស់កល្បជានិច្ចរបស់ព្រះអម្ចាស់ ។ វាជាអំណាចនៃពាក្យថា *នៅពេលដែល* ធ្វើឲ្យយើងបន្តដើរឆ្ពោះទៅមុខ ។ ■

*អ្នកនិពន្ធរស់នៅក្នុង កូឡុំប៊ីអង់គ្លេស ប្រទេស កាណាដា*

HE IS RISEN ដោយ ដេល ផាសុន



គូរដោយ រ៉ូប៊ើត ធី. បារ៉េត

# ហ្គរដុន ប៊ី ហ៊ីងគ្លី

**ហ្គរដុន ប៊ី ហ៊ីងគ្លី** បានធំឡើងដោយស្រឡាញ់បរិស្ថានធម្មជាតិ ។ ដើមឈើឈ្មោះ វ៉លណាត់មួយ ដែលលោកបានដាំកាលពីក្មេងត្រូវបានគេប្រើដើម្បីសង់វេទិកាសម្រាប់ **មជ្ឈមណ្ឌលសន្និសីទ ។** ជារឿយៗ ហ្គរដុន បានប្រៀបធៀបសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះទៅនឹង **ផ្កាយ** នាំផ្លូវ ជាផ្កាយមួយដែលលោកបានរៀនស្គាល់កាលពីក្មេង ។ លោក **បានធ្វើដំណើរ** ច្រើនជាង 3.2 លាន គ.ម. កាលលោកបម្រើនៅក្នុងសាសនាចក្រ ។ **ផ្កាយរណប** បានបញ្ជូនទីបន្ទាល់របស់លោកទៅជុំវិញសាកលលោក ។ ព្រះវិហារបរិសុទ្ធច្រើនជាង 70 កន្លែងត្រូវបានឧទ្ទិសឆ្លងកាលលោកជាប្រធាន រួមទាំងការសង់ឡើងវិញនូវ **ព្រះវិហារបរិសុទ្ធ ណៅវូ អិលលីណោយ** ផងដែរ ។

# ក៏មាននៅក្នុងច្បាប់នេះផងដែរ

## សម្រាប់យុវមជ្ឈិមវ័យ



### ដើរតាមផ្លូវនៃ សុភមង្គល

ប៊ីស្សព ហ្គេរ៉ាល កូសសេ បង្រៀនពីគោលការណ៍បីយ៉ាងដែលនឹងជួយអ្នកឲ្យគ្រប់គ្រងសុភមង្គលរបស់អ្នក មិនថាអ្នកមានស្ថានភាពបែបណានោះទេ ។

ទំព័រ 42

## សម្រាប់យុវវ័យ



ទំព័រ 52

### ចុះបើខ្ញុំគ្មានអារម្មណ៍ខ្លួលខ្វាញ់នៅក្នុងទ្រូងវិញ ?

កុំព្រួយបារម្ភឡើយ ។ មានវិធីជាច្រើនដើម្បីទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ។

## សម្រាប់កុមារ

### គំនិតអស្ចារ្យរបស់ជៀល

ត្រូវការរូបភាពព្រះវិហារបរិសុទ្ធមួយដើម្បីព្យួរនៅក្នុងផ្ទះរបស់អ្នកមែនទេ ?

ទំព័រ 78



CAMBODIAN
4 02109 86258 7

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ